រឿង

# កុលាបស្ទឹងខៀវ

ប្រលោមលោកមនោសញ្ចេតនា

និពន្ធ គូរគំនូរ និង រចនាក្របដោយ

អ្នកស្រី កែវ ចន្ទ័បូរណ៍

ហៅ មិត្រ មេត្រី

P.O.Box 600279
Saint Paul, MN 55119
USA
chanbokeo@yahoo.com
651-442-8941
www.angkorwat.com

ខែឧសភា២០០៣

រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO.COM

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៍

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្មឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង ស្នេកចាកផុតទៅ
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង បើសិននៅមានថ្ងៃស្នេក
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្មើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង សីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីស្នួនសុបិន
២៦- រឿង ម្លប់អសោក
២៧- រឿង ពិដេដ្ឋភានុមា
២៨- រឿង ផ្ការីកក្រៅស្នួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភ្នួងមាលា
៣៦- រឿង វាយោដួងចិត្ត

CHANBOKEO.COM

## សូមឧទ្ទិសចំពោះ

- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី **សុវណ្ណធី ធម្មិកា បារមីបុណ្យ** ជាបុត្រីទោល
- លោកឪពុក ប៊ុនថង និងអ្នកម្ដាយ កែវយឿង
- លោកឪពុកក្មេក មេងសួង និងអ្នកម្ដាយក្មេក កូវសាវ៉ាន់
- លោកគ្រូប៊ុនឈុននាម លោកគ្រូប៊ុនណាំ អ្នកគ្រូអ៊ុកវ៉ាន់ថា លោកគ្រូរស់សាន់
- លោកគ្រូអ្នកគ្រូរបស់នាងខ្ញុំទាំងអស់ ។
- អ្នកគ្រូទូចសារៀង អ្នកគ្រូកែវសុផុន លោកគ្រូលីតាយហុង
- លោកគ្រូរីនរស់ អ្នកគ្រូមៀចសុខារី អ្នកគ្រូស៊ីមចាន់យ៉ា
- អ្នកស្រីប៉ក់ដារិនី អ្នកស្រីមាយបេងយង់ លោកលេកស៊ីវហុង អ្នកស្រីអ៊ាបគិមណាង
- លោកខូតារាឫទ្ធិ នាយកគ្រប់គ្រង សមូហកម្មអក្សរសិល្ប៍នូហាច ភ្នំពេញ
- លោក អ៊ឹមសុនាថ លោកជិនសៅរិន លោកជាសយនា កាសែតកោះសន្តិភាព
- លោកយ៉ាន់បុរិន្ទ សាស្ត្រាចារ្យវិចិត្រសិល្បៈផ្នែកកំណាព្យនិងចំរៀងប្រពៃណី ។
- ចំពោះប្រិយមិត្តដែលជា អ្នកនិពន្ធ គន្ថការី និងកវីទាំងឡាយ ។



អ្នកស្រី កែវ ចន្ទ័បូរណ៍

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

# វាចាអ្នកនិពន្ធ

ស្ទឹងសង្កែបានកត់ត្រានូវអនុស្សាវរីយ៍រាប់មិនអស់ រវាងគូស្នេហ៍ជាច្រើននៅ បាត់ដំបងតាំងពីអតិតកាលរហូតបច្ចុប្បន្ន ។ ពេលនេះ ស្ទឹងសង្កែបានកត់ត្រានូវរឿង ដួងចិត្តសម្ងាត់របស់គូស្នេហ៍ថ្មីមួយទៀតហើយ តាមរយៈសាច់រឿងមនោសញ្ចេតនា ដែលអ្នកនិពន្ធបានប្រតិស្ឋនាមឱ្យថា កុលាបស្ទឹងខៀវ ។ នេះជាប្រលោមលោក ដែលពោរពេញទៅដោយរសជាតិស្នេហាផ្អែមល្ហែម ក្រោមឥទ្ធិពលរលកជីវិតដ៏ គ្រាំគ្រេង ដែលនាំឱ្យដួងចិត្តរបស់គូស្នេហ៍ត្រូវអណ្តែតឬលិចតាមនិស្ស័យកម្ម ។

ចំពោះកំហុសអក្ខរាវិរុទ្ធដោយអចេតនាទាំងឡាយនៅក្នុងសាច់រឿង សូម ប្រិយមិត្តមេត្តាជួយកែសំរួលអោយបាន ត្រឹមត្រូវតាមវេយ្យាករណ៍ខ្មែរប្រពៃផង ។ សូមប្រសិទ្ធិពរជ័យដល់ប្រិយមិត្តអ្នក អានទាំងអស់អោយបានជួបតែវឌ្ឍនសុខ សុវត្ថិភាព និងសុភមង្គលរាល់ទិវារាត្រី ។

នាងខ្ញុំអ្នកនិពន្ធ សូមទទួលនូវមតិយោបល់ពីប្រិយមិត្តអ្នកអាន តាមរយៈ អស័យដ្ឋានដូច ខាងក្រោមនេះ :

Pannalai Khmer Vissal
P.O.Box 600279
Saint Paul, MN 55119
USA
Khmervissal@yahoo.com www.angkorwat.com

CHANBOKEO.COM

អ្នកនិពន្ធ
អ្នកស្រី កែវ ចន្ទ័បូរណ៍

# កំណាព្យ

## **សុទដ្ឋិ**

គំនិតគិតល្អគិតថ្មុំថ្មើង　　　　លើកទឹកចិត្តឡើងជាមង្គល
ចំពោះខ្លួនឯងញាតិសោតសល់　　　　ទដ្ឋិនិមលផ្តល់រមណីយ៍ ។
គិតសុទដ្ឋិនាំចំរើន　　　　បុណ្យកុសល់កើនហៀវធរណី
នាំញាតិសប្បាយក្នុងអញ្ចលី　　　　ទដ្ឋិរមណីយ៍ត្រជាក់ចិត្ត ។
ចិត្តគិតទូលាយស្អាយគុណធមិ　　　　លាងភាពកករចាកវិបរិត
បេះដូងត្រជាក់ភពអម្រឹត　　　　វាចាកាយចិត្តសុខក្សេមក្សាន្ត ។
ទដ្ឋិប្រពៃចាកប្រទុស្ត　　　　នាំអារម្មណ៏មនុស្សទាំងរូបប្រាណ
អោយយល់មង្គលល្អថ្មើងថ្កាន　　　　បញ្ហាប៉ុន្មានស្រាយយ៉ាងស្រួល ។

CHANBOKEO .COM

## ស្រលាញ់

យើងស្រលាញ់គ្នាជាគ្រួសារ　　　មាតាបិតាព្រមទាំងបុត្រ
ស្រលាញ់ដោយចិត្តស្មោះបរិសុទ្ធ　　　លុះលង់ថ្ងៃផុតសូន្យជីវី ។
ស្រលាញ់គ្នាណាស់ផ្លាស់មិនបាន　　　ទាំងដួងចិត្តប្រាណអង្គអញ្ជលី
សច្ចាថៃថ្នូនសួនពលី　　　រក្សា រមណីក្នុងគ្រួយើង ។
ស្រលាញ់ជិតដិតស្និទ្ធដួងថៃ　　　មង្គលប្រពៃក្រៃថ្កុំថ្កើង
គ្រួសារក្រីក្រត្រដររឡើង　　　ទោះទ្រព្យស្តួចស្តើងចិត្តយើងមាន ។
យើងស្រលាញ់គ្នាលង់តទៅ　　　ជាគ្រួសារនូវសីលនិងទាន
ស្រលាញ់ពុកម៉ែញាតិគ្រប់ប្រាណ　　　គ្រួសារយើងថ្កានក្សាន្តរៀងទៅ ។

CHANBOKEO . COM

ជោរ

ខ្មែរយើងខ្លះជោរទ្រុបរទេស គោរពទាំងធ្វេសងប់ហួសក្បួន
តួយ៉ាងវត្ថុល្អនឹមនួន ស្ងួនផ្តល់កត្តិយសដល់ជាតិផ្សេង ។
នំផ្អែមហើយឆ្ងាញ់នំ**បារាំង** បង្អែមប្លែកខ្លាំងល្បីមិនលែង
ហៅចំណី**សៀម**ភ្លេចជាតិឯង ម្ហូរឆ្ងាញ់ក្រៃលែងហៅម្ហូរ**យួន** ។
ខោវែងវែងស្អាតសង្ហាតហៅ ខោ**បារាំង**នៅល្អសមស្ងួន
អាវហោប៉ៅច្រើនពាក់លើខ្លួន បែរខ្លួនចិត្តខ្មៅហៅអាវ**ចិន** ។
ចង្វាក់ចំរៀងច្រៀងពិរោះ បែរនាំគ្នាអស់ហៅយ៉ាងប៊ុន
ឡាំ**លាវ**កៀវក្បែងដៀងមិនញ៉ិន ប្រុសស្រីឡើងរាំពេញភូមិស្រុក ។
នេះហើយវិបត្តិជំងឺជោរ អ្វី១ល្អ១មិនចេះទុក
ស្រវាំអោយគេល្បីកាត់មុខ អោយខ្មែររងទុក្ខឈ្មោះឱនថយ ។

CHANBOKEO.COM

## ឥទ្ធិពលនៃភាពអត្តខាត់

សភាពតោកយ៉ាកក្រអត្តខាត់ ឱ្យចិត្តភ្លេចបាត់អស់សីលធមិ
ក្រពះខ្លោចផ្សាកាយាញ័រ មនុស្សល្អក្លាយចោរស្វ័យប្រវត្តិ ។
បំបិទឱកាសសិទ្ធិសេរី ប្រជាក្រេវក្រែស្ទុះមិនភ្លាត់
ច្បាស់ជាក្រោកឡើងបដិវត្តន៍ ផ្តួលរបបរដ្ឋមិនផុតការ ។
គម្លាតអ្នកក្រនឹងអ្នកមាន ហ្វូងមួយស្រេកឃ្លានក្រពះផ្សា
ហ្វូងមួយសំបូណ៌ចុកហូរហៀរ មាសប្រាក់ចាក់ធារហៀរពាសថ្នល់ ។
កត្តាគម្លាតឆ្ងាយអនេក អ្នកក្រសង្វេគព្រួយរចល់
អ្នកមានព្រងើយមិននឹកខ្វល់ ថ្ងៃមួយនឹងជល់ភាពវឹកវរ ។
ពិភពលោកធ្លាប់មានពិសោធន៍ ពេលប្រជាក្រោធក្រោកឡើងឈរ
សង្គ្រាមអ្នកមាននិងអ្នកក្រ ចរនាំប្រទេសធ្លាក់អន្តរាយ...!!

CHANBOKEO .COM

# ស្រវឹង

ស្រវឹងថ្នាំញៀនអាភៀនឬស្រា ស្រវឹងកញ្ឆាគង់អាចស្រាកស្រាន្ត
ស្រវឹងអំណាចកាចឥតលំអាន គ្មានថ្ងៃវិលបានស្រាកស្រាន្តថមថយ ។
អាភៀនកញ្ឆាស្រាទឹកត្នោតជូរ ពីរថ្ងៃយ៉ាងយូរអស់ឫទ្ធិពីកាយ
ស្រវឹងយ៉ាងណាគង់បែររសាយ ពីរថ្ងៃឆ្លងហើយស្វាងស្មារតីវិញ ។
ស្រវឹងអំណាចត្រេកយសបុណ្យសក្តិ សម្បត្តិមាសប្រាក់លោភៈពោរពេញ
មិនងាយស្រាកស្រាន្តពីខ្លួននោះមិញ រាល់ពេលវង្វេងស្រវឹងឥតត្រើយ ។
ស្រវឹងដុល្លារស្រវាអំណាច គំនិតកោងកាចឃ្លាតគុណធមិហើយ
ស្រវឹងនេះឈឺគ្មានថ្ងៃជាឡើយ គ្រូពេទ្យរាប់រយព្យាបាលមិនជា ។

CHANBOKEO . COM

## ដង្កូវ

ដង្កូវស៊ីចោះអស់ដំណាំ ងាប់មួយញាស់ប្រាំចាំបំផ្លាញ
ដង្កូវតូចធំទំក្រាបក្រាញ ស៊ីធាត់ឡើងខ្លាញ់ឆ្ងាញ់ចំណី ។
ដង្កូវសង្គមរាប់ពុំអស់ ប្រញាយច្បិចចោះអស់វិស័យ
ដង្កូវខ្វាំជាតិឃ្លាតសិរី ដង្កូវអប្រិយឆីជាតិឯង ។
ដង្កូវឆីស្លឹកជុះដាក់មែក ស្រវាក្រេបត្រែកដេកវង្វេង
ដង្កូវភ្លេចខ្លួនស្ងួនចំបែង ថ្ងៃមួយកម្ទេចឯងអស់មែកជ្រក ។
ដង្កូវអើយចាំកម្មនឹងស្នង ចង្រៃអ្នកសាងក្នុងសំបុក
ដង្កូវចាប់ផលសំណល់ទុក្ខ រលាយក្ដីសុខព្រោះកម្លៅរបស់អ្នក ។

CHANBOKEO.COM

## បញ្ញើក្អែក

អស់សព្វរុក្ខាចាក់ឫសដល់ដី ខុសតែមែកព្រៃឈ្មោះបញ្ញើក្អែក
ឥតឫសចាក់ដីរស់កល់ចុងមែក ស្រវាត្រងត្រែកមែកព្រឹក្សផ្សេងៗ។
ដូចកូនពេញវ័យមិនងើបព្យាយាម បង្ករហាមអោយម៉ែចំបែង
ពំនាក់គុណឪជួយចាត់ជួយចែង វង្វេងខ្លួនឯងដូចបញ្ញើក្អែក។
ដូចជនកម្លៅអោបដៃអោបជើង ស្វែងសក្តិថ្មីថ្កើងឡើងខ្ពស់ចម្លែក
មិនខុសប៉ុន្មានពីបញ្ញើក្អែក បុណ្យសក្តិក្រៃពេកប្លែកខ្វះកោសល្យ។
ជាតិបញ្ញើក្អែកប្លែកអស់រុក្ខព្រឹក្ស ដើមគេវរវឹកចេញផ្កាផ្លែផល
ឯបញ្ញើក្អែកដុះខ្ពស់ពីគល់ គ្មានផ្លែសោតសល់នឹងបេះភោក្តា។
ច្នេះគួរពិនិត្យបញ្ញើក្អែកព្រៃ អណ្តែតផុតដីគ្មានរសផលា
ចាញ់ម្ចាស់ផ្ទាល់ដីដើមសុទ្ធបន្លា តែផ្តល់ផលាត្រជាក់ជាប់ចិត្ត។

CHANBOKEO.COM

## ខ្មែរទំនើបនិងខ្មែរដំណើប

ខ្មែរអ្នកទំនើបចូលខ្លួនសិក្សា កសាងកាយាថ្លៃថ្លាប្រពៃ

ខ្មែរអ្នកដំណើបពើបផ្លូវកាត់ព្រៃ ចាំបាច់រៀនអី ទិញបរិញ្ញាវិញ។

ខ្មែរអ្នកទំនើបស្តាប់មុនស្រដី វិភាគវែងខ្លីអត្ថន័យរសពេញ

ខ្មែរអ្នកដំណើបស្រើបចង់បញ្ចេញ អំណាចអង្គអញស្តីចេញមុនគិត។

ខ្មែរអ្នកទំនើបរៀនពីអ្នកផង ជុំវិញខ្លួនហោងបណ្តុះគំនិត

ខ្មែរអ្នកដំណើបចេះគ្មានសល់ពិត ចំបាច់ "កីអ៊ុត" ស្តាប់ពីគេឯង?

ខ្មែរអ្នកទំនើបរៀនសព្វសាស្ត្រា សីលធម៌សាវតារសិក្សាគ្មានក្រែង

ខ្មែរអ្នកដំណើបពើបភាពវង្វេង សាវតារជាតិឯងផ្តាប់ក្នុងសំរាម។

ខ្មែរអ្នកទំនើបជើងដើរជាប់ដី លំទោនសិរសីជូនញាតិគ្រប់ប្រាណ

ខ្មែរអ្នកដំណើបដូចខ្លែងលង់ស្ថាន អណ្តែតអង្គប្រាណលែងស្គាល់អស់ញាតិទាំងឡាយ...

CHANBOKEO.COM

# ស្គរ

ទូងៗលាន់ឮកក្រើកដី　　ប្រជាប្រុសស្រីរត់មើលលាន់
ទូងៗក្នុងក្ដាំងខ្លាំងហាក់គ្រាន់　　ការពិតស្គរភន្ដ័ប្រហោងក្នុង ។
មិនខុសពីមនុស្សអួតក្អេងក្អាង　　ពើងទ្រូងច្រងាងបំប៉ោងអង្គ
ទិញសញ្ញាបត្រ័ស្រោបខ្លួនខ្ចង់　　ខាងក្នុងប្រហោងអវិជ្ជា ។
ឡើងបុណ្យឡើងសក្ដិតាមជើងខោ　　ទិញផ្លូវជាន់ដើរលាបបរិញ្ញា
ខ្ពឹមក្នុងសែនយ៉ាប់អាប់ប្រាជ្ញា　　វិជ្ជាសាស្ត្រាងងិតស្អប់ ។
ស្ដាយអ្នកមានឈ្មោះយសថ្កុំថ្កើង　　ដូចស្គរធំប៉ោងលាន់សន្ធប់
កក្រើកខ្ចារខ្ចរអស់ពិភព　　ក្នុងវិញបែរផុកភាពល្ងង់ខ្លៅ ។
ឱមិត្តអើយមិត្ត! ខ្មែរអើយខ្មែរ!　　ថ្ងៃណាយើងកែផុតកំឡៅ
ឈប់ទិញបរិញ្ញាស្រោបខ្លួនទៅ　　រៀនសូត្រត្រឹមត្រូវ....
ឱ្យសមនូវកត្ដិយសនិងបុណ្យសក្ដិរបស់យើង ។

## ទឹកភ្នែកសត្វគោ

អនិច្ចាពេលរស់គេចងខ្លុះ ចោះរន្ធច្រមុះអន្ទាក់ខ្សែ
ដេញខ្ញុំអូសផាលភ្ជួរពេញស្រែ រំពាត់ដេញអែតតបណ្តាក់ ។
រួចហើយដាក់នឹមផ្ទឹមជាគូ អូសរទេះយូរដឹករលាក់
កាត់វាលកាត់ភ្នំអូរជ្រៅរាក់ ដឹកស្រូវឱសគ្រាក់សព្វអស់ឈើ ។
ខែភ្លៀងភ្ជួរស្រែបំរើញាតិ ខែប្រាំងអូសទៀតជូនដំណើរ
នាំមុខរទេះដឹកសារពើ គោខ្ញុំបំរើមិនត្អូញឡើយ ។
ស្តាយពេលខ្ញុំចាស់គ្រាត្រូវស្លាប់ គេបែរព្រលាត់មិនកន្តើយ
ព្រលះសាច់ខ្ញុំយកចែកចាយ ញាតិផៅទាំងឡាយសប្បាយឆី ។
អនិច្ចាលោកនេះមិនយុត្តិធម៌ គោខ្ញុំកើតមក៏រងអវិចី
ពេលរស់គេវាយប្រើរញ៉ី ស្លាប់គេហែកឆីមិនខ្ចីស្តាយ ។
តើឯណាទៅផ្លូវសីលធម៌ សូមប្រាប់ខ្ញុំមក៏លោកចៅហ្វាយ
គោខ្ញុំខុសអីទើបមានកាយ គេវាយដំហើយព្រលាត់ទៀត?

CHANBOKEO.COM

## ជំងឺពុករលួយ

បើត្រឹមឈើពុកនោះមិនអី　　　នៅអាចកែឆ្នៃលៃជួយបាន
ពុកផុយគ្មានក្លិនគួររំខាន　　　អាចដុតភ្នក់បានខែរងា។
តែបើរលួយព្រួយណាស់អើយ　　　ក្លិនអាសោចន៍ហើយយ៉ាកវេទនា
ទីជិតទីឆ្ងាយយល់ក្លិនវា　　　អ្នកផងរអាថយជើងប្រាំ។
ជាតិជាជំងឺពុករលួយ　　　ជាតិខ្មែរវែងព្រួយឈឺរងកម្ម
រោគារ៉ាំរ៉ៃរីកលឿនផ្តាំ　　　គ្រូពេទ្យសកម្មលើកដៃរា។
ស្រុកទេសទន់ខ្សោយដង្ហោយយំ　　　ហៅអ្នកដឹកនាំពលប្រជា
សូមចាកផុតពុករលួយពៀរ　　　អោយជាតិប្រជារស់ក្សេមក្សាន្ត។

CHANBOKEO.COM

## កង្កែបបាតអណ្តូង

ខែប្រាំងទឹករីងហួតនៅបាត　　កង្កែបដេកស្ងាបក្នុងអណ្តូង
ឃើញរង្វង់មេឃជ្រៅហើយខូង　　ប៉ុនមាត់អណ្តូងមិនខុសសោះ ។
កង្កែបនឹកឡើងអស់សំណើច　　ហេតុអ្វីមនុស្សស្ងើចថាមេឃខ្ពស់
យើងមើលមិនឃើញធំអ្វីសោះ　　បើសិនយើងវាស់លោតចាប់ដល់ ។
ថ្ងៃដន្យភ្លៀងធំលង់អណ្តូង　　កង្កែបហក់ឡើងយ៉ាងតក្កហល
ខ្លួនប៉ើងធ្លាក់ដីពោះឆ្អិតឆ្អល់　　ឃើញមេឃទឹកឆ្ងល់ម្តេចដូរមាឌ?
កង្កែបភ្ញាក់ខ្លួនគិតច្រឡំ　　ការពិតមេឃធំមិនចង្អៀត
ជើងមេឃសែនឆ្ងាយភ្នំខ្ពស់ទៀត　　វេហាស៍ផងឃ្លាតហៅមិនឮ ។
លុះនឹកបែរក្រោយមើលអណ្តូង　　កង្កែបគេចផ្លូងខ្លាចធ្លាក់ឈឺ
អណ្តូងជ្រៅតូចតតពន្លឺ　　ធ្លាក់ចូលដេកឈឺលង់កម្លៅ...!!

CHANBOKEO.COM

## ជីវិត

ជីវិតជាឱកាស ឆក់រហ័សកុំយឺតយូរ
ជីវិតគឺតស៊ូ ក្លាហានប្តូរប្រឹងពុះពារ ។
ជីវិតជាសោភ័ណ ជាសុបិនស្រីស្រីង្គា
ជីវិតជាទ្រព្យា ចូររក្សាថ្នមយ៉ាងល្អ ។
ជីវិតជាបរមសុខ ត្រងថៃទុកក្នុងសីលធមិ
ជាសោភ័ណយ៉ាងបវរ ដូចកិន្នរស្រស់ផូរផង់ ។
ជីវិតមានលាក់អាថិ ស្វែងរកទ្វារស្រាយចំណង
ជីវិតជាសំណាង ចូរខំសាងភាពត្រឹមត្រូវ ។
ជីវិតជានាដកម្ម មានទុក្ខធំក្តីសោកសៅ
សប្បាយលាយឡំនៅ ត្រងយកទៅកុំប្រកែក ។
ជីវិតជាកតព្វកិច្ច កុំកែគេចគិតអល់ឯក
ជាចំរៀងដ៏ប្លែក គួរត្រងត្រេករែកត្រអាល ។
ជីវិតជាស្នេហា លើកហត្ថាទទួលក្រាល
បីយកសួគ៌វិសាល បណ្តុះថ្នាលក្នុងដួងចិត្ត ។
ជីវិតគឺវង្វេង ដើរផ្សងព្រេងស្វែងសុក្រិត
ត្រងយកភាពអម្រិត ប្រស់ជីវិតអោយភ្លឺថ្លា ។
ជីវិតមានតម្លៃ កុំគិតខ្លីខកអាត្មា
ធូនថៃខ្មែរសង្ខារ រស់យូរយារត្រកាលអើយ ។

CHANBOKEO.COM

## សំណើចកូនស្វា

អ្នកផងហៅខ្ញុំថាជាស្វា ដៃជើងកាយាមិនខុសមនុស្ស
ថៃ្ងដន្យខ្ញុំឆ្លាតវៃធ្លាយធ្លុះ ជាតិមនុស្សចុះចាញ់ខ្នាញ់មិនស្មើ ។
ខ្ញុំអង្គុយតុកាន់ប៉ាកកា ស៊ីញ៉េបោះត្រាប្ញកប្រហើរ
មានមនុស្សលុតក្រាបទូលបញ្ជើ តម្កើងជំទើលើកជើងស្វា ។
នេះព្រោះស្វាខ្ញុំមានប្រាជ្ញពេជ្រ ឱបាយល្បួងល្បិចកាន់កិច្ចការ
ជាន់កមនុស្សយ៉ាប់អាប់ប្រាជ្ញា ក្រាបទូលកូនស្វាអាទិទេព ។
ស្វាខ្ញុំចេះបរកាន់ចង្កូត នាំមនុស្សរលូតទីសព្វបែប
ជីវិតគ្រប់ពណិគួរចង់សេព ឋានសួគ៌ឋានប្រេតគ្មានចន្លោះ ។
មើលចុះ! មនុស្សល្ងង់លង់ល្បិចស្វា ខ្ញុំសើចអស្ចារ្យស្ទើរស្លាប់រស់
ហេតុអ្វីមនុស្សខ្លៅចាញ់ស្វាក្រោស ទូលខ្ញុំលើកបោះហោះដល់មេឃ?

CHANBOKEO.COM

**គិតយ៉ាងណា?**

ម្នាក់ថាគួរប្រៀននាំមនុស្សចេះ		គិតគូរត្រិះរិះរកឱបាយ

ចាប់ត្រីចំអែតចិញ្ចឹមកាយ		ប្រសើរជាងអោយត្រីស្រាប់ៗ។

ម្នាក់ថាអ្នកក្រកំពុងឃ្លាន		ពុំមានបឹងស្ទឹងនឹងចុះចាប់

ឱបាយល្អៗប្រែស្រអាប់		គ្មានទីរុតចាប់រស់យ៉ាងណា?

ម្នាក់ថាយើងគួរប្រដៅកូន		អោយស្ទួនវិជ្ជាសព្វសាស្ត្រា

ម្នាក់ថាអោយក្មេងរៀនយ៉ាងណា		បើក្រពះផ្សារអំពល់ប្រាណ។

ម្នាក់ថាគួរសង់ទីជំរក		ឱ្យអ្នកក្រជ្រកសុខក្សេមក្សាន្ត

ម្នាក់ថារើចេញ..ខូចបរិដ្ឋាន		អ្នកក្រត្រូវច្រានចេញឆ្ងាយទៅ។

ពេលនេះជាតិខ្មែរគិតយ៉ាងណា		ប្រជាខេមរាលង់ទុក្ខជ្រៅ

អ្នកក្រល្វិតល្វង់ខ្វះអស់ផ្លូវ		សូមជួយនាំទៅទីមានពន្លឺផង...

CHANBOKEO.COM

**សំណោកឈ្លូស**

កាលដើមមេឈ្លូសរស់សេរី　　　　សុខសាន្តឥតភ័យខ្វល់អំពល់
ស្រាប់តែថ្ងៃមួយសង្គ្រាមដល់　　　គ្រាប់ផ្ទុះរចល់ធ្លាក់ពាសដី ។
ឈ្លូសភ័យស្រែកហៅកូនពន្លក　　ប្រាយប្រាត់ព្រៃប្រោកជ្រកទីថ្មី
ចៃដន្យគេកប់មីនអរិចី　　　　　រាយប៉ាយពាសព្រៃខកផ្លូវរត់ ។
កូនមួយក៏ស្លាប់មួយពិការ　　　　មីនកាចអស្ចារ្យគួរតក់ស្លុត
សម្លេះជីវិតឥតរន្ធត់　　　　　　មេឈ្លូសកំសត់ព្រាត់កូនចៅ ។
លុះអស់សង្គ្រាមគម្រាមជាតិ　　　ខេមរាបែរឆ្លៀតលុងព្រៃជ្រៅ
កាប់ឈើរំលើងដុតសន្ធៅ　　　　　រុក្ខព្រឹក្សលំនៅជំរកសត្វ ។
ថ្ងៃនេះឈ្លូសអើយជ្រកឯណា　　　បើព្រៃខេមរាបែរខ្វាយខ្វាត់
ព្រៃធំក្លាយវាលសោកវិបត្តិ　　　ឱឈ្លូសកំសត់ព្រាត់មង្គលហើយ...

*ដោយ អ្នកស្រី កែវ ចន្ទ័បូរណ៍*

CHANBOKEO.COM

# វគ្គទីមួយ
# ខ្លាញ់

ឆ្នាំ១៩៧៤...

លើដងផ្លូវពីដូនទាវ មកក្រុងបាត់ដំបង តាមដងស្ទឹងសង្កែ មាណវីមួយរូប អាយុប្រមាណ២១ឆ្នាំ ជិះកង់ឌុបអំពៅមួយបាច់ធំ ព្រមជាមួយមានយួរក្រូចមួយចង់ផង ។ លុះមកដល់ជិតមាត់កំពង់ វត្តស្លាកែត ស្រាប់តែខ្សែដែលចងអំពៅក៏ដាច់ភឹងឡើង ធ្វើឲ្យធ្លាក់ដើមអំពៅរាយពេញថ្នល់ ។ ភ្លាមនោះ ស្រាប់តែមានរថយន្តមួយ បររឹងមកពីខាងក្រោយខ្នងមាណវីកិនដើមអំពៅនោះ បែកខ្ទេចខ្ទីរ អស់ជាច្រើនដើម ។ លុះដល់និតាយើងងាកបែរមើលតាមរថយន្ត មួយនោះ នាងក៏ចំណាំបានថាជារថយន្តម៉ាកស៊ីមកាពណ៌សថែមទាំង ចំណាំលេខឡានបានទៀតផង ប៉ុន្តែម្ចាស់រថយន្តមិនបានជាន់បង្អង់ ល្បឿន ឬក៏ចុះពីឡានមកជួយមើលទទួលខុសត្រូវអ្វីសោះ ដែលគេ បានបរកិនអំពៅរបស់នាងបែកខ្ទេចខ្ទីរអស់ជាច្រើនដើម ។

- ពុទ្ធោអើយ! មានលុយ មានឡាន តែគ្មានទឹកចិត្តអ្វីបន្តិច! នេះ ឬឥរិយាបថរបស់អ្នកមាន ? (ឆវីរអ៊ូតិចៗក្នុងមាត់)

នារីក៏ចុះពីកង់ទៅប្រមូលអំពៅទាំងអស់មកវិញ ថ្វីបើដើមខ្លះ ត្រូវឡានបរកិនឡើងខ្ទេចខ្ទុំហើយក៏ដោយ ព្រោះនឹកឃើញថានឹង ចោលរ៉ាយប៉ាយអោយនៅផ្លូវថ្នល់នោះ ហាក់ដូចជាមិនសមរម្យ ។ បន្ទាប់ពីសុំព្រាលពីអ្នកស្រុកដែលរស់នៅម្តុំៗនោះបានហើយ ឆវីក៏ ចងដើមអំពៅឆ្នោះបគ្គាសាជាថ្មីដាក់ពីក្រោយកង់ដោយមានអ្នកស្រុក ពីរនាក់មកជួយចងផង រួចហើយក៏ឡើងធាក់កង់តម្រង់ទៅផ្សារ ក្រោម ។ ថៃដន្យ នាងមិនបានជិះកង់ទៅផ្សារក្រោមទេ ប៉ុន្តែបែរ ជាបត់កង់ឡើងទៅស្ពានថ្មថ្មី តម្រង់ទៅកើតឆ្លងស្ទឹងសង្កែទៅវិញ រួចក៏បត់ចុះតាមផ្លូវ អែបបណ្តោយស្ទឹងសំដៅទៅរកសួនកុមារ ។ លុះមកដល់ម្តុំវត្តពោធិវាល

ស្រាប់តែនាងប្រទះនឹងរថយន្តដដែល
នោះទុកចតចោលនៅមាត់ផ្លូវមុខគេហដ្ឋានដ៏ស្កុកស្កម្ភមួយ ។ ធិតា
ក៏មានគំនិតព្រើលមួយកើតឡើងក្នុងចិត្តភ្លាម ។  នាងចុះពីលើកង់
ស្រាយយកដើមអំពៅដែលបែកសុសទាំងប៉ុន្មាន ដើរសំដៅទៅ ឡានមួយនោះ
រួចក៏យកដើមអំពៅសំពងខ្លាំងៗពីលើដំបូលឡាន លាន់ផុងផាំងៗ ។

- អេហ៍! នែ៎នាង! ធ្វើអីឡានខ្ញុំហ្នឹង ?

សម្លេងបុរសម្នាក់ស្រែកមកពីក្រោយខ្នង តែមាណវីយើងមិន ងាកទេ គិតតែពីសំពោងថែមទៀតយ៉ាងញាប់ដៃ រួចក៏បោះពង្រាយ ដើមអំពៅទាំងនោះទៅលើដំបូលឡាន ទើបបែរដើរសំដៅទៅចាប់ កង់ឡើងជិះធ្វើព្រងើយ មិនខ្វីទាំងយកភ្នែកសម្លឹងបុរសនោះផង ។

- នែ៎...ទៅណាមិនបានទេ! វាយឡានយើងប្រលាក់អស់ នាងត្រូវ សំអាតឡានសងយើងវិញភ្លាម ។

បុរសនោះស្ទុះទៅទាញកង់នារីពីក្រោយអោយឈប់តែនាងនៅ តែប្រឹងធាក់ទៅមុខមិនព្រមឈប់ ។ កាលបើប្រទាញប្រទង់ទៅមក ឆវីក៏អស់លំនឹងនឹងទប់កង់មិនជាប់ រួចក៏ដួលទាំងជំហរ ។ មាណព នោះឃើញដូច្នោះស្ទុះហក់ទៅជួយទប់មិនឲ្យដួលតែទប់មិនជាប់ ក៏ ដួលទាំងពីរនាក់ទៅដីព្រួសតែម្តង ។ ពេលនោះ ធិតាដួលផ្តេកខ្លួន សង្កត់លើកែងដៃខ្លួនឯង ហើយក៏ផ្កាប់មុខនាងទៅលើទ្រូងនរៈ ។ កល្យាណីភ្ញាក់ព្រើត ស្ទុះក្រោកយ៉ាងរហ័ស ថែមទាំងគំហកថាៈ

- ព្រហើនមែន!

មាណវីស្តីអោយបុរសនោះទាំងឃ្នាន់ខ្នាញ់ ។ គ្រាន់តែកែវភ្នែក អ្នកទាំងពីររត់ទង្គិចគ្នាភ្លាម ស្រាប់តែគេទាំងពីរភ្ញាក់ក្រញាង ធ្វើមុខ ភាំងដាក់គ្នា ទំនងភ្ញាក់ផ្អើលនៅក្នុងចិត្ត ។ បន្តិចមក គេបែរជានឹក ខ្មាស់ក្រសែភ្នែកគ្នាទៅវិញទៅមកយ៉ាងណាមិនដឹង ក៏នាំគ្នាបែរ គេមុខចេញពីគ្នាតែរៀងខ្លួនៗភ្លាមដែរ ។ មួយស្របក់ក្រោយមក មាណពក៏ងើបឈរឡើងវិញ ហើយសួរឆវីទំនងដឹងខ្លួនខុស :

- នាងមានរបួសត្រង់ណាទេ ?

CHANBOKEO.COM

ស្រាប់តែមាណវីយកដៃលាក់ក្រោយខ្នង ដើរត្រុយទៅលើកកង់ មកជិះ ដោយមិនតបអ្វីមួយម៉ាត់មកបុរសយើងវិញទេ ទំនងដូច ជាខឹងអន់ចិត្តនឹងបុរីដល់ស្ទូរហើយ ។ ឃើញកិរិយាដូច្នោះ មាណព បែរជាខឹងក្រេវ ស្រែកពីក្រោយមកថា :

- ឃើញរូបសម្បត្តិដូចគួរសមដែរ តែចរិតឈ្លើយមើលមិនបាន..!

កាលបើឮដូច្នោះ ធិតាឈប់កង់ហើយងាកក្រោយភ្លែត :

- នែ៎... ចង់ថាអោយនរណាគេដែរ ?

- គឺនរណាក៏ដោយអោយតែមានខ្លួន..! (នរៈបែរមុខចេញហើយ ស្រដីធ្វើព្រងើយ)

ស្រាប់តែធិតាស្រដីសើចចំអកវិញថា :

- មែនហ្មែស ? នេះបើចង់សំដៅលើអ្នកដែលមានមុខមាត់ស្អាត បាត រូបរាងសង្ហា បើកឡានថ្មី ហើយបរកិនអំពៅរបស់ខ្ញុំ រួច ហើយរត់គេចខ្លួនបាត់ មិនព្រមចេញមុខមកទទួលខុសត្រូវនោះ... អញ្ចឹង ពេលប្រទះឃើញគេ សូមកុំភ្លេចសួរគេផងណ៎ា តើថ្ងៃណា ទៅទើបគេឈប់ឈ្លើយ ហើយយកប្រាក់មកសងថ្លៃអំពៅខ្ញុំវិញ ?

ស្រាប់តែបុរសបើកភ្នែកធំៗ ឆ្លើយតបវិញ ភ្លាមថា :

- អូហ៍ ដូចគ្នាដែរ... បើសិននាងបានជួបអ្នកដែលយកដើមអំពៅ សាញៗ មកវាយឡានខ្ញុំប្រឡាក់នោះ សូមកុំភ្លេចប្រាប់ផងថាអោយ គេមកលាងសំអាតឡានខ្ញុំជាប្រញាប់ ។

ស្រាប់តែឆវីនោះទាញកែងដៃចេញពីក្រោយខ្នង មកបង្ហាញ របួសដែលមានឈាមហូររឹមៗលើកែងដៃ ហើយស្រដីថា :

- បើដូច្នោះ សូមអញ្ជើញសួរអ្នកមានខ្លួនម្នាក់នោះផងដែរថា កាល បើខ្លួនគេបានធ្វើអោយកូនក្រមុំអ្នកស្រុកម្នាក់ មានរបួសរហូតដាច់ ឈាម តើកាលណាទៅ ទើបគេលូនចូលទៅសំពះឪពុកម្ដាយនាង ដើម្បីសុំការអភ័យទោសពីលោកដែរ ?

ត្រូវមួយខ្នាយ បុរសសង្ហាបើកភ្នែកធំៗ បាត់មាត់ដូចគេចុកតែ ម្ដង ។ ភ្លាមនោះ គេក៏បែរមើលជុំវិញខ្លួន ស្រាប់តែប្រទះអ្នកជិត ខាងមានចាស់មានក្មេងពីរបីនាក់ នៅឈរមើលអ្នកទាំងពីរជិតៗ នោះ ព្រោះឮអ្នកទាំងពីរប្រកែកគ្នា ។ គេក៏នឹកខ្មាស់ក្នុងចិត្ត មិន ហ៊ានមាត់ ។ កាលបើមិនឮបុរសនោះតបអ្វីទេ ធិតាក៏រអ៊ូឡើងថា :

- ពុទ្ធោអើយ ! ថ្ងៃនេះខ្លាព្រៃខាំដាច់កែងដៃយើង ស៊យមែន !

CHANBOKEO.COM

ថាហើយ នាងក៏ជិះកង់ចេញទៅធ្វើមិនដឹង ទុកអោយបុរស នោះឈរមើលពីក្រោយធ្វើភាំង រកអ្វីឆ្លើយតបនឹងមាណវីវិញមិន បានសោះ ។ រំពេចនោះ ស្រាប់តែនាយនឹកពិភាល់ក្នុងចិត្ត នឹកចង់ ដឹងណាស់ថា នាងជានរណា នៅផ្ទះម្ដុំណា ។ គេក៏ស្ទុះចូលទៅ ក្នុងផ្ទះវិញ :

- ពូប្រេង! អោយខ្ញុំសុំខ្ចីកង់ម៉ាក្លែត ?
- អ្នកប្រុសបុរី យកកង់ទៅណាដែរបាទ ? ម៉េចក៏មិនបើកឡាន ?
- ខ្ញុំជិះដើរលេងតើហ៍ បន្តិចទៀតខ្ញុំមកវិញហើយ!

ថាហើយកម្លោះយើងក៏ហាក់ឡើងកង់ត្រុយ ជិះយ៉ាងលឿនដេញ តាមក្រោយមាណវីម្នាក់នោះ ។ បន្តិចមក គេក៏មកទាន់នាងភ្លាម ។ លុះចាប់អារម្មណ៍ហាក់ដូចជាមានមនុស្សតាមពីក្រោយ ធិតាក៏ងាក ក្លែត ស្រាប់តែប្រទះនឹងកម្លោះបុរី ក៏គិតក្នុងចិត្តតែម្នាក់ឯងថា :

- តាមមកសងសឹកឬអ្វីហ្នឹង ? មុខចម្លែកមិនដែលឃើញនៅម្ដុំនេះ ពីមុនមកសោះ... តើបុរសនេះជានរណាដែរ ?

លុះឃើញនាងបែរសម្លក់ញយៗ បុរីក៏បង្កើរពាក្យតែម្នាក់ឯង ជាចម្រៀងមួយ ច្រៀងផងហួចផង ឌឺដងអោយធិតាថា:

- សម្លក់សម្លឹងខឹងរឿងអ្វី ភ្នែកសដូចត្រី គេស្ងោររំងាស់បីខែ...!

ខ្ពាញ់ណាស់ កាលបើឮពាក្យឌឺដងនោះ ។ នាងក៏ច្រៀងចោល វិញធ្វើព្រងើយវិញដែរ :

- ស្រកៀរត្រចៀកម្លេះទេ ឮសម្លេងសត្វតុកកែ យំឡ្វេៗ ភ្លេច ងូតទឹកអស់បីខែ ឆ្អេះដូចសេះបង្កង់...!

អីយ៉ា! ថ្វីមាត់ណាស់តើហ៍! បុរីនឹកក្នុងចិត្ត ។ គេក៏ចេះតែជិះ ត្រឹកៗទៅមកតាមពីក្រោយនាង ធ្វើហីៗ ហាក់ដូចជាកំពុងបញ្ជើច បញ្ជើឫកពាអោយធិតាកាន់តែខ្ពាញ់ឡើងៗ ស្រាប់តែបុរសចាប់ភ្លឹក ថាមាណវីនោះបានជិះកង់បត់ចុះបត់ឡើង ពីវត្តពោធិវាល ចុះទៅ ដល់វត្តកណ្ដាល រួចទៅដល់ចុងស្ពានថ្មចាស់មុខសាលាខេត្ត ហើយ ក៏ទៅសួនយុវន័ រួចក៏ជិះបែរត្រលប់មកវត្តកណ្ដាលវិញ រួចក៏វត្ត ពោធិក្នុងហើយក៏ដល់វត្តពោធិវាលវិញ ។ ទ្រាំមិនបាន មាណពក៏ ស្រែកឡើងថា :

- នែ៎! ឡប់សតិហើយហ្ន៎ស ដែលជិះពទ្ធ័វង់ វិលទៅវិលមក មិនដឹងជាចង់ទៅណាសោះ... ?

CHANBOKEO.COM

និតាធ្វើព្រងើយមិនឆ្លើយទេ តែដល់ឮបុរសរអ៊ូជាលើកទីពីរ ទើបធ្វើជានិយាយរកជង្គង់របស់នាងថា :

- ឱ! ជង្គង់អើយ! យើងអាណិតឯងដល់ហើយ ដែលថ្ងៃនេះ ឯងត្រូវធ្វើការហួសកម្លាំង! ទ្រាំបន្តិចទៅណា៎! អស់កម្លាំងធាក់ ពេលណា ដួលកង់ត្រឹមហ្នឹងចុះ! ហើយឯងកុំទាន់អាលដើបអី ចាំព្រឹកស្អែក យើងមកមើលឯងវិញ ឮហើយនៅ ?

មាណពឮដូច្នោះក៏ភ្ញើកង៉ក់ៗ ភ្លាម ត្បិតរកនឹកពាក្យលែបខាយ ចាក់ផាវិញមិនរួច ។ អាល័យតែគិតស្ដុងមិនបានមើល ស្រាប់តែបុរី ជិះធ្លាក់ក្រឡុកតាមផ្លូវមួយយ៉ាងធំ គង្ហុកដៃកង់ ច្រលោតរូបនាយ ដួលទៅដីគ្មោល សឹងបាក់កស្លាប់នឹងកន្លែង ។ គេក៏មីម្នាស្ទុះក្រោក ឡើងភ្លាម បបោសដីពីខោអាវ ហើយក៏ទាញកង់ឡើងយកមកធាក់ បំរុងថានឹងជិះតាមមាណវីអោយដល់ផ្ទះ ស្រាប់តែបាត់រូបនាងឈឹង ពីផ្លូវថ្នល់បាត់ទៅ មិនដឹងថា នាងជិះគេចទៅពួនម្ដុំណាទេ ។ នៅខាងលិចផ្លូវតាមដងស្ទឹង ជាឧទ្យានក្រុង បរិបូណ៌ទៅដោយគុម្ពផ្កាធំ តូចចម្រុះគ្រប់យ៉ាង ។ នៅម្ខាងដងផ្លូវ ជាដីឡូត៍ដែលមានវត្តនិង ភូមិគ្រឹះធំៗ ពោរពេញទៅដោយដើមឈើធំតូចនឹងសួនផ្កាយ៉ាងល្អ ប្រណិត ។ បុរីបែរមើលជុំវិញខ្លួន រកនឹកថា តើមាណវីនោះសមជា អ្នករស់នៅក្នុងភូមិគ្រឹះមួយណាម្ដុំនោះ ។ បន្ទាប់មក គេក៏សួរខ្លួនឯងខ្សិបៗថា :

- តើនារីជាកូនចៅអ្នករស់នៅម្ដុំនេះ ឬក៏ជាអ្នកបម្រើ ? មើលទៅការស្លៀកពាក់របស់នាងសាមញ្ញណាស់ រួចជិះកង់ហើយឱបអំពៅ ទៀត... មិនសមជាកូនចៅអ្នកម្ដុំនេះទេ តែសម្ដីវិញឡូយគួរសម ស៊កសៀតអោយយើងវិញទាល់តែហារមាត់គាំងតែម្ដង មិនសមជាអ្នកបម្រើគេអ្វីបន្តិចឡើយ ។ ដើ1 ក្លាហានណាស់! ថ្ងៃក្រោយ នាងគង់តែដឹងដៃយើងទេ...

នឹកឡើងកាន់តែឆ្ងល់ឡើង នរៈកាន់តែខ្ចាញ់នឹងនារីយើងឡើង កាន់តែចង់ឈ្នះនាងឡើង :

- នេះគេគ្រាន់តែជាស្រីក្មេងធម្មតាៗម្នាក់ ហេតុអ្វីបានជាយើងត្រូវ ចាញ់សំដី ចាញ់ប្រាជ្ញ ចាញ់ចិត្តគេកើត.. ? ឆ្អើយធ្វើទុកសិនចុះ! ថ្ងៃក្រោយនឹងស៊ីសងគ្នាទៀត ។

កំពុងតែគិត ស្រាប់តែ... ទីន! ទីន!

នរៈបែរមើលឃើញ បុរសចំណាស់មួយរូបក្នុងវ័យប្រមាណ៤២ ឆ្នាំ ពាក់វ៉ែនតាស បរឡានវ៉ុលវ៉ាហ្គិន មកឈប់ក្បែរនាយ :

CHIANBOKEO.COM

- ក្មួយបុរីមែនទេ ?
- ជំរាបសួរ បាទ! លោកពូពេទ្យ វិចិត្រ ?
- អឺ! ពូហ្នឹងហើយ ពួកម៉ាករបស់លោកបុរាណ ប៉ាក្មួយឯង នោះអី ។ យើងនៅជិតគ្នានេះតើហ៍ ។
- អូហ៍ សូមទោសដោយខ្ញុំមើលលោកពូសឹងតែមិនស្គាល់ !
- តែពូស្គាល់បុរីច្បាស់ ព្រោះឯងមានរូបរាងដូចលោកប៉ាណាស់ ។ ហើយនេះរៀនចប់ចេញមកធ្វើការស្រុកយើងវិញហើយហ្ន៎ស ?
- បាទ! ទើបមកដល់ផ្ទះពីម្សិលមិញ ។
- អឺ! បើអញ្ចឹងពូទៅសិនហើយ ហើយសុំផ្តាំសួរសុខទុក្ខប៉ាម៉ាក់ ឯងផងណ៎ា!
- បាទៗ !

មានប្រសាសន៍ចប់ លោកក៏បត់ឡានចូលទៅក្នុងរបងផ្ទះដែល នៅក្បែរនោះបាត់ទៅ ។ បុរីក៏ឡើងធាក់កង់ត្រលប់ទៅផ្ទះវិញទាំង មិនអស់ចិត្ត ដែលគេមិនទាន់បានដេញទាន់ជាន់កែង ស៊ើបរកផ្ទះ
របស់នារីនោះថានារីថ្មីមាត់ពូកែនោះជាកូនចៅអ្នកណា ។

ការពិត បុរីជាកូនប្រុសទោលរបស់លោកបុរាណដែលជាវាគ្មិន
នៅឃោសនាការខេត្របាត់ដំបង ហើយដែលជាមិត្តជិតដិតរបស់ លោកដុកទ័រវិចិត្រ ។ បុរីបានទៅបែកទៅរៀននៅភ្នំពេញ តាំងពី ម្តាយគេស្លាប់ទៅ ហើយលោកបុរាណឪពុករបស់គេ បានរៀបការថ្មី ទៀតជាមួយអ្នកស្រីផៃយ៉ា ។ គេមិនចូលចិត្តម្តាយចុងថ្មីរបស់គេទេ ថ្វីបើអ្នកស្រីជាមនុស្សដ៏ល្អម្នាក់ក៏ដោយ ។ បុរសយើងបានទៅរស់ នៅជាមួយម្តាយមីងឯភ្នំពេញ ក្រោយមកក៏ទៅបន្តការសិក្សានៅ ប្រទេសជប៉ុន ។ ពេលនេះ គេចូលវ័យ២៥ឆ្នាំហើយ ទើបតែរៀន ចប់ ត្រលប់មកផ្ទះថ្មីៗនេះ ។ ថៃដន្យ គ្មាននរណាដឹងទេថាហេតុអ្វី បុរីត្រលប់មកផ្ទះវិញ កាលបើគេគេចខ្លួនពីផ្ទះទៅ៨ឆ្នាំមកហើយ ។
- បុរីទើបមកពីណាហ្នឹងកូន ? មើលហ្ន៎... ប្រលាក់ស្រមេកស្រមក ហើយដាច់ដៃដាច់ជើងផង!

នោះគឺជាសំដីរបស់អ្នកស្រីផៃយ៉ាទៅរកបុរី ពេលឃើញនរៈជិះ កង់មកដល់ ។
- បាទ! គឺជិះកង់ដើរលេងតាមដងស្ទឹង ធ្លាក់កន្លុកតាមផ្លូវ...

ស្រាប់តែអ្នកស្រីសើចខឹកៗឡើង :

CHIANBOKEO.COM

- នេះ ប្រហែលជាកូនជិះកង់លួចមើលក្រមុំៗតាមផ្លូវបណ្តោយដង ស្ទឹងយើងនេះទេដឹង បានជាមើលមិនឃើញកន្លុកនោះ ?

អ្នកស្រីនិយាយចំចំណុចខ្សោយប៉ក់តែម្តង ។ បុរីស្ងាត់មាត់ឈឹង មិនហ៊ានតបទេ រួចក៏ឈ្ងោកមុខគេចខ្លួនចូលបន្ទប់បាត់ទៅ ។ យប់បន្តិចទើបគេអើតមុខមកបរិភោគបាយជាមួយឪពុកម្តាយ រួចហើយក៏សំណេះសំណាលគ្នាជាមួយនឹងលោកទាំងពីរ ។ លោកបុរាណ ប្រសាសន៍សួរកូនប្រុសថា :

- បុរី! តើកូនបំរុងនឹងចូលធ្វើការកន្លែងណាដែរ ពេលនេះ ?

- បាទ មិនទាន់ដឹងទេ លោកប៉ា... ព្រោះឥឡូវនេះកូនហាក់ដូចជាកំពុងតែរសិមរសាំក្នុងចិត្តនៅឡើយ មិនដឹងថាចង់ធ្វើការ ឬក៏យកពេលសំរាកលំហែខ្លួនមួយពេលសិន...

អ្នកស្រីផៃយ៉ាលួចមើលទៅបុរីហើយញញឹមរួចពោលថា :

- កូនរសឹមរសាំក្នុងចិត្តបែបនេះមិនមែនដោយត្រូវស្នេហារំខាន បេះដូងទេហ៍ កូនប្រុស ?

បុរីឈ្ងោកមុខ មិនហ៊ានឆ្លើយទេ ត្បិតអ្នកស្រីនិយាយចំចំណុច ខ្សោយរបស់គេទៀតហើយ ។ គេគិតក្នុងចិត្តតែម្នាក់ឯងថា :

- ហេតុអ្វីបានអ្នកស្រីផៃយ៉ាមើលចិត្តយើងធ្លុះម្លេះ ? ចំណុចខ្សោយរបស់យើងអណ្តែតចេញពីក្នុងចិត្តមកក្រៅតាមរបៀបណា ដែលធ្វើអោយគាត់ទាយស្ថានការណ៍ត្រូវអោយរាល់តែដងយ៉ាងនេះ ?

ភរិយារបស់លោកមានប្រសាសន៍ដូច្នេះ លោកបុរាណក៏វាចា សួរទៅកូនប្រុសថា :

- អឺហ៍ មែនហើយកូន! ឯងបានបែកពីប៉ាម៉ាក់ទៅរៀនយកសញ្ញា បត្រ័ចំនួន៨ឆ្នាំហើយ ។ ឯងមិនដែលមានសង្សារអីនឹងគេទេ ?

បុរីញញឹមឡើង :

- ចុះបើកូន...មានសង្សារវិញនោះ តើលោកប៉ាចូលដណ្តឹងនាងឲ្យ កូនដែរទេ បាទ ?

- តែប៉ាចង់ដឹងសិនថា កូនស្គាល់គេប៉ុនណាដែរ ពេលនេះ ?

- គឺ គេជានិស្សិតប្អូនរៀនជំនាន់ក្រោយពីរឆ្នាំ តែមុខវិជ្ជាផ្សេង ។ គេស្រស់ស្អាតណាស់លោកប៉ា ។

- ស្រស់ស្អាតហើយមានវិជ្ជា... ល្អណាស់! ប៉ុន្តែ... តើកូនទាំងពីរនឹងចិត្តគ្នាទៅវិញទៅមកហើយឬនៅ ?

- គឺ...គ្រាន់តែលួចសម្លឹងហើយនិយាយព្រលយពាក្យ តែមិនទាន់ដែលបើកចំហដួងចិត្តប្រាប់គ្នាពេញលេញនៅឡើយទេ ប៉ា ។
- អឺហ៍! បើមិនទាន់នឹងចិត្ត ម្ដេចប៉ាហ៊ានទៅដណ្ដឹងគេកើតទៅ ? តិចលោពេលចូលដណ្ដឹងស្រាប់តែគេប្រកែក នោះយើងមិនបាក់មុខស្លាប់ហើយទេ ?
- តែគេនៅទំនេរមិនទាន់មានជាប់មាត់កនឹងអ្នកណានៅឡើយទេ..
- ច្បាស់ហើយហ្ន៎សកូន ?
- គឺ...ខ្ញុំលួចស៊ើបនឹងពីមិត្តភក្តិ ។
- ចង់បានប្រពន្ធអញ្ចឹងតើហ៍ បានជាហក់មកផ្ទះរកឪពុកម្ដាយវិញ (លោកបុរាណលាន់មាត់) បើមិនដូច្នោះទេ ឯងច្បាស់ជាមិនលេច មុខមកអោយប៉ាឃើញទេ មែនទេ ?

ប៊ុរីឈ្ងោកមុខ លួចចោលកន្ទុយភ្នែកទៅអ្នកស្រីផៃយ៉ា ។ ការពិតនាយមិនចូលចិត្តម្ដាយចុងរបស់នាយទេ តាំងពីយូរមកហើយ ។ គេមិនព្រមហៅអ្នកស្រីថាម៉ាក់ឬក៏ស្រដីរកអ្នកស្រីមុនឡើយ ថ្វីបើអ្នកស្រីមានកិរិយាស្រទន់ហៅរកនាយទៅមកដូចកូនចៅក៏ដោយ ។ ការពិតអ្នកស្រីមានកូនស្រីម្នាក់ដែរ បន្ទាប់ពីរៀបការជាមួយលោក បុរាណមក ប៉ុន្តែថៃដន្យនាងមានជំងឺធ្ងន់ហើយបានធ្វើមរណកាល ទៅតាំងពីនាងមានអាយុមិនទាន់ប្រាំឆ្នាំផង ។ ម្ល៉ោះហើយប៊ុរីក៏ក្លាយ ជាបុត្រទោលតែមួយរបស់លោកបុរាណទៅ ។

បន្តិចមក លោកបុរាណក៏មានប្រសាសន៍ថា :
- ឆ្លើយចុះ ប៊ុរី! ប៉ានឹងចូលដណ្ដឹងនារីដែលកូនពេញចិត្តនោះឲ្យកូនភ្លាមនៅពេលណាកូនមានការធ្វើ ។ ពេលនេះ ប៉ាមិនទាន់ហ៊ាន ចូលស្ដីរូបនាងនៅឡើយទេ ព្រោះបើគ្រួសារខាងស្រីគេសាកសួរ ប៉ាមិនដឹងថានឹងមានអ្វីជាបង្អែកធ្ងន់ចិត្ត ដើម្បីជាលេសចូលដណ្ដឹង គេទេ កាលបើកូនប្រុសគ្មានការធ្វើដូច្នេះ ។ ជាពិសេស បើនារីនោះគេមានតម្រេះវិជ្ជា មានការសិក្សាខ្ពង់ខ្ពស់ដូចឯងដែរ គេមិនសម្លឹងមើលកត្តិយសបុណ្យសក្តិឬទ្រព្យសម្បត្តិរបស់ប៉ាទេ ។ ប៉ាថាគេនឹងសម្លឹងគុណសម្បត្តិរបស់កូនជាជាង ព្រោះថាបើអត់ពីប៉ាទៅ កូនក៏នៅមានលំនឹងក្នុងជីវិតយ៉ាងប្រពៃសំរាប់ជ្រោមជ្រែងទទួលខុសត្រូវ ក្រុមគ្រួសាររបស់កូនដោយមិនភ័យខ្លាចរលំដួល ។

CHANBOKEO.COM

ប៊ុរីធ្វើមុខស្អុយប៉ែ កាលបើឮឪពុកមានប្រសាសន៍ដូច្នោះ ។ ការពិត គេបំរុងមកបាត់ដំបងតែពីរបីថ្ងៃទេ ដើម្បីសុំអោយលោក បុរាណចូលដណ្តឹងនារីដែលគេពេញចិត្ត រួចគេនឹងវិលត្រលប់ទៅ ភ្នំពេញវិញហើយ ។ ចៃដន្យ លោកបុរាណមិនព្រមទទួលពាក្យទៅ វិញ ហើយបែរជាជំរុញអោយគេរកការធ្វើជាជំនួស ។ គេធុញថប់ ក្នុងចិត្តពេក ក៏ងើបគេចទៅពួនក្នុងបន្ទប់បាត់ ទុកឲ្យលោកបុរាណ និងភរិយាមើលមុខគ្នា គ្រវីក្បាលទាំងពីរនាក់ ។

ការពិត ប៊ុរីធ្លាប់ទទួចសុំអោយអ្នកស្រីបូរា ម្តាយមីងរបស់ខ្លួន នៅភ្នំពេញទៅចូលដណ្តឹងនារីមួយរូបនោះម្តងហើយ តែគាត់មិន ហ៊ានដើររំលងលោកបុរាណ ទើបដេញអោយប៊ុរីចូលមកនិយាយជា មួយលោកប៉ាដោយខ្លួនឯង ។ តែមើលទៅ ប៊ុរីមិនបានសំរេចដូច បំណងដែលគេបានគិតទុកនោះទេ ។ គេប្រហែលជាត្រូវត្រលប់ ទៅភ្នំពេញវិញដើម្បីរកការធ្វើហើយ បើមិនដូច្នោះទេ លោកបុរាណ មិនដណ្តឹងប្រពន្ធអោយរូបគេឡើយ ។ យប់នោះ ប៊ុរីអង្គុយគិតចាក់ ស្មុគ្រស្មាញតែម្នាក់ឯងទល់ភ្លឺ...

ព្រហាមស្អែកឡើង...

ប៊ុរីដើរឆ្លងថ្នល់ទៅសំកុកនៅក្រោមដើមដូងមាត់ស្ទឹង សម្លឹង មើលត្រើយម្ខាង ឃើញមនុស្សម្នាចរច្រវាត់ ។ នៅក្នុងស្ទឹងវិញ មនុស្សចែវទូកទៅមក ខ្លះរកត្រី ខ្លះដឹកឥវ៉ាន់ ខ្លះដឹកមនុស្ស ។ គិតទៅម្នាក់ៗរវល់អោយរចល់ ទំនេរតែបុរសយើងមួយដែលនៅ សំកុករាប់ចុងត្រែងដែលរេរាំទោរទន់ទៅតាមជំនោរខ្យល់ ។ ប៊ុរី ឈរផ្ទឹងស្ងៀមស្ងាត់នឹកទៅដល់មនុស្សម្នាក់ដែលគេធ្លាប់មានចំណាង អនុស្សាវរីយ៍ជាមួយគ្នាកាលពីអតិតកាលលើឆ្នេរស្ទឹងសង្កែនេះ...

ស្ទឹងខៀវនាវស្នេហ៏

- រលករលករលេញប្រដេញតាមខ្យល់ នាំចិត្តខ្វាយខ្វល់អណ្តែតទៅឆ្ងាយ
ដងស្ទឹងបត់បែនសែនដាច់អាល័យ អារម្មណ៏ស្រម័យស្រមោលអតិត ។
- ទឹកស្ទឹងហូរទៅនាំចិត្តស្នេហា បេះដូងរៀមរ៉ាផ្ញើកែវវរមិត្រ
បងវិលច្រើនដងរកម្ចាស់ជីវិត តែត្រូវខកចិត្តត្បិតបាត់ពៅសូន្យ...
- ផ្សារក្រោមវត្តពោធិស្ពានថ្មស្ពានដែក ផ្តាំចិត្តសង្វេគក្រៀមក្រំស្រពោន
ថាបងសែននឹករលឹកមាសស្ងួន ពេលនេះនឹមនួនសុខទុក្ខយ៉ាងណា?
- វាយោរសាត់ណាត់ស្បៃពពក ឱភារិយោគនឹកមុំធិតា
សុរិយ៏យាងរះឱភាសភ្លឺថ្លា តែដួងចិន្តាស្រអាប់ឥតន័យ...

CHANBOKEO.COM

រំពេចនោះ ស្រាប់តែគេដាក់ភ្នែកទៅចំនារីម្នាក់កំពុងធាក់កង់ចេញពីទិសវត្តពោធិក្នុងសំដៅទៅស្ពានថ្មថ្មី កាត់មុំកន្លែងដែលនាយ កំពុងអង្គុយលេង ។ អីយ៉ា! នោះគឺជាមាណវីដែលគេបានវង្វេង បាត់កាលពីម្សិលនោះតើហ៏ ។ ឃើញនាងភ្លាមមាណពក៏នឹកខ្ញក់តែ ក្នុងចិត្តតែម្តង ។ គេស្ទុះភ្លែតចាប់ដុំដីមួយដុំគប់នាងរឹង ដោយការនឹកឃ្នាន់ខ្នាញ់ចំពោះរូបនាង តាំងពីម្សិលមិនទាន់អស់កំហួលនៅ ឡើយ ។

ផ្លក់! ដុំដីក៏រត់ត្រូវនាងកណ្តាលខ្នងពេលនាងជិះហួសទៅបន្តិចត្បិតឆវីមិនបានចាប់ភ្លឹកពីវត្តមានរបស់បុរីនៅមាត់ស្ទឹងតាមដងផ្លូវ នោះទេ.. ។ លុះត្រូវមួយដុំដីភ្លាម ស្រាប់តែនាងចាប់ហ្វ្រាំងជីក់ ចុះពីកង់ងាកបែរក្រោយរឹងយ៉ាងរហ័ស ។

- យី! អីក៏ឈ្លើយម្ល៉េះ ?

នាងខទានឡើង កាលបើឃើញភក្ត្រ័បុរីភ្លាម ។ ធិតាចតកង់បញ្ឈរហើយស្រវាដុំដីគប់បុរសយើងវិញ ពីរបីគ្រាប់ជាប់គ្នារងឹក ។ ប៉ក់! ដុំដីមួយដុំហោះត្រូវថ្ងាសបុរសយើងផាច់ ឈឺសឹងបែក អំពិលអំពៃក ។ ឃើញដូច្នោះនាងក៏សើចកខឹកឡើង :

- ហ្នឹង បានសមមុខ!

ថាហើយ នាងក៏ឡើងជិះកង់ចេញទៅ ។ បុរីមិនអស់ចិត្ត ក៏ស្រវាដុំដីមួយក្តាប់បាចចប្រាយលើនាងតែម្តង ។ ចៃដន្យ ធិតាមិន គេចទេ បែរជាឈប់កង់ហើយឈរសម្លក់ រួចហើយស្រដីថា :

- ម៉េច ? ចង់ធ្វើសង្គ្រាមណាស់មែនទេ ?

ម្តងនេះ ទាំងដុំដីដុំគ្រួសអ្វីៗនៅតាមដងផ្លូវម្តុំនោះហោះព្រោង ព្រាតឡើង ។ គេតដៃគ្នាទៅមក ប្រលាក់ដីមុខឡើងស្រមកមើល មិនយល់រៀងខ្លួន ។ អ្នកស្រុកក៏នាំគ្នារត់ឈូឆរនាំគ្នាមកចោមឈរ មើល ។ ស្រាប់តែពូប្រេងដើរមកដល់ :

- ស្លាប់ហើយ អ្នកប្រុសបុរី! ហើយលែងល្បែងយកឈ្នះចាញ់អី ហ្នឹង បានជានាំគ្នាគប់ដុំដីគប់គ្នាដូចគប់ឈ្លូងចូលឆ្នាំយ៉ាងអញ្ចឹង ?

លុះឃើញគេមកឈរមើលច្រើនពេក បុរីក៏ឈប់ហើយបែរមុខទៅម្ខាងយកដៃបបោសដីពីសក់ក្បាលនិងពីរង្វង់មុខ :

- គឺមានមនុស្សចម្លែកជិះកង់កាត់ភូមិយើង... ខ្លាចជាចោរទើបនឹក ចង់ប្រដៅខ្លះៗ
កុំអោយថ្លើមធំ ចូលមកលិបលម៉ុំនេះទៀតណាំពូ !
(ប៉ុរីឆ្លើយទៅពូប្រេងវិញ)
- ត្រូវ ! អ្នកដែលលួចគប់គេពីក្រោយខ្នងនោះហើយជាចោរ ពិត
ជាត្រឹមត្រូវដូចគេនេះនិយាយអញ្ចឹង ! ពូមានស្គាល់ចោរហ្នឹងទេ ?
នារីនោះសួរទៅពូប្រេង តែមិនព្រមយកដៃបោសដីប្រលាក់ពី មុខនាងចេញទេ
បែរជាយកដៃច្រត់ចង្កេះចង្អុលមុខប៉ុរី ហើយ ស្រដីបន្តទៅទៀតថា :
- នែ៎ ពលរដ្ឋដ៏សែនល្អ ! សូមមេត្តាអញ្ជើញជួយចាប់ចោរហារយ
ដែលចូលចិត្តលួចយកដុំដីដុំថ្មគប់អ្នកស្រុក ដែលធ្វើដំណើរកាត់ម្តុំ នេះផង
កុំស្ងវរៀនអត់ចិត្តអត់ថ្លើមពេក ឮហើយនៅ ? គួរតែរៀន ធ្វើគំរូល្អដល់អ្នកស្រុកយើងខ្លះៗ
បានទេ ?
អ៊ូយ ! ត្រូវមួយផ្លែទៀតហើយ ! ប៉ុរីធ្វើភ្នែកស្លឹ ឆ្លើយមិនរួច ត្បិតត្រូវមួយខ្លាយថ្មីទៀត ។
ពេលនោះ មាណវីក៏ឡើងកង់ធាក់ចេញទៅ ។ អ្នកស្រុកនៅទីនោះឈរធ្វើមុខញឹមៗ
តែគ្មានរណាគេ សួរអ្វី និយាយអ្វីទេ ។ បន្តិចមក គេនាំគ្នាដើរថយចេញអស់ទៅ ។
- ពូប្រេងស្គាល់នារីម្នាក់ហ្នឹងដែរទេ ?
ប៉ុរីសួរពូប្រេងដែលជាអ្នកចាំផ្ទះអោយលោកប៉ុរាណ ។
- អ្នកប្រុសចាប់អារម្មណ៍អ្វីពិសេសលើរូបនាងហ្ន៎ស ?
ពូប្រេងមិនឆ្លើយបែរជាសួរបញ្ច្រាសទៅប៉ុរីវិញ ។
- អត់ទេ ! គ្រាន់តែឃើញមុខលើកដំបូង ស្រាប់តែស្អប់ហើយនឹក
ខ្ពាញ់ក្នុងចិត្តតែម្តង ។
- អូហ៎ូ ! ប្រយត្ន័ណា៎ ! កុំស្អប់គេដោយមិនដឹងរឿង តិចលោស្អប់ វាប៉ះជំពាប់លើទៅ
ពិបាកខ្លាស់ធម្មជាតិណា៎ អ្នកប្រុស !
- ចេះតែថាហើយពូ... មនុស្សចំលែកនឹងគ្នាយ៉ាងនេះ តើឲ្យជំពាប់ យ៉ាងម៉េចនឹងកើតទៅ ?
គ្មាននិស្ស័យជាមួយអ្វីបន្តិចទេ លោក !
- ដឹងអីថា... ថៃដន្យវាសនាមើលមិនឃើញទេ ។
- អោយស្បថទៅចុះពូ ! មុខហ្នឹងរាងហ្នឹង បើអោយជំពាប់បាន ពិតមែននោះ
ប៉ុរីខ្ញុំសុខចិត្តទៅបួសវិញហើយ ។

CHANBOKEO.COM

- អីយ៉ា! កុំលែងធ្ងន់ៗអញ្ចឹងពេកអី ហ្នឹ! តិចប្រយត្ន័ខ្មោចទាញមាត់ អ្វីៗក្លាយជាការពិត ពិបាកមិនរួចខ្លួនពីចូលផ្នូសទៅ..!
- គ្មានថ្ងៃទេ ពូអើយ!

ពូប្រេងញញឹមលែងតវ៉ានឹងបុរីទៀតហើយ ប៉ុន្តែលួចនឹកក្នុង ចិត្តតែម្នាក់ឯងថា :
- ណ្ហើយ! អោយតែបានលួចគិតប្រទុស្តរាយនឹងគេដោយមិនដឹង ហេតុផលទៅ គង់ថ្ងៃណាបាបធ្លាក់មកលើខ្លួនវិញទេ ។ សង្ស័យ ណាស់ ក្រែងតែថ្ងៃក្រោយទៅបំរើគេសងដំងឺចិត្តវិញទេ ។

0000000000000000000

00000

0

CHANBOKEO.COM

# វគ្គទីពីរ
# ស្នូប់ជំពប់លើ

ល្ងាចនោះ ប៊ុរីក៏បររថយន្តទៅលេងមិត្តម្នាក់នៅដូនទាវឈ្មោះ សាមេត ។ ការពិត ប៊ុរីមិនសូវមានមិត្តនៅបាត់ដំបងទេ មានតែ សាមេតប៉ុណ្ណោះ ព្រោះគេធ្លាប់រៀនជាមួយគ្នាកាលនៅមធ្យមសិក្សា ហើយក៏បែកគ្នា ព្រោះប៊ុរីបានចេញទៅរស់នៅភ្នំពេញ ។ ពេលនេះ សាមេតរស់នៅឯដូនទាវ ធ្វើការនៅរោងចក្រដូនទាវ ក្បែរផ្ទះហ្នឹង តែម្តង ។

ការពិត ម្សិលមិញ ប៊ុរីបានទៅរកសាមេតម្តងហើយ តែគេមិន បានជួប ជួបតែអ្នកជិតខាងទើបខកការ ។ ថ្ងៃនេះ គេបរឡានកាត់ មុខវត្តស្លាកែតម្តងទៀត ស្រាប់តែនឹកឃើញដល់ម្សិលមិញ ដែល គេបរឡានកិនអំពៅនារីម្នាក់នោះ រួចហើយមិនបានចុះពីឡានមក មើលខុសត្រូវ ។ តាមពិត គេកំពុងប្រញាប់ត្រលប់ទៅផ្ទះ ព្រោះមានគេមកតាម ប្រាប់ថា អ្នកផ្ទះបានទទួលតេលេក្រាមមកពីភ្នំពេញ សំរាប់ប៊ុរី ។ កាលនោះ គេអាល័យភ័យអរឿងតេលេក្រាម នឹកថា ប្រហែលជាធិតាដ៏សោភាម្ចាស់ដួងចិត្តរបស់គេនោះ សរសេរមកគេ ទើបនាយខំរត់ទាំងប្រញិបប្រញាប់ទៅទទួលឥតបង្អង់ ហើយក៏ភ្លេច រឿងសមគួរនឹងមាណវីម្ចាស់អំពៅដើមទាំងនោះទៅ ។ ចៃដន្យអី តេលេក្រាមនោះមិនមែនមកពីសង្សាររបស់គេឯណា ។ ការពិតគឺជា តេលេក្រាមមកពីជប៉ុនទេតើដែល ផ្ញើដំណឹងពីរឿងការងាររបស់ប៊ុរី ដែលក្រសួងចង់ឲ្យប៊ុរីវិលទៅធ្វើការឯជប៉ុនវិញឆាប់ៗនេះ ។

ប៊ុរីជាកូនប្រុសទោលហើយត្រូវក្រុមគ្រួសារទំរើសតាំងពីតូច ។ ដោយហេតុនោះហើយទើបគេចូលចិត្តយកតែចិត្តខ្លួនជាធំ មិនសូវ នឹកគិតដល់ចិត្តនរណាទេ ។ អ្វីដែលគេចង់បាន គឺត្រូវតែយកអោយ បាន ។ ដល់មកជួបនារីមាត់ឆៅសំដីពូកែម្នាក់នោះ

CHANBOKEO.COM

គេប្រែជាចាញ់ ច្រាបដល់ទៅពីរលើក ជាពិសេសនៅចំពោះមុខសាធារណជនផងទៃ ទៀតផង ធ្វើអោយគេនឹកខ្ញាញ់ចង់ចាញ់ចង់ឈ្នះតែម្តង!

ពេលនេះ គេបរឡានហួសវត្តស្លាកែតទៅហើយ តែចិត្តនៅតែ នឹកខ្ញាញ់នារីនោះមិនទាន់បាត់ពីក្នុងចិត្តនៅឡើយទេ ។ គេស្រម័យ នឹកគិតរកឧបាយថា នឹងធ្វើយ៉ាងណាសងសឹកអោយបានឈ្នះម្តង ដើម្បីបំបាត់អាមាសដែលនាងធ្វើអោយរូបគេបាក់មុខ ។ កំពុងតែ មមើមមាយ ស្រាប់តែមានហ្វូងក្មេងរត់កាត់ទទឹងថ្នល់ ។ បុរីភ្ញាក់ ព្រើត ជាន់ចាប់ហ្វ្រាំងមិនទាន់ ក៏រេចង្កូតទៅបុកដើមអំពិលធំមួយ តាមដងផ្លូវ លាន់ក្តាំង ។ រថយន្តថ្មីស្រឡាង ត្រូវបែកច្រមុះអស់ រលីង ។ បុរីបែរក្រោយ មើលទៅមុខ ងាករកជំនួយ តែពេលនោះ រសៀលជ្រេបន្តិចទៅហើយ ។ គេមិនឃើញមានឡានម៉ូតូធ្វើដំណើរ ទៅមកទេ ក្រៅពីក្មេងៗម្តុំៗនោះមកឈរមើល ។

- ក្មួយប្រុស! ពុកម៉ែនៅទេ?

បុរីសួរក្មេងប្រុសម្នាក់អាយុប្រហែល១០ឆ្នាំ ។

- អត់នៅទេ បាទ! គាត់ទៅធ្វើការនៅបាត់ដំបង ព្រលប់បន្តិច ទៀតទើបមកដល់ ។

រំពេចនោះ តាចាស់ម្នាក់បានដើរមកមើល ។ បុរីក៏ស្ទុះទៅពឹង គាត់ភ្លាម ស្រាប់តែគាត់ឆ្លើយថា :

- អឺ! ចាំឲ្យកូនតាវាជូនចៅឯងទៅផ្ទះវិញ តែវាមិនទាន់មក ដល់ផ្ទះទេ ។ វាធ្វើការរោងចក្រក្រចៅនៅឆ្នួនទាវនេះឯង ប៉ុន្តែជួន កាលគេអោយវាធ្វើការថែមម៉ោងក៏មាន ។ ដូច្នេះឯងចាំបន្តិចទៅ ។ បុរីក៏នៅឈរវ៉េវ៉របន្តទៀត នឹងដើរចោលឡានទៅរកជំនួយក៏ មិនកើត ព្រោះវាព្រលប់ដែរទៅហើយ ម្ល៉េះហើយ ក៏សុខចិត្តនៅ ចាំបន្តិចទៀតទេ ។ ភ្លាមនោះ ស្រាប់តែគេក្រលេកឃើញមាណវី ពាក់ខោអាវពណ៌ខៀវរបៀបកម្មកររោងចក្រកំពុងជិះកង់តម្រង់មក ពីឆ្នួនទាវឆ្ពោះទៅទិសក្រុងបាត់ដំបង ។ គេអរភើតស្ទុះរត់ទៅស្កាត់ នឹងអាលសុំជិះត្រលប់ទៅបាត់ដំបងដែរ :

- អត់ទោស សូមពឹងបន្តិចបានទេ បាទ!

នារីនោះទុចកង់ឈឹក កាលបើមានមនុស្សរត់មកពាំងផ្លូវ ។ លុះ ក្រលេកចំមុខនារីកាលណា ស្រាប់តែបុរីចំហមាត់ឆ្ងង បើកភ្នែកធំៗ សំដែលអាការៈភ្ញាក់ផ្អើល ហើយឧទានថា :

- គឺនាងទៀតហើយ ?

មែនហើយ! នោះគឺមាណវីដែលនាយបានតាមរករឿងពីរដង រួចហើយ ។ កាលបើឃើញរថយន្តបុរីភ្លាម មាណវីសើចកខឹកៗ ឡើង ហើយស្រដីចំអកអោយនាយថា :

- យី! អស់លក្ខណ៍ហើយហ្ន៎ស ទើបមករកពឹង ?

បុរីខ្ញាញ់ណាស់ ចង់តែឆ្លើយយកចាញ់ឈ្នះទេ ។ គេដកឃ្លា ចេញពីផ្លូវ ទុកអោយនាងជិះចេញទៅ ត្បិតមិនចង់ជាប់សគុណ ។ តាមពិត ពេលនោះ គេក៏ចង់សាកចិត្តធិតាដែរថាតើនាងមានទឹកចិត្ត មកជួយរូបគេដែរទេ ។ ចៃដន្យ នាងបែរជាឡើងជិះកង់ចេញទៅ ធ្វើឫកព្រងើយមិនឃើញស្មគ្រ័ចិត្តជួយជូននាយទៅផ្ទះសោះ ។ ខក ចិត្តណាស់ បុរីក៏នឹកដល់រឿងយកចាញ់យកឈ្នះភ្លាម ។ គេក៏សុខ ចិត្តទុកឡានចោលទីនោះ ដោយមិនមាននឹកចង់ផ្តាំផ្ញើពីណាទេ រួច ហើយក៏រត់ត្រែទៅ ចាប់រានកង់ខាងក្រោយរបស់មាណវី
:

- នែ៎! អីក៏អត់ចិត្តម្ល៉េះហ្ន៎! ឃើញមនុស្សមានគ្រោះថ្នាក់ឡាន ហើយ សុខចិត្តទល់ត្របកភ្នែកមើល មិនព្រមជួយ!

ថាហើយមាណពក៏ហក់ឡើងជិះលើរានខាងក្រោយរបស់មាណវី ហើយក៏លូកដៃស្រវាអោបចង្កេះនាងខ្វាប់ ។ កល្យាណីភ្ញាក់ក្រញាង ដែលបុរសធ្វើដូច្នេះចំពោះនាង ។ ធិតាចាប់ហ្វ្រាំងង៉ក់ ចុះពីកង់ រួចលូកម្រាមដៃក្តិចដៃបុរីហើយស្រែកថា :

- យី! ព្រហើនណាស់តើ ?

- អីយ៉ូយ! ខ្យាដីរីនេះកាចម្ល៉េះ!

គេធ្វើមុខជូរ តែក៏លួចញញឹមផងដែរ កាលបើឃើញនារីសម្លក់ រូបគេវិញ ដោយកិរិយាឃ្នាន់ខ្ញាញ់ផង អៀនខ្មាសផងដែលត្រូវនរៈ អោបចង្កេះប៉ះខ្លួនប្រាណនាង ។ មាណវីក៏ផ្តួលកង់ចុះ រួចហក់គេច ទៅឈរនៅម្ខាង សំដែងឫកពាហាក់ដូចជាមានអារម្មណ៍មិនល្អ ចំពោះបុរីដែលសុខៗមកចាប់អោបចង្កេះនាងលេងទទេៗ ។ ការ ពិតនោះជាល្បិចរបស់បុរីទេ ។ បើគេមិនធ្វើដូច្នេះ ធ្វើម៉េចនឹងនារី ហក់ចុះពីកង់ ដើម្បីឲ្យគេបានឌុបនាងតាមសម្រួល នឹងអាលបាន ជិះត្រលប់ទៅផ្ទះវិញផងនោះអី ។ កាលបើនាងទំលាក់កង់ទៅដី ភ្លាម បុរីក៏ស្ទុះចាប់ដៃកង់ លើកតួឡើងហើយស្រដីថា :

- ម៉េចដែរ ? ឥលូវនេះ ចង់ឌុបខ្ញុំទៅផ្ទះ ឬក៏អោយខ្ញុំឌុបនាងទៅ ផ្ទះ ? រើសយកមួយទៅ ?

CHANBOKEO.COM

តែធិតាបែរជាឈរស្ងៀមធ្វើមុខក្រញូវ ។ មែនហើយ បើប្រើ តែសំដី
នាងប្រហែលជាមិនចាញ់ទេ តែដល់លេងប៉ះដៃប៉ះជើង
នាងត្រូវតែលើកទង់ជ័យស ។

- នែ៎ ព្រលប់ហើយណា៎! (បុរីនិយាយ) នៅច្រឹមច្រុមអញ្ជឹង តិច លោកាន់តែយប់ទៅ
នាំតែប៉ាម៉ាក់ចាំផ្លូវ ភិតភ័យទទេៗ ។

ដល់ឮបុរីពោលដូច្នោះ នាងហាក់ដូចជាដូរកិរិយាបន្តិចដែរ តែ
ក៏នៅអែអង់ដដែលមិនហ៊ានជិះពីក្រោយអោយបុរីឌុបទេ ។ ឃើញ ដូច្នោះ
បុរីក៏តឿនថែមបន្តិចទៀត :

- នែ៎នាង! ខ្ញុំនេះ មិនមែនសង្សារនាងទេ កុំអៀនកុំខ្មាស់អីណា៎!
គ្រាន់តែសុំដោយសារមួយពេលប៉ុណ្ណោះ ។ បើខ្ញុំមិនទាល់ច្រកទេ នោះ ខ្ញុំក៏មិនពឹងនាងដែរ
កុំបាច់បញ្ចេញកិរិយាអឹមអៀនដូច្នេះអី យ៉ាងណាក៏ខ្ញុំមិនលួចស្រលាញ់នាងដែរ
មុខមើលមិនបានយ៉ាងនេះ ខ្ញុំមិនយកធ្វើសង្សារឡើយ គឺសុខចិត្តលើកទុកអោយអ្នកផ្សេង ហើយ
កុំភ័យអីណា៎!

ខ្លាញ់ណាស់ កាលបើឮសំដីស៊កសៀតរបស់នាយយើង ។ ធិតា ងរប៉េវកញ្ឆក់ដៃកង់ពីបុរស
ហើយឡើងជិះរឹងធ្វើមិនដឹង ។ លុះ ឃើញដូច្នោះ បុរីក៏កាន់តែចង់ផ្ទាញ់ផ្ទាលថែមទៀតតែម្តង ។
គេក៏ ហក់ឡើងពីក្រោយនាង អោបចង្កេះធិតាសាជាថ្មី តែម្តងនេះ នាង បែរជាធ្វើមិនដឹង
ធ្វើឫកហាក់ដូចជាគ្មាននរណាជិះអោបចង្កេះនាង អ្វីសោះឡើយ
បែរជាលូកដៃក្តិចបុរសយើងសួរប៉ាត់ :

- អីយ៉ូយ! ខ្យាដីរីពីណាកាចម្ល៉េះលោក ? ខាំឈឺណាស់!

បុរីរអ៊ូរួចដកដៃចេញ ។ បន្តិចមកគេក៏ស្រវាអោបចង្កេះនាងជា លើកទីពីរ
តែលើកនេះគេឲ្យបនាងតឹងដៃជាងមុន ស្រាប់តែមាណវី យកម្រាមដៃក្តិចទៀត ។ តែម្តងនេះ
មាណពឈប់លែងដៃហើយ បណ្តោយអោយនាងក្តិចតាមស្រឡាញ់ សុខចិត្តទ្រាំឈឺនឹងក្តិច តែ
មិនអោយចាញ់ចិត្តទេ ។ បន្តិចមក គេក៏បន្លំផ្តេកកេសាលើខ្នងធិតា
ស្រូបយកក្លិនខ្លួននារីពេញបេះដូងរបស់គេ ។ ពេលនោះ ទ្រូងនរៈ ក៏រណ្តំញាប់ញ័រយ៉ាងចម្លែក...
រំភើបផង ញាប់ញ័រផង...រកបរិយាយ មិនត្រូវឡើយ...

CHANBOKEO.COM

ផ្កាស្នេហ៍...

- ទេពមន្តអ៊ីហ៊្មុំស្រូបឆក់យក　　បេះដូងពន្លកប្រុសរៀមរ៉ា
ឃើញភក្ត្រ័ធ្លាក់ខ្លួនលង់ស្នេហា　　រន្ធត់ចិន្តាញ័រអង្គប្រាណ ។
- ក្រអូបគន្ធាផ្កាកុលាប　　អារម្មណ៍រំភើបប្រៀបពុំបាន
យល់ក្លិនពិដោរផ្កាភ្ញុំផាន　　ដួងចិត្តក្សេមក្សាន្តប្រាណភិរម្យ ។
- ជួបគ្នាថ្មីៗហប្ញទ័យនឹក　　លួចស្នេហ៍ពន្លឹកលើមាសមុំ
ដៃបងទាំងគូលើកប្រណម្យ　　ផ្សងផ្កាក្រពុំទំចុងមែក ។
- ដងស្ទឹងសង្កែជាសាក្សី　　ព្រះពុទ្ធរមណីអង្គអនេគ
សូមជួយបងជួបផ្កាល្អឯក　　ជាគូគាប់ត្រេករួមភិសម័យ ។

ភ្លាមនោះ ស្រាប់តែមានក្មេងៗពីរបីនាក់បានឃើញ ក៏ស្រែក សួរលាន់ឡើងថា :
- យី! បងស្រីឱុបពីណាគេហ្នឹង ? កម្លោះមាឌធំយ៉ាងហ្នឹង ម៉េចក៏ មិនចេះដិះកង់ ?
ឲ្យស្រីៗឱុបអញ្ចឹងមិនចេះខ្មាសគេទេ ?

ស្រាប់តែមាណវីសើចខឹកៗ ហើយឆ្លើយវិញថា :
- គឺបងកំពុងដឹកមនុស្សពិការយកទៅពេទ្យ ។ គេនេះធំតែមាឌទេ
អូនអើយ ប៉ុន្តែចិត្តវិញតូចប៉ិនអាចម៍សុចឯណោះ ។ ប្អូនឃើញទេ សូម្បីជើងវែងៗប៉ុនហ្នឹងហើយ
នៅតែជិះកង់ខ្លាចធ្លាក់ដូចកូនក្មេង
ខំប្រវាតោងអោបចង្កេះបងអោយណែន មិនចេះខ្មាស់ក្មេងៗទេ ។
- ងាប់! យ៉ាប់អញ្ចឹងហើយ ម៉េចក៏បងមិនអោយនៅផ្ទះវិញទៅ ?
- ទុកនៅផ្ទះអោយទំនេរធ្វើអី ? ឱុបតាមទុកអោយនៅយាមកង់កុំ អោយចោរលួច
វាមានប្រយោជន៍ជាជាង ។

ថាហើយនាងក៏ជិះកង់ហួសទៅទុកអោយកូនក្មេងទាំងនោះអស់
សំណើចក្អាកក្អាយពីក្រោយលាន់រំពង ។
- អឺ! ខំសើចទៅ សើចទៅ... ទាន់សើចបាន ។

បុរីស្រដីទាំងខ្លាញ់ដែលឆវីស្រដីចាក់ផារូបនាយ ឲ្យក្មេងៗសើច ចំអក ។
គេក៏យកដៃរិតចង្កេះធិតារិតតែខ្លាំងឡើង ប៉ុន្តែនាងមិនឮ មាត់អ្វីមួយម៉ាត់សោះ ។ ពេលនោះ
គេមានអារម្មណ៍ថា ហាក់ដូចជា នឹកខ្លាញ់ក្នុងចិត្តចំពោះធិតាកាន់តែខ្លាំងឡើងៗ ម្ល៉ោះហើយក៏ផ្ទោប

CHANBOKEO.COM

ដៃរិតចង្កេះរបស់នាងយ៉ាងអស់ទំហឹង ធ្វើយ៉ាងណាអោយឈ្នះចិត្ត នាង ។ រំពេចនោះស្រាប់តែនាងស្រែកឡើងថា :

- អួយ!

រួចហើយក៏រេចង្កូតកង់ដួលប្រួសទៅដីធ្វើមុខឡើងស្វាយល្អក ។ បុរសយើងភ្ញាក់ព្រើតខំជួយទប់កង់វិញ តែទប់មិនរួច ក៏របូតដៃឲ្យ នារីដួលទាល់តែបាន ។ តែលើកនេះ មើលទៅ នាងមិនមានកិរិយា លែងសើចទេ... គឺនាងពិតជាមានលក្ខណៈហាក់ដូចជាកំពុងត្រូវ ខ្យល់ចាប់អញ្ជឹង ។ ប៊ុរីនឹកភ័យក្រោយតែម្ដង ក៏យកដៃអង្រួន :

- នាង! នាងយ៉ាងម៉េចហ្នឹង ?

តែនាងមិនឆ្លើយទេ គ្រាន់តែធ្មេចភ្នែក ខាំមាត់ធ្វើមុខហាក់ដូចជាកំពុងរំលត់នូវភាពឈឺចាប់ក្នុងខ្លួនជាខ្លាំង ។ កាលបើឃើញមុខ នាងកាន់តែស្វាយទៅៗ ប៊ុរីក៏លើកបីនាងឡើងទាំងចិត្តភិតភ័យ ញាប់ញ័រកាន់តែខ្លាំង :

- នាង... អាចក្រោកឈរបានទេ ?

ស្រាប់តែនិតាបែរជាត្រជាក់ដៃស្រឹតៗតែម្ដង ។ ប៊ុរីភ័យណាស់ក្នុងចិត្តនឹកស្ដាយដែលនាយលែងជ្រុលដៃ រិតខ្លួននាងតឹងពេករហូតចប់ដង្ហើមត្រូវស្ទះខ្យល់យ៉ាងនេះ ។ គេក៏លើកនាងបីឡើង ស្រាប់តែប្រទះនឹងខ្សែកបន្ដោងប្រាក់កាក់មួយ យួរណិងណោងចេញពី ក អាវរបស់នារី ។ គេភ្ញាក់ព្រើតចាប់យកមកមើល ឃើញចំណារលើ បន្តោងប្រាក់កាក់ដែលសរសេរថា វៃសង្កៃ ។ ពេលនោះស្រាប់តែ ប៊ុរីលាន់មាត់ឡើងថា :

- ស្រីម៉ៅ ?

បុរសសង្ហាក៏ប្រែទឹកមុខឡើងខៀវតែម្ដង ទំនងហាក់ដូចជា ភ្ញាក់ផ្អើលខ្លាំងណាស់ ។ បន្ទាប់មក មាណពលើកបីនាងដាក់លើ កែបកង់ ឯខ្លួនឯងវិញអង្គុយលើរានខាងក្រោយ រួចដាក់ក្បាលនាង អោយអោបទ្រោបលើស្មារបស់នាយ ។ គេយកដៃម្ខាងទប់ខ្លួននាង ដៃម្ខាងទៀតកាន់ចង្កូតកង់ ធាក់ចេញទៅយ៉ាងលឿន ។ តាមផ្លូវ គេនឹកស្ដាយក្រោយផង ព្រួយបារម្ភផង ដែលឃើញស្រីកល្យាណ ទន់ខ្លួនល្អក់បាត់មាត់ឈឹងលើស្មារបស់នរៈ មិនដឹងថានាងកំពុង ត្រូវខ្យល់ចាប់ឬមានជំងឺអ្វីទេ ។ ពេលនោះ មាណពប្រែជាមានចិត្តកន្ទុះរាហើយញាប់ញ័រយ៉ាងចម្លែក ពេលគេត្រកងខ្លួននារីក្នុងរង្វង់ ដៃរបស់គេ ។ ក្លិនខ្លួននារីដ៏ក្រអូបប្រហើរសាយក្លិនដណ្ដប់នាសានរៈ

CHANBOKEO.COM

បានធ្វើឲ្យបេះដូងគេរន្ធត់ច្របូកច្របល់ក្នុងចិត្តយ៉ាងចម្លែករកថាមិន ត្រូវ ។ ខណៈនោះ
នរៈមិនដឹងថា គេត្រូវនាំយកធិតាយើងទៅណា ទេ ។ គិតចុះគិតឡើង
គេក៏សំរេចចិត្តធាក់កងអោបនាងយ៉ាង លឿន សំដៅផ្ទះរបស់ខ្លួនតែម្តង ។

ពូប្រេងរត់ត្រហេបត្រហបមកទទួល :

- ស្លាប់ហើយអ្នកប្រុស! មានរឿងអ្វីហ្នឹង ?

អ្នកស្រីផៃយ៉ានិងលោកបុរាណក៏សំដែងការភ្ញាក់ផ្អើលដូចគ្នា ។
លោកបុរាណឃើញហើយក៏ស្ទុះរឹងចុះទៅជួយ :

- ស្រីក្មេងម្នាក់នេះជានរណាដែរទៅ ? នាងមានគ្រោះថ្នាក់អ្វីមែន
ទេកូន ?

បុរីមិនឆ្លើយសំនួររបស់ឪពុកនាយទេ បែរជាបន្ទន់កិរិយាទៅ
កាន់អ្នកស្រីផៃយ៉ា ហើយស្រដីថា :

- ខ្ញុំសុំផ្ញើនាងជាមួយអ្នកម៉ែងមួយភ្លែតបានទេ ។ ខ្ញុំចេញទៅហៅ ពេទ្យបន្តិចសិន ។
អរគុណបាទ!

ថាហើយ មាណពក៏បីកាយធីតាទៅដាក់នៅលើសាឡុងមួយក្នុង ផ្ទះ ហើយក៏រត់ចេញមកវិញ
ហៅពូប្រេង :

- ម៉ោះពូប្រេង! ជូនខ្ញុំទៅតាមពេទ្យជិតៗនេះបន្តិច ។

- បាទ ។

ថាហើយ ពូប្រេងក៏ហក់ឡើងឡានរបស់លោកបុរាណ បរនាំបុរី
ចេញទៅយ៉ាងប្រញិបប្រញាប់ ។

គ្រាន់តែពូប្រេងបរឡានចេញមកដល់មាត់របង ស្រាប់តែមាន
រថយន្តមួយបត់ចូលមកក្នុងរបងផ្ទះរបស់លោកបុរាណដែរ ប៉ុន្តែ
ដោយការភ័យបារម្ភចំពោះសុខទុក្ខមាណវី បុរីមិនបាននៅគួរសម ទេ ។
គេបែរជាជំរុញឲ្យពូប្រេងបរប្រួសទៅយ៉ាងប្រញិបប្រញាប់
ដើម្បីតាមរកពេទ្យអោយទាន់សភាពការណ៍ ។ លុះមកដល់ភូមិគ្រឹះ
ដ៏សង្ហាមួយមិនប៉ុន្មានរយម៉ែត្រខាងត្បូងផ្ទះរបស់លោកបុរាណ ពូ ប្រេងក៏ឈប់ឡាន ។
បុរីឃើញផ្ទះនោះហើយក៏លាន់មាត់សួរថា :

- នេះផ្ទះលោកដុកទ័រវិចិត្រនោះមែនទេ ពូប្រេង ?

CHANBOKEO.COM

- បាទ អ្នកប្រុស!

ប៊ុរីក៏ដើរតាមពីក្រោយពូប្រេងចូលទៅ ស្រាប់តែមានយុវជន ជំទង់មួយរូបអាយុប្រហែល១៤-១៥ឆ្នាំចេញមកទទួល :

- ជំរាបសួរបាទ? ពូមានការអ្វីដែរ?

- ខ្ញុំមកតាមលោកពេទ្យ អោយទៅជួយមើលអ្នកជំងឺនៅផ្ទះរបស់ខ្ញុំបន្តិច! លោកនៅផ្ទះទេហ៍? (ពូប្រេងសួរ)

- អូហ៍សូមទោស! លោកប៉ាទើបចេញទៅក្រៅមុននេះប៉ុន្មាននាទីមិនដឹងថ្មើរម៉ានត្រលប់មកវិញទេ ។

ឮដូច្នោះ ពូប្រេងបែរមុខសម្លឹងប៊ុរី ដែលកំពុងធ្វើមុខទំនងខកចិត្តព្រោះមិនបានជួបគ្រូពេទ្យដូចបំណង ។ បន្តិចមកគេក៏លាក្មេង ប្រុសនោះចេញមកវិញ អោយពូព្រេងទម្លាក់គេនៅផ្ទះវិញ នឹកថា បំរុងទៅរក្សានារីមួយរូបនោះ ហើយអោយពូប្រេងចេញទៅតាម ពេទ្យនៅត្រើយម្ខាងតែម្នាក់គាត់ ។ ថៃដន្យពេលគេចុះចេញពីឡាន ដើរចូលទៅក្នុងផ្ទះ ស្រាប់តែបាត់វត្តមានធនីមួយរូបនោះបាត់ទៅហើយ ឃើញតែលោកបុរាណនិងភរិយាអង្គុយចាំនាយដោយកិរិយា តក្កហល ។

- លោកប៉ា..! ចុះឯណានារីម្នាក់នោះ?

- គឺ សាច់ញាតិគេមកទទួលចេញអំបាញមិញនេះ ទៅហើយកូន!

- បាទ៎ លោកប៉ា? ម្ដេចក៏សាច់ញាតិនោះដឹងកើត ថាខ្ញុំនាំខ្លួននាង មកដល់ទីនេះ?

- គេមិនដឹងទេ...គឺជារឿងថៃដន្យតើហ៍! គេបានពឹងប៉ាឲ្យទៅជួយផ្សាយវិទ្យុប្រកាសរកកូនស្រីដែលបាត់ខ្លួនមិនឃើញត្រលប់ពីធ្វើការ មកផ្ទះដូចធម្មតា តែលុះចូលមកដល់ក្នុងផ្ទះ គេក៏ប្រទះនារីម្នាក់ នោះ ហើយក៏ស្គាល់ថាជាសាច់ញាតិរបស់គេ ទើបសុំខ្លួនដឹកនាង ត្រលប់ទៅវិញទៅ ។

- ចុះលោកប៉ា ម្ដេចនឹងជ្រាបទៅថាមនុស្សចម្លែកម្នាក់នោះជាសាច់ញាតិពិតប្រាកដរបស់អ្នកជំងឺ? តិចលោកប៉ាប្រគល់មនុស្សទៅឲ្យ អ្នកដែលមានបំណងមិនល្អ... នោះមិនគ្រោះទៅហើយទេហ៍ បាទ!

ឮប៊ុរីស្រដីដោយសម្ដែងកិរិយាព្រួយបារម្ភ អ្នកស្រីផៃយ៉ាក៏មានប្រសាសន៍បន្ថែមថា :

- គេនោះបានជួយដឹកនាងទៅមន្ទីរពេទ្យធំ នៅឯត្រើយម្ខាងហើយ

CHANBOKEO.COM

បើកូនចង់ទៅឃើញគេ ទីនោះមានឆ្ងាយឯណា ? អោយប្រេងគេ ជូនម៉ាក្លែតទៅណាំកូន ។

បុរីឮវាចារបស់ម្ដាយចុងភ្លាម ក៏ងើបឈរឡើងយ៉ាងរហ័សរួច លើកដៃសំពះអ្នកស្រី ហើយបបួលពូប្រេងចេញទៅរីងឥតបង្អង់ ។ អ្នកស្រីផៃយ៉ាភ្ញាក់ព្រើត បែរមើលលោកបុរាណ ក៏ឃើញលោក កំពុងភ្ញាក់ផ្អើលដូចគ្នា ដែលឃើញមាណពលើកដៃសំពះអ្នកស្រីជា លើកដំបូងក្នុងជីវិតរបស់គេតាំងពីលោកបុរាណរៀបការនឹងអ្នកស្រី ផៃយ៉ាជាង៨ឆ្នាំកន្លងមក ។

បុរីចុះពីរថយន្តរត់សំដៅទៅអាគាររក្សាអ្នកជំងឺ ស្រាប់តែប្រទះ នឹងលោកដុកទ័រមួយរូបកំពុងដើរចូលទៅដែរ :

- ជំរាបសួរលោកពូវិចិត្រ!
- អូហ៍ បុរី! ហើយក្មួយមានការអ្វីដែរទើបរត់ត្រហេបត្រហបមក ដល់ពេទ្យយើងទាំងយប់ព្រលប់ដូច្នេះ ?
- បាទ! គឺ...ខ្ញុំមកតាមរកអ្នកជំងឺ...ជាស្រីក្មេងមួយរូប...ដែលសាច់ ញាតិទើបតែដឹកចូលមន្ទីរពេទ្យមួយស្របក់មុននេះ ។
- ក្មួយស្គាល់គេដែរ ?
- បាទ! មិនស្គាល់ទេ... ប៉ុន្តែខ្ញុំជាអ្នកដែល...

បុរីធ្វើអេះអុញ មិនដឹងថាត្រូវពន្យល់យ៉ាងណាអោយសម... ថា នាយជាមនុស្សធ្វើអោយនាងខ្យល់គ ជាអ្នកសុំកង់ជិះ ឬជាអ្នកបាន ជួយសង្គ្រោះឌុបនាងទៅផ្ទះ ។ កាលបើឃើញនរៈស្រដឹតតាក់តុប ដូច្នេះ លោកគ្រូពេទ្យក៏មានប្រសាសន៍ថា :

- ពូកំពុងតែដើរទៅពិនិត្យរោគអ្នកជំងឺម្នាក់នោះដែរ ។ បុរីតាមពូ មក៍!
- បាទ!

មកដល់គ្រែអ្នកជំងឺមួយ... បុរីបានប្រទះឃើញមាណវីដែលគេ កំពុងដើររកនោះ នៅគេងស្ដូកស្ដឹងបន្ដោងសេរ៉ូម ។

- គេមានជំងឺអ្វីដែរលោកពូ ? (នរៈសួរទៅលោកគ្រូពេទ្យ)
- គឺ..ប្រពន្ធ័ខួរក្បាលរបស់នាងមិនបានទទួលអុកស៊ីសែនគ្រប់គ្រាន់ ដោយការខ្វះជាតិអាហារ ដោយធ្វើការហួសកម្លាំង ឬក៏ដោយសារ ខ្វះដំណេក

CHANBOKEO.COM

ជួនកាលមកពីស្ងួតស្លាក់ខ្យល់ដកដង្ហើមមិនគ្រប់គ្រាន់... ម្យ៉ាងទៀត
នាងមានកង្វះឈាមក្រហមទៀតផង ។

លោកដុកទ័រឆ្លើយវិញ ។ ប៊ុរីបែរសម្លឹងមុខស្លេកស្លាំងរបស់នារី ក្នុងចិត្តហាក់ដូចជានឹកព្រួយ
អាណិតដល់នាងផង សោកស្តាយផង ដែលគេបានលែងជ្រុលដៃទៅលើនារីហួសហេតុបន្តិច ។
បេះដូង គេក៏លោតកញ្ជ្រោលឡើងដោយក្តីបារម្ភចំពោះស្ថានភាពអាការរោគ របស់មាណវី ។
គេក៏បែរមកលោកដុកទ័រដែលកំពុងពិនិត្យរូបនាង ហើយស្រដីសួរបន្តថា :

- តើនាងនឹងទទួលគ្រោះថ្នាក់អ្វីធ្ងន់ធ្ងរទេ លោកពូ ?

លោកវិចិត្រឆ្លើយមកវិញថា :

- នេះសំណាងហើយដែលគេនៅក្មេងមាំទាំ! ពូសង្ឃឹមថានាងអាច
ជាសះស្បើយមកវិញធម្មតា ព្រោះនាងមកពេទ្យទាន់ពេល ។ បើ
សិនជានាងជាមនុស្សចាស់វិញនោះ ប្រហែលជាត្រូវពិការ...
- ពុទ្ធោ! (ប៊ុរីលាន់មាត់ទាំងភ្ញាក់ផ្អើល)
- ហើយចុះក្មួយស្គាល់នាងយ៉ាងម៉េចដែរ បានជាមកមើលនាងដល់ ទីនេះ ?
- គឺ...ខ្ញុំគ្រោះថ្នាក់រថយន្ត...
- ហើយក៏ជ្រួលជ្រួសកៀរនាងដួលហ្មែស ?
- បាទ! គឺស្រដៀងៗហ្នឹង...

លោកវិចិត្របែរមើលប៊ុរីមួយស្របក់ ទើបមានប្រសាសន៍ថា :

- នាងកំពុងត្រូវជាតិថ្នាំធ្វើឲ្យលង់លក់ចំនួនច្រើនម៉ោងទៀតទំរាំគេ ដឹងខ្លួនមកវិញ ។
ក្មួយទៅផ្ទះសំរាកសិនទៅ លុះព្រឹកស្អែក ចាំមក មើលគេវិញក៏បានដែរ ។
- បាទ! លោកពូ! ខ្ញុំនៅមើលនាងមួយស្របក់ទៀតចុះ!
- អញ្ចឹង ពូទៅពិនិត្យអ្នកជំងឺផ្សេងទៀតសិនហើយណា៎!
- បាទៗ! អញ្ជើញលោកពូ!

លោកដុកទ័រវិចិត្រក៏ដើរចេញទៅវិញ ។ ប៊ុរីដាក់ខ្លួនអង្គុយក្បែរ អ្នកជំងឺ
ហើយក្រឡេកមើលជុំវិញខ្លួន នឹកឆ្ងល់ក្នុងចិត្តតិចៗដែល
ធិតាដ៏សាមញ្ញមួយរូបនោះបានមកសំរាកនៅបន្ទប់ព្យាបាលពិសេស តែម្នាក់ឯង
មិនមានលាយឡំនឹងអ្នកជំងឺដទៃ ។ គេគិតក្នុងចិត្តថា:

CHANBOKEO COM

- តើជានាងជាស្រីម៉ៅឬជានរណាវិញ ? ហេតុអ្វីក៏បានទទួលការ ព្យាបាលយ៉ាងវិសេសដូច្នេះ ? ឬក៏ជំងឺរបស់នាង ជាជំងឺដែលគ្រូ ពេទ្យត្រូវព្យាបាលវិសេសជាងគេ ? ឬក៏នាង... ជាសាច់ញាតិរបស់ អភិជនណាម្នាក់ ? ហ្ស៎ស ? តិចលោនាងជាប្រពន្ធលួចលាក់របស់ គេ... ពុទ្ធោ!...ទេ មិនសមទេ បើតាមមើលទៅចរិតរបស់នាង ដែលស្លៀកពាក់រខេករខាកបែបកម្មករយ៉ាងនេះ មិនសមជាស្រី លួចលាក់របស់នរណាទេ ។ ប៉ុន្តែ... នាងធ្លាប់ជិះកង់ទៅណាមកណា រៀងរាល់ថ្ងៃតាមដងផ្លូវតែមួយគន្លង ឬក៏នាងជាកម្មកររោងចក្រ ក្រចៅនៅដួនទាវ រួចហើយមានផ្ទះនៅត្រើយខាងកើតដងស្ទឹង សង្កែ ខាងត្បូងទីក្រុង ? មើលទៅនាងមានប្រាជ្ញណាស់! សំដី ចាក់ថាវិញមិនណយទេ សមជាអ្នកដែលមានជំនឿលើខ្លួនឯងយ៉ាង មុតមាំ ហើយក៏បានរៀនសូត្រគួរសមផង ។

បុរីពិចារណាមិនអស់មិនហើយ ។ គេលួចគយគន់នារីយ៉ាងភ្លន់ភ្លឹក ។ ថ្វីបើធិតាមានទឹកមុខស្លេកស្លាំងបន្តិចមែន តែរង្វង់ភក្ត្រ័ របស់នាងនៅចោលសោភ័ណល្អត្រកាលតាមលក្ខណៈធម្មជាតិ មក ដណ្តប់អារម្មណ៍របស់នរៈអោយគិតប្លែកៗពីរូបនាង :

- នាងជាមនុស្សសាមញ្ញធម្មតាៗសោះ ហេតុអ្វីយើងចាប់អារម្មណ៍ ពីរូបនាង ហើយចង់ចាញ់ចង់ឈ្នះអ្វីជាមួយនាងម៉្លេះ ? ហេតុអ្វីបាន ជាយើងចូលចិត្តនឹកខ្លាញ់នឹងរូបនាង នៅរៀងរាល់ដងដែលយើង បានជួបមុខគ្នា ?

នរៈឈោងចាប់ម្រាមដៃធិរីអង្អែលបន្ថើរៗ ហើយស្រដីក្នុងចិត្ត ស្ងាត់ៗទៅកាន់ធិតាថា :

- សូមទោសផងណា៎ ដែលខ្ញុំបានលែងជ្រុលដៃ ធ្វើអោយនាងក្លាយ ជាឈឺរបៀបនេះ ។ ឆាប់នឹងខ្លួនវិញមក៏...កុំឲ្យខ្ញុំមានអារម្មណ៍ថា ខ្លួនកំពុងតែប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរមួយ...

បន្ទាប់មក គេក៏យកខ្នងដៃទៅស្ទាបថ្ងាសរបស់ធិរី ហើយក៏ សំរូតខ្នងដៃមកប៉ះថ្ពាល់នារីបន្ថើរៗ :

- នាងឈប់កាចដាក់ខ្ញុំទៀតទៅបានទេ ? ហើយយើងរាប់រកគ្នាជា បងជាប្អូនដូចកាលពីដើមវិញ តើនាងមានគិតយ៉ាងម៉េចដែរ ?

ថៃដន្យ ពេលនោះ នរៈយើងមានអារម្មណ៍ថា បេះដូងរបស់គេ កំពុងទទួលឥទ្ធិពលមួយយ៉ាងរំភើបចម្លែកមហិមា ។ គេសម្លឹងមុខ ធិតាមិនដាក់ភ្នែកទេ :

- ថ្វីបើរូបរបស់នាងមិនស្រស់ស្អាត មើលទៅធម្មតាៗ មិនមានតុប តែងខ្លួនហ៊ឺហាអ្វីទេ ប៉ុន្តែហេតុអ្វីក៏ខ្ញុំមានអារម្មណ៍ប្លែកៗចំពោះនាង

CHANBOKEO.COM

ទៅកើត ? ហើយចុះនាងវិញ...តើគិតយ៉ាងណាចំពោះខ្ញុំវិញដែរ ?

គេនៅអង្គុយគិតពិចារណាយ៉ាងយូរ រួចសម្លឹងមុខធិតា ស្មើរ តែមិនហ៊ានព្រិចភ្នែកទាល់តែសោះ ។ មែនហើយ! មុខហ្នឹង រាង ហ្នឹង... បានឆក់បេះដូងរបស់គេយកទៅបាត់តាំងពីគេបានជួបនាង តាំងពីលើកដំបូងនោះមកម្ល៉េះ ។ តាមផ្លូវមកផ្ទះវិញ គេក៏នៅតែ ពិចារណាមិនអស់មិនហើយដដែល...

- នេះយើងទើបតែមកដល់បាត់ដំបងពីរបីថ្ងៃ ស្រាប់តែជួបនាងពីរ បីដង... ហើយក៏មានរឿងជំពាក់គ្នារាល់ថ្ងៃដែរ តើខ្សែជីវិតរបស់ យើងទាំងពីរនៅមានអ្វីជំពាក់គ្នាទៀតទេ ទៅថ្ងៃស្អែក និងថ្ងៃបន្ត បន្ទាប់ទៀត ?

រាត្រីនោះ បុរីប្រឹងធ្មេចនិន្ទ្រាទាំងរសាប់រសល់ ។ ពេលនេះ គេ ភ្លេចនឹកនារីដែលគេស្រលាញ់ឯភ្នំពេញទៅហើយ ត្បិតគេអាល័យ តែនឹកស្តាយក្រោយចំពោះលទ្ធផលនៃចរិតលេងសើចរបស់គេ ពីរ ថ្ងៃកន្លងមក រហូតធ្វើឲ្យនារីម្នាក់ត្រូវចូលរក្សាខ្លួននៅមន្ទីរពេទ្យ ។ គេមិនអស់ចិត្តទេ ត្បិតនេះជាលើកទីមួយរបស់គេដែរ ដែលគេបាន ធ្វើផ្តេសផ្តាសទៅលើនារីភេទ ។

ព្រហាមឡើង...

- កូនទៅណាហ្នឹងទាំងព្រហាម ? មិននៅស្រស់ស្រូបបបរជាមួយ ម៉ាក់ប៉ាទេហ៎ ?

អ្នកស្រីផៃយ៉ាសួរទៅបុរីដែលកំពុងរៀបចំខ្លួនចេញទៅក្រៅ ។ - បាទ! គឺខ្ញុំគិតថានាំពូប្រេងទៅអូសឡានយកមកធ្វើ ព្រោះទុក ចោលនៅដួនទាវមួយយប់ហើយ ។

ការពិត នាយយើងភូតភរទេ ។ គេកំពុងអោយពូប្រេងទៅ អូសឡានយកមកជួសជុលមែន ប៉ុន្តែរូបគេវិញ បំរុងទៅពេទ្យធំ មើលមាណវីមួយរូបនោះតើហ៎ ។ ចៃដន្យ អ្នកស្រីផៃយ៉ានិងលោក បុរាណដែលកំពុងបរិភោគអាហារពេលព្រឹក មិនបានសួរនាំអ្វីទៀត ដែរ គ្រាន់តែលួចចោលកន្ទុយភ្នែកដាក់គ្នាហើយញញឹមតែប៉ុណ្ណោះ ត្បិតលោកដឹងចរិតរឹងរូសរបស់បុរី ។ បើគាត់និយាយអ្វីទៅទើស ចិត្ត ខ្លាចគេហក់ទៅភ្នំពេញវិញ នាំតែខានឃើញមុខនាយដូចមុនៗ រាល់ដងទៀត ។

លុះជិះរ៉ឺម៉កមកដល់មុខពេទ្យធំ បុរីក៏ចុះនៅទីនោះ ហើយពូ ព្រេងក៏ជិះរ៉ឺម៉កហួសទៅដួនទាវតែម្តង ។ បុរីដើររឹង ចូលទៅរក មាណវីឯបន្ទប់ព្យាបាលភ្លាម

CHANBOKEO.COM

ក្នុងចិត្តអន្ទះសាចង់ដឹងថា តើមាណវី នោះមានស្មារតីវិញហើយឬនៅ ។ ពេលគេទៅដល់មាត់ទ្វារ ក៏វាក់ អើនឹងវត្តមានបុរសសង្ហាមួយរូប ដែលបានមកដល់ទីនោះមុននរៈ យើងទៅទៀត ។ គេកំពុងតែនិយាយសាសងគ្នាជាមួយមាណវី ដោយទឹកមុខញញឹមទៀតផងទំនងហាក់ដូចជាស្គាល់នាងស្និទ្ធ ស្នាល ។ មើលទៅនារីនោះក៏ហាក់ដូចជាមានទឹកមុខប្រសើរជាងពី ម្សិលមិញដែរ ។ ប៉ុរីឃើញដូច្នោះក៏យកដៃគោះសន្លឹកទ្វារដែល របើកហើយឧទានឡើងភ្លាមថា :

- សាមេត ? ហេតុម៉េចមកដល់ទីនេះដែរ ?

បុរសនោះងាកផាំង បែរមើល :

- អូហ៍ អើហ៍! ប៉ុរី! នេះឯងមកដល់បាត់ដំបងពីអង្កាល់ហ្នឹង ?

គេក៏ដើបមករាក់ទាក់ ។ ពេលនោះ ប៉ុរីក៏តបវិញថា :

- គឺមកដល់ពីរបីថ្ងៃហើយ ហើយបានទៅរកឯងដល់ទៅពីរដង ថៃដន្យសំណាងមិនល្អ...ទើបមិនបានជួបឯង ។

- ហើយចុះឯងមកពីណាទៅណា បានជាមកដល់មន្ទីរពេទ្យនេះ ?

- គឺមកកាត់តាមនោះ ចូលមើលស្ថានភាពអ្នកជំងឺម្នាក់ តែដោយឃើញគេកំពុងមានសង្សារនៅចាំហើយ... គ្នាក៏គិតត្រលប់ទៅ វិញដែរ ។

មាណពស្រដីផង លួចដៀងកន្ទុយភ្នែកទៅមាណវីផង ឃើញនាងកំពុងសម្លក់នាយវិញទាំងទឹកមុខឃ្នាន់ខ្នាញ់កាលបើឮសំដីឌឺដង របស់នាយ ។ ឯភាពញញឹមលើផ្ទៃមុខរបស់ធិតាអំបាញមិញនោះ ក៏រត់បាត់អស់រលីង ។ តែសាមេតមិនបានចាប់ភ្លឹកថា អ្នកទាំងពីរ ធ្លាប់មានរឿងហេតុជាមួយគ្នា ពីមុនមកទេ ។ គេបែរជាអូសដៃប៉ុរី ទៅណែនាំអោយធិតាបានស្គាល់ទៅវិញ :

- ម៉ៅ! នេះពួកម៉ាកបងឈ្មោះប៉ុរី ទើបតែមកពីភ្នំពេញ ។ គេជាអ្នកក្រុងបាត់ដំបងនេះដូចយើងដែរ ។ ប៉ុរី! នេះអូនម៉ៅ គេធ្វើការនៅរោងចក្រក្រចៅជាមួយខ្ញុំដែរ ។

- សួស្តីអ្នកនាង! (ប៉ុរីធ្វើពើជាគួរសម)

តែម្ចាស់ខ្លួនគេនៅស្ងៀម មិនជំរាបសួរ មិននិយាយអ្វីទេ គ្រាន់តែញញឹមទំនងស្ងួតៗជាការគួរសមវិញប៉ុណ្ណោះ ។ មើលទៅនាងប្រហែលជាមិនសប្បាយចិត្តនឹងប៉ុរីហើយ ។ បន្តិចមក សាមេតក៏ លាចេញទៅវិញ :

CHANBOKEO.COM

- ម៉ៅ! បងជិតដល់ម៉ោងចូលធ្វើការហើយ ។ ថៃខ្លួនផងណា៎! ពេលណាទំនេរ បងមកលេងនឹងប្អូនទៀត ។

ម៉ៅលើកដៃសំពះ :

- ចា៎ស! អរគុណបងមេត ដែលបានចូលមកមើលខ្ញុំ!

រំពេចនោះ ស្រាប់តែប៊ុរីស្រដីថា :

- យី! សាមេត! សង្សារឈឺមួយទាំងមូល មិនសុំគេឈប់មួយថ្ងៃ ពីរនៅកំដរទេហ៎? ចេះទុកអោយគ្នា នៅត្រមង់ត្រមោចម្នាក់ឯង ដូច្នេះកើត?

ស្រាប់តែសាមេតបើកភ្នែកធំៗ លាន់មាត់ឡើង :

- ហ្ន៎ស? នរណាគេសង្សារនរណា? ឯងឆ្កួតហើយទេ? ឯងចង់ ថា នាងម៉ៅហ្នឹងប្ញែស សង្សារខ្ញុំ?

- ហើយចុះ មិនមែនទេ? (ប៊ុរីតប)

ស្រីម៉ៅអត់ទ្រាំមិនបានក៏តបឡើងថា :

- បងសាមេតបណ្ដូលចិត្តម៉ៅអើយ! មិនបាច់ប្រកែកទេ បើគេដឹង រឿងយើងយ៉ាងនេះទៅហើយ ទទួលការពិតទៅណា៎បង!

លើកនេះ សាមេតរិតតែភ្ញាក់ផ្អើលណាស់ទៅទៀត ។ គេយក ដៃទៅស្ទាបថ្ងាសធិតាយើងហើយស្រដីថា :

- នេះមិនមែនក្ដៅខ្លួនឡើងរវើរវាយឯណា ម៉េចបានជាម៉ៅនិយាយ អ្វីចំឡែកម្ល៉េះ? ឬក៏លោកគ្រូពេទ្យចាក់ថ្នាំខុស បានជាមានប្រតិកម្ម ប្លែកៗយ៉ាងនេះ ហ្ន៎សម៉ៅ?

ម៉ៅញញឹមឡើង ហើយចាប់ដៃសាមេត ស្រដីថែមថា :

- បើបងមេតទៅវិញ ម៉ៅច្បាស់ជានឹកបងបែកទ្រូងស្លាប់មិនខាន ទេ? មានគេអោយយោបល់ល្អយ៉ាងនេះទៅហើយ បងសុំឈប់ មួយថ្ងៃកំដរអូនម៉ៅក៏ល្អម្យ៉ាងដែរណា៎បង!

ម្ដងនេះ សាមេតដូចជាចាប់ភ្លឹកថា ច្បាស់ជាមានអ្វីខុសប្រក្រតី ហើយ ដែលអ្នកទាំងពីរខឹងឆ្លើយឆ្លងគ្នាទៅមកយ៉ាងចម្លែកបែប នេះ ។ គេក៏បែរមើលទៅប៊ុរី ហើយស្រដីទៅស្រីម៉ៅវិញទាំងលួច ញញឹមក្រឡួចមាត់ផង ថា :

- អូហ៍ បងក៏នឹកម៉ៅធំធេង ដូចតែគ្នាហ្នឹង តែបងត្រូវបំពេញមុខ នាទីការងារ! ដូច្នេះ បងគិតថានឹងសុំផ្ញើទុកអោយប៊ុរីនៅកំដរអូន វិញចុះ យ៉ាងម៉េចដែរ?

ស្រាប់តែបុរីនិងម៉ៅភ្ញាក់ក្រញាង កាលបើឮសាមេតនិយាយ ដូច្នោះ ។ បុរីញញឹមឡើង ទំនងហាក់ពេញចិត្តនឹងសំណូមពរនេះ :

- សង្សាររបស់សាមេតឯងសំដីភ្លៀវក្លាយ៉ាងនេះ ច្បាស់ជាជិតជា វិញហើយ មិនត្រូវការអោយនរណាកំនរទេមើលទៅ (បុរីពោល)

តែនាងម៉ៅមិនស្រដីតបនាយទេ បែរជាស្រដីទៅកាន់សាមេត វិញថា :

- ស្តាយណាស់ដែលម៉ៅចូលចិត្តឲ្យតែបងមេតម្នាក់ នៅកំនរម៉ៅ! ចំពោះអ្នកដទៃវិញ មិនបាច់ក៏បានដែរ ម៉ៅសុខចិត្តនៅម្នាក់ឯងចុះ ព្រោះខ្លាចទ្រាំមិនបាន!

- ខ្លាចអីទៅ ម៉ៅ ? (សាមេតសួរដោយលួចដៀងភ្នែកមើលបុរី)

- គឺខ្លាច... ស្អុយក្លៀក!

បុរីបើកភ្នែកម្ងូលក្លំ ។ សាមេតអត់មិនបានក៏សើចកខឹកឡើង :

- ម៉ៅចង់ថា បងយ៉ាប់ដល់ម្លឹងផងហ្ន៎ស ?

- អត់ទេ! ការពិតគឺ...ខ្លាចក្លិនក្លៀកក្របីឃ្លៀចនៅម្តុំៗនេះណា៎បង ចុះត្រាំភក់ហើយភ្លេចងុះសាប៊ូ..!

សាមេតអត់មិនបានក៏សើចកខឹកលើសដើម រួចលាចេញទៅ :

- ម៉ៅ! បងទៅហើយ! សំដីប៉ាច់យ៉ាងនេះ ច្បាស់ជាមេរោគរត់ ចោលអស់ថ្ងៃនេះមិនខានឡើយ ។ ចាំល្ងាច បើទំនេរ បងមកលេង ម៉ៅទៀត ។

សាមេតដើរចេញទៅ ថែមទាំងលួចមិចភ្នែកដាក់បុរីផង ទំនង ហាក់ដូចជាកំពុងប្រាប់នរៈថាគេយល់ស្ថានការណ៍រវាងអ្នកទាំងពីរ ។ លុះសាមេតដើរចេញផុតទៅ បុរីដាក់ខ្លួនជិតមាណវីហើយញញឹម ដាក់ធិតាយើងឡើង :

- បានគ្រាន់បើហើយហ្ន៎ស ទើបស្រដីប៉ប៉ោចអត់បាត់យ៉ាងនេះ ?

តែម៉ៅមិនឆ្លើយវិញទេ ។ នាងបែរជាធ្មេចបិទភ្នែកធ្វើមិនដឹង មិនឮ ។ ឃើញកិរិយារបស់នាងដូច្នោះ បុរីក៏កាត់យល់បានថា នាង កំពុងខឹងនឹងរូបគេនៅឡើយ ។ ថៃដន្យថ្ងៃនេះ គេបានតាំងចិត្តរួច ហើយថា គេនឹងមិនធ្វើអ្វីអោយល្អក់អារម្មណ៍នាងទេ ព្រោះចង់លាងកំហុសដែលគេបានធ្វើជ្រុលទៅលើនាងកាលពីម្សិលមិញ ។ ការ ពិត បុរីជាមនុស្សចូលចិត្តកំប្លែងលេងសើច ជាមួយមិត្តភក្តិណាស់ គឺជាទំលាប់ធម្មតារបស់គេតាំងពីដើមមកយូរហើយ ថ្វីបើមាណពជា មនុស្សរឹងរូសបន្តិចមែន ។ កាលបើឃើញនាងធ្មេចភ្នែក មិនព្រម និយាយរកខ្លួន បុរីក៏ស្រដីបន្តទៀតថា :

CHANBOKEO.COM

- ខ្ញុំសូមទោសណាំម៉ៅ ដែលខ្ញុំបានប្រព្រឹត្តជ្រុលជ្រួសលើនាងទាំង អំបាលម៉ាន
ពីរបីថ្ងៃកន្លងមកនេះ !

មាណវីនៅតែសំងំធ្មេចឈឹងធ្វើមិនឮដដែល ។ បុរីក៏ស្រដីបន្ត ទៀតថា :

- នេះ ថ្វីបើយើងធ្វើមិត្តនឹងគ្នាមិនបាន ក៏គួរតែកុំធ្វើសត្រូវនឹងគ្នា ធ្វើអ្វី នាំតែល្អក់ចិត្ត
ល្អក់អារម្មណ៍ទទេៗធ្វើអ្វី! ការពិត ខ្ញុំបារម្ភពី នាងណាស់ នាងដឹងទេ ?...

លុះមិនឮនារីយើងឆ្លើយថាម៉េច បុរីក៏នៅស្ងៀម មិនដឹងជាចង់ និយាយពីអ្វីទៀត ។
គេនៅសំកុកសម្លឹងមុខមាណវីយ៉ាងយូរ... រីឯ នាងម៉ៅវិញនៅតែធ្មេចភ្នែកសំងំស្ងៀមរហូតដែរ
មិនឃើញសួរអ្វី និយាយអ្វីជាមួយបុរីវិញទេ ។ ពេលនោះបុរីមានអារម្មណ៍ថាមាណវី
កំពុងបិទទ្វារដួងចិត្ត មិនព្រមទទួលមិត្តភាពពីរូបនាយឡើយ ។ ថៃដន្យ
បុរីជាមនុស្សដែលរឹងមានះបំផុត ហាមត្រង់ណា ដើរចូល ត្រង់ហ្នឹង ។
កាលបើម៉ៅមិនព្រមទទួលរាប់រករូបគេ មាណពនឹក ភ្នកចង់ជំនះស្ថានការណ៍ទៀតហើយ ។
គេយកដៃរបស់គេស្រវា ចាប់ដៃរបស់ធិតាយើងហើយច្រៀងថ្នមៗដាក់នាង ថា :

- ខឹងបងរឿងអ្វីសង្សារបងអើយ ម្ដេចអូនកន្ដើយមិនព្រមចេញស្ដី
ឲ្យបងបានធូរស្បើយក្នុងហឫទ័យ ឆ្លើយមកពិសីកុំនៅអឹមអៀន...

ស្រាប់តែធិតារលាស់ដៃចេញ ហើយបើកភ្នែកឡើង ឧទានកាត់ សំដីបុរីភ្លាមថា :

- នែ៎! ចង់ថា នរណាគេសង្សារអ្នក ?

ឃើញនាងបើកភ្នែកនិយាយរក បុរីអរភើត សប្បាយចិត្តភ្លាម រួចក៏ឆ្លើយរឹងឡើងថា :

- អូហ៍ ? ហើយ... នរណាគេទៅ លើកខ្លួនជាសង្សារបងហ្នឹង ? បងចង់ស្គាល់ដល់ហើយហ្ន៎...!
- និយាយតែផ្ដាស! យីអើ! អ្នកសម្ដែងល្ខោនមួយណា មុខក្រាស់ ដូចស្បែកក្របី
ច្រៀងយីកេឆ្នើលយក្សព្រៃ លាន់សូរដូចផ្គរខែ ប្រាំង
សូមមេត្តាវើឆាកទៅលេងនៅខាងក្រៅមន្ទីរពេទ្យបានទេ ? ពេលនេះ អ្នកជំងឺចង់សុំទី!
- ស្លាប់ហើយ! អ្នកជំងឺអីនិយាយប៉ប៉ាច់ដូចឈើពុត! គិតទៅតាម ហៅដុកទ័រអោយពិនិត្យសិន ។
- អញ្ចឹង កុំភ្លេចអោយគេពិនិត្យតួយីកេអំបាញ់មិញផង មើលទៅ
គេប្រហែលត្រូវការមន្ទីរព្យាបាលសតិរបស់គេហើយ ។

បុរីលួចញញឹម កាលបើដឹងថាធិតាចាញ់កលលេងរបស់នាយ

CHANBOKEO.COM

រហូតដល់នាងរបូតមាត់និយាយតបរូបគេវិញដោយមិនដឹងខ្លួន ។ ភ្លាមនោះ ស្រាប់តែមានកុមារីជំទង់ម្នាក់ អាយុប្រហែល១៣ឆ្នាំ ជិះកង់មកដល់ ដោយមានយួរចានស្រោក់ដាក់ម្ហូបមកផ្ញើម៉ៅផង ។

- បងម៉ៅ! ម៉ាក់អោយយកបបរនិងសាច់ចៀនមកផ្ញើ ។ ថ្ងៃនេះ គាត់ជាប់រវល់ការងារ ប្រហែលថ្ងៃត្រង់ គាត់នឹងអោយប៉ាឆៀងនាំ គាត់មកមើលបងទីនេះហើយ ។

នាងតូចក៏យកស្រោក់មកដាក់លើតុក្បែរគ្រែរបស់ម៉ៅ ហើយក៏បែរមើលទៅបុរីធ្វើភាំងព្រោះមិនដែលស្គាល់គ្នា ។ បុរីសួរនាងថា :

- នាងតូចជាប្អូនស្រីរបស់ម៉ៅមែនទេ ?

នាងតូចញញឹមរួចបែរមើលទៅនាងម៉ៅទំនងចង់ អោយឆ្លើយជំនួស ប៉ុន្តែម៉ៅធ្វើមិនដឹងហើយនិយាយទៅនាងតូចថា:

- ម៉ី! បងមានកម្លាំងវិញហើយ ប្រាប់ម៉ាក់ផងថាកុំបារម្ភអី! បន្តិចទៀត បងចេញទៅផ្ទះបានហើយណា៎ ។
- តែបងនៅមានមុខមាត់ស្លេកស្លាំងណាស់! (នាងតូចឆ្លើយ)
- បងជាមនុស្សមុខស្លេកតាំងពីដើមទៅហើយ... បងមិនមានឈឺ អ្វីធ្ងន់ទេអូន ។
- អញ្ចឹង ខ្ញុំទៅរៀនសិនហើយ ។ ជំរាបលាបង!

ថាហើយនាងតូចក៏ចេញទៅ ។ នៅពេញមួយព្រឹកនោះ បុរី បាននៅកំដរមាណវីរហូត ថ្វីបើនាងមិននិយាយរកគេវិញក៏ដោយ ។ គេមិនបានធ្វើអ្វីអោយរំខានចិត្តនាងដូចសព្វដងទេ ពិតមែនតែគេ នៅនិយាយលលេងនាងខ្លះៗក៏ដោយ គឺនរៈហាក់ដូចជាបន្ទូរកិរិយា ដាក់នាងរហូតលែងមានចិត្តចង់ឈ្នះចាញ់ដូចមុនហើយ...

oooooooooooooooooo

oooooo

CHANBOKEO.COM

# វគ្គទី៣
# អំពាល់

ប៊ុរីដើរត្រេះត្រុះទៅមកៗនៅក្នុងផ្ទះ ក្នុងចិត្តហាក់ដូចជាអផ្សុក ធុញថប់តប់ប្រមល់យ៉ាងណាមិនដឹង ។ រីឯលោកបុរាណានិងភរិយា ចេញទៅធ្វើការបាត់តាំងពីព្រឹក ។ ឯពូប្រេងនៅជាប់យកឡានរបស់ ប៊ុរីទៅធ្វើមិនទាន់ត្រលប់មកវិញនៅឡើយ ។ រំពេចនោះ ស្រាប់ តែមានរថយន្តថ្មីស្រឡាងមួយបរមកដល់មុខផ្ទះរបស់នរៈយើង ។

ទីន ! ទីន !

ប៊ុរីអើតមើលទៅ ក៏អរភើតស្រាយទឹកមុខភ្លាមមួយរំពេច រួច ហើយស្ទុះរត់ចុះដីយ៉ាងលឿនទៅទទួល :

- សួស្តី រ៉ាវុធ! យី! មកលេងដល់បាត់ដំបង មិនព្រមឲ្យដំណឹង គ្នាមុនសោះតែម្តងហើយនេះ៎ ! !

បុរសសង្ហាឈ្មោះរ៉ាវុធបើកទ្វាររថយន្តចេញមកហើយវាចាថា :

- ប៊ុរីមើលនែ៎... មាននរណាគេមកដែរនែ៎ក!

នារីពីររូបក្នុងសម្លៀកស៊ីវិល័យបែបទីក្រុង ចុះចេញពីរថយន្ត មក ហើយញញឹមយ៉ាងបំព្រងដាក់ប៊ុរី ។

- ពុទ្ធោអើយ ! សម្ផស្ស ! គិមណាង !

ប៊ុរីឧទានឡើងកាលបើប្រទះវត្តមានរបស់នារីរូបស្រស់ទាំងពីរ នាក់នោះភ្លាម ។ គិមណាងញូហើយ ក៏ឆ្លើយរីងថា :

- មានគេនឹកបងប៊ុរី រហូតរំអុកអោយបងរ៉ាវុធនិងខ្ញុំនាំគេមកដល់ទី នេះប្រញាប់ៗ ទើបមិនបានជំរាបបងមុននោះអី..! នេះ យើងជិះ យន្តហោះមកព្រឹកមិញភ្លាមក្តៅៗណា៎ អោយទាន់ចិត្តអ្នកដែលគេ នឹកបង!

ប៊ុរីញូដូច្នោះក៏ញញឹមអោយគ្រហាញតែម្តង :

CHANBOKEO . COM

- សម្ផស្សពិតជានឹកបងដល់ម្ល៉ឹងមែនហ្ន៎ស ? នេះយើងទើបតែ បែកគ្នាបីថ្ងៃទេតើហ៎...!

ស្រាប់តែសម្ផស្សងងឹកឡើង :

- នរណាគេទៅនឹកបងប៊ុរីនោះ ? គេចង់មកលេងបាត់ដំបងតើហ៎!

ប៊ុរីសើចខឹកៗរលាក់យ៉ាងស្រួល ។ ពេលនេះ អារម្មណ៍ស្មុគ្រ ស្មាញរបស់គេក៏រសាយបាត់ពីខ្លួនភ្លាម ។ ភ្លាមនោះ រ៉ាវុធក៏បបួល ប៊ុរីឡើងថា :

- តោះទៅដើរលេងអោយរហើយកាយបន្តិច ។ គ្នាត្រូវសម្ផស្សនិង គិមលីដុកដាន់ឡើងណែនទ្រូងហើយ ទៅរកកន្លែងបន្ធូរអារម្មណ៍ លំហែដួងចិត្តសិនបានទេ ?

អ្នកទាំងបួនក៏នាំគ្នាឡើងឡានបរសំដៅទៅភ្នំសំពៅភ្លាម ។ ថ្ងៃ នេះ ប៊ុរីសប្បាយចិត្តប្លែកណាស់ ព្រោះពីរបីថ្ងៃកន្លងមក គេធុញ ថប់កន្ទះរាក្នុងចិត្តយ៉ាងណាមិនដឹង ។ ការពិត រ៉ាវុធ គិមណាង និង ប៊ុរីស្គាល់គ្នាយូរឆ្នាំហើយ ។ គិមណាងជាគូកំណាន់របស់រ៉ាវុធពីរឆ្នាំ មកហើយ ។ គេមានគំរោងថានឹងរៀបការឆ្នាំនេះឯង ។ រ៉ាវុធក៏ជា អ្នកស្រុកបាត់ដំបងដូចប៊ុរីដែរ ចំណែកគិមណាងនិងសម្ផស្សជា អ្នកក្រុងភ្នំពេញចំតួ ។ ហើយសម្ផស្សនេះឯងក៏ជានារីកំពូលដួងចិត្ត របស់ប៊ុរី ដែលគេមករំអុកអោយលោកបុរាណចូលស្តីដណ្តឹង ។ គេ ទើបបានស្គាល់នាងប្រហែលជាងមួយខែនេះទេ កាលពីនៅជប៉ុន មុនពេលដែលនាងត្រលប់មកស្រុកខ្មែរវិញ ។ ថ្មីៗនេះ សម្ផស្ស បានចូលធ្វើការនៅក្រសួងពាណិជ្ជកម្មក្រុងភ្នំពេញ ។ ធិតាគឺជាបុត្រី អភិជនដ៏ស្តុកស្តម្ភមួយរូប មិនដែលស្គាល់អ្វីថាក្រ ថាខ្វះឡើយ ។ បន្ថែមពីលើនោះ នាងមានសោភណ៍សោភាមិនខុសពីឈ្មោះរបស់ នាងទេ គ្រាន់តែឆវីវាយឫករើសអើងឆ្មើងឆ្មៃបន្តិច ។ ចំពោះបុរស ដែលមិនមានរូបសម្បត្តិនិងទ្រព្យសម្បត្តិ កុំសង្ឃឹមថានឹងអាចដើរ ក្បែរនាងបានឲ្យសោះ ។ ពេលនេះ ឆវីសោភាឃានមកដល់ក្រុង បាត់ដំបងជាលើកដំបូង សង្ស័យតែនាងតាមមកស៊ើបដើងការរឿង ក្រុមគ្រួសារប៊ុរីហើយ ។ ថ្វីបើប៊ុរីមានរូបសម្បត្តិគួរសរសើរមានវិជ្ជា ចំណេះខ្ពង់ខ្ពស់ក៏ដោយ ប៉ុន្តែនាយនៅមានពិន្ទុចាញ់បុរសជាច្រើនឯង ភ្នំពេញ ។ ចៃដន្យ សម្ផស្សបែរជាចូលចិត្តប៊ុរីជាងគេ ព្រោះគេប៉ិន កំប្លុកកំប្លែង ខឹងច្រើនបន្តិចតែក៏ឆាប់រសាយ ហើយប៉ិនយកចិត្ត សម្ផស្សជាងគេបំផុតផង ។

CHANBOKEO.COM

ថ្ងៃនោះ គេនាំគ្នាឡើងដល់វត្តនៅលើកំពូលភ្នំសំពៅ រួចហើយ ក៏ចុះទៅតាមដណ្តើរខាងក្រោយភ្នំ ទៅលេងភូមិអ្នកស្រុកនៅឯជើង ភ្នំម្ខាងទៀត ។ កាលជំនាន់នោះ ស្រុកទេសកំពុងមានសង្គ្រាមរវាង សាធារណរដ្ឋខ្មែរ និងពួកខ្មែរក្រហម ។ លុះគេនាំគ្នាចុះទៅដល់ ជើងភ្នំភ្លាម ស្រាប់តែមានអ្នកស្រុករត់ត្រហេបត្រហបនាំដំណឹងមក ប្រាប់ថា មានខ្មែរក្រហមចូលកៀរអ្នកស្រុកចូលព្រៃទាំងថ្ងៃ ។ អ្នកទាំងបួនក៏ប្រញិបប្រញាប់រត់គេចខ្លួនទាំងភ្នែកនៅកញ្ជ្រឹងក ហក់បក ត្រលប់មកក្រោយវិញ យ៉ាងតក្កហល ។ នៅក្នុងរថយន្ត តាមផ្លូវ សម្ផស្សរអ៊ូរង៉ូវថា :

- ហ៊ឺ! ខ្ញុំស្មានថាបាត់ដំបងសប្បាយ! នឹងអីជាជំរកកណ្តុរលេងពួន ដាក់គ្នាយ៉ាងដូច្នេះសោះ..! សម្ផស្សលែងសប្បាយចិត្តអស់រលីងតែម្តង ។

យើញឆវីស្រដីទាំងជ្រួញចិញ្ចើម ប៊ុរីស្រដីលួងលោមនាងថា :

- ស្រុកភូមិមិនស្រួល... សម្ផស្សនឹងហើយតើហ៎! ស្ថានការណ៍ស្រុកទេសអាចផ្លាស់ប្តូរគ្រប់នាទី ។ យើងជាពលរដ្ឋក៏ត្រូវប្រយត្ន័ គ្រប់មុខនាទីដែរ ។

- តែសម្ផស្សមិនចូលចិត្តសង្គ្រាមអោយយើងរត់លូនទេ ។ មាន លុយប្រហែលសម្ផស្សនេះ ចង់គេចទៅនៅប្រទេសណាក៏បានដែរ កុំអោយតែត្រូវភ្លើងសង្គ្រាមយាយី ។

- តែនេះជាស្រុកកំណើតយើងណាអូន! នឹងរត់គេចទៅណាទៀត កើត ? ហើយទោះបីជាយើងអាចគេចខ្លួនបានមែន តែយើងគេច ឫសគល់ដើមកំណើតរបស់ខ្លួនបានឡើយ ។ (ប៊ុរីឆ្លើយ)

- តែអូនគិតថា ឫសគល់វាមិនសំខាន់ទេ អោយតែខ្លួនសុខទៅ កុំទៅរវល់រឿងជាតិកំណើតអ្វីនោះ អោយតែមានលុយ មានជីវិតរស់ សុខសប្បាយទៅ វាចប់បាត់ទៅហើយ!!

ពួវាចារបស់សម្ផស្សដូច្នោះ ប៊ុរីបាក់ទឹកចិត្តគ្រហែតតែម្តង ។ ភ្លាមនោះ គេគិតក្នុងចិត្តថា :

- សម្ផស្សអើយ! ធ្វើជាបញ្ញើក្អែកទុំមែកជាតិសាសន៍គេ តើមាន កត្តិយសអ្វីដែរទៅ ? ម្តេចបានជានាងមិនស្រលាញ់ទឹកដីរបស់ខ្លួន ឯងដូច្នេះ ? តើជាតិសាសន៍ដទៃគេនឹងសើចយំពលរដ្ឋយើងយ៉ាង ណា បើសិនគេបានឮពាក្យសំដីរបស់អូនពេលនេះ ? ដោយសារតែ ទឹស្តីនេះទេនឹង ទើបខ្មែរខ្លះចេះតែនាំគ្នាចាកចេញពីស្រុក មិននៅ ការពារប្រទេសកំណើតរបស់ខ្លួន រួចហើយ

CHANBOKEO.COM

ទុកអោយបរទេសជិត ខាងគេឈ្លានពានទឹកដីយើងស្រេចតែចិត្តយ៉ាងនេះ ? តើជាតិគេនឹងទុកចិត្តយើង ស្រលាញ់យើង ជួយយើងយ៉ាងម៉េច បានបើយើងមិនស្រលាញ់សូម្បីតែជាតិកំណើតរបស់ខ្លួនយើងផង ?

ប៉ុន្តែ បុរីបានត្រឹមតែគិតក្នុងចិត្ត មិនហ៊ានស្រដីចេញមកទេ ព្រោះឃើញសម្ផស្សមានអារម្មណ៍មិនល្អ ទោះបីជានិយាយ ក៏នាង ស្តាប់មិនបានដដែលហ្នឹង ។ ពេលនោះ អ្នកទាំងប្អូនលែងមាន អារម្មណ៍ល្អអស់ហើយ ត្បិតអាល័យតែនឹកភ័យក្រោយ ។ លុះគេបរ រថយន្តមកដល់ភូមិដំណាក់ហ្លួង ជិតបន្ទាយទាហានជើងក្របាម ស្រាប់តែគេឮសូរគ្រាប់ឆ្លោងផ្ទុះលាន់ក្នុងក្លាំងឡើងយ៉ាងសាហាវ ។ មនុស្សម្នាក៏កើតចលាចលរត់ប្រសាច រកទីកន្លែងជ្រករៀងៗខ្លួន ។ រំពេចនោះ មានគ្រាប់មួយធ្លាក់ផ្ទុះក្លាំង មិនឆ្ងាយពីរថយន្តរបស់ រ៉ាវុធប៉ុន្មានទេ ធ្វើអោយកញ្ចក់ឡានរបស់រ៉ាវុធបែកប្រាវខ្ទាយព្រោង ឡើងមួយរំពេច ។

- អូ៎យ !

គិមណាងស្រែកឡើង យកដៃខ្ទប់ស្មាដែលកំពុងបាញ់ឈាម តែ រ៉ាវុធមិនបានឈប់ឡានទេ ។ គេបែរជាប្រឹងបន្ថែមល្បឿនថែមទៅ វិញ នឹកថាចង់បរគេចសំដៅចូលក្រុង តែក៏មិនអាចរត់ទៅណាបាន ត្បិតមានមនុស្សរត់ប្រសេចប្រសាចពេញផ្លូវ ។ គ្រាប់ឆ្លោងកាន់តែធ្លាក់ញាប់ឡើងៗដូចគ្រាប់ភ្លៀង ។ ទីបំផុត រ៉ាវុធក៏ត្រូវចតឡានទុក ចោល ហើយរត់ចុះថ្មើរជើងម្តង ។ មាណពទាំងពីរក៏ជួយគ្រាហ៍ គិមណាងម្នាក់ម្ខាង ។ ចំណែកសម្ផស្សវិញរត់យករួចតែខ្លួន ហើយ រអ៊ូរង៉ូវមិនឈប់ឈរដែលនាងត្រូវមករត់គេចគ្រាប់ផ្ទុះថ្ងៃនេះ ។

ប្រហែលមួយម៉ោងក្រោយមក... គ្រាប់កាំភ្លើងក៏ស្ងាត់ទៅវិញ ។ រ៉ាវុធនិងបុរីជួយគ្រាហ៍គិមណាងចេញមកពីក្នុងក្រឡុកទឹកស្រះរបស់អ្នកស្រុកប្រឡាក់ភក់ស្រមក ។ មើលទៅគិមណាងក៏ហាក់ដូចជា ល្ហិតល្ហៃណាស់ដែរ ត្បិតនាងមានឈាមហូរច្រើនពេក ។ ភ្លាមនោះ នរៈទាំងពីររូបក៏បែររកមើលសម្ផស្ស ស្រាប់តែបាត់ស្រមោលនាង សូន្យ មិនឃើញនៅម្តុំក្បែរៗនោះទេ ។

- គេទៅណាអញ្ចេះ ? (បុរីលាន់មាត់)

ដោយក្តីបារម្ភចំពោះសម្ផស្ស បុរីមិនព្រមឡើងរថយន្តត្រលប់ ទៅក្រុងវិញទេ :

CHANBOKEO.COM

- រ៉ាវុធប្រញាប់នាំគិមណាងទៅពេទ្យភ្លាមទៅ កុំបង្អង់យូរ! ទុក
អោយខ្ញុំតាមរកសម្ផស្សម្តុំៗនេះចុះ រួចចាំខ្ញុំចេញទៅតាមក្រោយ ។
រ៉ាវុធក៏បញ្ឆេះឡាននាំគិមណាងចេញទៅ ។ ប៊ុរីក៏ប្រញាប់រត់ សាកសួរអ្នកស្រុកផង
ដើរវៃករកមើលក្នុងចំណោមអ្នករបួសទាំង ឡាយនោះផង កូកផងហៅផង រកតែសម្ផស្សម្នាក់
ប៉ុន្តែ ច្រើន ម៉ោងកន្លងទៅហើយ គេនៅតែមិនបានជួបនាងដដែល ។ ពេល នេះ
ប៊ុរីអស់កម្លាំងចិត្តរលីងពីខ្លួន :
- សម្ផស្ស! តើនាងសុខទុក្ខយ៉ាងណា ? ម្តេចបានជាខ្ញុំបណ្តោយឲ្យ
នាងវង្វេងពីក្រុមពួកយើងកើត ? ពេលនេះ នាងនៅឯណា ? ដឹង
ទេថាខ្ញុំកំពុងបារម្ភពីរូបនាងណាស់...!
ថ្ងៃលិចទៅហើយ...
ប៊ុរីនៅតែរកសម្ផស្សមិនឃើញ ។ គេក៏ធ្វើដំណើរចូលក្រុងបាត់
ដំបងវិញទាំងស្រកស្រុតកម្លាំងចិត្ត ។ គ្រាន់តែរ៉ឺម៉កដាក់គេចុះនៅ មុខផ្ទះរបស់លោកប៊ុរាណភ្លាម
ស្រាប់តែប៊ុរីឮសម្លេងមនុស្សស្រី សើចរអឹកចេញពីក្នុងផ្ទះរបស់នាយមក ។ គេនឹកពិភាល់ណាស់
ក៏ លាន់មាត់ឡើងថា :
- សម្ផស្ស ?
មែនហើយ! ប៊ុរីចំណាំបានថា នោះជាសៀងសំណើចរបស់និតា យើងច្បាស់ណាស់ ។
គេស្ទុះត្រុយទៅយ៉ាងលឿនតែម្តង ស្រាប់តែ ប្រទះនឹងសម្ផស្សនៅអង្គុយសើចកខឹក
ជាមួយឪពុកម្តាយរបស់នរៈ រៀបរាប់អំពីស្ថានការណ៍កាលពីព្រឹកមិញ ។ ប៊ុរីក៏ភ្ញាក់ក្រញាង រួច
ឧទានថា :
- សម្ផស្ស ? ម្តេចគេចមកដល់ទីនេះរហ័សម្ល៉េះ ?
- គឺ... ខ្ញុំបានពឹងអ្នកស្រុកជួយឌុបវេស្ប៉ាត្រលប់មកវិញនោះអី!
- ហ៊ឺ! ម៉េចក៏រត់មិនប្រាប់គ្នាអញ្ចឹង ? ខ្ញុំឯណោះ ភ័យលោះព្រលឹង ពេញមួយថ្ងៃហើយ
តាមរកសម្ផស្សពេញវាលម្តុំបន្ទាយជើងក្រហម
ហើយម៉េចក៏មកអង្គុយសើចយ៉ាងស្រួលដូច្នេះកើត ?
- អញ្ចឹង ឈប់ភ័យទៅ... ខ្ញុំសុខសប្បាយហើយតើហ៎! ម្យ៉ាងមក
ពីខ្ញុំឮបងរ៉ាវុធប្រាប់ថាបងសុខសប្បាយ ទើបមិនបានតាមទៅរក ។

CHIANBOKEO.COM

ប៊ុរីមិនអស់ចិត្តទេ ដែលនាងរត់យកតែព្រះអាយ៉ុសមិនគិតគ្នី គ្នាអ្វីសោះ ។ ប៉ុន្តែ ទោះជាយ៉ាងណា គេក៏មិនអាចបន្ទោសនាងបាន ដែរ ហោចណាស់ នាងឆ្លាតវៀងវៃហើយរហ័សរហួន ល្មមអាចរក មធ្យោបាយជួយខ្លួននាងឲ្យរួចគ្រោះថ្នាក់បាន ។ ចៃដន្យ ចំពោះប៊ុរី ដែលខំដាក់ចិត្តបារម្ភពីសុខទុក្ខរបស់សម្ផស្សយ៉ាងពុះពារ កាលបើ ឃើញនាងសើចរលាក់យ៉ាងស្រួលនៅឯផ្ទះ ដោយគ្មានបារម្ភអំពី សុវត្ថិភាពរបស់នាយវិញអ្វីបន្តិចសោះនោះ គេហាក់ដូចជាបាក់ទឹក ចិត្តស្រឡេត មិនមានអារម្មណ៍អ្វីល្អចំពោះនាងតែម្ដង ។ ផ្ទុយទៅ វិញគេបែរជាស្រកស្រុតកម្លាំងចិត្តអស់រលីង លើសពេលដែលគេ កំពុងដើររកនាងនៅម្ដុំបន្ទាយដើងក្រហមនោះឆ្ងាយណាស់ ។

បន្តិចមក ប៊ុរីដើរឈ្ងោកគេចខ្លួនចូលបន្ទប់ ទុកអោយសម្ផស្ស នៅជជែកលេងសំណេះសំណាលជាមួយលោកបុរាណ និងអ្នកស្រី ផៃយ៉ា ណែនាំខ្លួននាងអោយលោកទាំងពីរបានស្គាល់ ។ មាណពក៏ លូនប្រាសខ្លួនយកដៃគងថ្ងាសសន្ធឹងសន្ធៃលើគ្រែគិតតែម្នាក់ឯង ។ គេហាក់ដូចជាតប់ប្រមល់ក្នុងចិត្តសាជាថ្មីទៀតហើយ ។ ហេតុអ្វីទៅ ហ្ន៎ ? កាលមុននេះ គេបារម្ភពីសម្ផស្ស ហើយដើររកនាងសឹងស្លាប់ តែលុះមកជួបឃើញមាណវីសុខសប្បាយ ស្រាប់តែគេបែរជាអស់ កម្លាំងចិត្តទៅវិញ ?

មិនដឹងជាគិតចាក់ស្មុគ្រអស់យូរប៉ុនណាទេ ទំរាំគេដើបឡើង ងូតទឹកជំរះកាយ រៀបចំខ្លួនចេញមកជួបសម្ផស្សនៅបន្ទប់ទទួល ភ្ញៀវ ស្រាប់តែអ្នកស្រីផៃយ៉ាប្រាប់ថា នាងត្រឡប់ទៅស្នាក់នៅផ្ទះ លោកចៅហ្វាយស្រុកបាត់ទៅហើយ ព្រោះរង់ចាំជួបប៊ុរីយូរពេក ។ នាយយើងក៏មិនមាត់អ្វីដែរ កាលបើឮអ្នកស្រីផៃយ៉ាប្រាប់ ។ គេក៏ វិលចូលបន្ទប់វិញទៅ ។ មួយសន្ទុះធំក្រោយមក ស្រាប់តែនរៈនឹក ភ្ញុកទៅដល់ស្រីម៉ៅឯមន្ទីរពេទ្យភ្លាម ។ មែនហើយ! គេភ្លេចឲ្យ ឈឹងស្ងូន្យពីនារីម្នាក់នោះតែម្ដង ។ រំពេចនោះ គេក៏ហាក់ចុះពីលើ ផ្ទះរូ រត់ទៅសួរពូប្រេង :

- ឡានខ្ញុំធ្វើហើយឬនៅពូ ?
- បាទ នៅទេ! ប្រហែលពីរបីថ្ងៃទៀតទើបហើយ ។
- អញ្ចឹង សុំខ្ចីកង់ពូបន្តិចម៉ែក!
- អូហ៍ ហើយចុះអ្នកប្រុសមិនយកឡានលោកប៉ាសិនទៅ ។

CHANBOKEO.COM

- គឺ ពេលនេះ រាសីខ្ញុំមិនសូវល្អ ចេះតែប្រទះរឿងស៊ីយញ៉ីកញាប់ ពេក ទើបគិតថា មិនហ៊ានប្រើឡានរបស់លោកប៉ាទេ ។

ពូប្រេងស្ទុះទៅអូសកង់ចេញមកអោយបុរីយ៉ាងលឿន ។ ប្រាំ នាទីក្រោយមក មាណពក៏បានមកដល់មន្ទីរពេទ្យ ។ ថៃដន្យ គេមិន បានជួបធិតាដូចបំណងរបស់គេទេ ។ គ្រូពេទ្យដែលយាមប្រចាំការ បានប្រាប់ថា សាច់ញាតិបានទទួលនាងយកទៅព្យាបាលនៅផ្ទះតាំងពីរសៀលម្ល៉េះ ។ ឮដូច្នោះ បុរីខកចិត្តស្រលែត ស្រុតស្រយង់អស់ ដៃជើងតែម្តង មិនដឹងជាមកពីហេតុអ្វីទេ ។ គេក៏ឡើងជិះកង់ចេញ មកវិញទាំងចិត្តធុញថប់កន្ទះរា ត្បិតមិនដឹងថា គេត្រូវទៅរកនាង នៅទីណា...

នៅមាត់ស្ទឹងសង្កែ នរៈអង្គុយម្នាក់ឯងលើកៅអីថ្មក្រោមដើម ដូង សម្លឹងមើលចំណិតខែដ៏តូចស្តើងលើមេឃា ស្តាប់សៀងទឹកហូរ រឹមៗ ក្នុងចិត្តនឹកមិនអស់មិនហើយ ពីរឿងសម្ផស្ស រួចហើយស្រី ម៉ៅ ។ គេមិនយល់ចិត្តរបស់គេសោះថាហេតុអ្វី នាយបែរជារសោះ អស់ទឹកចិត្តម្ល៉េះនៅពេលនេះ ។ តើគេមានរឿងអ្វី ? នេះគេកំពុង ចាប់អារម្មណ៍លើស្រីម៉ៅហើយរំសាយចិត្តពីសម្ផស្ស មែនទេ ?

បុរីនឹកទៅដល់សម្ផស្សដែលមានរូបល្អសោភា មានធនធាន ទ្រព្យសម្បត្តិស្តុកស្តម្ភ ហើយមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ។ បើសិនជា គេបានរៀបការជាមួយនាង មួយជីវិតនេះ គេនឹងមានតែសេចក្តី សុខ ព្រោះគេមានទ្រព្យចាយវាយមិនអស់ ។ ប៉ុន្តែ... ចុះនាង ម៉ៅវិញ ? នាងជានរណាដែរ ? គេទើបតែជំពើបនាងពីរថ្ងៃសោះ តែដួងចិត្តនិងអារម្មណ៍របស់គេ បែរជាគិតពីមាណវីម្នាក់នោះឥត ឈប់ឈរសោះឥចឹង ? ហើយហេតុអ្វី គេខ្វល់ខ្វាយ ដើរអំពល់ ដេកអំពល់នឹកតែរូបនាងផង ?

នរៈលួចស្រដីខ្សិបៗតិចៗ សួរទៅខ្សែទឹកហូរក្នុងស្ទឹងថា :

- ហ៊ឺ! ម៉ៅអើយ! ពិតមែនតែនាងធ្វើអោយខ្ញុំខ្លាញ់បំផុត នៅ រៀងរាល់ពេលដែលខ្ញុំជួបមុខនាង... តែខ្ញុំពេញចិត្តនឹងឃើញរូប នាងជានិច្ច ជាជាងឲ្យនាងបាត់ខ្លួនទៅដោយឥតដំណឹងដូច្នេះដែរ ។ ខ្ញុំហាក់ដូចជា អផ្សុកក្នុងចិត្តណាស់កាលបើមិនបានឃើញមុខនាង ។ តើយើងមាន និស្ស័យអាចជួបគ្នាទៀតទេ ? ពេលណាទៅ ?

CHANBOKEO.COM

## នឹក

ជំនោររសាត់ផាត់យកអារម្មណ៍ ទុក្ខាក្រៀមក្រំឆ្ងាយដល់ជើងមេឃ
ពៅនៅទីណារៀមរ៉ាសង្វេគ នឹកពៅអនេកអណោចឱរា។
នឹកសួរសំនៀងសំដីស្រីមុំ នឹកភក្ត្រ័ស្រស់ឆោមលោមដួងចិន្តា
នឹកខ្លួចញញឹមលាក់នូវភាសា កន្ទុយនេត្រាលេបបេះដូងបង។
ពេលនេះបាត់ពៅបងនៅសោកា នឹកមាសធិតាចង់ជួបសាសង
ទ័យារន្ធត់នឹកសួនទងវង កែវអើយឆ្លើយផងអូននៅឯណា?
មេឃអើយនាំនឹកទឹកអើយនាំផ្តាំ ទៅស្រីស្រងាំបងចាំជីវ៉ា
ពៅអើយវិលវៃជួបថ្ងៃរៀមរ៉ា សាងរសស្នេហាជាថ្មីម្តងទៀត....

*បុរីអង្គុយបណ្តែតអារម្មណ៍សោកាតែម្នាក់ឯង... សម្តែងនូវភាព សោកសៅក្នុងចិត្ត នឹកដល់ចំណាងអនុស្សាវរីយ៍មួយ ដែលគេបាន ផ្ញើទុកនៅមាត់ស្ទឹងសង្កែនេះជាមួយនឹងយុវតីមួយរូប កាលពី៨ឆ្នាំ កន្លងទៅ...*

*oooooooooooooooooo*

*ooooo*

*o*

CHANBOKEO.COM

# វគ្គទី៨
# វៃសង្កៃ

ក្រុងបាត់ដំបង ឆ្នាំ១៩៦៦...

ថ្ងៃនេះជាថ្ងៃបណ្តែតប្រទីបចេញវស្សា ។ អ្នកស្រុកអ្នកក្រុងនាំ គ្នាដើរទាំងហ្វូងៗចុះទៅស្ទឹង ខ្លះសែងប្រទីបយកទៅបណ្តែតផ្សេង បំណាន់ផ្សេងៗ ។ ខ្លះអង្គុយលេង មើលក្មេងហែលទឹកដេញប្រទីប ដែលមានអុជទៀនរចនាជាក្បាច់ភ្លឺរន្ទាលចម្រុះពេញផ្ទៃទឹក ឃើញ ហើយគួរចាប់ចិត្តក្រៃលែង ។ ខ្លះក៏នាំគ្នាចេញលំហែយកខ្យល់ អាកាស សំរាកខ្លួនពីការងារនឿយហត់ ។ ខ្លះក៏ណាត់សង្សារជួបគ្នា បែបន់សុំ ព្រះជួយអោយគេបានសំរេចនូវបំណងទាំងឡាយក្នុង ជីវិត ។ ប្លែកអីតែបុរីទេ... ថ្ងៃនេះ គេខឹងនឹងប៉ាគេណាស់ ដែល សំរេចចិត្តរៀបការថ្មីទៀត ជាមួយស្ត្រីណាមិនដឹង ។ គេមិនចង់ឮ សូរសំណើចក្អាកក្អាយនៅក្នុងផ្ទះរបស់គេទេ ព្រោះចាស់ៗទាំងអស់ នោះកំពុងតែបំភ្លេចម្តាយរបស់គេ ដែលបានចែកស្ថានទៅនោះ ហើយ ។ ពេលនោះ បុរីទើបតែមានវ័យ១៧ឆ្នាំប៉ុណ្ណោះ ហើយឆ្នាំ នេះក៏ជាឆ្នាំចុងក្រោយរបស់គេនៅមធ្យមសិក្សាដែរ ។

បុរីដើរឈ្ងោកៗ យកស្បែកជើងឈូសដីអោយខ្វាយធូលីហុយ ឆ្លុមឡើង ធ្វើអោយអ្នកដំណើរតាមផ្លូវបែរសម្លក់គ្រប់គ្នា ព្រោះគ្រាប់ គ្រួសខ្លះបានខ្ទាតប្រលាក់ខោអាវរបស់គេ ។ ប៉ុន្តែ បុរីមិនបានចាប់ ភ្លឹកទេ ។ គេនៅតែឈ្ងោកដើរឈូសដីធ្វើមិនដឹងដដែល ។ រំពេច នោះស្រាប់តែគ្រាប់គ្រួសដែលគេឆាយនោះបានហោះចូលភ្នែកក្មេង ស្រីជំទង់មួយរូបអាយុប្រហែល១៣ឆ្នាំ កំពុងអោបកូនប្រទីបដើម ចេកតូចមួយដើរឆ្លងផ្លូវសំដៅមាត់ស្ទឹង :

– អ៊ូយ !

CHANBOKEO.COM

យុវតីលើកដៃមួយខ្ទប់ភ្នែកដោយការឈឺចាប់... ឯដៃម្ខាងទៀត មិនអាចទ្រទម្ងន់ប្រទីបបានក៏ធ្វើអោយប្រទីបជ្រុះក្តុកទៅដីបែកខ្ទេច ខ្ទីរតែម្តង ។ បុរីងើបមុខឡើង ឃើញនាងញីភ្នែកយ៉ាងញាប់ហើយ បែរសម្លក់រូបនាយចង់ស៊ីសាច់ទាំងរស់ ។ គេភ្ញាក់ខ្លួនព្រើត ដឹងថា ខ្លួនកំពុងធ្វើខុស ក៏ស្ទុះទៅជិត ហើយស្រដីថា :

- បងសូមទោសណានាងតូច !

ប៉ុន្តែនាងមិនបានស្រន់កំហឹងដោយពាក្យសុំទោសនោះឡើយ ។ នាងក៏ចាប់គល់ចេកតូចមួយកង់ គប់នាយផាច់កណ្តាលទ្រូងហើយ ស្រែកគំហកដាក់នាយថា :

- អ្នកគ្មានឪពុកម្តាយប្រដៅឬអ្វី ទើបឥតមារយាទយ៉ាងនេះ ? ដឹង ទេថា នេះជាប្រទីបដែលខ្ញុំកំពុងធ្វើដើម្បីឧទ្ទិសទៅពុកម៉ែដ៏ដូនជីតា របស់ខ្ញុំ ? ហេតុអ្វីក៏អ្នកមកបំផ្លាញខ្ញុំអញ្ចឹង ? អ្នកពិតជាមារ ជា ប្រេតហើយ បានមិនដឹងថាថ្ងៃនេះជាថ្ងៃបុណ្យដូច្នេះ ។

យុវតីយំផង រៀបរាប់ផង សំដែងអាការៈសោកស្តាយចំពោះ ប្រទីបរបស់នាងដែលបែកបាក់ខ្ចាត់ខ្ចាយពេលផ្លូវថ្នល់ ។ មនុស្ស ម្នាជិតៗនោះក៏ស្ទុះស្រ៊ូស្រមកឈរមើល ។ បុរីមិនហ៊ានស្រដីតប តទៅនាងវិញអ្វីទេ ព្រោះគេកំពុងតែដឹងថាគេមានកំហុស ។ នរៈ ក៏ស្ទុះឱនប្រមូលកំទេចប្រទីបនិងឥវ៉ាន់នានាមកផ្គុំគ្នាវិញ ។ ថៃដន្យ គេធ្វើទាំងរញីរញ័រព្រោះអាល័យតែរន្ធត់ចិត្តចំពោះពាក្យពេចន៍របស់ នាងតូច ប៉ុន្តែនៅប្រឹងរៀបផ្គុំចុះផ្គុំឡើង តាមដែលអាចធ្វើបាន ។ ភ្លាមនោះ មានកុមារតូចមួយរូបអាយុប្រហែល៨ឆ្នាំ បានរត់មកដល់ ហើយពោលដាក់យុវតីនោះថា :

- បងម៉ៅ ! ប៉ាម៉ាក់មានប្រសាសន៍ថា អោយបងចុះទៅមាត់ស្ទឹង ខាងក្រោមអោយឆាប់ឡើង នឹងអាលអុជទៀនអុចធូបផ្សងទាំងអស់ គ្នា ។ គាត់កំពុងចាំបងនៅមាត់កំពង់ឯណោះ !

នាងម៉ៅងើបមុខឡើង មើលទៅកុមារតូចទាំងទឹកភ្នែកនៅដក់ ក្នុងរង្វង់ភ្នែកនៅឡើយ រួចហើយក៏ស្រដីថា :

- ចិត្រា ! ជំរាបប៉ាម៉ាក់ផង ថាបងសុំទោសដែលមិនបានទៅ បណ្តែតប្រទីបជាមួយលោក ព្រោះបងខ្ជីខ្ជាធ្វើអោយប្រទីបមួយនេះ ជ្រុះធ្លាក់បាក់បែកអស់...

CHANBOKEO.COM

យុវតីស្រដីទាំងអណ្ដឹតអណ្ដក់ ។ កុមារតូចឮដូច្នោះក៏រត់ត្រលប់ ទៅវិញ ។ បន្តិចមក ប៊ុរីក៏ផ្គុំប្រទីបបានជាតួដូចឡើងវិញ គ្រាន់តែ មិនបានស្អាតដូចមុនប៉ុណ្ណោះ ។ គេក៏បែរលួងលោមនាងតូច ដោយ វាចាយ៉ាងទន់ភ្លន់ថា :

- ប្អូនស្រីឈប់យំទៅ ! បងសុំទោសណា៎ ! នេះជាកំហុសរបស់បង ទេ ។ ឥលូវបងខំផ្គុំបានវិញហើយ ថ្វីបើវាមិនល្អដូចដើម តែក៏សម ជាតួប្រទីបសំរាប់អុជបណ្ដែតនឹងគេបានដែរ ។ ម៉ោះ ! បងជួយ លើកទៅដាក់មាត់ស្ទឹង ! ប្អូនដើរតាមបងមក៏ !

នាងម៉ៅបែរសម្លក់ទៅប៊ុរីដោយក្រសែភ្នែកយ៉ាងមុត ទំនងដូច នៅខឹងមិនទាន់បាត់ ។ ប៉ុន្ដែប៊ុរីមិនបានប្រកាន់នឹងកិរិយារបស់នាង ទេ ព្រោះគេដឹងថា គេពិតជាប្រព្រឹត្តមិនសមដូចនាងតូចថាមែន ។ បន្តិចមក យុវតីក៏ដើរតាមពីក្រោយប៊ុរីរហូតដល់មាត់ស្ទឹងដែលមាន មនុស្សប្រុសស្រីផ្សេងមកជួបជុំបណ្ដែតប្រទីបអ៊ូអរ ។ ប៊ុរីក៏ដើរវាង រកកន្លែងទំនេរ រួចចាប់អុជទៀន អុជធូបឡើង :

- ប្អូនស្រីអង្គុយចុះមក៉ ! ហើយលុតជង្គង់សំពះផ្សងទៅណា៎...

ស្រីម៉ៅមិនឮមាត់កអ្វីទេ នាងលើកដៃផ្គុំឡើង ហើយសំពះបន់ ស្ងាត់ៗតែក្នុងចិត្ត បន្ទាប់មកឆវីក៏អូសយកប្រទីបដាក់ទៅក្នុងស្ទឹង បណ្ដែតចេញទៅ...

ប៊ុរីឈរមើលនាងតូចមិនដាក់ភ្នែកទេ ។ គេនឹកឆ្ងល់តែក្នុងចិត្ត ម្នាក់ឯងដែលឃើញយុវតីក្មេងច្រឡឹងតូចមួយមានកិរិយាចាស់ទុំដូច មនុស្សពេញវ័យ មិនដូចយុវតីផងទាំងពួង អាយុស្របាលៗនាង សោះ ។ យុវតីឈរមើលតាមដំណើរប្រទីបដែលចរលើទឹកដោយ កិរិយាស្ងៀមស្ងាត់ រហូតដល់ប្រទីបអណ្ដែតបាត់ពីក្រសែភ្នែកទៅ រួចហើយក៏ដាក់ខ្លួនអង្គុយលើស្មៅសំកុកធ្វើមុខស្ងួត ហាក់ដូចជាមិន សប្បាយចិត្តរឿងអ្វីមួយ ។ ប៊ុរីឃើញដូច្នោះ ក៏ដាក់ខ្លួនក្បែរនាង សួរថា :

- អោយបងសុំអង្គុយក្បែរផងណា៎ !

នាងតូចនៅស្ងៀម ។ ប៊ុរីបែរមើលនាងហើយក៏ស្រដីបន្តថា :

- ថ្ងៃនេះជាថ្ងៃបុណ្យបណ្ដែតប្រទីបចេញវស្សា ជាថ្ងៃដែលមនុស្ស ម្នាទាំងឡាយសប្បាយរីករាយជួបជុំគ្នាធ្វើបុណ្យ ។ ចៃដន្យ ចំពោះ មនុស្សខ្លះវិញ ថ្ងៃនេះជាថ្ងៃដែលគេមានទុក្ខសោកបំផុតក្នុងជីវិត....

CHANBOKEO.COM

បុរីស្រដីមកដល់ត្រង់នេះ ក៏រួលដើមក រកស្រក់ទឹកភ្នែក ។ ភ្លាមនោះ ស្រាប់តែយុវតីបែរមុខមកសួរនាយយ៉ាងរហ័ស :

- អូហ៍... មនុស្សប្រុសចេះកើតទុក្ខដែរ ?

បុរីប្រឹងលេបទឹកភ្នែកចូលទៅក្នុងពោះ ហើយដកដង្ហើមបន្ធូរ ការតានតឹងនៅក្នុងចិត្ត បន្តិចទើបស្រដីតបថា :

- នរណាថាមិនចេះ ? មនុស្សយើងមានរូប តែងតែមានអារម្មណ៍ មិនថាជាស្រីឬជាប្រុសទេ គេអាចមានអារម្មណ៍ សប្បាយ ព្រួយ កើតទុក្ខ បានគ្រប់ពេលទាំងអស់ហ្នឹង ។ មើលទៅប្អូនស្រីហាក់ដូច ជាកំពុងមានទុក្ខ បងវិញក៏មានអារម្មណ៍មិនខុសពីនោះប៉ុន្មានទេ...

ពេលនេះ នាងម៉ៅហាក់ដូចជាបន្ធូរឥរិយាបថរបស់នាងចំពោះ បុរីបន្តិចហើយ គឺតាំងពីយុវជនយើងផ្តុំប្រទីបសងវិញ រួចបានយក មកបណ្តែតក្នុងស្ទឹងបាននឹងគេដែរ ។ កាលបើឮប្រយោគនេះកាល ណា ធិតាក៏ពោលតបទៅវិញថា :

- មើលទៅសម្បុរសំបក បងប្រុសមិនសមជាកូនអ្នកក្រទេ ប៉ុន្តែ ហេតុអ្វីក៏មានទុក្ខនឹងគេដែរ ?

- អ្នកក្រឬអ្នកមាន មានទុក្ខ មានសប្បាយ ដូចតែគ្នាហ្នឹង ។ ប្អូន ដឹងទេ ? បងមិនសប្បាយចិត្ត ព្រោះម្តាយបងទើបតែអនិច្ចកម្មទៅ មិនបានប៉ុន្មានខែផង លោកប៉ាក៏មានគំរោងរៀបការថ្មីទៀត...

ស្រាប់តែនាងតូចម៉ៅនិយាយតបវិញថា :

- នោះប្រសើរហើយដែលបងប្រុសបានដឹងថាម្តាយស្លាប់ហើយបាន ធ្វើបុណ្យអោយ រួចលោកឪពុកក៏នៅសុខសប្បាយ រីឯជីវភាពវិញ ក៏មិនទាល់ច្រក ។ ប៉ុន្តែជីវិតរបស់ម៉ៅវិញ... យ៉ាប់ជាងនោះរាប់ រយដងទៅទៀត...!

ធិតាពោលដោយសំនួនពាក្យយ៉ាងសោកសៅ ។

- ប្អូនមានរឿងអ្វីធ្ងន់ធ្ងរក្នុងជីវិតណាស់ មែនទេ ? (បុរីសួរ)

- ចាស មែនហើយ ! ពុកម៉ែខ្ញុំជាអ្នកស្រែក្រីក្របំផុត មានកូន តូចៗបួននាក់ទៀត ។ ពុកខ្ញុំជាមនុស្សប៉ោឡៃ មិនចេះទទួលខុស ត្រូវក្នុងជីវិត ប្រមឹកស្រាហើយវាយប្រពន្ធកូនព្រឹកល្ងាច ឥលូវនេះ គាត់មានជំងឺថ្លើមដោយសារញៀនស្រា រង់ចាំតែថ្ងៃវិលត្រលប់ទៅ វិញតែម្យ៉ាងប៉ុណ្ណោះ ។ ចំណែកម៉ែធ្វើស្រែ តែដោយគាត់ត្រូវពុក វាយដំច្រើនពេក ក៏ក្លាយជាពិការធ្វើអ្វីលែងកើត ទើបលក់ស្រែលក់ ស្រូវ លក់ដីធ្លី ដើម្បីចិញ្ចឹមកូន ។ លុះគាត់ក៏អស់អីលក់ ក៏ធ្លាក់ដល់ ថ្នាក់លក់កូនអោយទៅធ្វើឈ្នួលបំរើគ្រួសារគេ តាមផ្ទះ តាំងពីតូចៗ ខ្លះមិនទាន់គ្រប់ប្រាំឆ្នាំស្រួលបួលផង ។

CHANBOKEO.COM

ម៉ៅស្រដីទាំងរអាក់រអួល ដោយក្តីសង្វេគក្នុងចិត្ត ។ បុរីស្តាប់ រឿងរបស់នាងមកដល់ត្រង់នេះ គេហាក់ដូចជារំជួលចិត្តអាណិត យុវតីពន់ពេកក្រៃ ។ កាលពីដើម គេគិតថាជីវិតរបស់គេអួរអាប់គួរ អោយធុញទ្រាន់ណាស់ ។ ប៉ុន្តែលុះដល់គេបានមកស្តាប់រឿងរបស់ ស្រីម៉ៅ ទើបដឹងថាសេចក្តីទុក្ខក្នុងជីវិតរបស់គេនោះវាតូចពេកក្រៃ មិនអាចយកមកប្រៀបធៀប ទៅនឹងជីវិតរបស់យុវតីមួយរូបនោះ បានឡើយ ។ បន្តិចមក គេក៏សួរនាងថា :

- ហើយពេលនេះ ប្អូនត្រូវម្តាយលក់អោយគេដើម្បីយកមកធ្វើជា អ្នកបំរើរបស់គ្រួសារណាមួយនៅបាត់ដំបងនេះ មែនទេ ?

- ចាស មិនមែនទេ! គាត់ជាមនុស្សចិត្តធម៌ បានជួយសង្គ្រោះម៉ៅ តាំងតែពីតូច ព្រោះពុកវាយម៉ៅសន្លប់ច្រើនដងដោយសារម៉ៅជួយ ការពារម៉ែ ជួនប្រកែកមិនព្រមទៅទិញស្រាអោយគាត់ ។ ថ្ងៃមួយ ពុកចាប់ខ្ញុំលក់ឲ្យទៅបំរើគេ នៅហាងលក់បាយមួយនៅភូមិស្វាយ ប៉ុន្តែខ្ញុំលួចរត់មកផ្ទះវិញជាច្រើនដង ។ លុះចៅកែតាមជេរគាត់ ពេក ពុកគាត់ក៏ចាប់ខ្ញុំវាយនឹងជន្ទល់រទេះរហូតសន្លប់...

- ពុទ្ធោ! ពុកអីក៏ចិត្តសាហាវម្លេះ ?

- នោះក៏គឺមកពីពុកប្រមឹកស្រា លែងស្គាល់កូន ស្គាល់ប្រពន្ធ ស្គាល់បាបបុណ្យ ខុសត្រូវអស់ហើយ...

- ហ៊ឺ! បងពិតជាអាណិតប្អូនណាស់!...ហើយចុះឥលូវនេះនាងតូច រស់នៅជាមួយនរណាដែរ ?

- គឺរស់នៅជាមួយក្រុមគ្រួសាររបស់អ្នកមានគុណសប្បុរស ។

- អូហ៍! ចុះគេមានដែលធ្វើបាបអ្វីប្អូនទេហ៍ ?

- ចាស មិនដែលទេ! លោកទាំងពីរជាមនុស្សដែលមានចិត្តធម៌ បំផុតចំពោះម៉ៅ ។ គាត់ចិញ្ចឹមម៉ៅដូចកូនចៅសាច់ឈាមរបស់គាត់ អញ្ចឹង គួរអោយកក់ក្តៅណាស់! ប៉ុន្តែ... ទោះជាយ៉ាងណាក៏ដោយ ក៏ចិត្តម៉ៅនៅតែរងា នៅតែត្រមង់ត្រមោចកណ្តោចកណ្តែងដដែល.. លោកទាំងពីរកាន់តែធ្វើល្អចំពោះម៉ៅកាលណា ម៉ៅកាន់តែអណោចអធម ក្នុងចិត្តឡើងកាលណោះ ព្រោះអីម៉ៅនឹកស្រណោះអាណិតដល់ប្អូនៗ ដែលមិនមានឱកាសទទួលជីវិតកក់ក្តៅដូចម៉ៅដែរ ។ ម៉ៅអាណិត ម៉ែដែលរស់នៅខ្វះខាតវេទនាឯស្រុក នឹកអាណិតពុកដែលលង់នឹង

CHANBOKEO.COM

ដងើស្រាមើលមិនជា... ចំណែកម៉ៅវិញ ទទួលបានត្រឹមតែសេចក្ដី សុខសំរាប់ខ្លួនឯង ម្នាក់ឯង
ហើយគ្មានមធ្យោបាយណាអាចចែក រំលែកសេចក្ដីសុខរបស់ខ្លួនអោយទៅប្អូនៗនិងម៉ែបាន...

និយាយមកដល់ត្រង់នេះ យុវតីក៏ស្រក់ទឹកភ្នែកសាជាថ្មី ។ ប៊ុរី អង្គុយស្ដាប់យូរទៅ
កាន់តែអាណិតអាសូរធិតាឡើង អត់ទ្រាំមិនបាន ក៏រលីងរលោងទឹកភ្នែកតាមនាងតូចដែរ ។
ភ្លាមនោះ គេក៏យកដៃ ទៅអង្អែលក្បាលយុវតីដោយដួងចិត្តក្ដុកក្ដួល ព្រោះតែក្ដីអាណិត
អាសូរយ៉ាងធំធេងរកអ្វីមកប្រៀបពុំបាន :

- សំណាងល្អហើយដែលប្អូនបានជួបមនុស្ស ដែលមានចិត្តកុសល
បុណ្យឧត្ដុង្គឧត្ដមជួយទំនុកបំរុងជីវិតរបស់ប្អូន ។ បើនាងពិតជាចង់ ជួយប្អូនៗនិងម៉ែមែននោះ
នាងត្រូវតែប្រឹងជួយខ្លួនឯងឡើង តាំង ខ្លួនជាមនុស្សល្អហើយខំរៀន
ធំឡើងនឹងអាលមានការធ្វើមាំមួន ។ ពេលនោះ
ប្អូននឹងអាចវិលបែរក្រោយជួយពុកម៉ែវិញបានយ៉ាងល្អ
វិញមិនខានឡើយ...

ធិតាងក់ក្បាល :

- ចាស! ម៉ៅក៏បានគិតដូច្នោះដែរ ។

ពេលនេះ នាងតូចហៅខ្លួននាងថាម៉ៅៗ ទំនងហាក់ដូចជាទុក ចិត្តប៊ុរីបន្តិចហើយ ។ ភ្លាមនោះ
ឆវីក៏សួរនាយវិញថា :

- ហើយចុះបងប្រុសឈ្មោះអីដែរ ? ជាអ្នកភូមិជិតៗនេះទេ មែន ទេហ៍ ?

ប៊ុរីញញឹមឡើងកាលបើឮនាងសួរដូច្នោះ ហើយឆ្លើយវិញថា :

- បងឈ្មោះរៃ រស់នៅជិតវត្តពោធិវាលនេះឯង តែគ្មានបងប្អូនទេ
មានតែម្នាក់ឯង អផ្សុកណាស់ ។ បើថ្ងៃរៀន គ្រាន់បន្តិច ព្រោះបាន ជួបមិត្តភក្តិ ។ ថ្ងៃនេះ
គេគ្រប់គ្នាជួបជុំបងប្អូន សប្បាយរីករាយ បណ្ដែតប្រទីបជុំគ្នា តែចំពោះបងវិញ
បងតប់ប្រមល់ហើយត្រមង់ ត្រមោចមិនខុសពីប្អូនទេ ។ ថ្វីបើបងមានឪពុក តែពេលនេះគាត់
លែងចាប់អារម្មណ៍ពីសុខទុក្ខរបស់បងហើយ ព្រោះកំពុងតែផ្ចង់
ចិត្តគំនិតសំរាប់គូស្រករថ្មីរបស់គាត់ ទើបបងក្លាយជាអផ្សុកហើយ មួម៉ៅតប់ប្រមល់ក្នុងចិត្ត
ហើយក៏ចេញមកដើរឈូសឆីលេងបន្លប់ អារម្មណ៍ហ្មងហ្មងនោះ ។ ចៃដន្យ
ការប្រព្រឹត្តរបស់បងបានធ្វើអោយ ដីចូលភ្នែកប្អូនដោយអចេតនា...

CHANBOKEO.COM

រួចក៏ធ្វើអោយប្រទីបធ្លាក់ដីបែក អស់ ។ ពេលនោះ ទើបបងភ្ញាក់ខ្លួនដឹងថា អ្វីដែលបងធ្វើដោយមិនបានគិតតែងតែផ្តល់លទ្ធផលអាក្រក់ដូច្នេះឯង ។

ពេលនោះ យុវតីក៏ញញឹមឡើង បញ្ចេញធ្មេញរាបស្មើគួរអោយ ស្រលាញ់ :

- មួយសន្ទុះមុននេះ ខ្ញុំខឹងនឹងបងប្រុសពិតមែន តែលុះដល់ស្តាប់ រឿងរបស់បងទៅ ខ្ញុំរសាយចិត្តឈប់ខឹងហើយ ។ យើងទាំងពីរ មានរឿងតប់ប្រមល់ក្នុងចិត្តដូចគ្នា ទើបទេវតានាំផ្លូវអោយយើងមក ជួបគ្នាធ្វើបងប្អូនបានពីរនាក់កុំអោយត្រមង់ត្រមោចទៀត ។

ឮវាចានាងតូចដូច្នេះ បុរីធូរទ្រូងខ្សាកតែម្តង :

- អញ្ចឹង យើងសុំគ្នាធ្វើជាបងប្អូនបានទេ ? គឺបងសុំម៉ៅធ្វើជាប្អូន ស្រីតែម្តង តើនាងតូចគិតយ៉ាងម៉េចដែរ ?
- ប៉ុន្តែ... ខ្ញុំជាកូនអ្នកក្រ បងជាកូនអ្នកមាន តើធ្វើបងប្អូននឹងគ្នា ម៉េចនឹងកើត ?
- ខុសហើយ យើងទាំងពីរក្រហើយខ្វះខាតដូចតែគ្នាតើហ៎...
- បងប្រុសនិយាយមានន័យយ៉ាងម៉េចហ្នឹង ?
- គឺមានន័យថា យើងទាំងពីរ ក្របងប្អូន ក្រសាច់ញាតិ ហើយខ្វះ សេចក្តីកក់ក្តៅក្នុងចិត្តរបស់យើងនោះអី... ភ្លេចហើយហ្ន៎ស ?
- គឺ...បងមានប្រសាសន៍ត្រូវណាស់ ប៉ុន្តែ... តើយើងធ្វើជាបងប្អូន ត្រឹមតែថ្ងៃនេះ ឬក៏បងប្អូនរហូតតទៅ ?
- គឺយើងសុំគ្នាធ្វើបងប្អូន ចាប់តាំងពីថ្ងៃនេះរហូតតទៅ...
- ដោយមិនគិតថា យើងទាំងពីរកើតចេញមកពីប្រភពគ្រួសារបែប ណាទេ មែនទេ ?
- ពិតមែនហើយ !

ស្រីម៉ៅឈ្ងោកមុខសម្លឹងស្មៅ ទំនងហាក់កំពុងគិត ។ មួយ ស្របក់មក នាងក៏ងើបមុខឡើងសួរទៀតថា :

- តែខ្ញុំក្រណាស់ គ្មានអ្វីជូនបងជាថ្នូរ តំណាងការទទួលខ្លួនជាបង ប្អូនជាមួយបងទេណា៎ !
- ចុះបងមានថា ចង់បានអ្វីពីប្អូនឯណា ?

យុវតីក៏ញញឹមឡើងហើយលើកដៃស្តាំហុចកូនដៃឡើង :

- អញ្ចឹង ! ម៉ោះ ! យើងផ្តក់ដៃគ្នា !

CHANBOKEO.COM

ឃើញដូច្នោះ បុរីញញឹមពព្រាយឡើងតែម្តង ព្រោះគេដឹងថា នាងតូចកំពុងបើកដួងចិត្តទទួលរូបគេជាបងប្អូន... គេក៏លើកកូនដៃ ផ្តក់ម្រាមដៃធិតាយ៉ាងរហ័ស ដោយចិត្តរំភើបត្រេកអរក្រៃលែង ហើយ ក៏វាចាឡើងទាំងរំភើបចិត្តថា :

- បងសុំធ្វើជាបងប្អូននឹងម៉ៅ ចាប់ពីថ្ងៃនេះរៀងរហូតទៅ ។

អ្នកទាំងពីរញញឹមដាក់គ្នាយ៉ាងរីករាយ ។ បន្ទាប់មក បុរីក៏ដោះ ខ្សែកប្លាទីនរបស់ខ្លួន មានបន្តោងប្រាក់កាក់ យកចេញពីកមកហុច អោយស្រីម៉ៅ :

- នេះនែ! បងមានរង្វាន់អនុស្សាវរីយ៍ចំពោះប្អូនស្រីដ៏ស្រស់ស្អាត របស់បង ។

ស្រាប់តែនាងតូចគ្រវីក្បាល :

- ម៉ៅមិនចង់បានទេ មើលទៅបែបថ្លៃច្រើនហើយ ខ្លាចពាក់ទៅ ប៉ាម៉ាក់ឃើញ នាំតែគាត់គិតថា ខ្ញុំជាក្មេងស្រវាស្រទេញ លោភចង់ បានទ្រព្យអ្នកដទៃ ។

- តាមពិត ខ្សែកនេះមិនថ្លៃទេ ព្រោះជាខ្សែកស្ពាន់ទេតើ (បុរីខំ កុហក ក្រែងនាងតូចមិនព្រមយក)

- បើជាស្ពាន់មែន ម៉ៅទទួលយកចុះ តែបើមាសវិញ មិនយកទេ!

- គឺពិតជាស្ពាន់ហើយ ។ នែ៎ក! បែរក្រោយមក បងពាក់អោយ ។

ស្រីម៉ៅក៏បែរខ្លួនហើយលើកសក់ឡើង អោយបុរីបំពាក់ខ្សែក អោយ ។ ភ្លាមនោះ យុវជនយើងស្រដីថា :

- ខ្សែកនេះជារង្វាន់ពីម៉ាក់របស់បង កាលពីបងប្រលងឌីប្លូមជាប់ ភ្លាម ។ គាត់បានឆ្លាក់ឈ្មោះនៅលើបន្តោងប្រាក់កាក់ថា "រៃសង្កែ" ព្រោះកាលបងនៅពីតូចៗ បងចូលចិត្តយំរករឿងគាត់ណាស់ ជា ពិសេស នៅពេលល្ងាចៗឡើង... ជួនកាល បងធ្លាប់ទៅឈរយំ

រំងាស់ឡើងៗ នៅមាត់ស្ទឹងសង្កែរហូតថ្ងៃលិចក៏មានដែរ ។

- ស្លាប់ហើយ! មិនដែលឮទេ កូនប្រុសយំរំងាស់ទំលាក់ទឹកភ្នែក ក្នុងស្ទឹងសង្កែ... ពិតជាគួរអោយអស់សំណើចណាស់ ។

ថាហើយ យុវតីក៏សើចខឹកៗឡើង ។ បុរីក៏ឈ្ងោកឱនខំទំពាក់ ភ្ជាប់មុខខ្សែកអោយជាប់ ហើយនិយាយថែមទៀតថា :

- នៅមានរឿងច្រើនលើសហ្នឹងទៀត តែពេលនេះ យប់ហើយ យើងគួរត្រលប់ទៅផ្ទះវិញសិន ដើម្បីកុំអោយចាស់ៗបារម្ភ ។ ថ្ងៃក្រោយជួបគ្នា បងនិយាយរឿងប្រាប់ម៉ៅទៀត ។ ពេលនេះ

CHANBOKEO . COM

សូមប្អូនថែរក្សាខ្សែកនេះឲ្យល្អផងណា៎! ពេលម៉ៅឃើញខ្សែកនេះ ក៏ដូចបានឃើញបងដែរ... គឺយើងមានគ្នាពីរនាក់ មិនត្រមង់ ត្រមោចដូចកាលមុនទៀតទេ ។

ថាហើយបុរីក៏ងើបឡើងដើរដឹកដៃនាងតូចត្រលប់ទៅវិញ ទាំង ទឹកមុខញញឹមរីករាយ ។ ចំណែកនាងតូចវិញក៏មានទឹកមុខស្រស់ថ្លា បំព្រងមិនខុសគ្នាឡើយ ។ មួយសន្ទុះធំមុននេះ គេមានអារម្មណ៍ ល្អក់កករទាំងពីរនាក់ ប៉ុន្តែពេលនេះ គេបែរជាមានអារម្មណ៍ ស្រស់ថ្លាក្រៃលែង ។ គេដើរបណ្តើរដដែកគ្នាបណ្តើរ ក្នុងចិត្តហាក់ ដូចជាមានអារម្មណ៍កក់ក្តៅហើយរំភើបក្នុងចិត្តរៀងៗខ្លួន ។ បន្តិច មកបុរីក៏សួរស្រីម៉ៅថា :

- តើផ្ទះប្អូននៅឯណាដែរ ម៉ៅ ?

យុវតីបែរចុះបែរឡើង ងាករកមើល ក៏លាន់មាត់ថា :

- អូហ៍! ខ្ញុំដើរហួសផ្ទះទៅហើយបង! តចឹង ខ្ញុំលាបងត្រឹមនេះ សិនចុះ ចាំស្អែក យើងជួបគ្នាទៀត ។

- បាទ! ស្អែកជួបគ្នាទៀត តែ... តើអោយបងទៅរកប្អូននៅឯណា ដែរទៅទើបជួប ?

- នៅកន្លែងបណ្តែតប្រទីបរបស់យើង បងមកកុំខានណា៎ ?

- បាទ! ចាំ! ស្អែកយើងជួបគ្នាមុនថ្ងៃលិចនៅទីនោះណា៎!

- ចា៎ស!

ថាហើយ នាងតូចក៏លើកដៃបក់បោយលាបុរី ហើយរត់ត្រឡប់ ក្រោយទៅវិញយ៉ាងលឿន ទុកអោយបុរីឈរមើលរហូតដល់នាង បាត់ស្រមោលក្នុងរាត្រីងងឹត ក្រោមពន្លឺភ្លើងគោមព្រឹមៗតាមផ្លូវ ។ បន្តិចមក គេក៏បែរខ្លួនដើរត្រលប់ទៅផ្ទះវិញដែរ ។

នៅក្នុងបន្ទប់គេង...

ថ្វីបើបុរីមានអារម្មណ៍ហាក់ដូចជាសប្បាយរីករាយក្នុងចិត្ត ប្លែក ជាងធម្មតា គេក៏នៅតែធុញថប់ក្នុងចិត្តខ្លះៗនៅឡើយ ត្បិតព្រឹក ស្អែកនេះ គេនឹងបានជួបមុខម្តាយចុងរបស់គេហើយ មិនដឹងថា ស្ត្រីមួយរូបនោះជានរណា មានចិត្តយ៉ាងណាទេ... គិតទៅគិតមក គេនៅតែខឹងនឹងឪពុករបស់គេដដែល មិនព្រមស្រកស្រុតកំហឹង បន្តិចណាឡើយ ។ គេខឹងព្រោះគេយល់ថា លោកបុរាណកំពុងតែ បំភ្លេចម្តាយរបស់គេហើយ ។ មួយយប់នោះ គេគេងបម្រះមួយ យប់ទើសភ្លឺ សប្បាយផងតប់ប្រមល់ផង... សប្បាយ ព្រោះគេបាន ស្គាល់ក្មេងស្រីមួយរូប គួរអោយស្រឡាញ់ ប៉ុន្តែ គេតប់ប្រមល់ ព្រោះគេមិនទាន់អាចត្រៀមចិត្តទទួលម្តាយថ្មីបាននៅឡើយ...

CHANBOKEO.COM

# វគ្គទី៥
# សង្សារ ?

ប៊ុរីគេងមិនលក់មួយយប់ហើយ នឹកទៅដល់រឿងអតិតកាល របស់គេផង នឹកបារម្ភទៅដល់នាងម៉ៅដែលមានជំងឺនោះផង មិនដឹងថានាងបានធូរស្រាលវិញហើយឬយ៉ាងណា ? គេចង់ទៅរកនាង ដើម្បីសួរសុខទុក្ខ តែគេមិនស្គាល់ផ្ទះនាងសោះ មិនដឹងថាទៅរក ឯណាទើបជួប ។ រំពេចនោះ ស្រាប់តែគេនឹកភ្នកទៅដល់សាមេត ភ្លាម :

- មែនហើយ! សាមេតគេស្គាល់ស្រីម៉ៅ ប្រហែលជាគេស្គាល់ផ្ទះ នាងដែរហើយ ។

រកតែមេឃស្វាងពន្លឺមិនទាន់ ប៊ុរីហក់រឺងទៅរកពូប្រេង :

- ខ្ញុំសុំខ្ចីកង់បន្តិចពូ!
- យី! ទៅណាទៀតហើយហ្នឹង អ្នកប្រុស ?
- ទៅរកមិត្តភក្តិនៅឌួនទាវបន្តិច បាទ!
- ចុះបើអ្នកនាងសម្ផស្សមករក តើអោយខ្ញុំជំរាបថាថាម៉េច ?
- ប្រាប់នាងឲ្យចាំនៅផ្ទះសិនទៅ ខ្ញុំទៅមិនយូរទេ ។ បន្តិចទៀត ខ្ញុំមកវិញហើយ ។

ថាហើយ ប៊ុរីឡើងកង់រឺងទៅយ៉ាងលឿន ។ ចៃដន្យពេលនាយទៅដល់ គេក៏បានប្រទះនឹងបុរសមួយរូបទៀតយ៉ាងសង្ហាកំពុងដើរ ចុះជណ្តើរផ្ទះមកដល់ :

- ប្អូនជាសាច់ញាតិរបស់សាមេតមែនទេហ៎ ?
- បាទ! ខ្ញុំឈ្មោះ សាមឿន ជាប្អូនរបស់គាត់ ។ ចុះបងវិញ ?
- មែនហើយ! បងឈ្មោះប៊ុរីជាមិត្តរបស់សាមេតបែកគ្នាតាំងពីយូរ មកហើយ ។ ពេលនេះគេនៅផ្ទះទេ ?
- បាទ មិននៅទេ ។ គាត់ទើបចេញទៅធ្វើការក្នុងរោងចក្រមុន នេះបន្តិច ថ្ងៃនេះចំវេន១២ម៉ោង ជួយជំនួសអ្នកធ្វើការម្នាក់ដែល កំពុងឈប់ឈឺនៅផ្ទះ...

CHANBOKEO.COM

- អូហ៍... ហើយចុះប្អូនស្គាល់អ្នកដែលឈើយប់នោះដែរ ?
- ស្រីម៉ៅនោះហ្មែស៎ ? ថីមិនស្គាល់...!
- អញ្ចឹង ល្អហើយ បងកំពុងតែរកផ្ទះរបស់ម៉ៅផង ។
- អូហ៍! បងស្គាល់ម៉ៅដែរ ?
- គឺ... ស្គាល់គ្នាតាំងពីតូចៗ តែក៏បែកគ្នាយូរឆ្នាំហើយដែរ ហើយ បងក៏កំពុងរកគេដូចគ្នា ។ ប្អូនស្គាល់ផ្ទះរបស់គេទេ ?
- បាទ! មិនស្គាល់ទេ គ្រាន់តែដឹងថា ផ្ទះម៉ៅនៅម្តុំវត្តពោធិក្នុង ។

ប៊ុរីសម្លឹងមុខមាណពសង្ហានោះមួយស្របក់ក៏សួរថា :
- ហើយប្អូនជាពួកម៉ាករបស់គេមែនទេ ?
- គឺ...ធ្លាប់រៀនជាមួយគ្នា តែលុះដល់ម៉ៅប្រលងឌីប្លូមជាប់ទៅ គេ ក៏ចេញធ្វើការ ហើយខ្ញុំទៅរៀនបន្តនៅសាលាបច្ចេកទេសទៀតទើប បែកគ្នា ។ ថៃដន្យ ម៉ៅបានចូលរធ្វើការរោងចក្រដូនទាវ ជានាយ ចំណាត់ការរងម្នាក់ ផ្នែកជាមួយគ្នានិងបងសាមេត ទើបយើងជួបគ្នា ហើយរាប់អានគ្នាទៅមកយ៉ាងជិតដិតឡើងវិញសាជាថ្មី ។
- អញ្ចឹង មានន័យថា ម៉ៅជាសង្សាររបស់ប្អូនមែនទេ ?

ពួសំនួររបស់ប៊ុរីភ្លាម សាមឿនញញឹមឡើង :
- ខ្ញុំបន់អោយតែអញ្ចឹងដែរណ៎ាបង តែម៉ៅគេមិនព្រមឆ្លើយសោះ ពេលខ្ញុំសួរគេម្តងៗ គេសម្លក់ដាក់ខ្ញុំសឹងជ្រុះគ្រាប់ភ្នែកឯណោះ ។

ប៊ុរីនៅស្ងៀមមួយស្របក់ក៏សួរបន្តថា :
- ហើយចុះសាមេតវិញ គេមានគូស្រករហើយឬនៅ ?
- នៅទេ ប៉ុន្តែគាត់កំពុងសម្លឹងគេម្នាក់ហើយ ។
- អូហ៍! ហើយគេមិនបានពេញចិត្តនឹងម៉ៅដែរទេ ?
- ស្លាប់ហើយ! បងមេតហ្នឹងហ្ន៎ស ពេញចិត្តម៉ៅ ? អត់ទេបង! បងមេត គាត់មានម្ចាស់បេះដូងរបស់គាត់រួចហើយ ជាអ្នកជិតខាង យើងនេះឯង ។ គាត់កំពុងខំធ្វើការសន្សំលុយនឹងអាលចូលដណ្តឹង រៀបការឆាប់ៗនេះ ។ ចំណែកម៉ៅវិញ បងមេតស្រលាញ់ជាប្អូនស្រី ទេ ព្រោះម៉ៅឧស្សាហ៍ធ្វើការហើយជាមនុស្សមានចិត្តណាស់ ។ ការពិត បងសាមេតសម្លឹងនាងត្រឹមតែជាអនាគតប្អូនថ្លៃប៉ុនហ្នឹងឯង ។

ឮដូច្នោះ ប៊ុរីហាក់ដូចជាតប់ប្រមល់បន្តិចដែរ ។ គេក៏យកដៃទៅគោះស្មាសាមឿនហើយស្រដីថា :

- អញ្ចឹង បងលាទៅវិញសិនហើយ! ចាំប្រាប់សាមេតផងថា បងនឹងមកលេងគេទៀតនៅចុងសប្តាហ៍នេះ ។

- បាទ!

ប៊ុរីក៏ឡើងធាក់កង់ត្រលប់ក្រោយទៅបាត់ដំបងវិញ ។ នៅលើ ដងផ្លូវត្រើយខាងកើតស្ទឹងសង្កែ ប៊ុរីជិះកង់ចុះឡើងពីរបីសាយឺតៗ តាំងពីស្ពានថ្មីថ្មីដល់ស្ពានថ្មចាស់ រេភ្នែករំពៃមើលថាតើគេគួររកម៉ៅ ឃើញដោយរបៀបណា...មែនហើយ! គេតប់ប្រមល់ក្នុងចិត្តណាស់ កាលបើគេមិនបានជួបម៉ៅសោះ ក្នុងចិត្តលួចនឹកព្រួយបារម្ភពីរូបនាងមិនឈប់ឈរ មិនដឹងថាអាការៈរបស់នាងបានប្រសើរឡើងវិញ ឬក៏យ៉ាងណាទៅហើយ...

បន្តិចមក គេក៏ជិះកង់ទៅឈប់នៅក្រោមដើមអំពិលមួយដើម នៅមាត់ស្ទឹង រួចគេចុះដើរតាមជំរេលច្រាំង ចុះសំដៅទៅកន្លែង ដែលគេធ្លាប់បាននាំម៉ៅបណ្តើតប្រទីបនាគ្រាមួយក្នុងអតីតកាល... ចៃដន្យ ពេលនេះគេមិនបានជួបនរណាទេ ក្រៅពីឃើញគុម្ពត្រែងយោលយោគតាមជំនោរខ្យល់រំភើយៗ លើឆ្នេរស្ទឹងតែប៉ុណ្ណោះ ។ គេនៅឈរសំកុកនៅទីនោះយ៉ាងយូរ... មិនដឹងថាពេលវេលាវិល ទៅមុខដល់ចំណុចណាទេ នរៈក៏ដើបដើរថយក្រោយទាញកង់ឡើង ជិះត្រលប់ទៅផ្ទះវិញ ។

លុះមកដល់មុខផ្ទះលោកដុកទ័រវិចិត្រ ដែលជាមិត្តភក្តិរបស់ លោកបុរាណ ស្រាប់តែគេនឹកភ្ញាក់ឡើងថា :

- មែនហើយ... បើយើងចូលសួរលោកពូវិចិត្រ ប្រហែលជាលោក ស្គាល់ផ្ទះម៉ៅដែរទេដឹង? ទាល់តែហ៊ានប្រថុយហើយទើបបាន ។

គេក៏បត់កង់ជិះចូលត្រៃទៅក្នុងរបងផ្ទះលោកគ្រូពេទ្យ ។ ស្ត្រី ចាស់ម្នាក់ចេញមកទទួល ។

- ជំរាបសួរយាយ! (ប៊ុរីលើកដៃសំពះ)

- អឺ! ហើយចុះចៅមករកពីណាដែរ?

- គឺ... រកលោកពូចិត្រ បាទ!

- អូហ៍! ថ្ងៃនោះលោកមិននៅទេ លោកមកវិញនៅព្រលប់ៗ ឯណោះ ។ ចំណែកអ្នកគ្រូណៃជាភរិយារបស់លោកវិញ មកផ្ទះពេល ថ្ងៃត្រង់ ។ ហើយចៅជានរណាដែរ?

CHANBOKEO.COM

ពេលលោកមកវិញ ចាំយាយ ជំរាបលោក! ប៉ុន្តែ មើលទៅមុខចៅដូចជាលោកបុរាណ វាគ្មិន
ឃោសនាការក្រុងដល់ហើយ... ជាកូនរបស់លោកបុរាណមែនទេ ?

- គឺ... ខ្ញុំឈ្មោះបុរី ជាកូនគាត់មែន ។
- អើុ! ម៉ោះៗ!ចូលលេងសិនមក៏ចៅ នៅអង្គុយលេងម៉ាស្របក់ សិនទៅ មិនយូរទេ
អ្នកគ្រូណៃនឹងមកដល់ផ្ទះវិញហើយ ។ អូហ៍... ឮថាចៅទើបមកពីប្រទេសជប៉ុនផងហ្អែស ?
- បាទ៉ៗ! មែនហើយ ។

ស្រាប់តែបុរីនឹកឆ្ងល់ក្នុងចិត្តភ្លាមថាហេតុអ្វីបានជាស្ត្រីចាស់នោះ
នឹងកើតថានាយជាកូនលោកបុរាណហើយទើបតែមកដល់ពីជប៉ុន ? គេសម្លឹងមើលគាត់ពីរបីដង
ក៏នៅតែរកនឹកមិនឃើញថា គេធ្លាប់ ស្គាល់គាត់ពីមុនមកទេ គឺច្បាស់ជាអត់សោះតែម្តង ។ ប៉ុន្តែ
កាល បើបានទទួលការស្វាគមន៍ពីម្ចាស់ផ្ទះទៅហើយ បុរីរកប្រកែកក៏មិន កើតដែរ ។
គេក៏ដើរដឹកកង់ទៅចតនៅក្រោមដើមស្វាយមុខផ្ទះ រួច ក៏ដើរតាមស្ត្រីចាស់នោះ ចូលទៅក្នុងផ្ទះ ។

- យាយស្គាល់លោកប៉ារបស់ខ្ញុំដែរឬ បាទ ?
- ថីក៏មិនស្គាល់ បើយាយលឿមខ្ញុំនេះ នៅបំរើលោកគ្រូពេទ្យ និង
ក្រុមគ្រួសាររបស់លោកនៅម្តុំនេះយូរមកហើយ ហើយធ្លាប់ឃើញ លោកបុរាណចុះឡើងផ្ទះនេះ
ញឹកញាប់ណាស់ ។

បុរីដើរចូលមកដល់ក្នុងផ្ទះ ឃើញការរៀបចំផ្ទះយ៉ាងប្រណិតគួរ អោយចាប់ភ្នែក ។ ភ្លាមនោះ
យាយលឿមមានប្រសាសន៍ ទៅ មាណពថា :

- ចៅនៅអង្គុយអានសៀវភៅលេងសិនចុះ យាយចូលចង្ក្រានដាំ
ចំអិនអាហារជូនលោកគ្រូពេទ្យនិងអ្នកគ្រូម៉ាឡែត ។
- បាទយាយ!

ថាហើយ យាយលឿមក៏ចេញទៅក្រោយបាត់ទៅ ។ បុរីក៏ដាក់
ខ្លួនចុះក្នុងកៅអីផ្តៅក្បាច់ដ៏ស្អាតមួយក្នុងផ្ទះ រួចទាញសៀវភៅមួយ យកមកអាន
ស្រាប់តែគេដាក់ភ្នែកចោលដោយចៃដន្យ ទៅបន្ទប់ មួយក្បែរនោះ ដែលមានទ្វារចំហ
ស្រាប់តែប្រទះឃើញមាណវីមួយ រូបកំពុងគេងដណ្តប់ភួយស្ទៀមស្ងាត់តែម្នាក់ឯងលើគ្រែ ។
គេភ្ញាក់ ព្រើតបើកភ្នែកធំៗដោយក្តីភ្ញាក់ផ្អើល រួចហើយក៏លួចឧទានខ្សិបៗ ក្នុងក្រអូមមាត់ថា :

- ម៉ៅ ?

CHIANBOKEO.COM

គេស្ទុះងើបឡើងដើរសំដៅទៅមាត់ទ្វារបន្ទប់យ៉ាងរហ័ស ដើម្បី ពិនិត្យអោយជាក់ច្បាស់ ។ មែនហើយ! នោះគឺជាស្រីម៉ៅពិតមែន គេមិនច្រឡំទេ! មាណពឈររកាំង សម្លឹងធិតាយ៉ាងភ្លឹក នឹកអរផង រន្ធត់ផងនៅក្នុងចិត្ត ត្បិតមិននឹកស្មានថា វាជាចៃដន្យដល់ម្លឹងទេ ដែលគេបានមកជួបនាងនៅទីនេះ ។ មើលចុះ! សូម្បីតែនាងមាន ទឹកមុខស្លេកស្លាំង ហើយទំនងស្រកស្រុតសាច់ឈាមខ្លះៗក៏ដោយ ក៏ភក្ត្ររបស់នាងនៅមានបង្កប់មន្តស្នេហ៍ ដ៏មានកិរិតឥទ្ធិពលយ៉ាង ចម្លែក ដណ្តប់បេះដូងរបស់ហ៊ុរី អោយរំជើបរំជួលរណ្តំគ្រាំគ្រេង... សម្លឹងគយគន់រូបនាងកាន់តែយូរ បេះដូងរបស់គេកាន់តែរណ្តំក្តុក ក្តាក់ៗ ខ្លាំងឡើងៗស្ទើរទប់ចិត្តមិនបាន ។

សោភ័ណទេវី

ល្អអើយសែនល្អគាប់ច័យា សោភ័ណសោភាម្ចាស់ដួងចិត្ត
ល្អគាប់កែវភ្នែកត្រេកនៃបនិត្យ ឃើញភ្លាមលង់ស្និទ្ធសោភ័ណផ្កា។
ស្រស់ល្អគ្មានពីរទេវីស្រី គន់គាប់ហឫទ័យពេញស្នេហា
បេះដូងកញ្ច្រោលយោលឱរា ស្រឡាញ់ម្ចាស់ផ្កាកុលាបស្រស់។
ល្អអើយល្អក្រៃចរណៃបង លង់ស្នេហ៍ទងវង់លង់សម្រស់
សោភ័ណសោភាសមទាំងអស់ បេះដូងបងស្មោះជូនស្រស់ម្នាក់។
ទទួលយកទេណោកន្និដ្ឋា សេចក្តីស្នេហាយ៉ាងស្មោះស្ម័គ្រ
បេះដូងកាត់ជូនកែវវរលក្ខណ៍ ជីវិតបងធ្លាក់ស្នេហ៍អមតៈអើយ!

បុរសឈរផ្អែកមាត់ទ្វារ លួចគយគន់ភក្ត្រានរីយ៉ាងស្ងៀមស្ងាត់ ដោយអារម្មណ៍រំភើបញាប់ញ័ររកស្មានមិនត្រូវ ហើយលួចគិតក្នុង ចិត្តតែម្នាក់ឯងទាំងក្តុកក្តួលថា :

- ម៉ៅ! នឹងទេ ថាបងសប្បាយចិត្តយ៉ាងណាដែលបងបានមកជួប ម៉ៅពេលនេះ ? បើកភ្នែកមក៏... បងចង់និយាយជាមួយម៉ៅណាស់ យើងបែកគ្នាយូរឆ្នាំហើយ... បងពិតជាមានអ្វីៗច្រើនដែលចង់ និយាយជាមួយអូន... បងពិតជាសោកស្តាយ ដែលថ្ងៃមុន បងបាន លេងសើចធ្ងន់ធ្ងរទៅលើម៉ៅជ្រុលជ្រួសបន្តិច រហូតធ្វើអោយអូន មិនស្រួលខ្លួនពីរបីថ្ងៃកន្លងមក... ម៉ៅ! បងសុំទោសណា៎! បង ពិតជាគ្មានចេតនាធ្វើបាបអូនពិតមែន...!

រំពេចនោះ ស្រាប់តែមាណវីប្រែខ្លួន ហើយបើកភ្នែកឡើង តែ

CHANBOKEO.COM

មិនបានចាប់ភ្លឹកទេ ថាមានបុរសលួចឈរមើលនាង ពីក្រៅមាត់ទ្វារ
ទៅ ។ ខណៈនោះ បុរីចង់ស្ទុះចូលក្នុងបន្ទប់របស់នាងដើម្បីថ្នាក់ថ្នម
ធិតាអោយសមនឹងទំហំចិត្តរបស់គេដែលអាណិតអាសូរ បារម្ភហើយ នឹករលឹកធិតាជាទីបំផុត...
ប៉ុន្តែគេខ្លាចចិត្តអ្នកផ្ទះ ព្រោះគេជាបុរស ហើយជាភ្ញៀវទៀត បើសិនធ្វើទៅ
ហាក់ដូចជាមិនសមរម្យទេ ។ គេឈរធ្វើត្រេះត្រុះៗនៅខាងក្រៅបន្ទប់ មិនដឹងថាត្រូវធ្វើយ៉ាងណា
គឺបានត្រឹមតែឈរមើលនាងពីចម្ងាយប៉ុណ្ណោះ ។ ធិតាក៏ប្រែខ្លួនរួច
ហើយប្រឹងដើបអង្គុយទាំងធីងធោង ។ ធនីយកដៃច្រត់គ្រែ ទំនង ហាក់ដូចជាចង់ដើបឈរ ។
បុរីឃើញហើយអត់ទ្រាំមិនបាន ក៏ស្រដី
ទៅកាន់ស្រីម៉ៅឡើងថា :
- ម៉ៅ !... អោយបងជួយទេ អូន ?

ឮសម្លេងបុរសយើងកាលណា នាងដើបមុខយ៉ាងរហ័សបែររក ម្ចាស់សម្លេងភ្លាម
ស្រាប់តែនាងបើកភ្នែកធំៗមូលក្រឡង់ដោយការ
ភ្ញាក់ផ្អើលចំពោះវត្តមានបុរសក្នុងផ្ទះរបស់នាង ។ ចៃដន្យ នាងមិន ស្រដីអ្វីតបនរៈទេ
ព្រោះមើលទៅហាក់ដូចជាកំពុងមានអាការៈល្ហិត ល្ហៃនៅឡើយ ។ ទ្រាំឈរមើលនឹងភ្នែកមិនបាន
បុរីក៏កាត់ចិត្ត ប្រថុយស្ទុះរឹងចូលទៅក្នុងបន្ទប់ ជួយទប់ខ្លួនធិតាភ្លាម :
- ចង់ចេញទៅក្រៅឬម៉ៅ ? ម៉ោះ ! បងនាំអូនទៅ !

គេនិយាយដោយសំដីស្រទន់ផ្អែមល្ហែម ខុសប្លែករាល់ដងដែល គេបានជួបនាង ។ មែនហើយ
បុរីបន្ទន់កិរិយាដាក់នារីយើងច្រើន ណាស់ ព្រោះគេកំពុងចាប់អារម្មណ៍លើស្រីម៉ៅ
កាន់តែខ្លាំងឡើងៗ រៀងរាល់ថ្ងៃ មិនថមថយកឺតណាទេ ។ មិនដឹងមាននិស្ស័យអ្វី ចេះ
តែនាំចិត្តគេ អោយគិតពីធិតាយើងមិនដាច់សោះ កាន់តែគិតដល់ ម៉ៅកាលណាវេលាណា
នរៈកាន់តែអាណិតអាសូរធិតាឡើង... រហូត ចង់ភ្លេចបាត់រលីង
នូវស្រមោលនារីដ៏ស្រស់ស្អាតឈ្មោះសម្ផស្ស ដែលគេធ្លាប់ឈ្លក់វង្វេងនឹងសោភ័ណរបស់នាង
នាគ្រាមួយនោះទៅ ហើយ ។

ស្រាប់តែម៉ៅរលាស់ដៃចេញ ហើយស្រដីតបវិញថា :
- ខ្ញុំអាចដើរដោយខ្លួនឯងបានហើយ... មិនអីទេ អរគុណ !

បុរីព្រលែងដៃនាង តែចិត្តនៅតែនឹកគិតបារម្ភដដែល :
- អោយបងជួយម៉ៅទៅណា៎... ក្រែងលោអូនដើរដួល ។ ម៉ៅចង់

CHANBOKEO.COM

ចេញទៅណាដែរ ?

តែម៉ៅបែរជាដើរតោងជញ្ជាំង ធ្វើហាក់ដូចជាមិនបានឮសំដី របស់បុរសយើង ។ បុរីក៏ដើរត្រិបៗចេញមកក្រៅតាមពីក្រោយ នាង ថែមទាំងលួចវាចាខ្សិបៗទៅកាន់និតាបន្តទៀតថា :

- ម៉ៅ ! អោយបងសុំទោសណា ចំពោះអ្វីៗកន្លងមក... ព្រោះអី បងប្រព្រឹត្តដោយខ្វះសតិ...! ម៉ៅអភ័យទោសអោយបងផង !

ឮប្រយោគនេះ ស្រីម៉ៅបែរមុខរកបុរី ហើយបើកភ្នែកសម្លឹង នរៈដោយក្រសែភ្នែកយ៉ាងមុត ព្រមទាំងស្រដីថា :

- យើងមិនមែនជាបងប្អូនឬជាសង្សារនឹងគ្នាទេ ហើយ....យើងក៏ មិនដែលជាមិត្តនឹងគ្នាម្តងណាដែរ... សុំមេត្តាកុំមកប្រើពាក្យបងអូន ជាមួយខ្ញុំឲ្យសោះ ។

បុរីញញឹមមិនឆ្លើយទេ ព្រោះគេមិនចង់អោយនាងមានអារម្មណ៍ ល្អក់កករ ។ ពេលនេះ បេះដូងរបស់គេបានដូរពណ៌ពីក្រហមទៅ ស្វាយ រួចទៅផ្កាឈូកអស់ទៅហើយ ។ គេលែងចង់ចាញ់ឈ្នះជា មួយនារីយើងអ្វីតទៅទៀតដែរ តាំងពីគេបានដឹងថា ម៉ៅគឺជាយុវតី ដ៏កំសត់មួយរូបនោះ ។ ថែមទៀត ការបែកពីគ្នាអស់រវាងជាយូរឆ្នាំ បានធ្វើអោយអ្នកទាំងពីរចំណាំគ្នាមិនបាន ម្ល៉េះហើយទើបមានការ ភន្ត័ច្រឡំខ្លះៗ ។ លុះឃើញអាការៈរបស់ម៉ៅដូចជានៅអស់កម្លាំង ល្វិតល្វៃហើយទ្រុឌទ្រោមជាងធម្មតា បុរីលែងមាត់កតវ៉ារករឿងអ្វី ដែរ ព្រោះនៅក្នុងជំរៅបេះដូងរបស់គេពេលនេះ មានសល់តែក្តី អាណិតអាសូរនិងក្តីនឹករលឹកដ៏ធំធេងចំពោះនាងតែម្យ៉ាងប៉ុណ្ណោះ ។ គេខំដើរជួយទប់ខ្លួននិតាពីក្រោយ ទោះបីជាឆវីនៅបញ្ចេញអាការៈ ទើសទាល់ចំពោះរូបនាយយ៉ាងណាក៏ដោយ ។

- លែងខ្ញុំទៅ ! ខ្ញុំចង់ចូលបន្ទប់ទឹក !

ឆវីស្រដីដាក់បុរសយើង ។ បុរីភ្ញាក់ក្រញាង នឹកអាមាសឡើង ក្តៅមុខក្តៅមាត់ រួចក៏ប្រញាប់លែងដៃភ្លាម ។

នៅក្នុងសាឡុងកណ្តាលផ្ទះ បុរីអង្គុយត្រដុសដៃរកនឹកថាគេត្រូវ ធ្វើយ៉ាងណា ដើម្បីបន្ទន់ចិត្តស្រីម៉ៅ ហើយរំសាយកំហឹងនិងការ ស្អប់ខ្ពើមរបស់នាងចំពោះរូបគេ ។ ពេលនោះ ម៉ៅបានចូលដំណេក សំងំយកកម្លាំងវិញហើយ

CHANBOKEO.COM

ដោយមិនរវល់នឹងគួរសមឆ្លើយឆ្លងនឹង រូបនាយដូចរាល់ដងទេ
មិននឹងថានាងអស់កម្លាំងចិត្តនឹងប្រយុទ្ធបុរី ឬក៏នាងកាន់តែស្អប់បុរីថែមឡើងនោះឡើយ ។

កំពុងតែអង្គុយគិតចាក់ស្មុគ្រម្នាក់ឯង ស្រាប់តែបុរីឃើញមាន រថយន្តមួយបរចូលមកដល់ ។ ស្ត្រីមួយរូបក្នុងវ័យប្រហែល៤០ឆ្នាំ ក្នុងសម្លៀកជាគ្រូបង្រៀន ដឹកដៃកូនប្រុសម្នាក់អាយុប្រហែល១០ឆ្នាំ ចុះពីរថយន្ត ។ លុះប្រទះវត្តមានរបស់នរៈយើងទីនោះ សុភាពស្ត្រី ក៏ញញឹមឡើងហើយមានប្រសាសន៍សួរនាយថា :

- ក្មួយប្រុសមានការអ្វីដែរ ? រកខ្ញុំឬក៏លោកដុកទ័រវិចិត្រស្វាមីខ្ញុំ ?

បុរីក្រោកឈរឡើងជំរាបសួរ ហើយក៏ឆ្លើយថា :

- បាទ៎! ខ្ញុំឈ្មោះបុរី ជាកូនលោកប៉ា បុរាណ...
- អូហ៍... ក្មួយជាកូនលោកបុរាណទេហ៍ ? អញ្ចឹងតើហ៍ ទើបមាន មុខមាត់ដូចជាប្រហែលៗ... នេ៎ះ! ក្មួយមកលេងពូមីងមែនទេ ?
- បាទ៎...! គឺមកលេងពូមីងផង ហើយមកសួរសុខទុក្ខស្រីម៉ៅផង

បុរីឆ្លើយទាំងរតាក់រតុប ។ អ្នកគ្រូឧទានឡើងថា :

- បុរីស្គាល់កូនម៉ៅដែហ៍ ? ក្រែងទើបតែមកដល់បាត់ដំបងពីរបីថ្ងៃ នេះតើហ៍... ?
- បាទ! គឺខ្ញុំនេះឆ្វេសប្រហែស មិនបានប្រយត្ន័ ក៏ធ្វើអោយម៉ៅ ទទួលគ្រោះថ្នាក់... រហូតដល់នាងត្រូវចូលមន្ទីរពេទ្យ...
- ពុទ្ធោ! អញ្ចឹងទេ ? ហើយក្មួយជួបម៉ៅហើយឬនៅ ?
- បាទ... គឺនាងកំពុងតែសំរាក ទើបក្មួយមិនហ៊ានរំខាន...

ការពិត សុភាពស្ត្រីនោះជាអ្នកគ្រូចរណៃ ភរិយាលោកគ្រូពេទ្យ វិចិត្រ ដែលជាឪពុកម្តាយចិញ្ចឹមរបស់ស្រីម៉ៅ ។ អ្នកគ្រូចរណៃនិង លោកគ្រូពេទ្យ មានបុត្របង្កើតបីនាក់ទៀត គឺ ចិត្រាជាកូនប្រុស អាយុ១៥ឆ្នាំ កូនស្រីឈ្មោះបារមី អាយុ១៣ឆ្នាំ និងកូនពៅឈ្មោះ វិសាល អាយុ១០ឆ្នាំ ។ លោកគ្រូពេទ្យធ្វើការនៅពេទ្យធំបាត់ដំបង ឯអ្នកគ្រូចរណៃធ្វើការជាអគ្គានុរក្សប្រចាំវិទ្យាល័យនារី នេតយ៉ង់ ។

កំពុងតែនិយាយគ្នា ចិត្រាក៏ឌុបបារមីចេញពីសាលាមកដល់ផ្ទះ ព្រមៗគ្នាដែរ ។ អ្នកគ្រូចរណៃក៏មានប្រសាសន៍ទៅបុរីថា :

CHANBOKEO.COM

- បើក្មួយមិនមានរវល់អ្វីទេ នៅបរិភោគបាយជុំគ្នាជាមួយមីងទី នេះហើយ ក្រែងលោស្រីម៉ៅគេភ្ញាក់ នោះក្មួយអាចសួរសុខទុក្ខគេ បានហើយ កុំអោយពិបាកទៅមកច្រើនដង ។

ប៊ុរីភ្ញាក់ព្រើត ចំពោះទឹកចិត្តដ៏ទូលំទូលាយរបស់អ្នកគ្រូ ដែលនិយាយចេញមកហាក់ដូចស្គាល់ជំរៅចិត្តនរៈយើងដល់បាតអញ្ចឹង ។ គេនឹកខ្មាស់ខ្លួនក្តៅមុខក្តៅមាត់ភាយៗតែម្នាក់ឯង នឹកគិតក្នុងចិត្ត :

- អ្នកមីងភ្នែកមុតមែនហ្ន៎...! ហេតុអ្វីបានជាលោកយល់ជំរៅចិត្ត យើងម្ល៉េះ កាលបើទើបនឹងជួបគ្នាសោះ ?

ការពិត អ្វីដែលប៊ុរីមិនចាប់ភ្លឹកនោះ គឺគេជាបុរស វ័យក៏ខុស គ្នាពីស្រីម៉ៅច្រើនឆ្នាំ បើជាពួកម៉ាកនឹងគ្នាក៏មិនសម បើជាអ្នកជិត ខាងស្គាល់គ្នាជិតដិតក៏មិនសម ព្រោះគេមិនដែលនៅស្រុកកំណើត យូរឆ្នាំហើយ ។ ហើយបើខ្លួនជាប្រុសកម្លោះចូលខ្លួនមករកសួរសុខ ទុក្ខកូនក្រមុំគេដល់ផ្ទះយ៉ាងនេះ តើអោយចាស់ៗ គិតយ៉ាងណាដែរ ទៅ ? ទោះជាយ៉ាងណា ពេលនេះ ប៊ុរីបានក្លាយជាកម្លោះមុខស្លឹក បន្តិចទៅហើយ ព្រោះហេតុការណ៍ពីរបីថ្ងៃកន្លងទៅនេះ បានផ្សាំង ចិត្តគេឲ្យអាណិតអាសូរស្រីម៉ៅ រហូតទន់ជ្រាយបេះដូងស្ទើររលីង ដូចតៅហ៊ូស្ងោរមិនខុសសោះ ។

ប៊ុរីឈ្លោកបរិភោគបាយរួមតុ ជាមួយក្រុមគ្រួសារអ្នកគ្រូចរណៃ សង្រួមឥរិយាបថស្ងៀមស្ងាត់ ក្នុងកិរិយាញញើតញញើមខ្លាចចិត្តអ្នក គ្រូ ប៉ុន្តែ ចំពោះអ្នកគ្រូនិងកូនចៅវិញ បែរជាមានការរួសរាយរាក់ ទាក់នឹងរូបនាយវិញយ៉ាងកក់ក្តៅ ហាក់ដូចជាញាតិមួយរូបរបស់គ្រួសារគេដែរ ។ មាណពនឹកចម្លែកចិត្តណាស់ កាលបើគេបានទទួល នូវភាពរមនាក្នុងគ្រួសាររបស់អ្នកគ្រូ ថ្វីបើថ្ងៃនោះ លោកគ្រូពេទ្យ វិចិត្រមិនបានវិលត្រលប់មកពិសារបាយផ្ទះរួមគ្នាក៏ដោយ ។

- ប៊ុរី រៀនចប់ហើយប្អូនក្មួយ ?

- បាទ អ្នកមីង! គឺចប់មកពីប្រទេសជប៉ុនថ្មីៗនេះ មិនទាន់មាន ការធ្វើនៅឡើយទេ...

បន្តិចមក អ្នកគ្រូក៏ណែនាំកូនៗទាំងបីអោយរាប់អានប៊ុរី :

- ពេលឃើញបងមកលេងយើង ទទួលបងអោយល្អផង ឮហើយ ឬនៅ កូនៗ ?

- បាទ! ចាស! ម៉ាក់! (អ្នកទាំងបីឆ្លើយព្រមគ្នា)

CHANBOKEO.COM

ប៊ុរីលួចមើលទៅកូនប្រុសស្រីរបស់អ្នកគ្រូចរណៃឃើញគេទាំងអស់មានកិរិយាសុភាពហើយស្លូតបូតគួរអោយស្រឡាញ់ ។ គេលួចលេបទឹកមាត់តែម្នាក់ឯងផ្សើមបំពង់ក លួចអាណិតខ្លួនឯងដែលមិនបានទទួលសេចក្តីកក់ក្តៅពីក្រុមគ្រួសារអស់រយៈជាយូរឆ្នាំ ។ ទោះបី ពេលនេះគេជាបុរសពេញវ័យទៅហើយក្តី ប៉ុន្តែបេះដូងរបស់គេនៅតែងង្ហោយទាមទាររកភាពកក់ក្តៅពីក្រុមគ្រួសាររបស់គេដដែល ជាដដែល ។ ថែមទាំងគេមិនដែលមានអារម្មណ៍ក្សេមក្សាន្តជា សមាជិកគ្រួសារដូចខណៈនេះឡើយ ។ ពិតមែនតែប៊ុរីមិនមែនជា សាច់ញាតិរបស់ក្រុមគ្រួសារអ្នកគ្រូ តែអ្នកគ្រូចរណៃនិយាយស្រដីទៅមកយ៉ាងរាក់ទាក់ចំពោះរូបនាយ មិនខុសពីកូនចៅម្នាក់របស់ អ្នកគ្រូឡើយ ។ គេរំភើបចិត្តចម្លែករក ស្មានមិនត្រូវដែលគេបានប្រទះគ្រួសារដែលមានសុភមង្គលមនោរម្យធំធេងយ៉ាងដូច្នេះ ។

ថ្ងៃនោះ ម៉ៅហាក់ដូចជាល្ងិតល្ងៃ មិនឃើញដើបនិយាយស្តីរក នរណាទេ ។ ដោយខ្លាចរំខានចិត្តម្ចាស់ផ្ទះផង ណាខ្លាចចិត្តនាងម៉ៅ ផងប៊ុរីក៏ដាច់ចិត្តលាអ្នកគ្រូចរណៃត្រលប់ទៅផ្ទះវិញ ។ មុននឹង ត្រលប់ទៅវិញ គេបានជំរាបអ្នកគ្រូថា :

- ក្មួយសូមអនុញ្ញាតមកលេងទីនេះញឹកញាប់បានទេ អ្នកមីង ?

អ្នកគ្រូលួចចោលកន្ទុយភ្នែកសម្លឹងទៅម៉ៅដែលកំពុងឆ្មេចគេង នៅក្នុងបន្ទប់រួចហើយក៏មានប្រសាសន៍ឆ្លើយទាំងញញឹមថា :

- មីងមិនថាអ្វីទេ បើក្មួយមកលេងរាប់អានគ្នាជាសាច់ញាតិសន្តាន យ៉ាងថ្លៃថ្នូរ ។ មីងគិតថាកូនៗរបស់មីងប្រហែលជាសប្បាយចិត្ត ណាស់ បើសិនជាគេមានបងប្រុសដ៏ល្អម្នាក់ជួយគ្រប់គ្រងផ្តល់ការ កក់ក្តៅ ជាពិសេសពេលមីងពូមិននៅ ។

អឺយ៉ា! អ្នកគ្រូស្រដីហាក់ដូចជារៀបព្រួល មិនឲ្យទឹករលកបក់ បោករំខានភាពស្ងប់សុខក្នុងគ្រួសាររបស់អ្នកគ្រូបានឡើយ ។ ប៊ុរី ឱនទទួលពាក្យអ្នកគ្រូហើយ ក៏សំពះលាចេញទៅ ។

នៅឯចង្រ្កានបាយ យាយលឿមនិងតាប្រេងអ្នកយាមផ្ទះអោយ អ្នកគ្រូចរណៃនៅអើតអើមដកកចំហមាត់ចង់ដឹងណាស់ថា តើសាច់រឿងថ្មីមួយក្នុងគេហដ្ឋានរបស់លោកដុកទ័រវិចិត្រ មានដំណើរ ផ្តើមយ៉ាងណាខ្លះ :

- នែ៎ តាប្រេង! យើងប្រហែលជិតបានស៊ីក្បាលជ្រូកនាងស្រីម៉ៅ

CHANBOKEO.COM

ហើយទេនឹង ? (យាយញញឹមបូញមាត់ផងយកដៃកេះតាប្រេងផង)

- ខ្ញុំក៏គិតដូចយាយវាឯងដែរណា៎...!

ការពិតទៅ ផ្ទះលោកគ្រូពេទ្យវិចិត្រមិនដែលមានភ្ញៀវដែលជា ប្រុសកម្លោះទេ មានតែចាស់ៗ ដែលជាមិត្តភក្ដិលោកពេទ្យ និង ភរិយារបស់លោកប៉ុណ្ណោះ ។ បុរីគឺជាភ្ញៀវកម្លោះទីមួយហើយដែល ដើរចូលភូមិដ្ឋាននេះ ដូច្នេះហើយទើបម្នាក់ៗហាក់ដូចជាចម្លែកចិត្ត គ្រប់ៗគ្នា ពេលគេប្រទះវត្តមានបុរីថ្ងៃនេះ ។

គ្រាន់តែបុរសដើរចេញផុតពីរបងផ្ទះមិនទាន់ផង បារមីស្ទុះទៅ ជិតស្រីម៉ៅ លួចកេះបងស្រីដែលកំពុងសម្ងំគេង :

- បងម៉ៅ! សង្សារបងទៅផ្ទះវិញហើយ ។

ស្រាប់តែ ម៉ៅបើកភ្នែកភ្លែតឡើង សួរថា :

- នរណាគេ សង្សាររបស់បង អូនបារមី ?

- គឺបុរសសង្ហាដែលមកលេងផ្ទះយើងអំបាញមិញនេះអី! ខ្ញុំក៏ធ្លាប់ ជួបគាត់នៅមន្ទីរពេទ្យម្ដងថ្ងៃមុនដែរ ។ មើលទៅគាត់មានកិរិយា ហាក់ដូច ជាចាប់អារម្មណ៍នឹងសុខទុក្ខរបស់បងឯងដល់ហើយ ។

ម៉ៅបូញមាត់អោយនាងតូចបារមីឈប់និយាយ :

- ស៊ូច! កុំមាត់ផ្ដេសផ្ដាសមើល៍! តិចគេហ្នឹងឮ បានចិត្តស្លាប់មិន ខានទេ ។ នែ៎! ការពិត គេមិនមែនជាសង្សារបងទេណា៎!

- អូហ៍! បើមិនមែន ហេតុអ្វីគាត់ហ៊ានមកដល់ផ្ទះតាមសួរសុខទុក្ខ បងយ៉ាងនេះ ? មើលហ្ន៎! គាត់ហ៊ានទាំងសុំម៉ាក់ដើម្បីមកលេងបង នៅពេលក្រោយទៀតផង...

- ម៉េចបានអូននឹង ?

- គឺខ្ញុំបានឮគាត់សុំម៉ាក់ផ្ទាល់ត្រចៀកណា៎! ហើយម៉ាក់វិញក៏ហាក់ ដូចជាមិនឮហាមឃាត់អ្វីដែរ ។

- ម៉ាក់គាត់ជាមនុស្សចិត្តទូលាយស្រាប់ទៅហើយ អូននឹងហើយតើ គាត់ច្បាស់ជាមិនថាអ្វីទេ បើគេសុំមកលេងពិតមែននោះ ។

- គឺមកពីគាត់យល់ថាគេជាសង្សារបងទេនឹង បានជាមិនឮម៉ាក់ ប្រកែកអីបន្តិចសោះ ។

ឃើញប្អូនលលេងនាងច្រើនពេក ម៉ៅក៏បិទភ្នែកសំងំវិញ ប៉ុន្តែ ក្នុងចិត្តហាក់ដូចរសាប់រសល់យ៉ាងណាមិនដឹង ។ បីបួនថ្ងៃកន្លងមក នេះ

CHANBOKEO.COM

សុខៗស្រាប់តែជីវិតរបស់នាងផ្លាស់ប្តូរខុសប្រក្រតី ដោយ មាននរៈចម្លែកម្នាក់តាមរករឿង រួចហើយក៏តាមយកចិត្ត មិនដឹងថា គេមានបំណងអ្វីចំពោះនាងទេ ។ ចំណែកនាងវិញ ថ្វីបើនាងហាក់ ដូចជាមានអារម្មណ៍ថា ស្អប់មុខគេឥតឧបមា តែពេលដែលគេទៅ បាត់ ម៉ៅបែរជាមានអារម្មណ៍រសាប់រសល់ នឹកគេយ៉ាងណាមិនដឹង ចង់ឲ្យតែគេត្រលប់មករកនាងវិញ ។ ប៉ុន្តែ លុះដល់នាងឃើញមុខ គេភ្លាម នាងបែរជាមានអារម្មណ៍ឃ្នាន់ខ្នាញ់ផង ខ្មាស់ផង ញាប់ញ័រ ក្នុងចិត្តយ៉ាងចម្លែកខុសធម្មតា ។ តើហេតុអ្វីទៅហ្ន៎ដែលធ្វើអោយ បេះដូងរបស់ឆវីមានអារម្មណ៍ប្រែប្រួលចម្លែកៗបែបនេះ ?

ooooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទី៦
## ផ្ការីកក្នុងដួងចិត្ត

ថ្ងៃនេះប៊ុរីបានឈៀងចូលមើលគិមណាងនៅមន្ទីរពេទ្យធំឃើញ រ៉ាវុធនៅមើលខុសត្រូវរូបនាងយ៉ាងដិតដល់ ហាក់បីដូចជាលលកញី ឈ្មោលមួយគូដែលស្រឡាញ់គ្នារកអ្វីប្រៀបបាន ។ គេក៏នឹកទៅដល់ សម្ផស្ស រួចហើយក៏នឹកទៅស្រីម៉ៅ... ពេលនេះ មិនដឹងថានារីមួយ ណាទេ ដែលរូបគេពេញចិត្តនឹងរើសជាគូពិតប្រាកដ ។ ការពិតទៅ ចិត្តរបស់នាយកំពុងតែជួបភាពរារែកបន្តិចហើយ...

រំពេចនោះ សម្ផស្សចូលមកដល់ :

- បងប៊ុរី! ស្លាប់ហើយ សម្ផស្សខំចាំនៅផ្ទះបងម៉ាព្រឹកមិនឃើញ បងសោះ ។ ម៉េចបានលួចមកសួរសុខទុក្ខគិមណាងមិនចាំអូនឥចឹង បង ? គួរអោយខឹងដល់ហើយ ។

ប៊ុរីញញឹម តបថា :

- ព្រោះបងមិនដឹងថា សម្ផស្សចង់មកមើលគិមណាងដែរនោះអី!

តែកិរិយារបស់ប៊ុរីពេលនេះ ហាក់ដូចជាពុំសូវស្និទ្ធស្នាលដូច សព្វដងដែលគេជួបនាងទេតែគេបែរធ្វើឫកហាក់ដូចជាមិត្តធម្មតាៗ ប៉ុណ្ណោះ ។ ឃើញនាយមានកិរិយាហាក់ដូចជាស្ងួតតោះតើយ នារី សោភាយើងក៏ពោលថា :

- បងប៊ុរី! សម្ផស្សមកលេងបងតែប៉ុន្មានថ្ងៃទេ នឹងទៅភ្នំពេញ វិញហើយ បងត្រូវតែយកចិត្តអូនបន្តិចណា៎ ប្រយត្ន័អូនអន់ចិត្ត!
- បាទ! (ប៊ុរីឆ្លើយ តែមិនព្រមងាកបែរមើលមុខនាងទេ មិនដឹង ថា មកពីហេតុអ្វី)

ឃើញនាយតោះតើយ សម្ផស្សជ្រួញចិញ្ចើម :

- ល្ងាចនេះ ប៉ាម៉ាក់បងហៅអូនទៅបរិភោគបាយជុំគ្នា... បងកុំគេច ខ្លួនពីផ្ទះដូចព្រឹកមិញណា៎... បាក់មុខសម្ផស្សអស់ហើយ ។

CHANBOKEO . COM

រ៉ាវុធឃើញបុរីសំដែងឥរិយាបថហាក់ដូចជាគ្មានព្រលឹងក្នុងខ្លួន គេក៏និយាយឡើងថា :
- បុរីអត់ឯងយុយឬអ្វី បានជាធ្វើមុខដូចមាន់ឈឺដូច្នេះ ?
- អូហ៍! អត់អីទេ... គ្រាន់តែមិនទាន់ស្វាងពីអារម្មណ៍រន្ធត់កាលពី ម្សិលមិញប៉ុននោះ ។
តែរ៉ាវុធនិងគិមណាងលួចមើលមុខគ្នា ហាក់ដូចជាចាប់អារម្មណ៍ ថា បុរីកំពុងស្រាយសម្ពន្ធ័របស់គេជាមួយសម្ផស្សព្រលែងចោល ហើយ ។ ប៉ុន្តែ សម្ផស្សមិនយល់ទេ ។ នាងនៅតែទទូច :
- បងបុរី... សន្យាអីជាមួយសម្ផស្សត្រូវចាំផងណា៎! កុំអោយអូន ខកចិត្តដោយការរង់ចាំទទួលពាក្យសន្យារបស់បងអោយសោះ ។
បុរីភ្ញាក់ព្រើតកាលបើឮប្រយោគនេះ ។ មែនហើយ កាលពីខែ មុនគេបានប្រគល់សន្យាមួយអោយទៅនាង ថាគេនឹងអោយប៉ាម៉ាក់ ចូលស្ដីសម្ផស្សជាគូជីវិត ។ តែពេលនេះ ស្ថានការណ៍ផ្លាស់ប្ដូរ... បុរីលែងមានចិត្តចង់ធ្វើតាមសន្យាហើយ ។ គេក្លាយជារវើកទៅ វិញដោយឯកឯង ។ ពេលនេះ គេលែងឃើញសម្ផស្សជានារី សំខាន់នៅក្នុងបេះដូងរបស់គេតែម្ដង ។ ហេតុអ្វីទៅហ្ន៎... បានជា ចិត្តរបស់គេប្រែប្រួលឆាប់រហ័សយ៉ាងនេះ ? តើការប្រែប្រួលរបស់ គេនឹងធ្វើបាបចិត្តសម្ផស្សយ៉ាងណា បើសិនជានាងបានដឹងថាបុរី កំពុងតែរំសាយចិត្តពីរូបនាង ? ទោះជាយ៉ាងណា បុរីមិនព្រមឲ្យ ចម្លើយនរណាងាយៗទេ កាលបើខ្លួនគេក៏មិនដឹងដែរថាគេត្រូវឆ្លើយ នឹងសម្ផស្សបែបណា កាលបើរូបគេកំពុងប្រែប្រួល...
បុរីឈ្លោកដើរចេញពីបន្ទប់ព្យាបាលរបស់គិមណាង ។
- ទៅណាហ្នឹងបងបុរី! សម្ផស្សចង់ទៅជាមួយបងដែរណា៎!
តែបុរីមិនឆ្លើយទេ ។ គេបែរជាធ្វើមិនឮហើយដើរចេញទៅ ។ កិរិយានេះ បានធ្វើអោយសម្ផស្សស្លោះទឹកមុខយ៉ាងចម្លែក ។ រីឯគិម ណាងនិងរ៉ាវុធក៏មើលមុខគ្នាហើយនៅស្ងៀមមិនហ៊ានស្រដីអ្វីអោយ ល្អក់កករអារម្មណ៍របស់មិត្តខ្លួនឡើយ ។ តើបុរីគេទៅណា ?...
ការពិត... បេះដូងរបស់គេកំពុងតែដង្ហោយរកស្រីម៉ៅ... កាល បើគេមិនបានឃើញមុខនាង បុរីមានអារម្មណ៍ធុញថប់ហើយអផ្សុក តប់ប្រមល់ក្នុងចិត្តណាស់ ។ គេទើបតែឃើញនាងកាលពីព្រឹកមិញ នេះតើហ៍ ។ ទើបតែបែកគ្នាមិនប៉ុន្មានម៉ោងផង គេក៏នឹកនាងសា ជាថ្មីទៀតហើយ ។ នរ:ហក់ត្រលប់ទៅរកនិតាម្ដងទៀត ។ ពេល នោះ

CHANBOKEO.COM

គ្មាននរណានៅផ្ទះទេក្រៅពីយាយលឿមនិងម៉ៅ ។ ថ្ងៃនេះ នារីមិនព្រមចេញពីបន្ទប់ទាល់តែសោះ គឺនៅតែសំងំគេងស្ងៀម ស្ងាត់មិនមាត់មិនកដូចកាលពីថ្ងៃដំបូងដែលគេបានជួបនាងឡើយ ។ ស្រស់ស្រីបានប្តូរចរិតរបស់នាងអោយរលីងស្រឡះតែម្តង ។ គេ នៅរេរាអន្ទះសា បែបន់សុំឲ្យធិតាចេញពីបន្ទប់ មកសន្ទនាជាមួយ រូបគេ ។ យូរម៉ោងកន្លងទៅហើយ... នាងនៅតែមិនព្រមចេញមុខ មកសោះ ។ ប៉ុន្តែ គួរអោយចម្លែកដែរ ថ្វីបើធិតាមិនព្រមចេញមុខមកស្រដីប្រស្រ័យអ្វីជាមួយនាយក៏ដោយ ក៏ប៉ុរីនៅតែមាន អារម្មណ៍ថាបេះដូងរបស់គេបានទទួលសេចក្តីសុខជាជាងពេល
ដែលគេនៅជាមួយសម្ផស្ស ។

លុះចាំយូរពេក មិនឃើញស្រីម៉ៅអើតមុខចេញមក ប៉ុរីមិន ហ៊ានរំខាន ក៏វិលត្រលប់ចេញទៅស្ងាត់ៗ មិនមាត់មិនកអ្វីដែរ ។

នៅមាត់ស្ទឹង កន្លែងអនុស្សាវរីយ៍ដែលគេធ្លាប់អូសប្រទីបរបស់ម៉ៅ បណ្តែតទឹកនៅថ្ងៃបុណ្យមួយកាលពី៨ឆ្នាំមុន ប៉ុរីឈរម្នាក់ឯងយ៉ាង ត្រមង់ត្រមោច...

- ម៉ៅ ! មិនដឹងថាអូនចំណាំរូបបងបានដែរឬយ៉ាងណា ? ខណៈ នេះ បងចង់និយាយជាមួយអូនណាស់ ដឹងទេ ? បងនឹកអូន... បងពិតជានឹកអូនមែន... ៨ឆ្នាំហើយដែលយើងបែកគ្នា... បងសូម ទោសដែលបងមើលអូនមិនស្គាល់ ហើយក៏ស្តាយក្រោយដែលបង បានប្រព្រឹត្តមិនគប្បីលើអូន... ម៉ៅ... ហេតុអីទៅហ្ន៎... ដែលយើង មិនអាចក្លាយជាមនុស្សជិតដិតស្និទ្ធស្នាលនឹងគ្នា ដូចគ្រាអតីតកាល បាន ? ហេតុអីអូនបិទផ្លូវមិនអោយបងចូលជិតរូបអូន ? ឬមួយក៏ បេះដូងរបស់អូនមានម្ចាស់សំរាប់ទទួលថ្នាក់ថ្នមរួចទៅហើយ ?

ក្រោមដំនោរត្រជាក់រំភើយៗ មាណពអង្គុយស្ងៀមស្ងាត់តែម្នាក់ ឯង សម្លឹងមើលខ្សែទឹកហូរឆ្ងាយទៅៗ ហាក់ដូចជាកំពុងខាបគួច យកព្រលឹងរបស់គេអោយហោះហើរចេញពីខ្លួន រួចហើយក៏អណ្តែត ទៅក្នុងភពស្នេហ៍ដ៏សែនវង្វេងមួយ..

ភពស្នេហ៍វង្វេង...

- បងស្នេហ៍រូបអូនគ្រប់វេលា ម្តេចស្រស់ពុំងាបែរព្រងើយ
ជួបភក្រ្តម្តងៗអូនតោះតើយ ឱមុំត្រាណត្រើយបងខុសអ្វី?
- ស្រលាញ់អូនណាស់ផ្លាស់មិនបាន ស្នេហ៍មុំកល្យាណពៅចរណៃ

CHANBOKEO.COM

បេះដូងបងមួយជូនស្រីថ្លៃ មិនប្រែទីទៃឱ្យស្រីខឹង ។

- ទទួលយកទេណា៎ពន្លក កុំអោយបងខកចាំដំណឹង

បងស្នេហ៍ឆោមឆ្លៅពៅព្រលឹង ជាតិហ្នឹងប្រាថ្នាសូមជាគូ...

នៅឯផ្ទះអ្នកគ្រូចរណៃវិញ...

លោកពេទ្យវិចិត្រទាញស្ទេតូស្កុបចេញពីត្រចៀក ហើយស្រដី ទៅកូនស្រីរបស់លោកថា :

- ម៉ៅ ! បេះដូងរបស់កូនដើរស្មើធម្មតាដូចប្រក្រតីវិញហើយ ។ ចូរ
កូនបរិភោគបាយហើយចូលគេងនៅម៉ោងទៀងទាត់ កុំអោយធ្វើការ ហួសកម្លាំងដូចមុនទៀត ។
ឈាមក្រហម(ហេមីគ្លោប៊ីន) របស់កូន កើនដល់កំរិតនហើយ
តែមិនទាន់គ្រប់គ្រាន់នឹងបណ្តោយអោយកូន ទៅធ្វើការនៅឡើយទេណា៎កូន ។
ប៉ានឹងអោយកូនសំរាកពីរថ្ងៃទៀត មុននឹងចូលធ្វើការវិញ ។ ដូច្នេះ ចូរកូនគេងអោយឆ្អែត
ហើយខំញុំា អាហារអោយគ្រប់គ្រាន់ហើយទៀងពេលវេលាផង ។

- ចា៎ស លោកប៉ា !

លោកវិចិត្រយកដៃអង្អែលក្បាលកូនស្រី ហើយមានប្រសាសន៍ បន្តថា :

- ប៉ានឹងថាកូនជាក្មេងល្អ តែងតែស្តាប់ពាក្យប៉ាម៉ាក់ប្រដៅរួចក៏ ឧស្សាហ៍ធ្វើការ ប៉ុន្តែ...
ទោះជាយ៉ាងណាក៏ដោយ ក៏កូនគួរថៃរក្សា សុខភាពខ្លួនកូនផង ។
ផ្ទះយើងមិនមានអ្វីខ្វះខាតរហូតដល់កូនត្រូវ ខំធ្វើការយប់ថ្ងៃនឿយហត់យ៉ាងនេះទេ ។
ឃើញកូនឈឺ... ប៉ាបារម្ភ
ណាស់... ថែខ្លួនបន្តិចណា៎កូនណា៎ ។

ម៉ៅនៅស្ងៀម មិនហ៊ានស្រដីតបអ្វីទៅឪពុកទេ ។ ការពិត នាងកំពុងប្រឹងធ្វើការសន្សំលុយ ផ្ញើទៅស្រុកជួយម្តាយនិងប្អូនៗ ។ ពិតមែនតែឪពុកនាងស្លាប់ទៅហើយ ប៉ុន្តែ ម្តាយនាងនិងប្អូនពីរ នាក់កំពុងតែមានសេចក្តីខ្វះខាតសព្វបែបយ៉ាង ។ រីឯប្អូនពីរនាក់ ទៀតក៏បាត់ខ្លួនទៅ តាំងពីឪពុករបស់នាងចាប់លក់អោយទៅបំរើគេ នៅខេត្តក្រៅតាំងពីយូរឆ្នាំកន្លងមកហើយ មិនដឹងថារស់ឬស្លាប់ ឬក៏យ៉ាងណាទេ ។ ការពិត ស្រីម៉ៅគោរពលោក វិចិត្រនិងអ្នកគ្រូ ចរណៃ ដែលជាឪពុកម្តាយធម៌របស់នាងណាស់ ។ ដោយព្រោះតែ លោកមានមេត្តាចំពោះនាងដ៏លើសលប់ ស្រស់ស្រីមិនសូវហ៊ាន រំខានចិត្តលោក អំពីរឿងនៅក្នុងក្រុមគ្រួសារកំណើតរបស់នាងទេ...

CHANBOKEO.COM

បន្តិចមក លោកគ្រូពេទ្យក៏ដើបចេញទៅ ។ ពេលប៉ នោះម៉ៅក៏ចេញមកក្រៅបរិភោគបាយជាមួយបងប្អូន ព្រមទាំងឪពុកម្តាយធម៌ ទាំងពីរ ស្រាប់តែត្រូវបារមីជាប្អូនខទានឡើងនៅចំពោះមុខលោក វិចិត្រនិងអ្នកគ្រូចរណៃ ថា :

- បងម៉ៅ...! នុ៎ះហ្ន៎! សង្សាររបស់បងមកសួរសុខទុក្ខបងទៀត ហើយ ។

ទាំងអស់គ្នាបែរមើលទៅតាមទិសដែលបារមីសម្លឹង ឃើញបុរី ជិះកង់មកដល់ពិតមែន ។ អ្នកគ្រូចរណៃនិងលោកវិចិត្រសម្លឹងមុខ គ្នា ហាក់ដូចជាយល់ស្ថានការណ៍ ។ បុរីដើរចូលមកដល់លើកដៃ ប្រណម្យឱនគោរពចាស់ៗម្ចាស់ផ្ទះ ។

- ម៉ោះ! ចូលរួមបរិភោគជាមួយគ្រួសារពូម្តងទៅ បុរី! នេះយើង ទើបនឹងចាប់ផ្តើមអាហារទេ (លោកគ្រូពេទ្យហៅ)

- បាទ! មិនអីទេ លោកពូ! ខ្ញុំនៅអង្គុយលេងខាងក្រៅនេះចុះ ។

ភ្លាមនោះ អ្នកគ្រូចរណៃក៏លួចមានប្រសាសន៍ ខ្សិបៗទៅកូន ស្រីថា :

- យាយលឿមប្រាប់ម៉ាក់ថា គេមកសួរសុខទុក្ខកូនពីរបីដងហើយ... បើមានអារម្មណ៍ល្អ កូនអាចចេញទៅទទួលគេបាន ។ តែបើកូន ទើសទាល់ ចាំម៉ាក់ទទួលគេជំនួសកូនក៏បានដែរណា៎!

ម៉ៅឈ្ងោកមុខនៅស្ងៀមមួយស្របក់ ក៏ពោលទៅម្តាយថា :

- កុំអោយរំខានម៉ាក់អី! ចាំកូនទទួលគេចុះ ចា៎ស!

បន្ទាប់ពីបរិភោគហើយ អ្នកគ្រូចរណៃដេញកូនចូលបន្ទប់អស់ ហើយអ្នកគ្រូក៏នាំស្វាមីឡើងទៅលើឡៅបាត់ទៅ ទុកពេលអោយស្រី ម៉ៅនិងបុរីមានឱកាសនិយាយគ្នា ទំនងដូចជាយល់ចិត្តកូនចៅ ។ ចៃដន្យ ពេលម៉ៅមកដល់ចំពោះមុខ បុរីបែរជាស្លាក់ក រកពាក្យអ្វី មកនិយាយជាមួយនាងមិនបានសោះ ។ គេសម្លឹងមុខធរី ទាំងឱភា រំជើបរំជួលញាប់ញ័រ ។ ចំណែកម៉ៅវិញក៏ដូចគ្នា ។ កាលមុន អ្នក ទាំងពីរជាគូសង្សឹក រកចាញ់រកឈ្នះ តែពេលនេះ គេបែរជាត្រូវ ច្រាបជាន់ទាំងពីរនាក់ ។ អ្នកទាំងពីរនៅអេះអុញដាក់គ្នាយ៉ាងយូរ ទំរាំបុរីដាច់ចិត្តស្រដីទៅធរី ដោយសំនៀងទន់ភ្លន់ថា :

- ម៉ៅ! អូនបាត់ខឹងនឹងបងហើយឬនៅ ?

ស្រីម៉ៅបើកភ្នែកមូលខ្លំ :

- ហេតុអ្វីខ្ញុំត្រូវបាត់ខឹងផង ?

- គឺបងបានមកសុំទោសអូនច្រើនដងហើយណា៎!

CHANBOKEO.COM

- តែខ្ញុំមិនទាន់បាត់ឈឺនៅឡើយទេ...
- អញ្ចឹង ម៉ៅអនុញ្ញាត្តអោយបងមកមើលថែទាំអូនទេ ដើម្បីអោយ អូនឆាប់បានជាសះស្បើយ ?
- ហើយចុះលោកប៉ានិងម៉ាក់ មានអនុញ្ញាត្តហើយឬនៅ ?
- បងថាសុំអនុញ្ញាត្តពីម៉ៅសិន ទើបបងទៅសុំគាត់ជាក្រោយ ។

ម៉ៅនៅស្ងៀមមិនឆ្លើយ ។ រំពេចនោះ បុរីដកផ្កាកុលាបមួយទងដែលគេលាក់នៅក្រោយខ្នងចេញមក ព្រមទាំងស្រដីថា :

- ពិតមែនតែផ្កាកុលាបមានបន្លា តែកុលាបមានសោភណ៍ស្រស់ ត្រកាលណាស់ សក្តិសមនឹងនារីមួយរូបដែលនៅអង្គុយនៅចំពោះ មុខបងម្នាក់នេះ ។ បងបានកាត់យកមកពីសួនច្បារផ្ទះបង ដើម្បី ផ្ញើម៉ៅតែម្តង សង្ឃឹមថាម៉ៅទទួលយកការសុំអភ័យទោសពីបង ។

បុរីស្រដីដោយអាការៈស្និទ្ធស្នាល ។ បន្ទាប់មកគេក៏ចាប់ដៃនារីអោយទទួលយកផ្កាមួយទងនោះ ។ ម៉ៅភ្ញាក់ក្រញាងកាលបើនរៈចាប់ដៃអោយនាងទទួលដូច្នេះ ។ មាណវីយកដៃកាន់ទងផ្កាទាំង ដួងចិត្តរន្ធត់ញាប់ញ័រ នឹងចង់ប្រកែកក៏មិនហ៊ាន នឹងថាទទួលយក ក៏មិនសម ។ ភ្លាមនោះ បុរីក៏ដាក់ខ្លួនអង្គុយចុះក្បែរស្រីម៉ៅ ហើយស្រដីបន្តទៅទៀតថា :

- អូនដឹងទេ ថា ម៉ៅជាផ្កាកុលាបមួយទងដ៏ស្រស់ស្អាតដែលកំពុង រីកក្នុងបេះដូងរបស់បង... ?

ពេលនោះ ម៉ៅរិតតែភ្ញាក់ផ្អើលឡើងថែមទៀតហើយ ។ មួយ ជីវិតនេះ នាងមិនដែលមានបុរសណាហ៊ានចូលមកជិតនិយាយស្តី រឿងស្នេហាត្រង់ៗដាក់នាងយ៉ាងនេះទេ ។ ធិតាញាប់ញ័រក្នុងចិត្ត រហូតរងាអស់ទាំងប្រាណស្វាយបបូរមាត់ល្អក់តែម្តង ។ កាលបើ ឃើញស្រីម៉ៅញ័រខ្លួនចំប្រប់ដូចកូនសត្វដូច្នេះ បុរីក៏ពោលឡើង :

- សន្សើមធ្លាក់ចុះ...ធ្វើអោយអូនរងាហើយ ! ម៉ោះ ! បងជូនអូន ត្រលប់ទៅក្នុងផ្ទះវិញ ។ ត្រូវខ្យល់ត្រជាក់ពេលយប់ក្រែងនាំឲ្យអូន លាប់ជំងឺសាជាថ្មី ។

បុរីក៏គ្រាហ៍ធិតាចូលទៅក្នុងផ្ទះវិញ តែមិនហ៊ានចូលបន្ទប់នាងទេ ។ គេនៅឈរសម្លឹងធិតាពីក្រៅបន្ទប់ទៅយ៉ាងយូរ ហើយបានប្រទះនឹងក្រសែភ្នែករបស់មាណវីជាច្រើនដង ដែលលបលួចសម្លឹងមកនាយពីក្នុងបន្ទប់មកវិញ ។ គេញញឹមដាក់នាងដោយដួងចិត្ត អាណិតអាសូរ ។

CHANBOKEO.COM

មួយសន្ទុះធំក្រោយមក ទើបគេដាច់ចិត្តលាស្រីម៉ៅត្រលប់ទៅ វិញ ។ នៅខាងលើរានហាល ចិត្រា បារមីនិង វិសាលកំពុងដកក ឈររហង់ មើលបុរីជិះកង់ចេញទៅ ។ បុរសយើងក៏លើកដៃលា ស្រាប់តែក្មេងទាំងអស់ក៏នាំគ្នាញញឹម ហើយលើកដៃបក់បោយតប មកមាណពវិញទាំងទឹកមុខសប្បាយរីករាយគ្មានរឱស្ថាន ។ តាមផ្លូវ បុរីមានអារម្មណ៍រីករាយស្រស់ថ្លាជាងសព្វកាលទាំងអស់ក្នុងជីវិត ។

បែរទៅស្រីម៉ៅវិញ ក៏ហាក់ដូចជាផ្លាស់ប្តូរឥរិយាបថចំពោះបុរី ច្រើនដែរ កាលបើឃើញមាណពបន្ទន់កិរិយាដាក់នាងយ៉ាងទន់ភ្លន់ ដូច្នោះ ។ នៅក្នុងបន្ទប់គេង ឆវីបានយកផ្កាកុលាបមកដាក់លើ ខ្នើយក្បែរខ្លួននាង រួចហើយគេងសម្លឹងផ្កាទាំងដួងចិត្តរំភើប...

កុលាបដួងចិត្ត

\- កុលាបពិតមែនតែបន្លា បែរក្លិនសោភាគួរនិត្យនៃប<br>
សោភ័ណរតកាលវិសាលទេព ចិន្តាភ្លើនក្រេបក្លិនភិសម័យ ។<br>
\- គន្ធាពិដោរផ្កាមួយទង ចងភ្ជាប់បេះដូងត្រើយនិស្ស័យ<br>
គូស្នេហ៍ពីរប្រាណក្សាន្តហឫទ័យ ជីវិតមានន័យស្រស់ដូចផ្កា....

*ooooooooooooooooo*

*ooooo*

*o*

CHANBOKEO.COM

# វគ្គទី៧
# ក្លិនស្នេហ៍សន្ធិយា

ស្អែកឡើង...

ម៉ៅមានកម្លាំងគ្រាន់បើហើយ ។ នាងក៏ដើបដើរចេញមកក្រៅ អង្គុយលេងក្នុងសួនច្បារមុខផ្ទះ ទំនងចាំផ្លូវនរណាម្នាក់ ។ ប៉ុន្តែ មួយថ្ងៃវាល់ល្ងាចរហូតថ្ងៃលិចទៅវិញហើយ គ្មាននរណាម្នាក់អើតមុខមកសួរសុខទុក្ខនាងដូចកាលពីម្សិលសោះ ។ លុះឃើញកិរិយា រសាប់រសល់របស់កូនស្រី អ្នកគ្រូចរណៃដើរមកជិត ហើយដាក់ ខ្លួនអង្គុយជិតធិតាហើយមានប្រសាសន៍សួរថា :

- ចាំផ្លូវគេ... មែនទេកូន ?

ម៉ៅភ្ញាក់ក្រញាងកាលបើឮម្ដាយសួរនាងត្រង់ៗ ហាក់យល់នូវបាតាលចិត្តរបស់ធិតាយ៉ាងច្បាស់ទៃង :

- ចាស! អត់ទេ ម៉ាក់! គ្រាន់តែកូនខានទៅធ្វើការយូរ ដូចជា អផ្សុកយ៉ាងណាមិននឹង ។

ឮសំដីនាងដូច្នោះ អ្នកគ្រូចរណៃញញឹម ព្រោះដឹងថាកូនកំពុង អៀននឹងម្ដាយមិនហ៊ាននិយាយស្ដីប្រាប់លោកវិញតាមត្រង់ ។ អ្នក គ្រូក៏ពោលសួរកូនស្រី បន្តទៀតថា :

- កូនស្គាល់ប៊ុរីយូរហើយហ្ន៎ស ? មើលទៅកិរិយារបស់គេ ហាក់ ដូចជាបារម្ភពីកូនក្រៃលែង ហើយគេក៏ហាក់ដូចជាសម្ដែងភាពស្និទ្ធ ស្នាលចំពោះកូនមិនតិចដែរ ។ តើមានរឿងអ្វីដែលម៉ាក់គួរដឹងដែរ ឬទេ ? កូននិយាយប្រាប់ម៉ាក់មកណ៎ា នឹងអាលឲ្យម្ដាយបានជួយ ស្រាយចំណងហ្នឹងក្នុងចិត្តរបស់កូនផង ។ ពេលឃើញកូនមានទឹកមុខក្រៀមក្រំដូច្នេះ ម៉ាក់ហាក់ដូចជាបារម្ភពីសុខទុក្ខផ្លូវចិត្តរបស់ កូនណាស់ ។

ម៉ៅឮដូច្នោះ ក៏លូកដៃស្រវាអោយចង្កេះម្ដាយ យកកេសាកើយ ស្មារបស់អ្នកគ្រូហើយស្រដីថា :

- ម៉ាក់! កូនទើបតែស្គាល់គេដោយចៃដន្យពីរបីថ្ងៃនេះតើហ៍... មិនដែលបានរាក់ទាក់ឬបបួលគេមកផ្ទះយើងម្ដងណាឡើយ ។ ការពិត

CHANBOKEO.COM

គេមកទីនេះដោយចិត្តរបស់គេប៉ុណ្ណោះ... ពេលនេះ កូនក៏មិនដឹង ដែរ
ថាគេមានបំណងយ៉ាងណាទេ ក្នុងការដែលគេទៅមកផ្ទះយើង ព្រឹកល្ងាចយ៉ាងនេះ ។
- អឺហ៍...ចុះម៉ាក់មានបន្ទោសកូនឯណា ? ការពិត គេមកសួរសុខ ទុក្ខកូនដល់ផ្ទះដូច្នេះនោះ
ប្រសើរហើយ ព្រោះគេកំពុងសម្តែងនូវ ភាពស្មោះត្រង់ចំពោះកូន តាមរយៈក្រសែភ្នែកចាស់ទុំ
ឃើញថាគេ ផ្តល់កត្តិយសអោយកូនពេញលក្ខណៈបំផុត ។ បើគេមានបំណងមិន ល្អលើកូននោះ
គេច្បាស់មិនហ៊ានចេញមុខមកអោយមនុស្សចាស់ ស្គាល់មុខ ស្គាល់មារយាទរបស់គេទេ ។
ម្យ៉ាងទៀត ម៉ាក់គិតថា គេមិនសម្លឹងរូបកូនត្រឹមតែជាញាតិជិតខាងទេ គឺប្រហែលជាឆ្ងាយ
ជាងហ្នឹងផងក៏មិនដឹង... ទើបគេហ៊ានប្រថុយចូលខ្លួនមកដល់ផ្ទះ របស់យើង
ឲ្យម៉ាក់និងប៉ាពិចារណារូបគេយ៉ាងដូច្នេះ...

ម៉ៅឈ្លោកមុខគិតមួយស្របក់ កាលបើបានឮសំដីម្តាយនិយាយ ប្រាប់នាងដូច្នោះ ។ បន្តិចមក
នាងក៏សួរទៅម្តាយវិញថា :

- ម៉ាក់! តើកូនខុសដែរឬទេ ដែលគេមកផ្ទះយើងញឹកញាប់ ? រួច
ហើយ តើកូនត្រូវប្រព្រឹត្តអាកប្បកិរិយាបែបណាបើគេមកសួរសុខ ទុក្ខកូន ?
ឬមួយក៏កូនត្រូវគេចមុខគេ មិនគួរជួបគេតទៅទៀត
ព្រោះយើងជាមនុស្សមានវ័យនិងភេទខុសគ្នា ខ្លាចញាតិគេនាំគ្នា សើចចំអកពេញស្រុកពេញភូមិ ?

អ្នកគ្រូចរណៃញញឹម ហើយឆ្លើយដាក់កូនថា :

- ការពិត មិនបាច់ធ្វើបាប ដាក់យុំខ្លួនឯងអីដល់ម្លឹងទេកូន! ភ្នែក ញាតិដែលចាំតែរិះគន់នោះ
មានយកមិនអស់ទេ តែអ្នកដែលចេះ ឈឺឆ្អាល ស្គាល់សុខទុក្ខអ្នកដទៃនោះទេតើ
ដែលកម្រកបាន ។ ពេលនេះ ល្មមដល់ពេលហើយដែលកូនរៀនឈរលើជំហរខ្លួនឯង
ដោយយកសីលធម៌និងគុណធម៌ជាបណ្តូល លើកស្ទួយជីវិតកូនឲ្យ ខ្ពង់ខ្ពស់ថ្លៃថ្នូរហើយជោគជ័យ ។
បើសិនបុរសណាម្នាក់ឃើញតម្លៃ របស់កូន ដោយមិនយករូបសម្បត្តិជាគោល
តែលើកយកគុណធម៌ និងទឹកចិត្តជាកត្តាផ្តល់តម្លៃដល់កូនស្រីរបស់ម្តាយ គេនោះគឺជាគូ
ជីវិតដ៏ល្អប្រពៃម្នាក់ដែលកូនគួរជ្រើសរើសយកគេហើយ ។ ម្យ៉ាង ទៀត
កុំបិទផ្លូវជីវិតរបស់ខ្លួនអោយចង្អៀតចង្អល់ធ្វើអ្វី ។ បើគេមក រាប់អានយើងដោយល្អ
ដោយកិត្តិយសថ្លៃថ្នូរតាមរយៈចាស់ទុំដូច្នេះ កូនក៏គួរសម្លឹងគេលេងៗទៅ ក្រែងគេជាមនុស្សល្អ
អាចពឹងផ្អែក ជីវិតនឹងគ្នាទៅវិញទៅមកបានទៅថ្ងៃមុខ ។ បើសិនជាជោគជតា
ព្រេងនិស្ស័យបែរជាមិនមានអំណោយផលវិញ ក៏កូននៅអាចរាប់គ្នា ជាញាតិជិតខាងបានដែរ

ពោលគឺ យើងមានញាតិបន្ថែមម្នាក់ទៀត យ៉ាងកក់ក្ដៅ ប្រសើរជាងគិតអគតិចំពោះគេ ហើយបិទទ្វារមិនរាប់ អានគ្នាទៅវិញទៅមក ។ ពេលនោះ យើងអាចបាត់បង់ មិត្តម្នាក់ ញាតិសន្ដានជិតខាងម្នាក់ ឬគូស្រករដ៏ល្អម្នាក់ យ៉ាងអាសារបង់ ។

អ្នកគ្រូយកដៃជ្រោងសក់កូនស្រី ដោយដួងចិត្តអាណិតមេត្តា រួចមានប្រសាសន៍បន្តថា :

- ម៉ាក់បានចិញ្ចឹមកូនមកយ៉ាងល្អ ហើយក៏មានជំនឿយ៉ាងមុតមាំលើ កូនស្រីរបស់ម៉ាក់ជានិច្ចថាកូនជាមនុស្សមានគំនិតចាស់ទុំ មានហេតុ ផល ចេះគិតគូរវែងឆ្ងាយ ល្មមអាចទទួលខុសត្រូវជីវិតរបស់ខ្លួន បាន ។ ម៉ាក់នឹងប៉ាវង់ចាំជួយលើកទឹកចិត្តកូន ផ្ដល់កម្លាំងចិត្តឲ្យ កូនជានិច្ច មិនថាពេលណាវេលាណាទេ ។ ដូច្នេះ ល្មមដល់ពេល ហើយ ដែលកូនត្រូវចាប់ផ្ដើមដកស្រង់ការពិសោធន៍ក្នុងជីវិតដោយ ពឹងលើជំហររបស់ខ្លួនឯង ។ រីឯប៉ាម៉ាក់វិញ ក៏នៅពីក្រោយ រង់ចាំ ជួយជ្រោមជ្រែងកូនជានិច្ច មានការអ្វី ចូរកូនមកពិគ្រោះនឹងម៉ាក់ប៉ា កុំឲ្យខ្លាចចិត្តអោយសោះ ដើម្បីអោយម៉ាក់ប៉ាមានឱកាសផ្ដល់ការ ណែនាំដល់កូនដើម្បីចៀសវាងការភ្លាំងភ្លាត់ក្នុងជីវិត.. កុំភ្លេចណា៎! កិត្តិយសស្ត្រី ស្ថិតនៅលើការប្រព្រឹត្តយ៉ាងប្រពៃរបស់កូន មិនមែន ស្ថិតនៅលើពាក្យញាតិដែលរង់ចាំតែរិះគន់ទិទៀននោះទេ ។

- ប៉ុន្តែ... កូននិងគេម្នាក់នោះ ពិតជាមិនមានចំណងអ្វីនឹងគ្នាមែន ណា៎ម៉ាក់! កូនគិតថាគេគ្រាន់តែមកសួរសុខទុក្ខកូនព្រោះគេដឹងខ្លួន ខុស ដែលគេធ្វើអោយកូនត្រូវឈឺខ្លួនគេងពេទ្យអស់ជាច្រើនថ្ងៃ ។

- អឺៗ! បើគេមករាប់រកយើងហើយ ទទួលគេខ្លះទៅ កុំទាន់អាល គិតអាក្រក់ពីគេអី ក្រែងលោគេជាមនុស្សល្អ នោះយើងនឹងបាន ទទួលញាតិម្នាក់បន្ថែមទៀត ដូច្នេះមានទៅខាតអ្វី? តែបើកូនចាប់ ភ្លឹកថា គេមានបំណងមិនល្អលើរូបកូននោះ ប្រញាប់មកពិគ្រោះនឹង ម៉ាក់ប៉ា ឮហើយនៅ?

- ចា៎សម៉ាក់!

អ្នកគ្រូចរចៃនិយាយស្ដីជាមួយកូន ដោយពាក្យពេចន៍ទន់ភ្លន់ ប្រកបដោយគតិអប់រំនិងការលើកកម្លាំងចិត្ត មិនអោយកូនស្រក ស្រុតទឹកចិត្តឬចង្អៀតចង្អល់ក្នុងចិត្តឡើយ ។ ថ្វីបើពេលនេះស្រីម៉ៅ បានប្រកែកនឹងម្ដាយ ថានាងមិនមានទំនាក់ទំនងអ្វីនឹងបុរីក៏ដោយ ក៏អ្នកគ្រូនៅតែមិនអស់ចិត្តដដែល

CHANBOKEO.COM

ចំពោះចំណងសម្ពន្ធ័ថ្មីដែលប៊ុរី បានផ្តល់ចំពោះស្រីម៉ៅ តាមរយៈអ្នកគ្រូនិងលោកដុកទ័រវិចិត្រជាស្វាមី ។ បើថានឹងឃាត់ក៏មិនសម ព្រោះប៊ុរីក៏មិនទាន់បានបញ្ចេញ កិរិយាអ្វីចំពោះនាងម៉ៅ ដែលគួរអោយទើសភ្នែកចាស់នៅឡើយ... ប៉ុន្តែ បើអោយអ្នកគ្រូចំហដៃពេកក៏មិនបានដែរ ព្រោះក្មេងអាច យល់ខុសថាអ្នកគ្រូធូររលុង មិនយកចិត្តទុកដាក់នឹងជីវិតនាងម៉ៅ ដែលជាកូនស្រីចិញ្ចឹម នោះបុរសអាចឆ្លៀតឱកាសធ្វើមិនល្អចំពោះ នាង ។ ការពិត អ្នកគ្រូចរណៃនិងលោកដុកទ័រវិចិត្រជាមនុស្ស សម័យថ្មី មិនសូវជាមានចិត្តចង្អៀតចង្អល់ប៉ុន្មានទេ ចំពោះរឿង ទំនាក់ទំនងរបស់កូនចៅជាមួយមិត្ត ។ លោកចូលចិត្តអប់រំកូនតាម កាលៈទេសៈជាជាង ពោលគឺលោកចំហឱកាសអោយកូនចូលមក ពិគ្រោះរឿងផ្សេងៗក្នុងជីវិត ។ ដូច្នេះហើយទើបយើងឃើញស្រី ម៉ៅមានកិរិយានឹងធឹង មានសណ្តាប់ធ្នាប់ ហើយមានជំនឿលើខ្លួនឯងយ៉ាងមុតមាំជាងក្មេងស្រីធម្មតា វ័យស្រករៗ នាង ។

បន្តិចមក អ្នកគ្រូចរណៃក៏វិលទៅបំរើលោកដុកទ័រវិចិត្រឯក្នុង ផ្ទះវិញទៅ ទុកឲ្យស្រីម៉ៅអង្គុយដកដង្ហើមយកខ្យល់អាកាសនៅឆ្លា សួនខាងមុខផ្ទះ បន្ធូរភាពហ្មួហ្មងក្នុងចិត្ត ដែលនាងបានឈឺគេង គ្រែអស់ជាច្រើនថ្ងៃ ។ ពេលនោះថ្ងៃរសៀលគងព្រៃហើយ ។ ធិតានឹកអផ្សុកក្នុងចិត្តយ៉ាងណាមិនដឹង ក៏ទាញក្រមាអំបោះស្តើងមួយមក ទទូរ ហើយបក់ដៃហៅប្អូនប្រុសពៅរបស់នាងអោយមកជិត :

- វិសាល!

- បាទ បង!

- បងចេញទៅលេងមាត់ស្ទឹងម៉ាភ្លែត ឲ្យស្វាងអារម្មណ៍ ។ បន្តិច ទៀត បងមកវិញហើយ ។ អូនជំរាបម៉ាក់ប៉ាផងណា៎!

- បាទ!

វិសាលក៏រត់ចូលទៅក្នុងផ្ទះវិញទៅ ។ ឯស្រីម៉ៅក៏ដើបឡើង ដើរចេញទៅក្រៅឆ្ពោះផ្លូវសំដៅមាត់ស្ទឹងសង្កែ ។ ថ្វីបើនាងទើបនឹង ដើបពីឈឺមិនទាន់មានកម្លាំងកំហែងគ្រប់គ្រាន់ តែថ្ងៃនេះ ម៉ៅមាន អារម្មណ៍ថា ក្នុងខ្លួនរបស់នាងបានធូរស្រាលច្រើនណាស់ ។ ចៃដន្យ ក្នុងចិត្តរបស់នាងបែរជាទទួលការតប់ប្រមល់ជាងមុនទៅវិញ ។

មកដល់មាត់ស្ទឹង ធិតាក៏ដាក់ខ្លួនអង្គុយចុះលើដង្គត់ឈើមួយ ភ្នែកសម្លឹងទៅខ្សែទឹកដែលកំពុងហូរខ្ជួលខ្ជាញ់ ។ នៅឯនាយ ស្ទូរ កាំភ្លើងធំលាន់គ្រឹមៗ

CHANBOKEO.COM

ពីទិសខាងលិច... បានអង្រួនបេះដូងមាណវី ឲ្យរីងរិតតែរំដើបរំជួល
នឹកទៅដល់ម្ដាយនិងប្អូនបង្កើតរបស់នាង ដែលរស់នៅឯស្រុកព្រះនេត្រព្រះ
មិនដឹងថាគេមានជីវិតយ៉ាងណា ហើយទេ ។
ឆវីមិនដែលបានវិលទៅស្រុកកំណើតវិញពីរបីឆ្នាំហើយ
គឺតាំងពីស្រុកទេសកើតវឹកវរសង្គ្រាមជាមួយខ្មែរក្រហមមក ។ ធិតា
នឹកគិតទៅដល់ជីវិតរបស់នាង តាំងពីតូចក្រូចឆ្មារ រហូតមកដល់ បច្ចុប្បន្ន...
នឹកទៅដល់គ្រាមួយដែលនាងបានជួបយុវជនម្នាក់កាល ពី៨ឆ្នាំមុននៅទីនេះ...
ហើយក៏បានសុំគ្នាធ្វើបងប្អូន ។ ចៃដន្យ គេមិនដែលវិលត្រលប់មករកនាង
ដូចសំដីរបស់គេដែលបានសន្យា នាងឡើយតាំងពីថ្ងៃគេបែកពីនាងទៅនាគ្រានោះមក ។ ធិតាហាក់
ដូចជានឹកខ្វាញ់នឹងយុវជនម្នាក់នោះមិនបាត់សោះ ដែលគេមិនបាន រក្សាសន្យា... បន្តិចមក
នាងក៏នឹកភ្នកទៅដល់ប៊ុរី... មិនដឹងជា
និស្ស័យអ្វីទេដែលនាំអោយនាងមានជីវិតជំពាក់វ៉ាក់វិនជាមួយបុរស នេះ
តាំងពីថ្ងៃជួបគ្នាដំបូងមក ។ នឹកដល់មាណពនេះកាលណា
នាងកាន់តែឃ្នាន់ខ្នាញ់ក្នុងចិត្តចំពោះគេខ្លាំងឡើងៗរកស្រដីមិនត្រូវ ទាល់តែសោះ ។

ខ្នាញ់

- ហេតុអ្វីអូនខ្នាញ់នឹងបងម្ល៉េះ?    ខ្នាញ់ស្ទើរតែប្រេះបែកឱរា
  ជួបមុខនឹកខ្នាញ់បែកនឹកគ្នា    ចិត្តស្រីពាំងាសែនវង្វេង ។
- ហេតុអ្វីអូនខ្នាញ់ចង់ផ្ទាញ់បង    តែអាណិតផងលួចសង្រែង
  ជួបខ្នាញ់បែកនឹកគិតកើយគេង    ខ្នាញ់ខ្ទក់វង្វេងស្វែងចម្លើយ ។
- ខ្នាញ់ណាស់នឹកណាស់ប្រាសមិនបាន    ខ្នាញ់នឹកភុំផានឥតល្ហែល្ហើយ
  ខ្នាញ់នឹកតែបងគ្មានពេលស្បើយ    ឯណាចម្លើយប្រាប់មកពៅ ។
- ខ្នាញ់ៗៗ...ស្រលាញ់ផង    ខ្នាញ់ខ្ទក់ព្រោះបងឃ្លាតឆ្ងាយទៅ
  ខ្នាញ់បងមិនយល់ចិត្តឆោមឆ្នៅ    ខ្នាញ់ស្រឡាញ់ពៅខ្ទក់ក្នុងចិត្ត...

ស្បែសន្និយា ក៏ចាប់លាតសន្ធឹងគ្របដណ្ដប់ផ្ទៃពសុធាទាំងមូល
អោយកាន់តែងងឹតបន្តិចម្ដងៗ...

ធិតាក៏ដើបឈរឡើង បែរក្រោយបំរុងថានឹងឡើងច្រាំងត្រឡប់ ទៅផ្ទះវិញហើយ
ស្រាប់តែធិតាជំពប់ខ្លួនជល់ទ្រូងបុរសម្នាក់ភិប ។ ធិតាភ្ញាក់ក្រញាង ដើយឡើងមើលមុខ

CHANBOKFO.COM

ក៏ប្រទះនឹងបុរីកំពុងឈរ ក្រពាត់ដៃលួចគយគន់រូបនាងពីក្រោយយ៉ាងស្ងៀមស្ងាត់ តាំងពីកាលណាមក ក៏មិនដឹង ។

- ម៉ៅ! (បុរីហៅឆវីខ្សិបៗ)

តែម៉ៅបែរឈ្ងោកមុខគេចចេញធ្វើមិនឮ ។ ភ្លាមនោះ បុរីលូកចាប់ដៃឆវីទាញបង្អាក់អោយនាងឈប់ កុំអោយដើរទៅមុខទៀត ។ ចៃដន្យ ឆិតាទើបតែជាពីឈើនៅល្អិតល្ហៃអស់កម្លាំងនៅឡើយ ។ នាងទប់ខ្លួនមិនជាប់ ក៏ផ្ងាកក្រោយរកដួល ។ បុរីឃើញដូច្នោះក៏ស្ទុះ រឹងលូកដៃទៅត្រកងកាយនាងពីក្រោយយ៉ាងរហ័ស ចូលទៅក្នុងរង្វង់ដៃរបស់គេពេញជំហរតែម្តង ។

- នែ៎! លេងអីផ្តេសផ្តាសយ៉ាងនេះ ? ដឹងទេថាទីនេះជាកន្លែង សាធារណៈ ?

ម៉ៅគំហកតិចៗ ហើយប្រឹងរើបម្រះ ដើបគេចពីរង្វង់ដៃបុរី ។ មាណពញញឹមហើយក៏លើកខ្លួននាងបញ្ឈរឡើង :

- សូមទោស! បងគ្មានចេតនាទេណា៎ម៉ៅ!

ស្រីម៉ៅដើបមុខឡើងសម្លឹងបុរីយ៉ាងមុត :

- យើងមិនមែនជាសាច់ញាតិនឹងគ្នាទេ សូមមេត្តាកុំប្រើពាក្យស្និទ្ធ ស្នាលនឹងខ្ញុំបែបដូច្នេះ ។ ខ្ញុំមិនអាចទទួលបានទេ!

- បើម៉ៅទទួលបងជាសាច់ញាតិមិនបាន... អញ្ចឹង ទទួលបងជាគូ សង្សារវិញ យ៉ាងម៉េចដែរ ? នោះយើងនឹងអាលបានស្និទ្ធស្នាលគ្នា ជាងមុនផង...

- តែផ្តាស! នរណាគេចង់ធ្វើសង្សារខ្លួន ?

បុរីសើចដាក់នារីបញ្ចេញជើងធ្មេញយ៉ាងស្អាត :

- នរណាក៏ដោយ ដែលប៉ិនដឹកងរដាក់បង ដើម្បីអោយបងរត់តាម អង្វរនោះអី ។

- ឆ្កួត! អ្នកមមើមមាយខុសកន្លែងហើយ! ទៅរកសង្សារនៅ កន្លែងផ្សេងទៅ ។ ទីនេះគ្មានអ្នកទំនេរ សំរាប់ជួយស្រោចស្រង់ យិតយោងបេះដូងអ្នកទេ ។

បុរីភ្ញាក់ព្រើត ហើយឧទានឡើងថា:

- ពុទ្ធោ! អូនមានម្ចាស់ចិត្តហើយឬ ម៉ៅ ?

ស្រីម៉ៅសម្លក់បុរី :

- យី! ចេះមកសួរអីផ្តេសផ្តាសអញ្ចឹង... ឆ្កួតទេដឹង ?

CHIANBOKEO.COM

និតាស្ទុះដើរចេញយ៉ាងរហ័ស ។ ចម្លែកណាស់ មុននេះបន្តិច នាងអង្គុយរសាប់រសល់នឹកចង់ជួបមុខគេណាស់ ប៉ុន្តែ លុះដល់នាង ជួបមុខគេហើយ តែបែរជាចង់តែរត់គេចពីរូបគេចេញទៅវិញ ។ ហេតុអ្វីទៅហ្ន៎ ? និតាពិតជាមិនយល់ចិត្តខ្លួនឯងឡើយ ។ ឃើញ ម៉ៅនៅតែមានះដើរចេញទៅ បុរីស្ទុះរឹងទៅស្កាត់ពីមុខមាណវីរួច លើកដៃរាំងឡើងដើម្បីខាំងផ្លូវ :

- បងមិនឲ្យម៉ៅទៅទេ ទាល់តែយើងនិយាយគ្នាសិន ។

ម៉ៅកៀសដៃបុរីចេញ តែនាយនៅខឹមិនព្រមដក ហើយបែរជា ស្រវាអោបនាងផ្ទាប់ដើមទ្រូងរបស់គេទៅវិញយ៉ាងណែន ។

- នែ៎! លែងមើស៍! ធ្វើអ្វីឆ្កួតៗបែបនេះ ? (ម៉ៅវាចាទាំងខ្នាញ់)

តែមាណពមិនលែងទេ បែរជាអោបនាងពេញរង្វង់ដៃកាន់តែ ណែនឡើង ។ ថ្វីបើគេមិនហ៊ានរិតខ្លួននាងយ៉ាងតឹងដូចកាលលើក មុនក៏ដោយ តែក៏តឹងល្មមមិនអោយម៉ៅរត់គេចរួចងាយៗឡើយ ។

- ឈប់គេចពីបងទៅណា៎ម៉ៅ! បងមានរឿងច្រើនណាស់ដែល បងចង់និយាយគ្នាជាមួយអូន ។

ម៉ៅភិតភ័យញ័រខ្លួនចំប្រប់ កាលបើត្រូវបុរសអោបរិតខ្លួននាង យ៉ាងជិតស្និទ្ធដូច្នោះ ។ ភ្លាមនោះ នាងខឹងណាស់ដែលគេមកប៉ះ ពាល់រូបកាយនាងដោយមិនខ្លាចក្រែងរអែងចិត្ត ប្រៀបហាក់ដូចជា មិនទុកកត្តិយសឲ្យនាងអ្វីបន្តិចសោះ ។ និតាមួម៉ៅពេក ក៏ហារមាត់ ខាំកំភួនដៃបុរសខ្ទាប់ពេញមាត់ យ៉ាងអស់ទំហឹង :

- អ្ហ៎! (បុរីឧទានដោយភ្ញាក់ព្រោះត្រូវនិតាខាំដៃ)

តែបុរីមិនរើទេ បែរជាសុខចិត្តឈរសំងំស្ងៀមឲ្យមាណវីខាំអស់ ទំហឹងតាមចិត្តដែលនាងកំពុងខឹងឃ្នាន់ខ្នាញ់នឹងរូបគេ ។

ស្នាមខាំដាំស្នេហ៍

- ស្នាមខាំក្រឡៅដៅលើសាច់ ស្នាមស្នេហ៍ប្តូរផ្តាច់ស្មោះភក្តី  
ស្នាមខាំដាំចិត្តផ្ចិតភិសម័យ ធ្វើដួងហឫទ័យលើមាសស្ងួន ។
- ស្នាមអើយស្នាមដៅក្រឡៅរូប អោយបងរំភើបស្នេហ៍នឹមនួន  
ស្នាមខាំដាំស្នេហ៍ពៅមាសស្ងួន អង្រួនចិត្តបងអោយយន់ចិត្ត ។
- ស្នាមខាំដៅគាប់ជាប់ទ័យា ឆ្លាក់ឈ្មោះពំងាកែវវរមិត្រ

CHANBOKEO.COM

ក្នុងបេះដូងរៀមត្រៀមនៃបនិត្យ ដៅដានអម្រិតផ្តិតស្នាមស្នេហ៍។

\- ស្នាមអើយស្នាមខាំដាំពាក្យពេចន៍ ស្នេហ៍ស្មោះជានិច្ចមិនកែប្រែ

ផ្ញើជូនមេឃដីនិងដួងខែ រយជាតិនៅតែស្មោះស្នេហ៍មួយ។

បន្តិចមក ធិតាក៏ព្រលែងមាត់ចេញ ។ ចែដន្យ ប៊ុរីនៅមិនព្រមលែងនាងពីរង្វង់ដៃរបស់គេដដែល ។ រំពេចនោះ ឈាមហូររីមៗស្រក់ចេញពីដៃប៊ុរីតាមរង្វង់ស្នាមខាំ ។ រីឯស្រីម៉ៅវិញក៏មាន អារម្មណ៍ថានាងបានទទួលរសជាតិឈាមរបស់បុរសយើង នៅ តាមជើងធ្មេញរបស់នាងដែរ ។ ពេលនោះមាណវីនឹកភ័យជ្រួចក្នុង ពោះដែលខ្លួនធ្វើជ្រុលទៅលើនរ: ។ បេះដូងរបស់មាណវីក៏លោតកញ្រ្ជោលគ្រាំគ្រេងឡើង... ធ្វើឲ្យនាងញ័រចំប្រប់សាជាថ្មី ។ ស្រីម៉ៅ ប្រមូលកម្លាំងជាចុងក្រោយប្រឹងបម្រះយ៉ាងអស់លទ្ធភាព ដើម្បី គេចពីរង្វង់ដៃរបស់មាណព ។ ដោយការប្រទាញអូសចុះអូសឡើង អ្នកទាំងពីរក៏ដួលធ្លោលទៅលើដី ។ ខ្លួនម៉ៅទាំងមូលក៏រលំគ្រេងលើ ទ្រូងរបស់នរ:ដោយឥតព្រៀងទុក ។ នេះជាលើកទីពីរហើយដែលធិតាយើងដួលរលំលើទ្រូងបុរសដោយអចេតនា ។ ស្រីម៉ៅនឹកខ្មាស ខ្លួនឡើងក្រហមថ្លាល់ងាំង រួចស្រាប់តែរងាញ័ររណ្តំចង្កាក្រឹកៗមួយ រំពេច ។ ឃើញដូច្នោះ ប៊ុរីក៏ស្ទុះងើបឡើងលើកនារីអោយអង្គុយ រួចក៏ស្រវាក្រមារបស់នាងរលាស់ដណ្តប់អោយធិតាភ្លាម ។ កាលបើឃើញនាងមិនទាន់បាត់រងា គេក៏ដោះអាវក្រៅរបស់គេយកមកគ្រប លើខ្លួននាងមួយជាន់ទៀត :

\- អន់រងាខ្លះហើយឬនៅ ម៉ៅ ?

ម៉ៅមិនឆ្លើយទេ ព្រោះបេះដូងរបស់នាងកំពុងតែញាប់ញ័រខ្លាំង ណាស់... ប៊ុរីដាក់ខ្លួនអង្គុយចុះពីមុខធិតា យកដៃបបោសកេសានាង ដោយថ្នមៗ ។ គេសម្លឹងមុខធិតាដោយក្រសៃភ្នែកយ៉ាងស្រទន់ រួចហើយស្រដីខ្សិបៗស្រាលៗទៅកាន់កល្យាណីយើងថា :

\- ម៉ៅ! ឈប់ម៉ួម៉ៅខឹងនឹងបងទៀតទៅណា៎! យើងធ្វើល្អចំពោះ គ្នាវិញបានទេ ? បើមិនបានជាបងប្អូន ឬសង្សារ សុំត្រឹមតែជានឹង មិត្តនឹងគ្នាក៏បានដែរ...

ម៉ៅងើបមុខឡើងសម្លឹងកែវភ្នែកបុរសយ៉ាងយូរ បន្ទាប់មកក៏ ស្រដីតបថា :

\- ប៉ុន្តែពេលនេះ ខ្ញុំលែងទទួលពាក្យរបស់នរណាទៀតហើយ...

\- ព្រោះអីទៅម៉ៅ ?

CHANBOKEO.COM

- ព្រោះម៉ៅមិនជឿថាជាពាក្យពិត...

ម៉ៅបែរមុខសម្លឹងខ្សែទឹកហូរ រួចហើយដកដង្ហើមធំបន្ធូរទ្រូង... បន្តិចមកក៏ស្រដីតិចៗថា :

- កាលពី៨ឆ្នាំមុន មានគេម្នាក់មកសុំខ្ញុំធ្វើជាបងប្អូននឹងគ្នា ចៃដន្យ គេបានត្រឹមតែសន្យាចោលប៉ុណ្ណោះ... គេមិនដែលត្រឡប់មករកម៉ៅ តាមពាក្យសន្យារបស់គេវិញឡើយ តាំងពីគេបែកពីខ្ញុំទៅនៅរាត្រី បុណ្យបណ្តែតប្រទីបមួយនោះ ។

រំពេចនោះ ម៉ៅឈ្ងោកមុខ លួចលេបទឹកភ្នែកចូលក្នុងបំពង់ក វិញ ។ បុរីឮវាចានិតាកាលណា ក៏រំជួលចិត្តឥតឧបមា រកថាមិនត្រូវ បន្ទាប់មកក៏ឆ្លើយតបវិញដោយបេះដូងញាប់ញ័រថា :

- កាលនោះ គេមានដំណើរជីវិតគ្រួសារផ្លាស់ប្តូរទាន់ហន់ ទើបគេ ត្រូវឃ្លាតចេញទៅដោយមិនបានមកលាម៉ៅផ្ទាល់... ប៉ុន្តែ ទោះជា យ៉ាងណា គេក៏ខំរត់មកតាមរកម៉ៅវិញជាថ្មីម្តងទៀតជាច្រើនដង... ប៉ុន្តែមិនដែលបានជួបម៉ៅសោះ ។ ពេលនេះ គេក៏វិលត្រលប់មក ម្តងទៀត... ហើយគេក៏នៅអង្គុយចំពោះមុខអូននេះហើយ ដើម្បី មកសុំទោសម៉ៅ... តើអូនអាចអភ័យទោសអោយគេបានដែរទេ ?

ស្រាប់តែម៉ៅងើបមុខឡើងសម្លឹងបុរីដោយក្រសែភ្នែកភ្លឺផ្លេកៗ ទំនងចង់បញ្ជាក់ថានាងចំណាំបុរីបានរួចទៅហើយ ។ បន្តិចមកនាង បែរមុខចេញទៅវិញ ថែមទាំងស្រដីថា :

- ចៃដន្យ ខ្ញុំឈប់ទទួលស្គាល់គេម្នាក់នោះ តាំងពីយូរមកហើយ...

ទោះជាយ៉ាងណា បុរីមិនអស់ចិត្តដដែល ។ គេលូកដៃទៅចាប់ ដៃឆវីមកកាន់អង្អែលបន្ថើរៗ ហាក់ដូចជាប្រាថ្នាលួងលោមនាងឲ្យ បាត់ច្រឡោតខឹង :

- បងដឹងថាអូនកំពុងមានអារម្មណ៍មិនល្អចំពោះបង ព្រោះតែរឿង រ៉ាវប៉ុន្មានថ្ងៃមុននេះ ទើបអូនទទួលបងពេលនេះមិនបាន ។ ប៉ុន្តែ បងក៏មិនអាក់អន់ស្រពន់ចិត្តអ្វីនឹងអូនដែរ...ការពិត អូនខឹងនឹងបង បងបែបនេះក៏សក្តិសមហើយ ព្រោះបងបានប្រព្រឹត្តមិនគប្បីពិត មែន ។ ទោះជាយ៉ាងណា សុំអោយតែអូនដឹងរឿងមួយផងថាពេល ដែលបងឃើញអូនឈឺ... បងចង់យកខ្លួនបងឲ្យទៅឈឺជំនួសអូន វិញ... បងពិតជាចង់ឃើញអូនរីករាយ អូនសុខសប្បាយ ប្រាស ចាកទុក្ខសោកផងទាំងឡាយ ថ្វីបើ ពេលខ្លះអូននិយាយស្តីមិនពិរោះ ដាក់បងក៏ដោយ ក៏គង់នៅគ្រាន់បើជាជាងឃើញអូនឈឺហើយ មិន ព្រមស្រដីដាក់បងដែរ...

CHANBOKEO.COM

ប៊ុរីស្រដីដោយដួងចិត្តញាប់ញ័រ ។ មែនហើយ! គេពិតជាមាន វិប្បដិសារីដូច្នោះពិតមែន ។ មិនដឹងមកពីហេតុអ្វីទេ ដែលវត្តមាន របស់ស្រីម៉ៅអាចផ្លាស់ប្តូរចិត្តគំនិតរបស់គេ យ៉ាងប្លែកដល់ម្ល៉ឹង ។ បន្តិចមក គេក៏និយាយសួរធិតាជាថ្មីម្តងទៀតថា :

- អោយបងសុំឱកាសកែខ្លួនជាថ្មីបានទេ ម៉ៅ ?

ម៉ៅនៅស្ងៀមមិនមានស្តី ទំនងដូចជាកំពុងគិត ។ មួយសន្ទុះ ក្រោយមក ធិតាក៏ស្រដីតបវិញថា :

- ម៉ាក់ប៉ារបស់ខ្ញុំតែងមានប្រសាសន៍ថា តម្លៃមនុស្សមិនមែនស្ថិត នៅលើបបូរមាត់ដែលគេខំប្រឹងអួតអំពីគុណសម្បត្តិរបស់គេនោះទេ តែស្ថិតនៅលើការប្រព្រឹត្តរបស់បុគ្គលនោះជាជាង ថាតើការប្រព្រឹត្ត របស់គេមានសច្ចៈភាពនិងមានគុណធម៌កំពស់ប៉ុនណាដែរ ។ ពេល នេះ ម៉ៅក៏ចង់ដឹងដែរ ថាតើលោកអាចប្រព្រឹត្តបង្ហាញសច្ចភាពនិង គុណធម៌ចំពោះម៉ៅបានដូចសំដីរបស់លោកដែរឬអ្វី...

កាលបើឮវាចារបស់ស្រស់ស្រីដូច្នោះ ប៊ុរីក៏ញញឹមឡើងដោយក្តី ត្រេកអរ ត្បិតដឹងថានាងកំពុងតែចំហឱកាសអោយគេបានបង្ហាញ នូវសន្តានចិត្តរបស់គេចំពោះនាងសាជាថ្មី ។ នរៈពោលតបយ៉ាង រហ័សទៅមាណវីវិញភ្លាម :

- បងមិនខ្លាចនឹងបង្ហាញអោយអូននិងក្រុមគ្រួសាររបស់អូនឃើញ ទេ ។ ម៉ៅរង់ចាំមើលចុះ ។ បងពិតជាមិនអោយអូនខកសង្ឃឹម ដោយសារបងជាថ្មីម្តងទៀតឡើយ ។ បងសូមសន្យា! !

ពេលនេះ បរិយាកាសហាក់ប្រែជាធូរស្រាលវិញហើយ ។ ទាំង ពីរនាក់អង្គុយនៅទីនោះស្ងៀមស្ងាត់យ៉ាងយូរ សម្លឹងទឹកស្ទឹងដែល ឆ្លុះពន្លឺពណ៌កុលាបយ៉ាងស្រស់ស្អាត នាពេលសន្ធ្យាមុនរង្សីសុរិយា លាលោកជាចុងក្រោយ ។

អ្នកទាំងពីររកនឹកពាក្យអ្វី មកនិយាយជាមួយគ្នាមិនបានទៀត សោះ ក្រៅពីលួចចោលកន្ទុយភ្នែកដាក់គ្នាទៅវិញទៅមក ទំនង ហាក់ដូចជាចង់ដឹងចិត្តគ្នា តែគ្មាននរណាហ៊ានហើបមាត់សួរអ្វីពីគ្នា មុនឡើយ ។ មួយស្របក់ក្រោយមក កាលបើឃើញម៉ៅអង្គុយរងា អោបដៃ ប៊ុរីក៏ដាច់ចិត្តពោលឡើង :

- អនុញ្ញាត្តអោយបងផ្តល់ភាពកក់ក្តៅដល់ម៉ៅខ្លះបានទេ ?

ម៉ៅភ្ញាក់ព្រើតចំពោះសំដីបុរស ។ ភ្លាមនោះ ប៊ុរីក៏រំកិលខ្លួនមក ជិតនាងហើយលូកដៃស្រវាត្រកងចង្កេះធិតាពីក្រោយ :

CHANBOKEO.COM

- បងបែកពីអូន៨ឆ្នាំហើយ... តើម៉ៅមានចាំបងខ្លះដែរឬទេ ?

ពេលនោះ ស្រីម៉ៅហាក់ដូចជាបន្ទូរឥរិយាបថចំពោះបុរី បន្តិច ហើយ ។ នាងក៏នៅស្ងៀមសំងំទទួលភាពកក់ក្តៅពីរង្វង់ដៃរបស់ នរៈមួយស្របក់មក ទើបឆ្លើយវិញថា :

- តើគួរអោយម៉ៅចាំគេទៀតទេ កាលបើគេទៅចោល មិនដែល
នឹកនាត្រលប់មករកម៉ៅវិញម្តងណាសោះ ?
- មានន័យថាអូននៅចំណាំបងបាន តែអូនបិទទ្វារដួងចិត្តមិនព្រម
ទទួលស្គាល់បងដោយសារបងទៅបាត់ដំណឹងមែនទេ ?

ម៉ៅនៅស្ងៀមទំនងមែន ។ បុរីឃើញដូច្នោះក៏ពោលបន្តថា :

- បងសុំទោសណា៎ដែលកាលណោះបងត្រូវចេញដំណើរទៅភ្នំពេញ
ដោយមិនបានព្រាងទុក ទើបមិនបានមកលាម៉ៅ ។ ប៉ុន្តែរៀងរាល់ ឆ្នាំ
បងតែងវិលមករកម៉ៅនៅទីនេះ ជាពិសេសពេលសាលាវ៉ាកង ម្តងៗ ។ ថៃដន្យ
បងគ្មានសំណាងបានជួបអូនសោះ ។ ម្យ៉ាងទៀត កាលណោះ បងក៏ភ្លេចសួរថាផ្ទះម៉ៅនៅឯណា...
ទើបយើងព្រាត់គ្នា
ដល់ទៅ៨ឆ្នាំ ។

តែម្តងនេះ ធិតាយើងលែងមានចិត្តចង់តវ៉ាចាញ់ឈ្នះនឹងបុរី ទៀតអស់រលីង ព្រោះនាងបានឃើញបុរីបន្ទូរកិរិយារបស់គេចំពោះ នាងយ៉ាងច្រើនលើសលប់ណាស់ទៅហើយ ។ ថ្វីបើនាងងងឹកដាក់ គេយ៉ាងណាក៏ដោយ ក៏គេនៅតែយោគយល់នាងជានិច្ច ។ ដូច្នេះ មានន័យថា គេមិនទាន់ភ្លេចនាងដូចដែលនាងធ្លាប់គិតកន្លងមក នោះទេ ។ បន្តិចមក ម៉ៅឈ្ងោកក្រសៃភ្នែកសំយុងចុះក្រោម ក៏ ប្រទះឃើញឈាមហូររឹមៗចេញពីរង្វង់ស្នាមខាំ លើកំភួនដៃឆ្វេង របស់នរៈ ។ នាងមានអារម្មណ៍ហាក់ដូចជានឹកស្តាយក្រោយណាស់ ក៏យកជាយកន្សែងរបស់នាងទៅជូតអោយនរៈបន្ថើរៗ ព្រមទាំង វាចាខ្សិបៗថា :

- សូមទោសណា៎... ដែលម៉ៅខាំ...អោយរបួស !

ស្រាប់តែ បុរីញញឹមឡើង ឆ្លើយវិញថា :

- ម៉ៅធ្វើដូច្នោះល្អហើយ នឹងអាលបានបោះត្រាចំណាំផងថា បុរីជាកម្មសិទ្ធិរបស់ម៉ៅតែម្នាក់...
- តែផ្តាស... ម៉េចនិយាយអីអញ្ចឹង ? (ធិតាលាន់មាត់)
- អូនមិនចង់បានអញ្ចឹងទេហ៎ ម៉ៅ ?

CHANBOKEO.COM

ស្រីឆោមមិនឆ្លើយទេ នាងបែរជាលូកដៃក្តិចចង្កេះបុរីភ្លាម ។ ពេលនោះ មាណពទទួលអារម្មណ៍ភ្លាមថានាងកំពុងតែអៀនខ្មាស ក្នុងចិត្ត ធ្វើអោយគេនឹកត្រេកអររំភើបតែក្នុងចិត្តម្នាក់ឯងយ៉ាង រំជើបរំជួល ។ បន្តិចមក គេក៏ឈ្ងោកមុខសម្លឹងភក្ត្រម៉ៅហើយវាចា បន្តថា :

- ដឹងទេថាបបូរមាត់ម៉ៅក៏នៅមានប្រលាក់ឈាមរបស់បងដែរ ?

មាណវីភ្ញាក់កន្ត្រាក់កាលបើឮដូច្នោះ ។ នាងក៏លើកដៃជូតយ៉ាង រហ័ស ស្រាប់តែបុរីចាប់ដៃនាងជាប់ :

- ចាំបងជូតអោយអូនវិញណា៎ ?

ឆវីទុចដ៏ក់ដើបមុខសម្លឹងមុខនរៈ មិនទាន់នឹងឆ្លើយថាម៉េចផង ស្រាប់តែគេយកបបូរមាត់របស់គេ មកផ្តិតលើបបូរមាត់របស់នាង យ៉ាងស្និទ្ធ ។ ពេលនោះ ធិតាវិតតែភ្ញាក់ផ្អើលខ្លាំងឡើងហើយ ។
នាងយកម្រាមដៃខ្ទាមមុខគេរួចច្រានចេញភ្លាមព្រមទាំងគំហកថា :

- ព្រហើនម្ល៉េះ ?

រួចហើយ នាងក៏ច្រានទ្រូងបុរសយ៉ាងអស់ទំហឹងដៃ រហូតដល់ បុរីផ្ងាកក្រោយដោយមិនដឹងខ្លួន ព្រោះគេមិនបានប្រុងប្រយត្ន័ជា មុន ។ ឆវីក៏ម្ចីម្ចាស្ទុះស្ទាររត់ឡើងច្រាំង សំដៅទៅផ្ទះ យ៉ាងលឿន ទាំងដួងចិត្តរន្ធត់តក់ស្លុតញាប់ញ័រយ៉ាងចម្លែកដែលបុរសបានបំពាន នាងដោយឥតអៀនខ្មាស ។ ទឹកភ្នែកពីរតំណក់ក៏ហូរស្រក់ចុះកាត់ ផ្ទៃមុខដោយឯកឯង ។ នាងពិតជាមិនយល់ទេ ថាហេតុអ្វីចិត្តនាង ច្របូកច្របល់ម្ល៉េះពេលនាងជួបមុខគេម្តងៗ ។ នាងគិតអ្វីធ្វើអ្វីមិន ដែលត្រូវសោះ ហើយចេះតែធ្វើយ៉ាងនេះខុសយ៉ាងនោះខុសឆ្គងតែ រហូត ។ បុរីស្ទុះក្រោករឹងយ៉ាងរហ័សរត់តាមពីក្រោយធិតា :

- ម៉ៅ ! ម៉ៅ ! បងសុំទោស... អំបាញមិញ បងភ្លេចស្មារតី... បងសុំទោសណា៎អូនណា៎ !

នរៈរត់តាមអង្វរម៉ៅ តែនាងមិនស្តាប់ទេ គិតតែពីទទូរក្រមារត់ ចូលផ្ទះទាំងទឹកភ្នែកហូរសស្រាក់ ។ ថ្វីបើពេលនោះ ព្រលប់ងងិត បន្តិចទៅហើយ ក៏ភ្លើងគោមតាមផ្លូវបានបំភ្លឺអោយដឹងដែរថា ឆវី កំពុងរត់ផងយំផង ។ ថៃដន្យ នាងភ្លេចដោះអាវក្រៅសង្ហាស់គេ វិញមុននឹងចូលផ្ទះ ។ លុះចូលដល់ក្នុងបន្ទប់ ទើបនាងដឹងថាអាវ របស់នរៈស្ថិតនៅលើខ្លួននាងនៅឡើយ ។ ប៉ុន្តែតើអោយនាងធ្វើ ដូចម្តេច ? នាងកំពុងខឹងខកចិត្តនឹងមាណពខ្លាំងណាស់ ។ ធិតា ពិតជាមិនមុខក្រាស់

CHANBOKEO.COM

ដើរត្រលប់យកអាវមួយនោះ ទៅសងបុរស យើងវិញទេ ។ នាងចាប់ទាញអាវយកមកកាន់ រួចហើយក៏ចាប់ ហែក... ស្រាប់តែទុចដឹក់ទៅវិញ ព្រោះវាវែកមិនដាច់ចិត្តធ្វើ សោះ ។ ស្រីម៉ៅក៏បោះអាវចោលទៅលើឥដ្ឋហើយខ្ទប់មុខយំសសឹក ម្តងទៀត ។ ខ្លួននាងញ័រចំប្រប់ហាក់ចង់គាំងបេះដូង ដាច់ដង្ហើម ម្តងៗទៅហើយ ។

ពេលពីនរៈវិញ គេរត់តាមក្រោយមាណវីរហូតមកដល់ក្នុងផ្ទះ ប៉ុន្តែ គេមិនហ៊ាននិយាយស្តីអ្វីឲ្យភ្ញាក់ផ្អើលម្ចាស់ផ្ទះដែរ ។ ពេល នោះ លោកគ្រូពេទ្យនិងភរិយាកំពុងនៅឯលើឡៅ គ្មាននរណានៅ ខាងក្រោមសោះ ក្រៅពីវិសាលម្នាក់ ។

- វិសាល ! អោយបងពឹងប្អូនបន្តិចបានទេ ?
- បាទបង !
- សុំខ្មៅដៃនិងក្រដាសមួយមក ។

វិសាលក៏ស្ទុះយកមកអោយ ។ បុរីក៏ចាប់សរសេរខ្សៀកៗមួយ ស្របក់ក៏បត់ហុចទៅអោយវិសាល :

- សូមផ្ញើសំបុត្រនេះជូនម៉ៅផងបានទេ ? ហើយប្រាប់គេផង ថា ស្អែកព្រឹកបងនឹងត្រលប់មកវិញ !
- បាទបង !

វិសាលស្ទុះយកសំបុត្រនោះទៅអោយស្រីម៉ៅភ្លាម ។ បុរីនៅ អង្គុយរោខាងក្រៅផ្ទះមួយស្របក់ រង់ចាំមើល ក្រែងម៉ៅចេញមក ក្រៅវិញ ។ ជិតមួយម៉ោងទៅហើយ គេនៅតែមិនឃើញស្រស់ស្រី លេចមុខមកដដែល ។ អស់ចិត្តនឹងរង់ចាំតទៅទៀត គេក៏ដើប ឡើងដើរថយត្រលប់ទៅវិញ ទាំងដួងចិត្តក្តុកក្តួលនិងសោកស្តាយ ដែលគេធ្វើជ្រុលជ្រួសទៅលើម៉ៅដោយមិនបានគិតវែងឆ្ងាយ ។

ពេញមួយរាត្រី នរៈគេងមិនលក់ទាល់តែសោះ... គេរសាប់ រសល់... គេធុញថប់កន្ទះរាក្នុងចិត្តយ៉ាងណាមិនដឹង ។ នៅវេលាវង់ ពាក់កណ្តាលអាធ្រាត គេក៏ដើបឡើងធាក់កង់សំដៅទៅផ្ទះម៉ៅទាំង យប់... ពេលនោះ ផ្ទះលោកគ្រូពេទ្យបានបិទភ្លើងចូលនិទ្រាអស់ ទៅហើយ ។ បុរីនៅអង្គុយសំកុកលើកង់ម្នាក់ឯង ឯម្ខាងចញ្ចើម ថ្នល់ ស្តាប់សូរសៀងកាំភ្លើងធំលាន់ល្ងើយៗពីទិសភ្នំវាយចាប :

CHANBOKEO.COM

– ឱ ស្នូរកាំភ្លើងអើយ! ថ្វីបើអ្នកលាន់ឮក្នុងខ្លាំងយ៉ាងណាក៏នៅមិន
ស្មើនឹងកម្លាំងព្យុះដែលបោកបក់ដួងចិត្តខ្ញុំពេលនេះទេ? តើខ្ញុំត្រូវ ធ្វើយ៉ាងណា
ទើបបេះដូងរបស់ខ្ញុំបានស្រាកស្រាន្តពីភាពអន្ទះសា កន្ទះរា?
តើខ្ញុំកំពុងលង់នៅក្នុងជម្រៅនៃសេចក្ដីស្នេហាមែនទេ?
តើក្ដីស្នេហ៍ណាមួយជាក្ដីស្នេហ៍ពិតប្រាកដទៅហ្ន៎? ចិត្តត្រេកត្រអាល
ភ្លើតភ្លើនចំពោះនារីស្រស់ឆើតឈ្មោះសម្ផស្ស ឬកចិត្តរំភើបរំជើប
រំជួលព្រោះក្ដីអាណិតអាសូរចំពោះនារីសាមញ្ញធម្មតាដូចស្រីម៉ៅ?
    មាណពដើយសម្លឹងដំបូលផ្ទះរបស់ស្រីម៉ៅយ៉ាងយូរ រួចហើយ ដកដង្ហើមវែងៗ
ទំនងហាក់បីដូចជាកំពុងទំលាយសារ ផ្ញើដួងចិត្ត ស្នេហាទៅស្រីម៉ៅ
តាមរយៈជំនោរព្រះពាយពាក់កណ្ដាលរាត្រីនោះ ហើយ...
មិនដឹងថាតើនារីយើងបានទទួលអារម្មណ៍នោះដែរឬទេ? ចង្រិតយំច្រេចៗកាត់ភាពស្ងាត់ជ្រងំ
ឆ្លើយឆ្លងនឹងសម្លេងកាំភ្លើងធំ ពីទិសខាងលិច អមជាមួយសម្លេងស្លឹកឈើបក់ខ្សាកៗកាត់ស្បៃ
រាត្រីខ្មៅងងឹត បានធ្វើឲ្យបេះដូងបុរសយើង រិតតែរណ្ដំលាន់ឡើង
សន្ធប់ដួងចិត្តដែលកំពុងធុញថប់កន្ទះរា...

ញាប់ញ័រ

- ញាប់ញ័រដួងចិត្តត្បិតស្នេហ៍ស្រី ឱរាព្រួយភ័យខ្លាចស្រីព្រាត់
ញាប់ញ័ររន្ធត់ព្រោះប្រតិពទ្ធ័ នារីឆោមរតនឹដួងទ័យា។
- ញាប់ញ័រកាយអង្គលង់វិយោគ នឹកកែវពន្លកស្រស់ពំងា
ញាប់ញ័រព្រោះកាយសែនកំព្រា បេះដូងឃ្លាតឃ្លាម្ចាស់នៃបនិត្យ។
- ញាប់ញ័ររំភើបស្រើបឱរា ស្នេហ៏ពៅធិតាកែវវរមិត្រ
ញាប់ញ័រត្បិតពៅមិនយល់ចិត្ត ហឫទ័យវិបរិតគិតសង្រេង។
- ញាប់ញ័រចំប្រប់ឈប់មិនបាន អារម្មណ៏រូបប្រាណក្លាយវង្វេង
ញាប់ញ័ររន្ធត់សោកចំបែង នឹកអូនម្នាក់ឯង...ថ្លែងមិនរួច...

0000000000000000000

00000

0

# វគ្គទី៨
# គ្រោះ

ថ្ងៃងពីស្រីម៉ៅយើងម្តង...

នៅក្នុងបន្ទប់ ស្រីម៉ៅយំឡើងហើមភ្នែកស្ពុរតែម្តង ។ នេះជាលើកទីមួយហើយដែលនាងមានអារម្មណ៍ថា នាងបានធ្វើអ្វីមិនសម រម្យចំពោះខ្លួនឯង... នោះគឺភាពទន់ភ្លន់ឆាប់ជឿចិត្តជឿលើការថ្នាក់ថ្នមក្លែងក្លាយរបស់បុរសរហូតដល់គេហ៊ានលូកថ្លើមប្រមាថកិត្តិយស របស់នាង ។ មួយជីវិតនេះ នាងមិនដែលមាននរណាធ្វើដាក់នាង ដល់ម្លឹងទេ ។ ធិតាតូចចិត្តណាស់ គេងស្រក់ទឹកភ្នែកបណ្តើរសម្លឹង អាវបុរសបណ្តើរ នឹកម្តងៗ ហាក់ដូចជាចង់តែកាប់ចិញ្ច្រាំអាវនោះជំនួសម្ចាស់វាម្តងៗទៅហើយ ។

បន្តិចមក... នាងក៏ស្រវាទាញសំបុត្ររបស់ប៊ុរីដែលវិសាលបានយកមកហុចអោយនាងកាលពីមួយស្របក់មុននេះ យកមកក្រញី យ៉ាងឃ្នាន់ខ្នាញ់ រួចហើយក៏គប់ចោលទៅលើជញ្ជាំងខ្ទាប់ ។ សំណុំក្រដាសហោះប៉ើងធ្លាក់រមៀលចុះតុកៗទៅដល់មាត់ទ្វារ ស្រាប់តែអ្នកគ្រូចរណៃបើកទ្វារចូលមកដោយថៃដន្យ ធ្វើអោយអ្នកគ្រូភ្ញាក់ ក្រញាងតែម្តង ។

- ម៉ៅ មានរឿងអ្វីហ្នឹងកូន ?

ឃើញវត្តមានរបស់ម្តាយកាលណា ម៉ៅក៏ភ្ញាក់ផ្អើលដូចគ្នាដែរ... នាងបែរគេចមុខជាប្រញាប់ហើយយកដៃជូតទាំងភ្នែកយ៉ាងរហ័សពី រង្វង់មុខ ប៉ុន្តែក៏មិនអាចលាក់ជិតពីក្រសៃភ្នែករបស់ម្តាយបានដែរ ថានាងកំពុងតែពួនយំ ។ ឃើញដូច្នោះអ្នកគ្រូចរណៃដាក់ខ្លួនអង្គុយ ចុះជិតកូន ហើយយកដៃអង្អែលស្មានាងបន្ទើរ :

- មានរឿងអ្វីដែលកូនចង់ពិគ្រោះនឹងម៉ាក់ទេ ក្រែងលោម៉ាក់អាច ជួយអ្វីកូនបានខ្លះ ?

CHANBOKEO.COM

ស្រាប់តែម៉ៅដើបស្រវាអោបចង្កេះម្ដាយយំហ៊ូតែម្ដង ។ អ្នកគ្រូ ភ្ញាក់ព្រើតយកដៃអោបកូនវិញ អង្អែលខ្នងបន្ដើរៗ :

- ប៉ុរីគេធ្វើអ្វីមិនសមរម្យលើកូនមែនទេ ?

អ្នកគ្រូសម្លឹងមុខកូនដោយពិភាល់ក្នុងចិត្ត ។ ម៉ៅងក់ក្បាលរួច ហើយនៅតែយំសសឹកដដែល ។ ពេលនោះអ្នកគ្រូក៏លែងសប្បាយ ចិត្តដែរហើយ ។ លុះបណ្ដោយឲ្យកូនស្រីសម្រក់ទឹកភ្នែកអស់ចិត្ត អស់ចង់ហើយ ទើបអ្នកគ្រូមានប្រសាសន៍សាជាថ្មី ថា :

- តើគេប្រព្រឹត្តមិនគប្បីយ៉ាងណាខ្លះលើកូន ដើម្បីអោយម៉ាក់មាន ឱកាសដាក់ទោសគេវិញអោយសមមារយាទ ? ដឹងទេ ធ្វើយ៉ាងនេះ គឺមើលងាយម៉ាក់ប៉ាទាំងស្រុងតែម្ដង...

ឮដូច្នោះ ស្រីម៉ៅដើបមុខឡើងជូតទឹកភ្នែកភ្លាម ហើយដើប ជំរាបម្ដាយថា :

- គេមិនបានធ្វើអ្វីធ្ងន់ធ្ងរទេ... គ្រាន់តែបន្លំចាប់ម៉ៅថើប...
- ផ្ដាសមែន..! (អ្នកគ្រូលាន់មាត់) មិនអីទេ កូន! ចាំព្រឹកស្អែក ម៉ាក់ហៅគេមកសួរអោយ ។
- ម៉ាក់... បំរុងធ្វើអ្វីហ្នឹង ?
- គឺម៉ាក់ចង់ហៅគេមកសួរមុខចាស់ៗថាគេកំពុងលេងសើចរឿងអ្វី លេងពិតរឿងអ្វី... ហើយគេត្រូវតែមានចម្លើយសមរម្យចំពោះកូន ស្រីរបស់ម៉ាក់ ព្រោះម៉ាក់មិនអាចបណ្ដោយអោយម៉ៅក្លាយជានុយ លេងសើចរបស់របស់បុរសឡើយ ។

នៅមាត់ទ្វារ លោកដុកទ័រវិចិត្រឈរសម្លឹងមុខកូនស្រីស្ងៀម ស្ងាត់មិនមានស្រដីអ្វីយូរហើយ ។ កាលបើឃើញចរណៃស្រដីរកកូន ចប់ លោកក៏មានប្រសាសន៍ដែរ :

- ម៉ៅ! ប៉ាម៉ាក់ជាម្លប់សុខរបស់កូន ។ អ្វីៗត្រូវតែមានការដោះ ស្រាយដោយមានសីលធម៌ថ្លៃថ្នូរជាគោល ។ កូនឈប់យំទៅណា៎! ថ្ងៃស្អែក ម៉ាក់ប៉ានឹងស្វែងរកផ្លូវដោះស្រាយមិនអោយកូនស្រក់ទឹក ភ្នែកតទៅទៀត ។

កាលបើឮឪពុកមានប្រសាសន៍ដូច្នោះ ម៉ៅមានកម្លាំងចិត្តប្រើស តែម្ដង ដោយដឹងថា លោកទាំងពីរយកចិត្តទុកដាក់នឹងសុខទុក្ខ របស់នាង ។ ធិតាលើកដៃឡើងប្រណម្យភ្លាម :

- សូមទោសលោកប៉ា! សូមទោសម៉ាក់!...ដែលកូននាំក្ដីអាមាស ចូលផ្ទះ នៅពេលនេះ ។
- ខុសហើយកូន! (អ្នកគ្រូចរណៃមានប្រសាសន៍) ការពិតកូនមិន បាននាំក្ដីអាមាសចូលផ្ទះទេ គឺអ្នកផ្សេងតើហ៎ដែលនាំរឿងប្លែកៗ ចូលផ្ទះរបស់យើង... នែ៎! ឈប់គិត ឈប់ទោសៈទៅ ។

CHANBOKEO.COM

ឆាប់គេងយកកម្លាំង ប្រយត្ន័លាប់ជំងឺមកវិញ ខានធ្វើការ តិចលោ
គេបញ្ឈរយើងពីការងាររហូតទៅ ។ ថែខ្លួនឡើងណា៎កូនណា៎! ប្រយត្ន័ឈឺលាប់សាជាថ្មី ។
អ្នកគ្រូចរណៃក៏ដើបដើរចេញទៅ :
- គេងទៅណា៎កូន! ព្រឹកស្អែក យើងនិយាយគ្នាទៀត ។
លោកគ្រូពេទ្យស្រដីមករកម៉ៅរួច ក៏ទាញទ្វារបន្ទប់បិទអោយ នាងវិញ
ទើបដើរតាមក្រោយអ្នកគ្រូចរណៃចេញទៅ ។ ពេលនោះ
មាណវីយើងហាក់ដូចជាមានអារម្មណ៍ធូរស្រាលល្អប្រសើរមកវិញខ្លះ
ហើយដែលប៉ាម៉ាក់របស់នាងផ្តល់កម្លាំងចិត្តដល់នាងយ៉ាងកក់ក្តៅ ។ កាលមុននេះ
នាងភិតភ័យណាស់ ខ្លាចលោកស្តីបន្ទោសពេលនាង ទំលាយការពិតជំរាបលោក ។ ផ្ទុយទៅវិញ
លោកបែរជាផ្តល់ភាព កក់ក្តៅដល់នាងហើយរកវិធីដោះស្រាយចំពោះអំពើឆ្គាំឆ្គងរបស់បុរី
ចំពោះនាងនៅព្រឹកស្អែកនេះទៀតផង ។ ធិតាជូតទឹកភ្នែកជំរះពី
ថ្ពាល់យ៉ាងស្ងួតហើយក៏ដាក់កេសាលើខ្នើយស្រវាភួយដណ្តប់ ស្រាប់
តែដាក់ភ្នែកទៅចំដុំក្រដាសសំបុត្ររបស់បុរី ដែលនាងក្រញីបោះ
ចោលមួយសន្ទុះធំមុននេះនៅក្បែរមាត់ទ្វារ ។ ស្រស់កល្យាណក៏នឹក
ពិភាល់ក្នុងចិត្តចង់ដឹងណាស់ថា នរៈសរសេរអ្វីខ្លះមកដល់រូបនាង ។
ធិតាក៏ដើបឡើងស្រវាសំណុំក្រដាសយកមកលាតអានភ្លាម :
- ម៉ៅ! អភ័យទោសអោយបងណា៎ម៉ៅដែលបងវង្វេងសតិ មិន ចេះទប់ស្មារតី
បានប្រព្រឹត្តឆ្គាំឆ្គងលើម៉ៅ... ប៉ុន្តែបងហ៊ានសន្យា ចំពោះម៉ៅដោយយកកត្តិយសកូនប្រុសមកធានា
ថាបងនឹងចូលខ្លួន មកទទួលការដាក់ទោសពីចាស់ទុំរបស់អូន នៅវេលាព្រឹកស្អែកនេះ
ហើយបងសុខចិត្តទទួលខុសត្រូវសព្វយ៉ាង តាមដែលលោកគិតថា
ជាការសមរម្យបំផុតចំពោះម៉ៅ ។ ពេលនេះ ប្រហែលជាម៉ៅឈឺ ចិត្តហើយខឹងនឹងបងណាស់
ប៉ុន្តែសូមអូនដឹងផងដែរថា... បងបាន
កាត់បេះដូងរបស់បងផ្ញើនៅលើត្របកផ្កាកុលាបឆ្នេរស្ទឹងខៀវ ក្រុង បាត់ដំបងនោះរួចហើយ...
យល់ចិត្តបងទេ អូន ? បុរី...
ម៉ៅអានហើយអានទៀត បីបួនសា... នាងមិនអស់ចិត្តទេថាគេ និយាយពិតឬយ៉ាងណា...
ធិតាដើយមើលទៅក្បាលដំណេកឃើញ កុលាបមួយទងដែលគេយកមកអោយនាងកាលពីម្សិល
នៅមាន ភាពស្រស់ញញឹម ប្រកបដោយសោភ័ណស្រស់បំព្រងនៅឡើយ ។ ខណៈនេះ

CHANBOKEO.COM

នាងប្រែជាជ្រួលច្របល់ក្នុងចិត្តសាជាថ្មី... នាងនឹកដល់ គេទៀតហើយ... កាន់តែធ្មេចបំភ្លេច កាន់តែឃើញរូបគេអណ្ដែត ឆ្លៀតឡើងក្នុងអារម្មណ៍នាងកាន់តែញឹកញាប់ឡើង ។ ថ្វីបើនាងនៅឃ្លាន់ខ្ញាញ់នឹងគេយ៉ាងខ្លាំងពិតមែន ប៉ុន្តែ អក្សរដែលគេចារបីបួន បន្ទាត់នោះបានធ្វើអោយបេះដូងរបស់នាង ញាប់ញ័ររំជើបរំជួល យ៉ាងចម្លែក... តើនាងត្រូវឆ្លើយយ៉ាងណា ? តើចាស់ៗនឹងមាន គម្រោងដាក់ទោសប៊ុរីយ៉ាងណា ? ហើយចុះឪពុកម្ដាយប៊ុរីវិញ តើគាត់មានប្រតិកម្មយ៉ាងណាដែរ បើសិនជាលោកដឹងរឿងនេះ ?

មាន់រងាវខ្សើយៗបីដងហើយ...

ព្រឹកនេះជាថ្ងៃអាទិត្យ ម៉ៅភ្ញាក់ឡើងមានអារម្មណ៍ថាមានកម្លាំង វិញហើយ ក៏ដើបឡើងចូលចង្ក្រានបាយ ជួយយាយលឿមដណ្ដាំ អាហារស្រស់ស្រូបជូនឪពុកម្ដាយ ព្រមទាំងប្អូនទាំងបីផង ។

- ស្លាប់ហើយ ចៅ! ឯងជាមែនទែនហើយហ្អែស បានជាមកចូល ចង្ក្រានជួយយាយ ? (យាយលឿមសួរ)
- ចាស! ខ្ញុំស្រួលខ្លួនវិញហើយយាយ! ស្អែកនេះ ខ្ញុំអាចចូលធ្វើ ការវិញបានហើយ ។
- អឺ! សាធុៗ ដែលចៅជាសះស្បើយមកវិញ ។ យាយឃើញឯង ឈឺនៅក្នុងបន្ទប់មិនមាត់មិនកពីរបីថ្ងៃ យាយចេះតែបារម្ភ...
- ខ្ញុំមិនមានឈឺអ្វីធ្ងន់ទេយាយ គ្រាន់តែអស់កម្លាំងនឹងឆោងតែប៉ុន ហ្នឹងតើហ៎ ។
- ហើយចុះថ្ងៃនេះ ចៅចង់ធ្វើអ្វីជូនម៉ាក់ប៉ាហ្នឹង ?
- ធ្វើអីប្លែកមាត់បន្តិចទៅ ព្រោះខ្ញុំខានធ្វើជូនគាត់ពិសារជិតមួយ អាទិត្យហើយ ប្រហែលជាលោកនឹកស្នាដៃកូនស្រីហើយទេដឹង..

ស្រីម៉ៅនិយាយលេងជាមួយយាយលឿម ។

- អញ្ជឹង ចៅនៅធ្វើអាហារចុះ ។ យាយគិតទៅរកជួយបោកគក់ សម្លៀកបំពាក់ជាមួយតាខេមបន្តិច ។
- ចាសយាយ!

យាយលឿមក៏ដើបចេញទៅក្រោយផ្ទះបាត់ទៅ ។ ស្រីម៉ៅក៏ ស្រវាចាប់កាំបិតឆ្វិតឆ្វង់អាហារយ៉ាងឆ្ងាញ់ពិសារភ្លាម ។

- បងម៉ៅ! បានម្ហូបអីហ្នឹង ឈ្ងុយណាស់!

CHANBOKEO.COM

នាងតូចបារមីឈ្ងោកមុខសម្លឹងអាហារនៅលើតុដែលម៉ៅរៀបចំ ជូនក្រុមគ្រួសាររបស់នាង ។
នៅក្បែរនោះ ចិត្រាកៀកស្មាប្អូនស្រី ស្រដីបន្តទៀតថា :
- យើងទាំងអស់គ្នានឹកស្មានដៃបងម៉ៅណាស់ប៉ុន្មានថ្ងៃនេះ សង្ស័យ តែព្រឹកនេះ
ចិត្រាច្បាស់ជាកើតជំងឺហាល់បាយមិនខានទេ ។
ម៉ៅសម្លក់ប្អូនប្រុសកាលបើគេចំអន់នាងលេង ។ វិសាលរត់ពី
ក្រហែងណាមិនដឹងមកអោបបងស្រីពីក្រោយ :
- ហើយចុះបងម៉ៅជាទីស្រលាញ់ មានសម្រាំងអ្វីពិសេសសំរាប់ វិសាលដែរឬទេ បាទ ?
ស្រីម៉ៅយកដៃមិចចង្កាប្អូន ហើយឆ្លើយថា :
- ចំពោះប្អូនពៅបណ្ដូលចិត្តវិញ បងមានអ្វីប្លែកៗអោយប្អូនជានិច្ច កុំភ័យអីព្រលឹងបងអើយ !
នៅពីក្រោយខ្នង លោកគ្រូពេទ្យវិចិត្រនិងភរិយាញញឹមដាក់គ្នា យ៉ាងចំព្រង
កាលបើឃើញបរិយាកាសមនោរម្យក្នុងគ្រួសាររបស់
លោកបានវិលត្រលប់មកដូចប្រក្រតីវិញហើយ ។ លោកទាំងពីរក៏ ដាក់ខ្លួនអង្គុយចុះ
ទទួលទានអាហារដែលម៉ៅបានធ្វើសម្រាំងជូន ។
- មានអារម្មណ៍ធូរស្រាលហើយហ្មែស កូនម៉ៅ ?
អ្នកគ្រូចរណៃសួរ ។ ស្រីម៉ៅចាក់ទឹកត្រជាក់ជូនលោកបណ្ដើរ ឆ្លើយបណ្ដើរទៅម្ដាយវិញថា :
- ចា៎សម៉ាក់ ! កូនជាស្រួលបួលវិញហើយ ។ គិតថាស្អែកនេះកូន
អាចត្រលប់ចូលទៅធ្វើការវិញបានហើយ ។
លោកគ្រូពេទ្យក៏ហៅស្រីម៉ៅ :
- ម៉ោះកូន ! ចូលអង្គុយរួមបាយជាមួយគ្នាមក កុំធ្វើកិច្ចការអ្វីតែ ម្នាក់ឯងពេក
ចែកប្អូនចិត្រានិងប្អូនបារមីរៀនធ្វើខ្លះទេ ប្រយត្ន័គេ ក្លាយជាពិការលែងចេះធ្វើអ្វីអស់ទៅ ។
- ចា៎ស លោកប៉ា !
មែនហើយ ព្រឹកនេះ ទាំងស្រីម៉ៅ ទាំងគ្រប់ៗគ្នាក្នុងគ្រួសារ
ហាក់ដូចជាមានការរីករាយប្លែកដែលគេបានបរិភោគអាហារជុំគ្នា ។ មួយសន្ទុះក្រោយមក
ម៉ៅក៏ដើបរៀបចំទុកដាក់ចានក្បានបន្ទាប់ពី បរិភោគរួច
ស្រាប់តែមានរថយន្តមួយបរចូលមកដល់មុខផ្ទះរបស់ នាង ។
លោកគ្រូពេទ្យឃើញហើយក៏រត់ចេញទៅទទួលដោយមាន
អ្នកគ្រូចរណៃដើរតាមពីក្រោយទៅផង ។ ម៉ៅលួចសម្លឹងពីក្នុងផ្ទះ ទៅ

CHANBOKEO.COM

ក៏ប្រទះឃើញបុរសស្ត្រីចំណាស់ពីររូបក្នុងសម្លៀកបំពាក់ថ្លៃថ្នូរឈាន ដើងចុះចេញពីឡានមក ។ នាងមិនចាប់ភ្លឹកថាលោកទាំងពីរថាជា នរណាទេ ប៉ុន្តែនាងចំណាំមនុស្សទីបីច្បាស់ណាស់ ។ នោះគឺជាប៊ុរី ដែលធ្វើជាអ្នកបើកបរជូនបុរសស្ត្រីពីររូបនោះ ។ គ្រាន់តែក្រលេក ឃើញមុខនរៈភ្លាម បេះដូងរបស់នាងកញ្រ្ជោលឡើងភិបៗតែម្តង :

- នេះគេមកជួបម៉ាក់ប៉ារបស់យើង ដូចដែលគេសន្យាមែនតើហ៍!

ម៉ៅលួចសួរតែក្នុងចិត្តម្នាក់ឯង ។ ថែដន្ស នាងមិនហ៊ាននៅ ក្បែរនោះលួចស្តាប់ការសន្ទនារបស់ចាស់ៗឡើយ ណាមួយនឹក អៀនប៊ុរីផង នាងក៏ប្រមូលចានក្បានរត់ចូលចង្ក្រានបាយបាត់ទៅ ។ កំពុងតែសម្ងំលាងចាន ស្រាប់តែវិសាលរត់មកប្រាប់ថា :

- បងម៉ៅ! ម៉ាក់មានប្រសាសន៍ថាឲ្យលើកទឹកទៅទទួលភ្ញៀវ ។
- អឺ! បន្តិចចាំបងអោយបារមីលើកទៅ ។
- តែគាត់ផ្តាំថាអោយបងលើកទៅដោយខ្លួនឯង ។

ម៉ៅភ្ញាក់ព្រើតកាលបើឮវិសាលស្រដីប្រាប់ដូច្នោះ ។ នាងក៏មិន ហ៊ានប្រកែកអ្វីដែរ ។ ធិតាយើងក៏ប្រញាប់លើកថាសចេញទៅតាម ក្រោយវិសាលភ្លាម ។ មកដល់ក្នុងបន្ទប់ទទួលភ្ញៀវ នាងឱនលុត ជង្គង់ចុះ រៀបកែវទឹកដាក់ជូនភ្ញៀវម្នាក់មួយ ទាំងមុខឈ្ងោកមិន ហ៊ានងើបឡើងបន្តិចឡើយ ត្បិតនាងខ្លាចប្រទះនឹងខ្សែភ្នែករបស់ ប៊ុរីដែលអង្គុយនៅទីនោះដែរ ។ ថែដន្ស ត្រចៀកនាងមានបិទ ឯណា ។ ភ្លាមនោះ នាងបានឮម្តាយនាងខ្សិបដាក់នាងថា :

- ស្រីម៉ៅ! លោកអ៊ំបុរាណនិងក្រុមគ្រួសារនៅបរិភោគអាហារថ្ងៃ ត្រង់ជាមួយយើងថ្ងៃនេះ ។ ចូរកូនរៀបចំបាយទឹកបន្ថែមជូនលោក ទាំងអស់គ្នាផងណា៎!
- ចា៎សម៉ាក់! (ម៉ៅឆ្លើយខ្សិបៗ ទាំងឱនមុខដដែល)

ព្រមពេលនោះដែរ ឆវីឮលោកបុរាណមានប្រសាសន៍ឡើង ទៅកាន់លោកគ្រូពេទ្យវិចិត្រថា :

- កាលពីថ្ងៃដំបូងដែលគេទើបមកដល់បាត់ដំបង ប៊ុរីបានមករំអុក ថាសូមអោយខ្ញុំចូលស្តីដណ្តឹងនារីម្នាក់អោយគេ រួចស្រាប់តែមិត្ត ស្រីរបស់គេនោះបានមកតាមប៊ុរីដល់ក្រុងបាត់ដំបងនេះ ថែមទាំង បានបង្ហាញខ្លួនឲ្យខ្ញុំនិងម៉ាក់វាស្គាល់ដោយឥតរួញរា ហើយសុខៗ.. កាលពីយប់ម្សិលមិញ ប៊ុរីអើតមុខមកពិគ្រោះជាមួយខ្ញុំនិងម៉ាក់វា សាជាថ្មីម្តងទៀត...

CHANBOKEO.COM

ម៉ៅកំពុងសសៀរដើរចេញទៅក្រោយវិញ ស្រាប់តែឮវាចា របស់លោកបុរាណដូច្នោះភ្លាម នាងហាក់ដូចជារន្ធត់ចិត្តភ្លាម រិល មុខរកកលនឹងងួល ។ ធិតាយកដៃទប់នឹងជញ្ជាំង ធ្វើមុខខ្មៅប៉ៃ ហាក់ដូចជាចង់ខ្យល់គ ។

- បងម៉ៅ! យ៉ាងម៉េចហ្នឹងបង ?

បារមីឃើញស្រីម៉ៅមានទឹកមុខមិនស្រួលក៏រត់មកជួយគ្រាហ៍ ។

- បងមិនអីទេ អូនមុំ គ្រាន់តែនៅនឹងឆោងបន្តិចបន្តួចប៉ុណ្ណោះ ។ ថាហើយ នាងក៏ប្រឹងដើបដើរធ្វើក្លាហាន សំដៅទៅផ្ទះបាយ លួចពួនសម្ងំសំរក់ទឹកភ្នែកតែម្នាក់ឯង សាជាថ្មីម្តងទៀតហើយ ។

- នេះឬចិត្តបុរស ? (ម៉ៅគិតក្នុងចិត្ត) ពិតជាអណ្តែតសាវារកទុក ចិត្តអ្វីមិនបានឡើយ... គួរអោយខ្ពើមរអើមណាស់!

ម៉ៅធុញថប់ហួហ្មងក្នុងចិត្ត នឹកឃ្នានខ្នាញ់យ៉ាងណាមិនដឹង រក ថាមិនត្រូវសោះ ។ ទឹកភ្នែកហូរមួយតក់ហើយមួយតក់ទៀត មិន ព្រមឈប់ ។ បន្តិចក្រោយមក ស្រាប់តែចិត្រារត់យកសំបុត្រមួយ មកហុចអោយនាង :

- បងម៉ៅ! មានសំបុត្រមួយមកពីព្រះនេត្រព្រះផ្ញើមកបងហ្នែក! អ្នករត់តាក់ស៊ីគេយកមកអោយអំបាញ់មិញនេះ ។

ម៉ៅដើបជូតទឹកភ្នែក លូកដៃទទួលសំបុត្រពីប្អូនប្រុសយ៉ាង រហ័ស ។ កាលបើឃើញបងស្រីមានទឹកភ្នែកទឹកសំបោរ ចិត្រាឈរ ភាំង មិនអស់ចិត្ត :

- បងម៉ៅ មានរឿងអ្វីហ្នឹង ?

- អូហ៍ បងមិនអីទេអូនត្រា! (ម៉ៅឆ្លើយខ្សឹបៗ) គ្រាន់តែបង ស្វាបហៀរទឹកភ្នែកប៉ុនហ្នឹងតើហ៍ ។

ចិត្រាដើរចេញទៅវិញ ទាំងងឿងឆ្ងល់តែក៏មិនហ៊ានដេញដោល អ្វីដែរ ។ រីឯម៉ៅវិញ កាលបើបានទទួលសំបុត្រហើយ ក៏ហែកយក មកអានភ្លាម មានសេចក្តីយ៉ាងខ្លីថា :

- មកដល់ក្មួយម៉ៅ! ម៉ែរបស់ក្មួយនឹងប្អូនៗបានទទួលរងគ្រោះជា ទម្ងន់ នៅក្នុងការផ្តក់គ្រាប់ផ្លោងរបស់ខ្មែរក្រហមចូលភូមិ កាលពី ម្សិលមិញនេះ ។ បើមានឱកាស សូមមកមើលម្តាយឯងផង ។ ចំណែកប្អូនទាំងពីរបានធ្វើមរណកាលហើយ ។ ពីមីងនិងពូ ។

CHANBOKEO.COM

ភ្លាមនោះ ម៉ៅក៏ខ្ទប់មុខយំតែម្នាក់ឯងស្ងៀមស្ងាត់ មិនហ៊ាន រំខានដល់ឪពុកម្តាយដែលកំពុងមានភ្ញៀវនោះទេ ។ ម្យ៉ាង វាជា ការអាមាសបំផុតចំពោះនាង បើសិនឆរីបង្ហាញភាពទន់ខ្សោយ របស់ខ្លួននៅចំពោះមុខបុរី ដែលជាបុរសពោរពេញទៅដោយចិត្ត មហាសាវ៉ា ។

បន្តិចមក នាងរត់ចូលបន្ទប់ ស្រវ៉ាអាវពីរបបន្លាស់ដាក់ក្នុងកូន សំពៀតតូចមួយ ហើយសរសេរសំបុត្រខ្សៀកៗពីរបីម៉ាត់ រួចក៏បក់ ដៃហៅ វិសាល ដែលនៅអង្គុយមើលសៀវភៅមុខបន្ទប់របស់នាង មកប្រាប់ថា :

- វិសាល ! ចាំយកសំបុត្រនេះទៅជូនម៉ាក់ប៉ាផង ។ បងចេញទៅ ក្រៅម៉ាភ្លែត ។

វិសាលធ្វើមុខភាំង នឹកឆ្ងល់ក្នុងចិត្ត ហើយក៏សួរវិញថា :

- បងទៅក្រៅតែម៉ាភ្លែត ហេតុអ្វីចាំខ្ចប់ខោអាវទៅផង ?

- កុំសួរបងច្រើនអី វិសាល ! ពេលម៉ាក់ប៉ាអានសំបុត្រនេះហើយ លោកនឹងបានជ្រាបមិនខាន ។

ថាហើយ នាងក៏សសៀរដើរតាមចំហៀងផ្ទះ ចេញទៅក្រៅ ។ ចៃដន្យ បុរីបានអើតអើមដកក តាមសម្លឹងរកនារីជាយូរហើយ ។ កាលបើឃើញស្រមោលនាងភ្លិបភ្លែត តាមចន្លោះចង្រឹងបង្អួចនៅ ខាងចំហៀងផ្ទះ គេក៏សុំខ្លួនចេញទៅក្រៅ រត់តាមធិតាយើងពី ក្រោយភ្លាមមួយរំពេច ។ ពេលនោះ ចាស់ៗក៏ទុចដំណើរសន្ទនា ហើយបែរមើលមុខគ្នាធ្វើឡឹងឡង់ៗ មិនយល់ហេតុការណ៍ ។ ភ្លាម នោះ វិសាលក៏ដើរខិនៗចូលមកជិតម្តាយ ហុចសំបុត្រស្រីម៉ៅជូន លោកភ្លាម :

- បងម៉ៅផ្ញើកំណាត់តូចនេះជូនម៉ាក់និងលោកប៉ា បាទ !

អ្នកគ្រួចរណៃក៏ចាប់កំណាត់យកមកអានភ្លាម :

- ជំរាបម៉ាក់និងលោកប៉ា ! កូនសូមទោសដែលត្រូវចេញទៅទាំង ទន់ហាន់មិនបានជំរាបម៉ាក់និងលោកប៉ាផ្ទាល់ ព្រោះម៉ែនិងប្អូនៗនៅ ឯព្រះនេត្រព្រះបានទទួលរងគ្រោះ ដោយគ្រាប់ផ្លោងកាលពីយប់ មិញ ។ កូនកំពុងធ្វើដំណើរទៅមើលម៉ែ ហើយទៅធ្វើបុណ្យសពប្អូន ផង ។ កូននឹងវិលវិញក្នុងពីរបីថ្ងៃទៀត ។ ម៉ៅ !

- ពុទ្ធោ ម៉ៅ !

អ្នកគ្រួចរណៃលាន់មាត់ រួចហើយហុចសំបុត្រអោយស្វាមី ។ ទាំងអស់គ្នាមានការព្រួយបារម្ភចំពោះម៉ៅពេក ក៏នាំគ្នារត់ខ្វាត់ខ្វែង

CHANBOKEO.COM

ចេញតាមស្កាត់រកមាណវីយើងភ្លាម ត្បិតបារម្ភចំពោះសុវត្ថិភាព របស់នាងដែលកំពុងធ្វើដំណើរត្រលប់ទៅស្រុក ក្នុងកាលៈទេសៈ ដែលស្រុកទេសកំពុងរងសង្គ្រាមធ្ងន់ធ្ងរ ។ រីឯការសន្ទនារវាង ចាស់ៗទាំងបួនរូបក៏ត្រូវអាក់ខានទៅវិញ ។

និយាយពីស្រីម៉ៅម្តង...

ធិតាចេញមកដល់មាត់ទ្វាររបងផ្ទះ ក៏ហៅរ៉ឺម៉កមួយ ឡើងជិះ សំដៅទៅចំណតឡានក្រុងនៅផ្សារក្រោយឯត្រើយម្ខាងភ្លាម ។ ក្នុង ខណៈនោះ ធិតាមានអារម្មណ៍វិលវល់ណាស់ គិតអ្វីលែងចេញហើយ ក្រៅតែពីបោះជំហានទៅមុខតែម្យ៉ាង លែងដឹងថាតើនាងសំរេចចិត្ត ទាំងតក្កហលនោ ះខុសឬត្រូវ ឬក៏យ៉ាងណាទៅវិញទេ ។ ភ្លាមនោះ នាងក៏ឮសម្លេងកូកហៅពីក្រោយមកថា :

- ម៉ៅ! ឈប់សិនអូន!

ស្រស់កល្យាណងាកបែរក្រោយ ស្រាប់តែប្រទះបុរីជិះកង់របស់ ចិត្រាតាមពីក្រោយនាងយ៉ាងលឿន ។ ធិតាភ្ញាក់ព្រើត នឹកក្នុងចិត្ត តែម្នាក់ឯងថា :

- ពុទ្ធោអើយ! ហើយគេមកតាមយើងធ្វើអីហ្នឹង ?

តែនាងបែរអង្គុយធ្វើមិនដឹង បណ្តោយអោយរ៉ឺម៉កដឹកនាងរហូត ដល់ចំណតឡានឈ្នួល ។ លុះហុចលុយអោយរ៉ឺម៉កហើយ ម៉ៅក៏ ឡើងជិះឡានម៉ុងហ្គួតបន្តទៀត ។ បុរីទំលាក់កង់ចោលព្រូសនៅ កណ្តាលថ្នល់ហក់ឡើងជិះឡានឈ្នួលជាមួយធិតាភ្លាម ដោយគ្មាន និយាយស្តីអ្វីមួយម៉ាត់តទៅទៀតដែរ ត្បិតពេលនោះ គេដឹងថា មាណវីកំពុងមានអារម្មណ៍មិនល្អចំពោះរូបគេ ទោះបីជាគេនិយាយ ក៏នាងមិនស្តាប់នាយឡើយ ។ នរៈរត់ទៅដាក់ខ្លួនអង្គុយចុះក្បែរធិតា ភ្លាម ។ រំពេចនោះ រថយន្តក៏ចេញដំណើរ ។ លោកវិចិត្រក៏បានបរ ឡាននាំចិត្រាមកដល់ចំណតដែរ តែក៏មិនអាចឃាត់អ្វីអ្នកទាំងពីរ បានឡើយ ព្រោះខណៈនោះ រថយន្តបានចេញដំណើរទៅហើយ ។

តាមផ្លូវ ម៉ៅអង្គុយទទូរក្រមាអំបោះស្តើងមួយ ឈ្ងោកមុខ ធ្វើ ស្ងៀមស្ងាត់ សំដែងឥរិយាបថតោះតើយព្រងើយ ចំពោះបុរីដែល អង្គុយក្បែរនោះ ។ នាងខំប្រឹងទប់ចិត្តថាមិនយំ មិនស្រក់ទឹកភ្នែក ឡើយ តែក៏មិនអាចធ្វើបានឡើយ ។ ទឹកភ្នែកចេះតែស្រក់ធ្លាក់ចុះ មកដោយឯកឯង ។ ពេលនោះ បុរីមិនបានដឹងទេ ថានាងស្រក់ ទឹកភ្នែកព្រោះរឿងអ្វី គ្រាន់តែដឹងថាគេជាដើមហេតុដែលធ្វើអោយ

និតាមានអារម្មណ៍មិនល្អ កាលពីព្រលប់ម្សិលមិញ ។

ដោយនឹកអាណិតនិតាព្រួចក្នុងចិត្ត ប៊ុរីក៏លូកដៃទៅចាប់ដៃឆរី កាន់យ៉ាងណែន ស្រាប់តែប្រទះឃើញនាងកំពុងក្តាប់សំបុត្រមួយ ក្នុងដៃ ទំនងជាសំបុត្រមកពីឆ្ងាយ ក៏កាត់យល់ថាប្រហែលជាមាន ដំណឹងអ្វីមិនល្អមកពីស្រុកកំណើតហើយ ។ គេក៏មិនសួរអ្វីអោយរំខានចិត្តរបស់និតាយើងដែរ ។ ម្យ៉ាងទៀត គេកំពុងជិះក្នុងរថយន្ត ឈ្នួលដែលមានផ្ទុកអ្នកដំណើរជាច្រើនសិបអ្នកទៀត ដូច្នេះ ពិតជាមិនមែនពេលវេលាដ៏សមរម្យទេ សំរាប់គេនិយាយអ្វីជាមួយស្រី ម៉ៅ ក្រៅតែពីបណ្តោយអោយពេលវេលាតាមតែដំណើរ ។ ឡាន ក្រុងបរគ្រឿនៗ ដឹកនាំអ្នកដំណើរចេញទៅតាមដងផ្លូវជាតិលេខ៥ សំដៅក្រុងសេរីសោភ័ណ ។

ទិដ្ឋភាពដីភូមិស្រុកទេសតាមដងផ្លូវស្រស់ស្អាតណាស់ ។ ប៉ុន្តែ ថៃដន្យអ្វី ខ្មែរក្រហមបានកប់មីនតាមផ្លូវ ធ្វើឲ្យគ្រោះថ្នាក់ចរាចរ រាប់មិនអស់ ។ រីឯដងផ្លូវជាតិបានក្លាយជាក្រហេងក្រហូងពិបាកធ្វើ ដំណើរក្រៃលែង ។ ម្យ៉ាងទៀត សម័យនោះ គេច្រើនធ្វើដំណើរតែ ពេលថ្ងៃរះពេញពន្លឺមានចរាចរទ័ពតាមផ្លូវមមាញឹកទេ ។ ពុំនោះ សោត ម្នាក់ៗលាក់ពួនអាត្មាស្វែងសុវត្ថិភាពហើយ ត្បិតខ្មែរក្រហម មិនសូវយោគយល់នរណាប៉ុន្មានឡើយ បើសិនពួកវាចេញមុខមក ស្កាត់ដំណើររចរាចររបស់អ្នកស្រុកម្តងៗ ។

តាមផ្លូវ រថយន្តក៏ឈប់ដាក់អ្នកដំណើរចុះឡើង ឡើងចុះ តាំង ពីម្តុំក្បាលខ្មោច អូរតាគី រហូតដល់មង្គលបុរី ភ្នំតូចភ្នំធំ ទំរាំដល់ សេរីសោភ័ណ ថ្ងៃត្រង់ល្មម ។

- ម៉ៅ ! ចុះញុំាបាយសិនទេអូន ? ថ្ងៃត្រង់ហើយ ! បើសិនមិនញុំា ប្រយត្ន័ក្រែងលោអូនឈឺលាប់ដងឹមកវិញណា៎ ។

ប៊ុរីខ្សិបដាក់ត្រចៀកមាណវី ប៉ុន្តែ នាងមិនរវល់នឹងឆ្លើយទេ ។ អ្នកដំណើរខ្លះចុះពីរថយន្ត ទៅរកទទួលទានអាហារនៅក្នុងផ្សារ ។ ខ្លះទៀតក៏អើតកទិញចំណីនិងបាយកញ្ចប់តាមបង្អួចឡាន ។ ប៊ុរីក៏ សំរេចចិត្តទិញអាហារពីកញ្ចប់តាមចន្លោះបង្អួច ព្រោះគេមិនដាច់ ចិត្តដើរចោលអោយនិតានៅអង្គុយលើរថយន្តតែឯង ។

- ណែះ ! ញុំាមួយម៉ាត់សិនទៅ កុំអោយរូបកាយយើងទ្រុឌទ្រោម ក្រែងមានការអ្វីតាមផ្លូវម្តេចម្តា យើងមានបាយកល់ពោះខ្លះ ។

CHANBOKEO.COM

បុរីឱ្យបទទូចអោយស្រីម៉ៅបរិភោគ ។ ថៃដន្យអ្វី នារីមិនឃ្លាន អាហារទេ
ត្បិតក្នុងចិត្តរបស់នាងកំពុងតែគិតវិល់វល់ដល់ម្តាយនៅ ឯស្រុកឯណោះ ។
ឃើញនាងមិនព្រមបរិភោគ បុរីក៏ខ្ចប់បាយទុក វិញមិនបរិភោគដូចគ្នាដែរ ។
មួយសន្ទុះក្រោយមក រថយន្តក៏ចេញ ដំណើរទៅមុខទៀត បែរទិសសំដៅខេត្តសៀមរាប ។
ការពិត បុរី មិនដែលធ្វើដំណើរតាមផ្លូវនេះទេ តាំងពីក្មេងមក ព្រោះគេធ្លាប់តែ
ជិះទូកតាមទន្លេទៅសៀមរាបតែប៉ុណ្ណោះ ។ លុះស្រុកទេសកើត សង្គ្រាមរីកវរ
គេជិះតែយន្តហោះធ្វើដំណើរទៅមកជាជាង ។ នេះ ជាលើកទីមួយហើយ
ដែលគេធ្វើដំណើរកាត់តាមដំបន់នេះ ។

លុះរថយន្តបរឡើងភ្នំជញ្ជាំងមួយស្របក់ បុរីសង្កេតឃើញថា
ព្រៃព្រឹក្សាតាមដងផ្លូវកាន់តែមានសភាពក្រាស់ឡើងៗ រីឯចរាចរ វិញក៏កាន់តែរលោះទៅៗ
នៅសល់តែឡានឈ្នួលបីបើកបន្តកន្ទុយ គ្នាតែប៉ុណ្ណោះ ។ ពេលនោះ
គេនឹកពិភាល់ក្នុងចិត្តយ៉ាងណាមិនដឹង ទេ ។ ពេលនោះ
បេះដូងរបស់គេលោតរណ្តំឱបខាក់ៗខុសប្រក្រតី តែម្តង ។ បន្តិចមក រថយន្តក៏ឆ្លងខ្នងភ្នំជញ្ជាំង
សំយុងក្បាលធ្វើ ដំណើរចុះទៅដីរាបវិញ ។ នៅមិនទាន់ដល់ភូមិជប់ផង ស្រាប់តែ
បុរីឮសូរគ្រាប់កាំភ្លើងលាន់ឡើង ផូងៗ យ៉ាងខ្ទ័រខ្ទារមកពីគ្រប់ទិស តែម្តង ។ ភ្លាមនោះ
ស្រាប់តែរថយន្តរេចង្កូត ហើយអ្នកបើកបរក៏ ស្រែកឡើងថា :
- ប្រយត្ន័! យើងត្រូវខ្មែរក្រហមឡោមពទ្ធ័បាញ់ពួកយើងហើយ ។

ផូង! កង់ឡានខាងមុខមួយផ្ទុះឡើង ទាញរថយន្តអូសធ្លាក់ ស្ទាមភ្លោះតាមដងផ្លូវ
គ្រវីអ្នកដំណើរទាំងឡាយម្តងទៅឆ្វេង  ម្តង ទៅស្តាំផ្អើលពេលឡាន ។
ទាំងអស់គ្នាក៏ស្រែកខ្ញៀវខ្ញារំពងឡើង ។
បុរីបែរមើលស្រីម៉ៅឃើញនាងមានទឹកមុខតក់ស្លុតមហិមា ។ គេក៏
ចាប់ធិតាអោបផ្ទាប់នឹងទ្រូងកុំអោយនាងភិតភ័យ ។ រថយន្តរត់ទាំង
ក្រឡេកក្រឡុកលឿនផងយឺតផងតាមដំណើរ ។ បុរីអត់មិនបានក៏
ស្រវាអោបស្រីម៉ៅលោតចេញតាមបង្អួចទាំងប្រថុយ... បើនៅលើ ឡានក៏នឹងស្លាប់ដោយគ្រោះថ្នាក់
តែបើលោតចេញសង្ឃឹមថានឹង មានឱកាសរស់ខ្លះ ។ រំពេចនោះ ស្រាប់តែ មានគ្រាប់ផ្លោងធំមួយ
ហោះមកបុកចំច្រមុះរថយន្ត ផ្ទុះលាន់ក្ញុងឡើងយ៉ាងខ្ទ័រខ្ទារ ធ្វើឲ្យ
តួរថយន្តឆ្លេឆ្លារេចាកផ្លូវជាតិចូលព្រៃប្រោក ផ្ងៀងក្រឡាប់បះជើង ច្រងាងតែម្តង ។ ភ្លាមនោះដែរ

គ្រាប់កាំភ្លើងតូចធំក៏ធ្លាក់ចុះយ៉ាង ប្រសាចដូចភ្លៀង ។ ប៊ុរីរមៀលធ្លាក់ចុះមកតាមជំរាលភ្នំ អោបស្រី ម៉ៅជាប់នឹងដើមទ្រូងឥតរបេះ រហូតដល់ធ្លាក់ក្នុងដីកន្លុករណ្តៅ មួយ ។ បន្តិចមក គេក៏ងើបឡើង ចាប់អូសដៃធិតារត់កាត់ព្រៃ :

- អូនងើបរត់ទៅរួចទេ ម៉ៅ ?

ប៊ុរីសួរម៉ៅ ប៉ុន្តែធិតាយើងមុខស្លេកណាស់ និយាយលែងចេញ ទៅហើយព្រោះតែការតក់ស្លុតដ៏មហិមា ។ ភ្លាមនោះឆរីក៏ទន់ជង្គង់ ដួលប្រួសទៅលើដី ។ ប៊ុរីបុកពោះភិបៗតែម្តង ។ គេក៏ងើបឡើង លូនចេញពីរណ្តៅហើយងើបក្បាលបែរចុះបែរឡើង សម្លឹងមើល ទិសជុំវិញខ្លួន នឹងអាលនាំស្រីម៉ៅរត់គេចខ្លួន ស្រាប់តែមានគ្រាប់ កាំភ្លើងធំមួយហោះមកធ្លាក់ចុះក្បែរនោះ ផ្ទុះឮសូរក្ទុងៗយ៉ាងខ្លាំង ហ៊ុំងអស់ត្រចៀក ឆេះភ្លើងសន្ធោកំពស់មេឃ ។ ភ្លាមនោះ ប៊ុរី មានអារម្មណ៍ថាក្រហាយសាច់ ក្រហាយមុខក្រហាយភ្នែកយ៉ាងខ្លាំង ដោយសារចំហាយផ្សែងគ្រាប់ផ្ទុះនោះ រួចហើយ គេក៏ដួលត្នោល ទៅលើដី ។ ដោយក្តីបារម្ភចំពោះសុវត្ថិភាពរបស់ម៉ៅពេក មាណព ក៏ខំងើបប្រវេប្រវាបើកភ្នែករកមើលនាង ។ តែគួរអនិច្ចាពន់ពេក ណាស់ ពេលនោះភ្នែកទាំងគូរបស់គេ មើលអ្វីលែងឃើញហើយ ក្រៅតែពីមានអារម្មណ៍ថាឈឺក្រហាយខ្លាំងណាស់ មិនខុសពីអំណាច ម្ទេសរោលពេញប្រស្រីនោះឡើយ ។ ឯឯងខ្លួនវិញក៏ចុកចាប់ស្មើរ ទ្រាំមិនបាន :

- ម៉ៅ ! អូននៅឯណា ?... តើអូនយ៉ាងណាហើយម៉ៅ ?

គេលូនប្រវាប្រវាស្ទាបរាវរកខ្លួនធិតា ប៉ុន្តែគេចំណាំមិនបានទេ ថានាងនៅចម្ងាយណាពីខ្លួនគេ នៅម្តុំខាងណា ។ ខណ:នោះ នរ: បាន ឮសំដីមនុស្សស្រែកកាត់ព្រៃរំពងមកថា :

- ពួកមិត្តនើរបង្ហើយជីវិតមនុស្សទាំងនេះឲ្យអស់ទៅ កុំអោយវា ងើបមកតដៃយើងនៅថ្ងៃក្រោយទៀតបាន ហើយហ្វូងមិត្តខាងនេះ នាំគ្នាទៅជួយជញ្ជូនឥវាន់ចេញពីឡាន យកទៅជំរំយើងវិញ ។

ប៊ុរីញាប់ញ័រក្នុងចិត្តណាស់ មិនដឹងថាខ្លួនត្រូវក្ស័យថ្ងៃនេះដោយ សារពួកចោរព្រៃ ឬក៏ខ្មែរក្រហមទេ ។ ចំណែកម៉ៅវិញ ក៏បាត់ពីដៃ របស់នាយទៀត ។ គេដេកសន្លឹងនៅលើដី នឹកសង្វេគអនិច្ចានៅ ក្នុងចិត្តតែម្នាក់ឯង រួចដកដង្ហើមកាន់តែខ្សោយទៅៗ ក្នុងខណ: ដែលគ្រាប់កាំភ្លើងនៅតែបន្តសម្លេងផ្ទុងផាំងៗ ឥតឈប់ឈរនៅ ឡើយ :

- លោកប៉ា ! កូនប្រហែលជាមិនបានវិលទៅជួបលោកប៉ាវិញទេ...

CHANBOKEO.COM

ម៉ៅ! អូននៅកន្លែងណា... សូមអោយអូនចៀសផុតគ្រោះសាហាវ គ្រានេះផង..
ឱ! ខ្មែរអើយ! ហេតុដូចម្តេចក៏ប្រហារតែខ្មែរគ្នាឯង ? ហេតុអ្វីបានយើងកើតមកមានរូបជាមនុស្ស
ប៉ុន្តែបែរជាមានចិត្ត ទុស្តសាហាវចំពោះមនុស្សដូចគ្នាមិនខុសឡើយពីសត្វតិរច្ឆានយ៉ាង ដូច្នេះ ?
កាលបើខ្មែរច្បាំងគ្នាឯង ស្លាប់ទាំងសងខាងអស់ទៅ តើ បាននរណារក្សាជាតិខ្មែរតទៅទៀត ?
ឬក៏យើងពេញចិត្តនឹងអោយ បរទេសលុកលុយកាន់កាប់ប្រទេសរបស់យើងជាជាង ?

ប៊ុរីខ្សិបហៅស្រីម៉ៅខ្សោយទៅៗកណ្តាលព្រៃតែម្នាក់ឯង...

- ម៉ៅអើយ... បងស្តាយណាស់ដែលបងជួយការពារអូនមិនបាន... បើជាតិក្រោយមានមែន
សូមអោយបងមានឱកាសជួបអូនសាជាថ្មី ម្តងទៀតផង... ណា៎ម៉ៅ! ...
ម៉ៅ....បងស្រលាញ់អូន...!!

ទឹកភ្នែកពីរតំណក់បានហូរចុះចាកនេត្រារបស់នរៈជាចុងក្រោយ
នៅមុនពេលគេបិទភ្នែករលត់ស្មារតីទៅ... មាត់គេក៏នៅតែដង្ហោយ
រកស្រីម៉ៅរហូតដល់គេមិនអាចហៅឈ្មោះនាងបានតទៅទៀត...

0000000000000000000

00000

0

CHANBOKEO.COM

# វគ្គទី៩
# អសន្តិសុខ

មិនដឹងអស់ពេលយូរប៉ុនណាទេ...

បុរីខំបើកនេត្រាសាជាថ្មី... ប៉ុន្តែគេនៅមើលមិនឃើញដដែល រួចហើយមានអារម្មណ៍ថា គេកំពុងគេងលើខ្នើយ មានភួយដណ្តប់ ពីលើខ្លួនទៀតផង ។ គេយកដៃស្ទាបភ្នែក ឃើញហើមប៉ោងស្តួរ យ៉ាងធំ ។ រីឯសាច់មុខនៅក្រហាយមិនទាន់បាត់នៅឡើយ ។ មែន ហើយ នរៈមិនទាន់ស្លាប់នៅឡើយទេ ។ បុរីក៏ប្រែខ្លួន បំរុងចង់ ងើបអង្គុយ ស្រាប់តែមានអារម្មណ៍ថាឈឺអស់ពេញទាំងខ្លួនស្ទើរទ្រាំ មិនបាន ។

រំពេចនោះ ស្រាប់តែនាយឮសូរសិរីបជើងដើរចូលមក ។ គេក៏ ប្រញាប់សួរភ្លាម :

- អត់ទោស អ្នកម្ចាស់ផ្ទះ ! ពេលនេះ តើខ្ញុំនៅទីណាដែរ ?
- ចាស បងប្រុសនៅផ្ទះពុកម៉ែខ្ញុំ តែពុកចេញទៅដើរយាមល្បាត នៅក្រៅភូមិហើយ ចំណែកម៉ែទៅជួយអ្នកស្រុកព្រោះមានអ្នក របួស ច្រើនណាស់កាលពីម្សិលដែលត្រូវខ្មែរក្រហមស្ទាក់ប្លន់ ។ នេះបើកុំតែមានកងទាហានចេញទៅជួយ ម្ល៉េះសមស្លាប់អស់គ្រប់ គ្នាទៅហើយ..

បុរីស្តាប់សម្លេងទៅដឹងថាជាសម្លេងក្មេងស្រីជំទង់ម្នាក់ ។

- ហើយចុះនាងតូចឈ្មោះអីដែរ ?
- ឈ្មោះភី ចាស !
- ហើយនាងតូចនៅផ្ទះតែម្នាក់ឯងទេ ?
- មិនមែនទេ នៅពីរនាក់បងស្រី តែគាត់គមិនចេះនិយាយអីទេ ។
- ពុទ្ធោ ! គួរអោយអាណិតណាស់ ។

ភ្លាមនោះ បុរីមានអារម្មណ៍ថា ភ្នែកខ្លួនក៏ក្រហាយ ស្បែកមុខក៏ ក្រហាយយ៉ាងចម្លែក ។ គេខំប្រឹងងើបអង្គុយតែក៏ងើបមិនរួចសោះ

CHANDBOKEO.COM

ព្រោះនឹងឆោងរសោះរសេះអស់ដៃជើងយ៉ាងណាមិនដឹង ។ រំពេច នោះ
គេក៏នឹកដល់ម៉ៅព្រួចក្នុងចិត្តតែម្តង ។

- នាងតូច... តើប្អូនដឹងទេ ថានរណាជាអ្នកសង្គ្រោះបងយកមក ទីនេះ ?
- ភីមិនដឹងទេ គ្រាន់តែដឹងថា ពុកនិងអ្នកស្រុកបានជួយរំដោះអ្នក របួសពីម្តុំជើងភ្នំជញ្ជាំង
តែភាគច្រើនស្លាប់អស់ហើយ នៅរស់តែបី បួននាក់ទេ ។
បងប្រុសសំណាងហើយដែលរួចជីវិតមកបាន ។

នាងតូចឆ្លើយផង ដើរចេញទៅផង ។ ប៊ុរីក៏ឆ្មេចគេងទៅវិញ ដោយដួងចិត្តតប់ប្រមល់ :

- ម៉ៅអើយ ! ពេលនេះ អូនមានសុខទុក្ខរបស់អូនយ៉ាងណាទៅ ហើយ ?
តើអូនគេចផុតពីគ្រោះកំណាចគ្រានោះដែរឬទេ ?

មាណពគេងស្តូកស្តឹងនៅលើគ្រែដោយក្តីអស់សង្ឃឹម :

- បងសោកស្តាយណាស់ម៉ៅ ដែលយើងត្រូវប្រទះនឹងឧប្បត្តិហេតុ ធ្វើអោយយើងបែកគ្នា...
សូមទេវតាជួយតាមថែរក្សាអូនកុំខាន !

ភ្លាមនោះ ប៊ុរីមានអារម្មណ៍ថា មានដៃមួយមកស្ទាបថ្ងាសរបស់ នាយ ហើយក៏ស្ទាបទ្រូង ។
គេភ្ញាក់ព្រើត នឹកក្នុងចិត្តថា ប្រហែល ជានាងតូចភីមកមើលអាការៈរបស់នាយហើយ ។
ស្រាប់តែជននោះ យកក្រណាត់ជ្រលក់ទឹកក្តៅមកជូតខ្លួនអោយមាណព ជូតរបួសថែម
ទាំងផ្លាស់ក្រណាត់រុំរបួសអោយនាយផង ។ គេអត់មិនបាន ក៏សួរ ជននោះថា :

- លោកគ្រូពេទ្យមែនទេ ?

តែជននោះនៅមិនឆ្លើយទេ ។ គេក៏លូកចាប់ដៃជននោះដែល កំពុងរុំរបួសអោយនាយសាជាថ្មី
ស្រាប់តែគេភ្ញាក់ព្រើត ចាប់ភ្លឹកថា ដៃនោះតូចទន់ដូចដៃស្រី ។

- សូមទោស ! ខ្ញុំគ្មានចេតនាទេ ការពិត មកពីខ្ញុំឈឺផ្សាមុខរបួស ពេក
អត់មិនបានទើបចាប់ដៃអ្នកនាង...

ពេលនោះ ប៊ុរីដូចជាចាប់ភ្លឹកហើយថាជននោះគឺជានាងគ បង ស្រីរបស់នាងតូចភី ។
អញ្ចឹងតើហ៎ បានជានាងមិនស្តីតបអ្វីមករក នាយវិញសោះ ។ បន្តិចមក
នាងគក៏ជួយលើកប៊ុរីអោយអង្គុយ
ឡើងរួចហើយក៏ចាប់ដៃបុរសដាក់ថ្នាំដាក់កែវទឹកអោយនាយលេប ។ ប៊ុរីក៏ទទួលយកលេបភ្លាម
ព្រោះកំពុងតែឈឺចាប់ក្នុងខ្លួនស្ទើរទ្រាំ មិនបាន ។ នៅក្នុងចិត្តគេវិញ
នរៈនឹកពិភាល់យ៉ាងណាមិនដឹងដែល ខ្លួនបានមកស្នាក់នៅផ្ទះអ្នកស្រុកចម្លែកមិនដែលស្គាល់

CHANBOKEO.COM

ហើយថែម ទាំងបានទទួលការថែទាំពីម្ចាស់ផ្ទះយ៉ាងល្អទៀតផង ។ ហេតុអ្វីគេ
មានចិត្តល្អនឹងរូបនាយម្ល៉េះ ? នេះឬសន្តានចិត្តខ្មែរជនបទ ? ពិត
ជាគួរអោយកោតសរសើរណាស់ដែលគេមានទឹកចិត្តចេះជួយមនុស្ស
ដូចគ្នាក្នុងគ្រាមានគ្រោះអាសន្ន ។

គួរអោយឆ្ងល់ណាស់! កាលពីម្សិលមិញ ប៊ុរីបានប្រទះខ្មែរមួយ ក្រុមដែលមានចិត្តសាហាវ
ឃោរឃៅបាញ់សម្លាប់តែខ្មែរគ្នាឯង ។ ប៉ុន្តែថ្ងៃនេះ
គេបែរជាមកជួបមនុស្សដែលសង្គ្រោះមនុស្សដូចគ្នាឲ្យ ផុតពីគ្រោះថ្នាក់ទៅវិញ...
គិតៗទៅពិភពលោកនេះហាក់ដូចជាគ្មាន យុត្តិធម៌អ្វីសោះ ។ អ្នកខ្លះមានចិត្តដូចសត្វតិរច្ឆាន
អ្នកខ្លះទៀតមាន
ចិត្តជាព្រះវេស្សន្តរ ប្រេតនិងមនុស្សរស់នៅក្នុងភពមួយជាមួយគ្នា..
ពិតជាគួរអោយព្រឺខ្លាចមែន ។

សំណាងល្អដែរ ប៊ុរីមិនមានគ្រោះថ្នាក់បាក់ឆ្អឹងបាក់ឆ្អែងទេគ្រាន់
តែបានរងជាតិឧស្ម័នពុលរបស់គ្រាប់ផ្លោង បណ្តាលអោយរលាកខ្លួន រលាកភ្នែក
ហើយគ្រាំក្នុងខ្លះប៉ុណ្ណោះ ។ ព្រលប់បន្តិច ម្ចាស់ផ្ទះក៏ ត្រលប់មកដល់វិញទាំងពីរនាក់ប្តីប្រពន្ធ ។

- យ៉ាងម៉េចហើយ ក្មួយប្រុស ? បានគ្រាន់បើខ្លះទេហ៍ ?

បុរសជាម្ចាស់ផ្ទះសួរ ។

- បាទ! នៅក្រហាយពេញខ្លួន... តែមិនអីទេ ប្រហែលពីរបីថ្ងៃ ទៀតជាសះស្បើយវិញហើយ ។
អរគុណពូខ្លាំងណាស់ ដែលបាន ជួយសង្គ្រោះជីវិតរបស់ក្មួយអោយផុតគ្រោះថ្នាក់ ។
- អូហ៍! មិនបាច់អរគុណទេ ។ ការពិត ពូមិនបានទៅយកក្មួយពី ព្រៃនោះទេ
គឺកងទ័ពយើងគេទៅរំដោះមក ហើយក៏សែងយកក្មួយ មកផ្ញើអ្នកភូមិយើង
រួចពូក៏ចូលរួមចំណែកទទួលរក្សាក្មួយទៅ ។
- ហើយចុះលោកពូមានដឹងដំណឹងពីនារីម្នាក់ឈ្មោះម៉ៅ ដែលជា
អ្នកដំណើរក្នុងឡានក្រុងធំមួយនោះទេ បាទ ?
- អូហ៍ ហើយនាងត្រូវជាអ្វីនឹងក្មួយដែរ ?

ប៊ុរីនៅអេះអុញមិនដឹងឆ្លើយយ៉ាងណាក៏ប្រថុយនិយាយថា :

- បាទ! ជាប្រពន្ធខ្ញុំ... ខ្ញុំបារម្ភពីសុវត្ថិភាពរបស់នាងណាស់ ។

CHANBOKEO.COM

- បើអញ្ជឹង ចាំពូសួរដំណឹងពីអ្នកភូមិអោយ ត្បិតយើងចែកគ្នាថែ រក្សាអ្នករបួសផ្សេងៗគ្នា ទំរាំយើងអាចជួយរកមធ្យោបាយជូនក្មួយ ត្រលប់ទៅផ្ទះវិញបាន សង្ឃឹមថាប្រពន្ធក្មួយផុតពីគ្រោះថ្នាក់ដូចគ្នា ដែរចុះ ។

ពេលនោះ នាងភីចូលមកហៅ :

- ពុក! ម៉ែ! អញ្ជើញពិសារបាយ ។

ក្រុមគ្រួសាររបស់ម្ចាស់ផ្ទះក៏នាំគ្នាតម្កង់ជុំវិញស្ពកបាយ ។ ភ្លាម នោះ បុរីមានអារម្មណ៍ថា នាងគបានមកជួយលើកខ្លួននាយឲ្យងើប អង្គុយផ្អែកនឹងខ្នើយ បន្តិចមក នាងក៏ដួសបាយបញ្ចុកមាត់នរ: ។ បុរីទទួលយកអាហារទាំងដួងចិត្តរំជើបរំជួល :

- ហ៊ឺ! ហេតុអ្វីក៏យើងមានរាសីធ្លាក់ចុះដល់ថ្នាក់គេបញ្ចុកបាយយ៉ាង នេះ ? ប៉ុន្តែ... បើសិនជាអ្នកបញ្ចុកបាយយើងនេះ ជាស្រីម៉ៅវិញ យើងប្រហែលជាមានសេចក្តីសុខក្នុងចិត្តយ៉ាងស្ងប់មិនខាន ។ ម៉ៅ អើយ... អូននៅឯណា ? សុខសប្បាយឬក៏យ៉ាងណា ? សូមទេវតា ជួយតាមថែរក្សាអូនកុំខាន...

គេបរិភោគបាយបណ្តើរ នឹកដល់ឆវីម្ចាស់ចិត្តបណ្តើរ ។ ថ្វីបើ ពេលនោះ ក្រពះរបស់គេកំពុងកញ្ជ្រោលរកអាហារខ្លាំងយ៉ាងណា ក៏ដោយ ហើយទោះបីជារសជាតិអាហារសៃនឆ្ងាញ់យ៉ាងណាក៏ដោយ ក៏បុរីមានអារម្មណ៍ថា គេកំពុងតែលេបដុំដីដុំគ្រួសទៅវិញ ព្រោះចិត្ត របស់គេនឹកទៅរកតែស្រីម៉ៅមិនមានលោះមួយនាទីណាឡើយ ។

បីបួនថ្ងៃកន្លងទៅ...

បុរីបានគ្រាន់បើខ្លះហើយ ប៉ុន្តែនៅមិនទាន់បាត់ហើមភ្នែកនៅ ឡើយទេ ។ គេនៅតែមើលអ្វីមិនទាន់ឃើញដដែល ចេះតែស្រវាំង ប៉ុន្តែអាចមើលអ្វីឃើញស្រមេលោស្ទុងៗបន្តិចៗជាងមុន ។ ឯមុខ របួសលើខ្លួនក៏ហាក់ដូចជាចាប់ផ្តើមសះជាបន្តបន្ទាប់ ។ គេងើប ដើរបានហើយ គ្រាន់តែមិនអាចចេញទៅណាបានឆ្ងាយនៅឡើយ ។ ម៉្ញ៉ៗ គេទន្ទឹងពេលវេលាដែលគេអាចជាភ្នែកមកវិញ នឹងអាល ចេញតាមរកស្រីម៉ៅបណ្តូលចិត្តរបស់គេវិញ ។

ថ្ងៃនេះ ម្ចាស់ផ្ទះចេញទៅបំពេញការងារដូចធម្មតាសល់តែនាង តូចភីចាំផ្ទះ ។ បុរីអផ្សុកពេក ក៏សួរនាងថា :

CHANBOKEO.COM

- ប្អូនភីមានចូលរៀនសាលាអីហ្នឹងគេទេ ?
- ចាស! ថីមិនរៀន តែអាទិត្យនេះ សាលាវ៉ាកងហើយ ទើបអាច មកលេងផ្ទះបាន ។
- អូហ៍ ហើយចុះប្អូនរៀននៅឯណាដែរ ?
- ចាស នៅស្វាយ ត្រូវប្រលងឌីប្លូមឆ្នាំក្រោយហើយ ។
- អូហ៍ រៀនបានខ្ពស់ណាស់តើហ៍ ។ ហើយចុះម្តុំភូមិប្អូននេះអត់ មានសាលាទេ បានទៅរៀនឆ្ងាយផ្ទះម្ល៉េះ ?
- អត់មានទេ មានតែបថមសិក្សា ។ ពេលសាលាចូលកងវិញ ខ្ញុំក៏ត្រូវទៅនៅស្វាយជាមួយបងប្អូន បែកពុកម៉ែទៀតហើយ ។
- ហើយចុះបងគរបស់ប្អូននោះ គេរៀនកើតដែរ ?
- ហ៉ៃសៗ! បងគរៀនអីកើត បើនិយាយមិនកើតផង ? សព្វថ្ងៃ គាត់នៅផ្ទះ យាមតែមាន់ទាទេ បងអើយ ។

ពេលនោះ ប៊ុរីនឹកអាណិតនាងគព្រួចក្នុងចិត្តតែម្តង ។ មែន ហើយ ប៉ុន្មានថ្ងៃនេះ នាងគបានមករក្សាថែទាំរូបគេទាំងព្រឹកល្ងាច តាំងពីបញ្ចុកបាយ រហូតជូតសំអាតខ្លួន បោកខោបោកអាវអោយ សព្វគ្រប់ទាំងអស់ មិនខុសពីសាច់ញាតិសន្តានម្នាក់ ថ្វីបើនាងមិនសូវមកជិតៗនោះអោយនាយហៅពឹងយ៉ាងណាក៏ដោយ ក៏នាងតែងតែមកអើតតាមម៉ោងតាមវេលាមិនដែលដាច់ ហាក់ដូចជាគេ បានណាត់ម៉ោងទុកអញ្ចឹង ។ ចំណែកម្ចាស់ផ្ទះវិញ ក៏មានចិត្តថ្លើម ទូលំទូលាយគួរអោយកោតគោរពបំផុត ។ គេបានទទួលរក្សាប៊ុរី ហាក់ដូចជាសាច់ញាតិរបស់គេម្នាក់ដែរ ។ រីនាងតូចភីក៏សំដីពិរោះ សមជាក្មេងដែលបានទទួលការអប់រំយ៉ាងប្រពៃ ។ ហ៊ឺ! ហេតុអ្វីក៏ គ្រួសារគេកក់ក្តៅម្ល៉េះហ្ន៎ ថ្វីបើគេរស់នៅជនបទដាច់ស្រយាល ? ចំណែករូបនាយវិញ មួយជីវិតនេះ រកភាពកក់ក្តៅមិនឃើញនឹងគេ សោះ ។ ម្តាយនរៈមានជំងឺតាំងពីគេនៅក្មេង ហើយក៏ធ្វើមរណកាលទៅ ។ ប៊ុរីក៏ត្រូវចាកចេញពីផ្ទះព្រោះគេមិនអាចទទួលយក ម្តាយថ្មីបាន ។ គេបានចេញទៅរស់នៅឆ្ងាយផ្ទះ អស់ជាយូរឆ្នាំ ។ ថ្មីៗនេះ គេត្រលប់មកផ្ទះវិញ តែជីវិតរបស់គេនៅតែរកពន្លឺ សេចក្តីសុខក្នុងចិត្តមិនបានដដែល...

រសៀលនេះ នាងតូចភីជិះកង់យកឥវ៉ាន់ទៅផ្ញើញាតិម្នាក់ដែល ទើបឆ្លងទន្លេ ទុកអោយប៊ុរីនៅផ្ទះតែឯង ។
- បងកុំទៅណាអោយសោះ ប្រហែលជាមួយម៉ោងទៀត ខ្ញុំមកដល់ វិញហើយ ។

CHIANBOKEO.COM

ផ្តាំហើយនាងតូចធាក់កង់ចេញទៅ ។ ប៉ុរីគេងម្នាក់ឯង អផ្សុក ពេកក៏ងើបរាវផ្លូវដើរចេញមកក្រៅ ស្រាប់តែភ្លាត់ជើងជាន់ខុសកាំ ជណ្តើរ ធ្លាក់មកដីរ៉ូទាំងជំហរ ។ ពេលនោះ គេមានអារម្មណ៍ថារូប គេបានធ្លាក់ទ្រោបសង្កត់លើខ្លួននារីម្នាក់ ដែលកំពុងអង្គុយនៅកាំ ជណ្តើរខាងក្រោម ។ គេមានអារម្មណ៍ថា ច្រមុះរបស់គេបានទៅ ទង្គិចនឹងកញ្ចឹងកខាងក្រោយរបស់ធិតា ហើយស្រាប់តែចាប់ភ្លឹកនូវ ក្លិនខ្លួនដ៏ក្រអូបប្រហើររបស់នារីម្នាក់នោះ ។ មែនហើយ! គេធ្លាប់ ចំណាំក្លិននេះពីមុនមកនៅលើខ្លួននារីម្នាក់ ដែលបេះដូងរបស់គេ កំពុងដង្ហោយហៅ ។ មាណពស្រវាចាប់នាងជាប់រួចឧទានឡើងថា:

- ម៉ៅ! គឺអូនមែនទេ? ម៉ៅគឺ... អូនសុខសប្បាយទេ មែនទេ?

មាណពត្រេកអររំភើបរហូតចង់ស្រក់ទឹកភ្នែក ស្រាប់តែនារី នោះបម្រះចេញយ៉ាងអស់ទំហឹងហើយរត់គេចចេញទៅ ។ ប៉ុរីស្ទុះ ងើបស្រែកពីក្រោយថា :

- ម៉ៅ... មកវិញអូន... កុំទៅណាចោលបង... ម៉ៅ...!

អនិច្ចា! មាណវីនោះមិនបានវិលត្រលប់មកវិញទេ ។ មាណព នៅឈរកណ្តាលថ្ងៃក្តៅពេលកម្លាំង មិនព្រមចូលក្នុងផ្ទះវិញឡើយ មាត់វិញស្រែកហៅរកម៉ៅមិនឈប់...

- ម៉ៅ! អូនឈប់ខឹងនឹងបងបានទេ... បងសូមអង្វរណា៎ម៉ៅណា៎! បងសូមអង្វរ ឈប់ធ្វើបាបចិត្តបងបានទេអូន...?

ថ្វីបើអូនខឹង...

- ថ្វីបើដឹងហើយថាអូនខឹង តែបងនៅរឹងស្រលាញ់អូន
មិនប្រែប្រួលចិត្តគេចពីស្ងួន ស្រឡាញ់និមន្ទួនទ្វេជាដប់ ។
- ដឹងហើយថាអូននៅខ្នក់ខ្នាញ់ បងរិតស្រឡាញ់ពៅសំណព្វ
មិនខឹងតបទេស៊ូខាំមាត់ ស្នេហ៍នារីរតន៍ឥតផ្លាស់ប្តូរ ។
- ដឹងហើយថាអូននាងខកចិត្ត បងរិតអាណិតថែមអាសូរ
បេះដូងរហែកមិនស្រែកថ្ងូរ ជីវិតបងប្តូរដើម្បីអូន ។
- ដឹងច្បាស់ថាអូននឹងប្រណី ដល់ចិត្តភក្តីចាំស្រីស្ងួន
ដឹងថាអូនពិតវិលជួបជូន ជួបគ្នាសាងខ្លួនស្នេហ៍មង្គល....

CHANBOKEO.COM

រំពេចនោះ គេមានអារម្មណ៍ថាបេះដូងរបស់គេលែងចង់ធ្វើការ ទៀតហើយ ហើយក៏ងងឹតមុខឈឺងដួលប្រូសកណ្តាលទីធ្លាក្រោម កំដៅថ្ងៃនឹសែនក្តៅមហិមា ។

ប៉ុរីប្រែខ្លួនមកវិញ ឮសម្លេងនាងតូចភីស្រដីថា :

- បងប្រុស គាត់គ្រុនក្តៅមមើមមាយទៀតហើយពុក!

- បើអញ្ចឹង បន្តិចទៀតពេលម៉ែកូនមកពីធ្វើការ អោយគេចាក់ថ្នាំ បន្តិចមើល៍ ក្រែងបានគ្រាន់បើវិញ ។

ប៉ុរីស្រែកសួរពូម្ចាស់ផ្ទះ :

- លោកពូ... ស្រីម៉ៅគេបានមកដល់ទីនេះណ៎ាលោកពូ... គេមិន មានគ្រោះថ្នាក់អ្វីទេ ។

- ហ្អ៎ាក! បើប្រពន្ធក្មួយមកដល់ទីនេះមែន ម៉េចក៏គេមិននៅជួប ក្មួយ ? តើគេគេចចេញទៅណ៎ាវិញ ? សង្ស័យតែក្មួយគេងយល់ សប្តិមមើមមាយផ្តេសផ្តាសហើយ ។ នែ៎ក សម្ងំយកកម្លាំងសិនទៅ បន្តិចទៀត មីងឯងមកចាក់ថ្នាំអោយហើយ ។

ប៉ុរីដាក់ខ្លួនលើខ្នើយវិញ ទាំងមិនអស់ចិត្ត ត្បិតគេចាំច្បាស់ ណាស់ថាគេមិនបានយល់សប្តិមមើមមាយទេ ។ នារីម្នាក់នោះគឺជា ម៉ៅឥតក្លែងក្លាយ ។ ប៉ុន្តែ... តើអោយនាយក្រោកដើររកនាងឯណា ទៅ កាលបើនាយមិនទាន់ជាជំងឺភ្នែកផងនោះ ? បន្តិចមក គេក៏ លួចដើបស្រាយក្រណាត់រុំភ្នែក សាកល្បងបើកភ្នែកមើល ។ ចង្រៃ អី ភ្នែករបស់នាយនៅតែហើមស្តុរងដែល មិនឃើញស្រកស្រុត ទៅណាសោះ ។ សម្លឹងអ្វីមិនឃើញ នរៈក៏ដាក់កេសាលើខ្នើយវិញ យកដៃគងថ្ងាស អស់កម្លាំងចិត្តពីខ្លួនរលីងធេងតែម្តង ។

យប់នោះ ប៉ុរីប្រឹងរៀនបរិភោគអាហារដោយខ្លួនឯងដោយមិន អោយនរណាជួយទេ ។ គេហាក់ដូចជាកំពុងចង់ជាសះស្បើយពីជំងឺ ណាស់ ព្រោះគេចង់ចេញទៅតាមរកស្រីម៉ៅ ។ មីងម្ចាស់ផ្ទះបាន ចាក់ថ្នាំពីរស៊ីរ៉ាំងអោយមាណព ថែមទាំងអោយនាងគ មកដាស នាយពីរដងអោយដើបបរិភោគថ្នាំ ត្បិតគាត់ឃើញមាណពគ្រុនក្តៅ ខ្លាំងពេក ។

នៅកណ្តាលអាធ្រាត ស្រាប់តែមានស្នូរកាំភ្លើង ទុងទាំងយ៉ាងទ្រហឹងគួរអោយព្រឺខ្លាច ។ ពូម្ចាស់ផ្ទះក៏នាំកូនប្រពន្ធ រត់ចូលត្រង់សេការពារខ្លួន ។ ប៉ុរីក៏ស្ទុះដើប ដើរពតីមពពើម ចុះ មកនឹរកជំរកការពារនឹងគេដែរ ។ ពេលនោះ នរៈឮស្នូរសន្ធឹកមាត់ អ្នកស្រុកកូកហៅកូនចៅអឺងកង :

- ខ្មែរក្រហមចូលកៀរអ្នកស្រុកហើយ... ឆាប់រត់... ប្រយត្ន័គេបាញ់ សម្លាប់មួយពូជ... ជួយផង...

CHANBOKEO.COM

បុរីរន្ធត់ចិត្តណាស់ មិនដឹងថាខ្លួននាយត្រូវជួយខ្លួនយ៉ាងណាទេ កាលបើនាយងងឹតភ្នែកយ៉ាងនេះ ។ ពេលនោះ ស្រាប់តែគេនឹក ដល់នាងគ មិនដឹងថានាងបានដឹងព្រឹត្តិការណ៍ជុំវិញខ្លួនពេលនេះ ដែរឬក៏យ៉ាងណា ។ គេក៏ឡើងទៅលើផ្ទះវិញ ដើរគោះជញ្ជាំងផ្ទង ផាំងៗ ។

- ធ្វើស្អីហ្នឹងក្មួយប្រុស ? (ពូម្ចាស់ផ្ទះស្រែកពីដីមក)
- គឺខ្ញុំគោះហៅប្អូនគ មិនដឹងថានាងចុះដល់ដីហើយឬនៅ ?
- អូហ៍... ពូបាននាំនាងចុះដល់ដីហើយ ។ ក្មួយឆាប់ចុះមក ក្រែង គ្រាប់វាផ្លាតត្រូវ ឮហើយនៅ ?

បុរីក៏វាវពតពើមតាមក្រោយពូម្ចាស់ផ្ទះចូលត្រង់សេមួយ ។

- នៅទីនេះសិនហើយ ពូត្រូវចេញទៅការពារភូមិឯខាងក្រៅ ។ ចូររក្សាគ្នាទៅវិញទៅមកអោយបានល្អឮហើយនៅ ?

ពូនិយាយប្រាប់ទាំងអស់គ្នា ហើយក៏ទាញទ្វារត្រង់សេបិទ ទើប លើកាំភ្លើងចេញទៅ ។ ពេលនេះបុរីមានអាការៈធុញថប់ណាស់ដែល ខ្លួនជាប្រុសតែបែរជាមិនអាចជួយអ្វីនរណាបាន សូម្បីតែខ្លួនឯង ។ ដោយនឹកមិនអស់ចិត្តសោះ គេក៏ដើបរកចេញទៅក្រៅ ។

- ក្មួយប្រុសចង់ទៅណាហ្នឹង ?

មីងម្ចាស់ផ្ទះសួរ ។ បុរីបែរក្រោយឆ្លើយថា :

- ខ្ញុំគិតថាទៅអង្គុយនៅខាងក្រៅចាំបញ្ឆោតខ្មាំង ។ បើសិនជាគេ ចូលយាយី ខ្ញុំនឹងរត់ទៅទិសផ្សេងបង្វែងដាន កុំឲ្យគេចាប់ភ្លឹកថា មីងនិងប្អូនៗលួចពួននៅទីនេះ ។
- តើឯងធ្វើអ្វីនឹងកើតទៅបើឯងងងឹតភ្នែកដែរនោះ ?
- ពេលនេះ ជាពេលយប់ណ៎ាមីង... ទោះជានរណាក៏មើលអ្វីមិន ឃើញដែរ ទាល់តែប្រើប្រាជ្ញាហើយ ។

ថាហើយ គេក៏ដើបចេញទៅ ។ ថ្វីបើពេលនោះ គេនៅមិន ទាន់ស្រួលខ្លួននៅឡើយ ប៉ុន្តែមនសិការកូនប្រុសដ៏រឹងមាំម្នាក់ បាន មកដាស់ចិត្តគេអោយដើបឡើងយ៉ាងក្លាហាន ។ កាលបើម្ចាស់ផ្ទះគេ មានសន្តានចិត្តចំពោះនាយយ៉ាងឧត្តុង្គឧត្តមទៅហើយ តើខ្លាចអ្វីនឹង តបស្នងគុណបំណាច់នោះវិញ ។ គេបានដើបចេញទៅក្រៅ វាវបានរនុករទេះមួយ ស្រាប់តែឮសន្ធឹកមនុស្សរត់ប្រសេចប្រសាច ពេញភូមិ ។ មានខ្លះលួចខ្សិបតិចៗស្រែកប្រាប់គ្នីគ្នាក្នុងភូមិថា :

CHANBOKEO.COM

- ឪយ... ពួកអាវខ្មៅចូលមកពីខាងភូមិស្រែះ ឆាប់គេចចេញពី ភូមិ លឿនឡើង!

ភ្លាមនោះ ស្រាប់តែមានដៃមួយមកទាញបុរី :

- ម៉ោះក្មួយ ឆាប់រត់តាមគេទៅ កុំនៅសម្ងំទីនេះអី ក្រែងគ្មាន សុវត្ថិភាព...

នោះគឺជាសំដីរបស់មីងម្ចាស់ផ្ទះ ។

- ចុះពូវិញនោះ ?

- យើងរត់សិនទៅ... ពូមានកាំភ្លើង... គាត់ប្រហែលជាអាចការ ពារខ្លួនគាត់បាន មិនអីទេ ។

ភ្លាមនោះ បុរីដឹងថាមានដៃមួយទៀតអូសនាយរត់ចេញវឹង ។ មាណពក៏រត់តតេះតតះតាមតែដំណើរ ។ មែនហើយ មួយជីវិត កន្លងមកនេះ បុរីមិនដែលស្គាល់អ្វីថាលំបាក ថានឿយហត់ទេ ព្រោះគេជាបុត្រត្រកូលអ្នកគ្រាន់បើមួយរូប រស់នៅស្រណុកសុខ ស្រួលតែរហូតមក ចង់បានអ្វីគឺបានហ្នឹង ។ ម្យ៉ាងទៀត ច្រើនឆ្នាំ កន្លងទៅ គេរស់នៅឯបរទេស មិនដែលដឹងថា តើការរស់នៅ អត្តខាត់របៀបអ្នកក្រីក្រនោះវាយ៉ាងណាយ៉ាងណីទេ ។ វេលានេះ គេស្គាល់ហើយ ការលំបាកនឹងភាពតក់ស្លុតរន្ធត់.. វាគួរអោយព្រឺ ខ្លាចរអារណាស់ ។

បុរីតោងដៃអ្នកផ្ទះជាប់ព្រោះខ្លាចវង្វេងគ្នា ។ រំពេចនោះ នាយ ក៏ដើរផុងគន្លុកមួយដួលភីង របូតដៃចេញពីគ្នីគ្នាវឹង ។ រីអ្នកស្រុក ទាំងឡាយក៏នាំគ្នារត់គេចទាំងភិតភ័យតក់ស្លុត រកកន្លែងលាក់ខ្លួន ប្រសេចប្រសាចពេញព្រៃ គ្មាននរណាជួយនរណាទេ ។ ស្រាប់តែ មានដៃមួយមកស្រវាទាញបុរី អោយដើបឡើងរត់គេចខ្លួនបន្តទៅ ទៀត ។ មកដល់ម្តុំដីទួលកប់ខ្មោចមួយ អ្នកទាំងពីរក៏នាំគ្នារត់ពួន លាក់ខ្លួននៅទីនោះ តាមចន្លោះផ្នូរខ្មោចដែលមានគុម្ពោតព្រៃដុះ យ៉ាងស៊ុបទ្រុប ។ បុរីកាន់ដៃមនុស្សម្នាក់នោះជាប់មកជាយូរហើយ មិនបានចាប់ភ្លឹកអ្វីបន្តិចទេ ។ ប៉ុន្តែលុះដល់គេនាំគ្នាអង្គុយពួនសម្ងំ ស្ងៀមស្ងាត់មួយស្របក់បាត់ហត់មក ទើបនរៈចាប់ភ្លឹកថាដៃដែលគេ កំពុងកាន់នោះគឺជាដៃនារីម្នាក់ដ៏ទន់ល្មើយ មិនសមជាដៃរបស់នាង តូចភីឬនាងគទេ ព្រោះមាណវីទាំងពីររូបជាកូនអ្នកជនបទ ធ្វើការ ហត់នឿយណាស់ពិតមិនអាចមានដៃទន់ល្វតល្វន់ដូច្នេះបានឡើយ ។ ពេលនោះ បុរីគិតឃើញអ្វីម្យ៉ាង ក៏នឹករំភើបត្រេកអរនៅក្នុងចិត្តតែ ម្នាក់ឯងមិនស្រដី រួចក៏នៅអង្គុយក្តាប់ដៃនោះមិនព្រមលែងឡើយ ថ្វីបើម្ចាស់គេបានកញ្ឆក់ទាញយកចេញទៅវិញ ជាច្រើនដងហើយក៏ ដោយ ។ មាណពយើងមានកម្លាំងប្រើសលែងហត់ លែងតក់ស្លុត

CHANBOKEO.COM

នឹងហេតុការណ៍អ្វីអស់រលីង ក្រៅតែពីអង្គុយញញឹម អង្អែលដៃនារី
ដោយខិរាញាប់ញ័រមិនស្រាកស្រាន្ត ។
បន្តិចមក ប៊ុរីក៏កើតគំនិតព្រើល ធ្វើជាអង្គុយឯក់ទំលាក់កេសា ទៅលើស្មានារី
លួចស្រូបស្រង់ក្លិនខ្លួនរបស់នាងយ៉ាងស្ងៀមស្ងាត់ ។ លុះឃើញម្ចាស់គេមិនកំរើកអ្វី ម្តងនេះ
មាណពក៏លូកដៃម្ខាងទៀត ទៅក្រសោបចង្កេះនារីម្តង បន្លំធ្វើហាក់ដូចជាខ្លួនកំពុងមមើមមាយ
ស្រាប់តែ... ប៉ាត់! នាយត្រូវដៃមួយលូកក្តិចឈឺ មិនខុសពីកំស្ទួល ក្អែបខាំប៉ុន្មានឡើយ ។
ពេលនោះ នាយកាន់តែយល់ច្បាស់ហើយ ថានរណាធ្លាប់មានកិរិយាបែបនេះ
ចំពោះរូបនាយពីមុនមក ។ បេះដូងរបស់គេក៏រណ្តំឡើង យ៉ាងរំភើបរំជើបរំជួលក្រៃលែង ។
ថ្វីបើពេលនេះ ម្នាក់ៗស្ថិតនៅក្នុងស្ថានការណ៍គួរឲ្យរន្ធត់ភ័យខ្លាច
តែប៊ុរីបែរជាមានអារម្មណ៍ថាខ្លួនគេ កំពុងតែហោះអណ្តែតត្រសែត នៅឯស្ថាន
សួគ៌ាល័យដ៏រុងរឿងឯណោះទៅវិញ ។ ទ្រាំមិនបាន
គេក៏ស្រវាចាប់អោបក្រសោបនារីយ៉ាងណែនពេញរង្វង់ដៃ ដោយក្តី ញាប់ញ័ររំភើបត្រេកអរ
ព្រមទាំងលួចខ្សិបដាក់ត្រចៀកនាងថ្នមៗ ផងថា :
- ម៉ៅ! បងដឹងណា៎... ថាជារូបអូន... ឈប់រត់គេចពីបងទៀតទៅ
ណា៎ បណ្តូលចិត្តបង... ដឹងទេ ថាបងនឹកអូនប៉ុនណា... ព្រួយបារម្ភ
ពីអូនក្រៃតណា...ឈប់ធ្វើបាបចិត្តបងទៀតទៅ បានទេអូន ?
សូរកាំភ្លើងនៅលាន់ឮខ្ទួងៗផុងផាំងល្វើយៗពីភូមិមក... អ្នក
ស្រុកទាំងឡាយក៏ប្រឹងរត់គេចពួនក្នុងព្រៃយ៉ាងស្ងៀមស្ងាត់ ។ នៅ
ក្នុងគុម្ពោធព្រៃគោកខ្មោចឆ្ងាយពីភូមិ ចន្លោះផ្នូរខ្មោចមួយគូ ប៊ុរីពួន
ឱបក្រសោបនារីម្នាក់ក្នុងរង្វង់ដៃរបស់គេដោយដួងចិត្តបេតីប្រតិពទ្ធ័ ពេញទ័យា ។
គេលែងខ្វល់ហើយថា ពិភពលោកបែរទៅណា វិល ទៅខាងណា
គិតតែម្យ៉ាងថាគេត្រូវរក្សាម្ចាស់ស្នេហារបស់គេ អោយ ស្ថិតនិត្យនៅជាប់នឹងខិរាមិនអោយ
នាងបែកឃ្លាតទៅណាពីរូបគេ បានទៀតឡើយ ។
ពន្លឺថ្ងៃជះពន្លឺព្រាងៗឯបូព៌ាទិស...
គ្រាប់កាំភ្លើងក៏ស្ងប់ទៅវិញ ។ អ្នកភូមិទាំងឡាយក៏នាំគ្នាដើប
ចេញពីកន្លែងលាក់ខ្លួនដើរត្រលប់ទៅភូមិវិញ ។ ប៊ុរីក៏ដើរកាន់ដៃ
នារីត្រលប់ទៅផ្ទះវិញដូចគេដូចឯង ។ ដោយហេតុថានាយនៅមាន ជំងឺភ្នែកមិនអាចមើលផ្លូវបាន

CHANBOKEO.COM

ប៉ុរីក៏មានលេសដើរកាន់ដៃនារីផ្ញើ ហាក់ដូចជាខ្លួនពិការជួយខ្លួនអ្វីមិនរួច ហើយបណ្តោយអោយនារីដឹក ដៃតាមតែដំណើររហូតដល់ផ្ទះវិញ ដោយចិត្តត្រេកអររំភើបដែលគេបាននៃបនិត្យមាណវីយ៉ាងផ្អែមល្ហែមពេញមួយរាត្រីកន្លងមក ។

oooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី១០
# បន្លាអតិត

ថ្ងៃរះភ្លឺបន្តិច ពូម្ចាស់ផ្ទះក៏មកដល់វិញដោយសុខសប្បាយ ។ រំពេចនោះ ប៊ុរីឮអ្នកស្រុករត់ខ្សៀវខ្សសស្រែករំពងឡើង ថា :
- ពូមេឃុំអើយ! មានឡានកងទព័ខ្លះគេធ្វើដំណើរទៅបាត់ដំបង វិញថ្ងៃនេះ ។ ពូទៅសុំគេដាក់ផ្ញើអ្នករបួសធ្ងន់ៗទៅពេទ្យធំខ្លះទៅ...
មែនហើយ ការពិតម្ចាស់ផ្ទះនោះគឺជាមេឃុំទេតើហ៎ ។ ភ្លាម នោះគាត់ក៏ឆ្លើយវិញថា :
- បាទ! ខ្ញុំនឹងចេញទៅសុំគេឥឡូវនេះហើយ ។
បន្ទាប់មក គាត់ក៏បែរមកនិយាយដាក់ប៊ុរីថា :
- បើសុំគេបាន ពូនឹងផ្ញើក្មួយទៅបាត់ដំបងវិញនឹងគេដែរណ៎ា ។
ថាហើយ គាត់ក៏ចុះដណ្តើរផ្ទះចេញទៅ ។ ភ្លាមនោះ ប៊ុរីមាន អារម្មណ៍ថាចង្អៀតចង្អល់ក្នុងចិត្តយ៉ាងម៉េចមិនដឹង ។ ប្រហែលជា មួយម៉ោងក្រោយមក ពូមេឃុំក៏ត្រលប់មកវិញ :
- ម៉ោះ! រៀបចំខ្លួនទៅ ក្មួយ! ពូសុំគេដាក់ក្មួយទៅជាមួយបាន ហើយ ។ ឡានគេចេញដំណើរក្នុងរវាងមួយម៉ោងទៀត ។
ស្រាប់តែប៊ុរីប្រកែកញ៉ាញ :
- ខ្ញុំមិនទាន់ចង់ទៅទេ លោកពូ...!
- ព្រោះហេតុអីទៅ ?
- គឺ... មកពីខ្ញុំមិនចង់ទៅចោលប្រពន្ធរបស់ខ្ញុំនោះអីបាទ!
- តែភ្នែករបស់ក្មួយឯង ទុកឲ្យនៅដំបៅយូរមិនបានទេ ប្រយ័ត្ន ងងឹតកែលែងជាទៅ ។

- ចៃដន្យ ខ្ញុំមិនចង់អោយប្រពន្ធយល់ថា ខ្ញុំរត់យករស់តែម្នាក់ឯង ដែរ ។
បើសិនជាត្រូវពិការដោយសារតែរក្សាភក្តីភាពចំពោះប្រពន្ធ នោះ ខ្ញុំក៏អស់ចិត្តដែរ
ទោះបីនាងអាចទទួលខ្ញុំវិញបានឬមិនទទួល ក៏ដោយ ក៏ហោចណាស់
ខ្ញុំបានសម្តែងអោយនាងដឹងថា ខ្ញុំមាន បេះដូងសំរាប់រូបនាងតែម្នាក់គត់ក្នុងជីវិតនេះ ។

បុរីនិយាយឮៗ ដោយឥតខ្មាសអៀន ទំនងចង់អោយនរណា ម្នាក់ក្បែរនោះ
បានឮសំដីរបស់នាយអញ្ជឹង ។

- ច្បាស់ហើយហ្នែស ថា ក្មួយមិនចង់ទៅបាត់ដំបងមែន.. ?
- បាទ! ច្បាស់ហើយ ។
- ប៉ុន្តែទោះជាយ៉ាងណា ក៏ពូមិនអនុញ្ញាត្តិអោយនៅទីនេះដែរ ។
ម្តុំនេះលែងមានសុវត្ថិភាពហើយ ។ ពូកំពុងគិតថាយកប្រពន្ធនិង
កូនទៅផ្ញើនឹងសាច់ញាតិនៅបាត់ដំបងវិញ ដើម្បីចៀសវាងនូវភាព
អសន្តិសុខទាំងឡាយដែលធ្លាប់កើតមានឡើងនៅក្នុងភូមិយើង ។

ស្រាប់តែបុរីសួរវិញយ៉ាងរហ័សថា :

- មានន័យថា អ្នកមីង និងគ្រប់ៗគ្នាត្រូវទៅបាត់ដំបងថ្ងៃនេះដែរ មែនទេ លោកពូ ?
- មែនហើយ! បើឯងចង់នៅទីនេះ...ប្រហែលជាឯងត្រូវដាំបាយ បរិភោគដោយខ្លួនឯងហើយ
គ្មាននរណាគេនៅមើលថែទាំតទៅ
ទៀតទេណា៎ ។

ភ្លាមនោះ បុរីក៏ញញឹមឡើង :

- បើទាំងអស់គ្នាក្នុងគ្រួសារចេញទៅហើយ តើអោយខ្ញុំរស់នៅតែ ម្នាក់ឯងម្តេចនឹងកើត ?
ខ្ញុំសុខចិត្តធ្វើតាមលោកពូចុះ ។

ពូមេឃុំក៏ញញឹមមកវិញដែរ ។

ជាងមួយម៉ោងក្រោយមក បុរីក៏បានឡើងជិះលើឡានទ្រុងមួយ ព្រមជាមួយអ្នករបួសមួយចំនួន
ព្រមទាំងក្រុមគ្រួសាររបស់ពូមេឃុំ ផង ។ តាមផ្លូវគេសួរទៅនាងតូចភីខ្សិបៗថា :

- នែ៎ បងស្រីរបស់នាងតូចសុខសប្បាយទេ ? គ្នាមិនចេះនិយាយ មិនចេះស្រដីអ្វីយ៉ាងនេះ
តើគេគឹងចិត្តយ៉ាងណាទៅហ្ន៎ ?
- គឺបងគ មានសន្តានចិត្តត្រជាក់ ច្បាស់ជាមិនអីទេណា៎បង!
- ហើយពេលនេះគេកំពុងធ្វើអ្វីដែរ ?

- បងចង់និយាយជាមួយគាត់មែនទេ ?
- អោយបងនិយាយយ៉ាងណា បើគេស្តាប់បងមិនឮផងនោះ ?
- គឺនិយាយដោយដៃណា៎...
- និយាយដោយដៃយ៉ាងម៉េច ?
- គឺគាត់នៅអង្គុយក្បែរបង ខាងស្តាំនេះឯងតើប៉ា!

ថាហើយនាងតូចក៏ចាប់ដៃបុរសអោយទៅប៉ះដៃរបស់នាងគ ។ ប៊ុរីភ្ញាក់ព្រើតដែលនាងតូចយល់ចិត្តរបស់ខ្លួន ។ គេក៏ស្រវាចាប់ដៃ នាងគកាន់យ៉ាងណែនភ្លាម ហើយអង្គុយធ្វើមិនដឹង ។ ភ្លាមនោះ គេមានអារម្មណ៍ថា មានដៃមួយទៀតលួចលូកមកក្តិចចង្កេះរបស់ មាណពយ៉ាងឈឺអើយសែនឈឺ ក៏ប៉ុន្តែ... ទោះជាយ៉ាងណាក៏នាយ មិនព្រមព្រលែងដៃនាងគទៅវិញងាយៗដែរ ។ ពេលនេះនរៈមានអារម្មណ៍ថាឧប្បត្តិហេតុទាំងឡាយប៉ុន្មានថ្ងៃកន្លងមកនេះមិនមែនជាគ្រោះកាចសម្រាប់ជីវិតរបស់នាយទេ ប៉ុន្តែជាឱកាសដ៏ល្អមួយឲ្យគេបានបង្ហាញដួងចិត្តដ៏ស្មោះរបស់នាយចំពោះនារីម្នាក់ ដែលគេកំពុង ប្រតិពទ្ធ័ ថាគេពិតជាស្វាមីស្លាប់រស់ដើម្បីនាងយ៉ាងប្តូរផ្តាច់ ។

ក្បួនរថយន្តទាហានបន្តកន្ទុយគ្នា មានចំនួនប្រមាណជាងដប់ឡានបានធ្វើដំណើរទៅមុខគ្រឿនៗ តាមសម្រួល គ្មានអ្វីមករំខាន រារាំងដំណើររបស់គេ ដូចកាលពីអាទិត្យមុនដែលប៊ុរីធ្វើដំណើរមក នោះឡើយ ។ ប្រហែលជាកងទ័ពព្រៃឃើញកងកម្លាំងទាហានរដ្ឋ មានគ្នាច្រើនទេដឹង ទើបគេមិនចេញមុខមកសង្វៀញជីវិតមនុស្ស ដូចមុនទៀត ។ មិនបានពីរម៉ោងស្រួលបួលផង ក្បួនរថយន្ត ទាហាន ក៏បានវិលមកដល់ទីក្រុងបាត់ដំបងដោយសុវត្ថិភាព ។

ប៊ុរីកំពុងរាវផ្លូវចុះពីរថយន្តទ្រុង ស្រាប់តែ...
- បងប៊ុរី...!

សូរសម្លេងនារីម្នាក់ស្រែកមករកយ៉ាងគ្រលួច ។ ប៊ុរីភ្ញាក់ព្រើត ងើបមុខឡើងធ្វើងីងើបែររកម្ចាស់សម្លេង :
- គិមណាង...ជាស្រួលបួលហើយប្អូនស ? ហើយម៉េចបានដឹងថា បងជិះរថយន្តនេះមកបាត់ដំបង... ?

គិមណាងដើរមកជិតប៊ុរី ព្រមជាមួយរ៉ាវុធផង :

CHANBOKEO.COM

- គឺបងរ៉ាវុធទៅទទួលខ្ញុំចេញមកពីមន្ទីរពេទ្យធំ ហើយបើករថយន្ត កាត់តាមផ្លូវនេះ
ក៏ប្រទះឃើញបងតែម្តងទៅ ។

លុះឃើញបុរីដើរធ្វើពើមៗ រ៉ាវុធក៏សួរឡើង :

- ឯងមានជំងឺអីហ្នឹង បានជាឯងស្លេកស្លាំងប្លែកម្ល៉េះ ? ហើយថែម
ទាំងដើរដូចមនុស្សងងឹតភ្នែក... ?
- គឺគ្នាត្រូវចំហាយជាតិផ្សែងឧស្មន័គីមីរបស់កាំភ្លើងធំ... ឈឺភ្នែក
មិនទាន់ជាសះស្បើយនៅឡើយទេ ។
- ហើយឯងទៅចុះឈ្មោះធ្វើកងទ័ពតាំងពីអង្កាល់ បានជាចូលលុក
លុយសមរភូមិឡើងមានរបួសយ៉ាងដូច្នេះទៅហើយ ?

បុរីនៅស្ងៀមមិនហ៊ាននិយាយតទៅទៀត ។ ស្រាប់តែ រ៉ាវុធ មានវាចាបន្តថា :

- ចង់អោយខ្ញុំជូនទៅផ្ទះទេ បុរី ?
- មិនអីទេ រ៉ាវុធ... ខ្ញុំគិតថា នឹងទៅជាមួយគ្រួសាររបស់ពូមេឃុំ វិញបានហើយ ។
- នរណាគេទៅជាពូមេឃុំនោះ ?
- គឺគ្រួសារដែលទើបចុះពីរថយន្តអំបាញមិញ ជាមួយខ្ញុំនេះអី ។
- អូហ៍! ខ្ញុំឃើញគេនាំគ្នាឡើងរ៉ឺម៉កចេញទៅអស់ហើយតើហ៍ ។
- ភ្ញាក់ ? ម៉េចអញ្ចឹង ? ម៉េចគ្រួសាររបស់គាត់ចេញទៅចោលខ្ញុំ អោយនៅតែម្នាក់ឯងកើត ?
មិនគួរអោយជឿទេ! ឯងកុំនិយាយ លលេងគ្នាអញ្ចឹងមើស៍!
- ប្រហែលជាគាត់ឃើញខ្ញុំនិងគិមណាងមកជួបឯង ប្រហែលស្មាន ថាយើងមកទទួលទេដឹង
បានជាគាត់នាំគ្នាចាកចេញទៅ ។

បុរីឮហើយមិនអស់ចិត្តទេថា គ្រួសារពូមេឃុំនោះ ដើរចេញ ចោលរូបនាយពិតមែន ។
គេក៏កួកឡើងថា :

- ពូមេឃុំ! អ្នកមីង!... ប្អូនភី!
- នែ៎ កួកស្អីកណ្តាលក្រុងហ្នឹង ? មិនចេះខ្មាស់គេទេហ៍ ? (រ៉ាវុធ ឃាត់) ហើយឯងមានស្គាល់ថា
គាត់ឈ្មោះអី ទៅស្នាក់នៅផ្ទះឯណា ដែរទេ ?
- គឺ... មិនស្គាល់ទេ... តែខ្ញុំអាចស្មានដឹងថា គាត់នាំគ្នាទៅស្នាក់ នៅឯណាហើយ ។
- បើដូច្នេះ យើងទៅផ្ទះសិនទៅ ចាំតាមរកគ្រួសាររបស់គាត់តាម
ក្រោយ ។

CHANBOKEO.COM

បុរីឡើងរថយន្តជាមួយរ៉ាវុធនិងគិមណាង ក្នុងចិត្តគិតមិនអស់
មិនហើយថាហេតុអ្វីគ្រួសារពូមេឃុំទុកនាយចោលដោយមិនបានលា មួយម៉ាត់អញ្ចឹង ។
នាយមិនយល់...ពិតជាមិនយល់ទេ ។ ហើយចុះ ម៉ៅវិញនោះ ?
ហេតុម្តេចបានជានាងដើរចោលនាយកើត កាលបើ ពីយប់មិញនេះ
នាងបានបង្ហាញនូវភាពទន់ភ្លន់ផ្អែមល្ហែម ចំពោះ រូបមាណពយ៉ាងជិតដិតស្និទ្ធស្នាលបំផុតនោះ ?
ហេតុអ្វីនាងមាន ឥរិយាបថផ្លាស់ប្តូរលឿនរហូតដល់នាយស្មានមិនត្រូវយ៉ាងនេះ ?

មិនយូរប៉ុន្មាន រ៉ាវុធក៏ឈប់រថយន្ត ។

- ម៉ោះ ! ចុះមក !

រ៉ាវុធដឹកដៃបុរីសំដៅទីមួយ... បត់ចុះបត់ឡើងកាន់តែឆ្ងាយទៅ ហើយក៏ឡើង កាំជណ្តើរ ។
បុរីនឹកឆ្ងល់ក្នុងចិត្តក៏សួរថា :

- រ៉ាវុធកំពុងនាំខ្ញុំទៅណាហ្នឹង ?
- ស៊ូច ! បន្តិចទៀតដឹងហើយ ។ ណេ៎ះ ! អង្គុយចុះមក !

បុរីដាក់ខ្លួនអង្គុយចុះ ស្រាប់តែគេឮសន្ធឹកម៉ាស៊ីនរោទិ៍ឡើង :

- យី ! នាំខ្ញុំទៅណាហ្នឹង រ៉ាវុធ ?
- បន្តិចទៀត ឯងដឹងហើយ ។

បុរីនឹកតប់ប្រមល់ក្នុងចិត្តយ៉ាងណាមិនដឹងទេ កាលបើរ៉ាវុធនិង
គិមណាងមិនឮនិយាយពន្យល់អ្វីប្រាប់គេបន្តិចសោះ ។ រំពេចនោះ
ស្រាប់តែមានសម្លេងឃោសនសព្ទផ្សាយថា :

- សូមភ្ញៀវមេត្តាដាក់ខ្សែក្រវាត់ នៅពេលយន្តហោះកំពុងបើកបរ ពេលនេះ
យន្តហោះមានដំណើរទៅទីក្រុងភ្នំពេញ នឹងត្រូវទៅដល់ ក្នុងរវាងមួយម៉ោងទៀត ។

បុរីភ្ញាក់ព្រើតដូចគេចាប់គ្រវែង ហើយឧទានថា :

- នេះឯងកំពុងនាំខ្ញុំទៅភ្នំពេញមែនទេ ?
- មែនហើយ !
- ម៉េចអញ្ចឹង ? ខ្ញុំកំពុងចង់ទៅផ្ទះខ្ញុំឯបាត់ដំបងនោះតើហ៍ ។
- គឺខ្ញុំធ្វើតាមតែបញ្ជាទេ ។ សូមទោសណា៎បុរី !
- ធ្វើតាមបញ្ជា ? បញ្ជានរណា ? លោកប៉ាប្ញែស ?
- គឺ... ស្រដៀងៗហ្នឹងទេដឹង ?

CHANBOKEO .COM

ប៊ុរីមិនអស់ចិត្តក៏សួរគិមណាងដែលនៅអង្គុយជិតវ៉ាវុធ :

- ហើយគិមណាងមាននឹងរឿងអ្វីដែរទេ ថាហេតុអ្វីវ៉ាវុធនាំខ្លួនខ្ញុំ ឡើងយន្តហោះទេភ្នំពេញវិញ ?

- ប្អូនមិនបាននឹងអ្វីទេណ៎ាបង ព្រោះទើបតែចេញពីពេទ្យទៅផ្ទះ វិញ ។ មានតែបងវ៉ាវុធទេដែលអាចឆ្លើយសំនួរបងប៊ុរីឯងបាន ។

ប៉ុន្តែវ៉ាវុធនិយាយស្តីកាច់កុង ចាប់ចុងប្រយុងដើម រកតែប៊ុរី យល់អ្វីមិនបានសោះ ។ មាណពក៏បិទមាត់ទៅវិញ ដោយដួងចិត្ត ប្រមល់ ។ យូរៗម្តងគេលួចខ្សិបតែម្នាក់ឯងថា :

- ម៉ៅ...! ហេតុអ្វី អូនចាកចេញពីបង ដោយមិនស្រដីអ្វីមួយម៉ាត់ ប្រាប់បងអញ្ចឹង ? បងពិតជាមិនយល់ទេអូន...

គេដាក់ក្បាលផ្អែកនឹងកៅអី បិទភ្នែកស្រម័យនឹកទៅដល់ស្រី ម៉ៅគ្មានស្រាកស្រាន្ត ។ មួយម៉ោងក្រោយមក យន្តហោះក៏បានមក ដល់ពោធិចិនតុង ។ ពេលនោះមានរថយន្តមួយបរមកដល់ទទួល យកប៊ុរីនិងមិត្តរបស់គេចូលទៅភ្នំពេញ ។ មួយសន្ទុះក្រោយមក ប៊ុរីក៏បានត្រូវនាំខ្លួនចូលទៅក្នុងបន្ទប់មួយ :

- ទីនេះជាកន្លែងណាដែរ វ៉ាវុធ ? (ប៊ុរីសួរ)

- គឺជាមន្ទីរពេទ្យណ៎ាកូន ។

សម្លេងបុរសម្នាក់ឆ្លើយឡើង ។

- លោកប៉ា! (ប៊ុរីឧទានឡើងដោយត្រេកអរ) ជំរាបសួរលោកប៉ា! ម៉េចបានលោកប៉ាជ្រាបថាកូនមានគ្រោះថ្នាក់ ?

លោកបុរាណយកដៃអង្អែលក្បាលកូន ហើយមានប្រសាសន៍ តបទៅកូនប្រុសវិញថា :

- គឺអ្នកភូមិចិត្តសប្បុរសគេសរសេរសំបុត្រមកប្រាប់ប៉ាយូរថ្ងៃហើយ តែដោយសារផ្លូវចរាចរគ្រោះថ្នាក់ពេក ទើបប៉ារកមធ្យោបាយទៅ ទទួលកូនមិនបាន ។ ថៃដន្យ មានគេតេអូមកប្រាប់ពីព្រឹកមិញ ថា កូនបានត្រលប់មកវិញតាមឡានទាហាន ទើបប៉ាពឹងវ៉ាវុធឲ្យទៅ ទទួលកូនមកនេះអី ។

- ប៉ុន្តែហេតុដូចម្តេចលោកប៉ាចាំបាច់អីនាំកូនមកដល់ភ្នំពេញផង ?

- មកពីទីនេះមានពេទ្យល្អៗ សំរាប់ព្យាបាលកូនរបស់ប៉ាអោយឆាប់ ជាវិញបានរហ័សទាន់ចិត្តហើយជោគជ័យផង ។

- តែកូនចង់នៅគេងពេទ្យឯបាត់ដំបងជាជាង...

- ព្រោះអ្វីទៅ ?

CHANBOKEO . COM

- ព្រោះម្ចាស់បេះដូងរបស់កូននៅទីនោះ...
- ប៉ុន្តែ តើម៉ែក្មេក ឪក្មេករបស់កូនក្រមុំណាមួយទៅ ដែលកើតជំងឺ ខ្វះសតិ ហ៊ានទទួលកូនប្រសារខ្វាក់ភ្នែក ហើយគ្មានការធ្វើដូចកូន ឯងយ៉ាងនេះ ? កូនអើយ... ឯងមានគិតទេ ?

ប៊ុរីនៅស្ងៀមមិនហ៊ានស្រដីតទៅទៀត ។

ថ្វីបើពេលនេះ ក្នុងចិត្តគេអន្ទះសារកអ្វីប្រៀបមិនបានយ៉ាងណា ក៏ដោយ ក៏ប៊ុរីត្រូវតែតាំងចិត្តដាច់ខាត ស៊ូទ្រាំនៅសំរាកក្នុងមន្ទីរ ពេទ្យ ទទួលការព្យាបាលយ៉ាងហ្មត់ចត់ពីសំណាក់លោកគ្រូពេទ្យ ទីនោះ ដើម្បីអោយគេឆាប់មានឱកាសវិលទៅបាត់ដំបងវិញ ទៅរក ម្ចាស់ដួងចិត្តរបស់គេដែលគេកំពុងនឹករលឹកយ៉ាងមហិមា ។

- ម៉ៅអើយ ! ចាំបងណ៎ាអូន... បងនឹងវិលវិញរកអូនមិនខាន !

ចាំបងណ៎ាអូន

- ចាំបងណ៎ាអូនស្ងួនពំងា ពេលនេះឃ្លាតឃ្លាមិនយូរថ្ងៃ
ព្យាបាលរោគហើយបងវិលវៃ ជួបស្រស់ចរណៃថ្លៃវរលក្ខណ៏ ។
- ចាំបងណ៎ាពៅកុំសោកា ដួងចិត្តស្នេហាយ៉ាងស្មោះស្ម័គ្រ
បេះដូងរៀមមួយបានដៅឆ្លាក់ ស្នេហាអមតៈមិនប្រួលប្រែ ។
- ចាំបងណ៎ាស្រីថ្លៃពន្លក បងនឹងវិលមកថ្នាក់ថ្នមស្នេហ៏
ត្រកងលួងលោមប្រលោមថៃ ម្ចាស់ចិត្តមាសមេឱ្យនាងក្សាន្ត ។
- ចាំបងណ៎ាមុំកុំយំថ្វី ចិត្តស្នេហ៏ភក្តីផ្ញើកល្យាណ
រៀមនឹងវិលវិញរកកល្យាណ រួមសាងជីវិតនិត្យមង្គល ។

ច្រើនអាទិត្យកន្លងទៅ...

ប៊ុរីបើកភ្នែកឡើងសាជាថ្មី... ភ្លាមនោះ គេរំភើបរីករាយក្នុង ចិត្តណាស់ដែលគេអាចមើលឃើញអ្វីៗជុំវិញខ្លួនម្តងទៀត ។ លោក គ្រូពេទ្យលើកវ៉ែនតាហុចអោយទៅប៊ុរីថែមទាំងមានប្រសាសន៍ថា :

CHANBOKEO.COM

- ពេលនេះ លោកត្រូវប្រើវ៉ែនតាជាជំនួយមួយពេលហើយ មិន
នឹងថាលោកត្រូវការយូរប៉ុនណាទេ ប៉ុន្តែបើសិនលោកថែទាំភ្នែក តាមបែបបទវេជ្ជបញ្ជា
នោះប្រហែលជានឹងអាចជាសះស្បើយមួយ រយភាគរយបាន មិនយូរមិនឆាប់ ។

នរៈទទួលវ៉ែនតាយកមកពាក់ រួចលើកដៃជំរាបលាលោកគ្រូ ពេទ្យដោយចិត្តរំភើបញាប់ញ័រ ។
គ្រាន់តែចេញមកដល់ក្រោមន្ទីរ
ពេទ្យភ្លាម ស្រាប់តែ :

- បងបុរី..!

បុរីបែរមើលម្ចាស់សម្លេងយ៉ាងរហ័ស ឃើញនារីសោភាមួយរូប ពាក់អាវវាលក
បញ្ចេញគល់សុដនយ៉ាងល្អគាប់ភ្នែក ស្លៀកសំពត់ ខ្លី ពាក់វ៉ែនតាខ្មៅកំពុងឈរអោបផ្កាមួយបាច់ធំ
រង់ចាំរូបគេ ។ នរៈ បើកភ្នែកធំៗ ហើយខទានទាំងភ្ញាក់ផ្អើលថា :

- អូនផលា ?
- ចា៎សមែនហើយ! អរគុណបងណាស់ដែលនៅចំណាំអូនបាន!

នារីដើរចូលមកជិត ហុចបាច់ផ្កាជូនអ្នកកម្លោះ ទាំងទឹកមុខ ញញឹម ។
បុរីលើកដៃទទួលយកទាំងចិត្តភ្ញាក់ផ្អើល ញាប់ញ័ររន្ធត់ យ៉ាងណាមិនដឹង ។
តើធិតារូបស្រស់នោះជានរណា ?

- ម៉េចអូនដឹងកើតថាបងគេងមន្ទីរពេទ្យនេះ ? (បុរីសួរ)
- គឺមកពីអូនធ្វើការទីនេះនោះអី! តែថ្ងៃនេះជាវេនសំរាកទើបអូន អាចមកស្ទាក់ចាំផ្លូវបងបាន ។

បុរីបែររកមើលជុំវិញខ្លួន ក្រែងលោលោកបុរាណ ឬក៏វ៉ាវុធមក
ទទួល ។ តែគេមិនឃើញនរណាម្នាក់សោះ ។

- រកមើលអ្នកដែលត្រូវមកទទួលទៅផ្ទះមែនទេ ?

បុរីងក់ក្បាល ។ ធិតាសោភាក៏ពោលបន្តថា :

- ខ្ញុំបានជួបលោកប៉ានិងម៉ាក់របស់បង កាលពីកន្លះម៉ោងមុននេះ...
- អូហ៍... ហេតុអីផលាស្គាល់ប៉ាម៉ាក់របស់បងកើត ?
- ចឹក៏មិនស្គាល់ បើអ្នកមីងផៃយ៉ាជាម្ដាយមីងរបស់ខ្ញុំ ។
- ពុទ្ធោ..! ម៉េចក៏អញ្ចឹងទៅកើត ? (បុរីលាន់មាត់ខ្សិបៗ)

ការពិត បុរីស្គាល់ផលាយូរឆ្នាំហើយ តែមិនដឹងថានាងជាក្មួយ ស្រីរបស់អ្នកស្រីផៃយ៉ាសោះ ។
ភ្លាមនោះ មាណវីក៏ឆ្លើយថា :

CHANBOKEO.COM

- នេះបើកុំតែលោកទាំងពីរ ចូលមកមើលបង នៅមន្ទីរពេទ្យនេះ ម្ល៉េះសមខ្ញុំមិនដឹងថា បងជាកូនប្រុសរបស់លោកពូបុរាណតែរហូត

ហ្នឹង ។ គិតទៅ ផែនដីពិតជាមូលមែន!

- ហើយចុះអូនមានដឹងទេ ថាលោកទាំងពីរនៅចាំបងកន្លែងណា ?

- គឺ... គាត់មិនបាននៅចាំបងទេ ព្រោះខ្ញុំស្ម័គ្រខ្លួនចាំបងហើយ ។ ពេលនេះ ប្រហែលជាគាត់កំពុងតែចាំបងនៅផ្ទះរបស់ខ្ញុំហើយ ។

- អ្ហ៎ស ? ថាម៉េច ? គាត់ទៅផ្ទះអូនផលាឯង ?

- ចា៎ស ? ហើយម៉េចបានជាធ្វើមុខភ្ញាក់ផ្អើលអញ្ចឹងផង ?

- គឺ....

ប៊ុរីនិយាយលែងចេញតែម្តង ។ ការពិត ផលាជានារីម្នាក់ដែល មាណពធ្លាប់សុំស្នេហា កាលគេនៅរៀននៅមហាវិទ្យាល័យឯភ្នំពេញ

ហើយធ្លាប់បានដើរលេងជាមួយគ្នាយ៉ាងជិតដិតទៀតផង ។ ថៃដន្យ ពេលគេបានទៅរៀននៅជប៉ុន គេក៏ចាប់ណាយចិត្តពីនាងទៅដោយ ឯកឯង ។ ពេលនេះ

គេកំពុងតែត្រូវធ្នឹងស្លាក់ទទឹងកហើយ ។

មិនយូរប៉ុន្មាន ផលាក៏បររថយន្តមកដល់វីឡាមួយដ៏ធំជង្រ្គឹង ។ ប៊ុរីចុះពីរថយន្ត ដើរចេញទៅ ទាំងដួងចិត្តច្របូកច្របល់អំពល់ខុស ប្រក្រតី ។ នៅទីនោះ ប៊ុរីក៏បានប្រទះវត្តមានរបស់លោកបុរាណនិង ភរិយា ព្រមទាំង

លោកផៃយ៉ាតនិងអ្នកស្រីឆដាជាឪពុកម្តាយរបស់ កញ្ញាផលានៅទីនោះផង ។ គេក៏លើកដៃផ្តុំជរាបសួរ ។

- ម៉េចហើយកូនប្រុស ? ជាស្រួលបួលហើយហ្អែស ?

អ្នកស្រីផៃយ៉ាសួរ ។

- បា៎ទ! គឺជិតដូចធម្មតាវិញហើយ ។ (ប៊ុរីឆ្លើយ)

ពេលនោះ ប៊ុរីសង្កេតឃើញចាស់ៗហាក់ដូចជាយកចិត្តទុកដាក់ ចំពោះសុខទុក្ខរបស់នាយគ្រប់គ្នា ។ គេនឹកពិភាល់ក្នុងចិត្តតែម្នាក់ ឯង លួចគិតថា :

- តើលោកទាំងបួននាក់កំពុងគិតអ្វីដែរទៅ ? ឬក៏លោកបានដឹង រឿងអតិតកាលរវាងយើងនិងផលា ?

CHANBOKEO.COM

គេនឹកភ័យខ្លួនផ្អួចៗ រសាប់រសល់នៅមិនសុខសោះ ។ ខណៈ នោះ លោកបុរាណក៏មានប្រសាសន៍ថា :

- យើងនឹងស្នាក់ទីនេះពីរបីថ្ងៃ រង់ចាំមើលថាតើភ្នែករបស់កូនមាន ប្រតិកម្មយ៉ាងណាដែរ ។ បើមានរឿងអ្វីមិនស្រួល នោះកូនអាចវិល ត្រលប់ទៅអោយពេទ្យពិនិត្យវិញបាន មិនបាច់ធ្វើដំណើរឆ្ងាយ ។ បន្តិចទៀត មីងបូរារបស់ឯងក៏នឹងមកដល់ទីនេះ បរិភោគបាយជុំគ្នាដែរ ។

បុរីដាក់មុខចុះមិននិយាយអ្វីទេ ។ ការពិត គេជាមនុស្សបាន មាត់បានកណាស់ តែពេលនេះ គេគ្មានអារម្មណ៍ចង់និយាយលេង ជាមួយនរណាទេ ។ ចិត្តគេចង់តែហោះត្រលប់ទៅបាត់ដំបងវិញថ្ងៃ នេះតែម្តង ។ ចៃដន្យចាស់ៗមានកម្មវិធីផ្សេងៗធ្វើឲ្យនាយត្រូវ អាក់ខានបំណងរបស់គេអស់រលីងតែម្តង ។

អ្នកស្រីឆដាអង្គុយសម្លឹងមុខបុរីយូរហើយ ក៏សួរថា :

- បុរីទៅរៀនជប៉ុនអស់ពីរបីឆ្នាំ ដូចជាមិនដែលឃើញសរសេរសំបុត្រអ្វីមកលេងសួរសុខទុក្ខអីសោះ ប្រហែលជាជាប់រៀនមមា ញឹកហើយមើលទៅ!

នរៈធ្វើមុខញឹមៗមិនហ៊ានឆ្លើយទេ ។ តើនរណាទៅ ហ៊ានឆ្លើយ នោះលោកអើយ បើកាលណោះ បុរីដើរលេងមានមិត្តស្រីរាប់មិន អស់យ៉ាងនោះ ? ឃើញនាយនៅអឹមអៀន លោកផៃយ៉ាតមាន ប្រសាសន៍ថា :

- ប្រហែលជាកូនធុញទ្រាន់នឹងការសន្ទនារបស់ចាស់ៗហើយបុរី! នែ៎ បើអផ្សុកពេក... ចេញទៅនិយាយលេងជាមួយនឹងផលាទៅ ។ គេបែកឯងយូរឆ្នាំហើយ ប្រហែលជាមានអ្វីច្រើនត្រូវនិយាយប្រាប់ គ្នា មែនទេ ? ទៅចុះណ៎!

បានទទួលការអនុញ្ញាតហើយ បុរីក៏ដើបទៅអង្គុយនៅកៅអីថ្ម មួយនៅចំហៀងផ្ទះ មើលសេកក្នុងទ្រុងមួយគូកំពុងចឹកគ្នា :

- ឱ! សេកអើយ... មើលទៅអ្នក ហាក់ដូចជាមានសេចក្តីសុខ ណាស់... តែខ្ញុំវិញហេតុដូចម្តេចបានជាតប់ប្រមល់ម្លេះ ?

ភ្លាមនោះ ផលាយកទឹកត្រជាក់មកហុចអោយបុរសយើង រួច ដាក់ខ្លួនអង្គុយជិតនាយភ្លាម :

- ពីរឆ្នាំហើយ ដែលយើងដាច់ដំណឹងពីគ្នា ។ ពេលនេះ ផលា ចង់ដឹងណាស់ថា បងបុរីនៅគិតយ៉ាងណាដែរចំពោះរឿងយើង ?

CHANBOKEO.COM

ប៊ុរីភ្ញាក់ព្រើតដែលផិតាសួរនាយត្រង់ៗដូច្នេះ ។ គេមិនឆ្លើយ តបនាងសោះ បែរជាសួរត្រលប់ទៅវិញថា :

- ហើយចុះផលា នៅគិតយ៉ាងណាចំពោះបងវិញ ?

ផលាសម្លឹងមុខនរៈដោយក្រសែភ្នែកភ្លឺថ្លាផ្លេកៗ :

- ផលាមិនដែលប្រែប្រួលចិត្ត ពីរឿងអតិតកាលនិងពាក្យសន្យា របស់យើងទេ ប៉ុន្តែ... ផលាក៏មិនដឹងដែរថា បងនៅមានចិត្ត ចំពោះផលាដដែល ឬក៏យ៉ាងណា ?

មែនហើយ... ប៊ុរីមានចិត្តប្រែប្រួលមិនទៀងម្តងណាឡើយ ។ គេជាបុរសសម្បូណ៌ស្នេហ៍ ទៅដល់កន្លែងណា មានមិត្តស្រីត្រង់ហ្នឹង សន្យាត្រង់ហ្នឹង... រួចហើយក៏ភ្លេចចោលសូន្យឈឹងត្រង់ហ្នឹងដែរ ។ ពេលនេះ គេរកអ្វីមកនិយាយប្រាប់ផលាមិនបានឡើយ ។ មាណព នៅស្ងៀម មួយស្របក់ ក៏ស្រដីថា :

- មនុស្សយើងខ្លះ កាលនៅយុវវ័យតែងធ្វើអ្វីមិនបានគិតរាក់ជ្រៅ ទេ គិតតែពីធ្វើៗទៅដោយភាពភ្លើនភ្លើន ព្រើលតាមចំណង់ដោយ មិនគិតអំពីលទ្ធផលចុងក្រោយ ។ ថៃ្ងដន្យ លុះគេឈានចូលដល់ វ័យមួយទៀតដែលចេះទទួលខុសត្រូវ... ទើបគេដឹងថា អ្វីដែលគេ បានប្រព្រឹត្តពីក្មេង ជាអំពើកម្លៅ ខ្វះការពិចារណា ហើយគេក៏ មានវិប្បដិសារីនឹកស្តាយក្រោយចំពោះការប្រព្រឹត្តរបស់គេ រួចគេក៏ មានចិត្តសោកសៅ ព្រោះមិនដឹងថាត្រូវធ្វើយ៉ាងណា ដើម្បីកែកុន អតិតកាលអោយមកល្អជាវិញបាន...

- មានន័យថា ទូករបស់បងចេញចាកកំពង់ ស្វែងត្រើយថ្មីហើយ មែនទេ ?

- មិនមែនទេ... គឺមានន័យថា បងរកដីដាំដើមដូងរបស់បងមិន ទាន់បាន ម្ល៉ោះហើយក៏ចេះតែអណ្តែតត្រសែតរកទីដែលសមគួរនឹង ទម្លាក់ផ្លែដូងដាំ... ថៃ្ងដន្យពេលរកដីបានហើយ ដូងរបស់បងក៏ត្រូវ ចោរលួចបាត់ទៅ... ទើបពេលនេះ បងមិនដឹងថា បងគួរធ្វើយ៉ាង ម៉េចតទៅទៀតឡើយ ។

ផលាជ្រួញចិញ្ចើម ទំនងដូចជាកំពុងគិតនូវសំដីរបស់ប៊ុរីដែល ប្រកបដោយប្រស្នាជីវិត ។ បន្តិចមក នាងក៏ស្រដីថា :

- ដូច្នេះ ផលាមិនគួរនឹងសាងក្តីសង្ឃឹមអ្វី ចំពោះរឿងយើង តទៅ ទៀតដែរ មែនទេ ?

ប៊ុរីងក់ក្បាល ហើយវាចាតបខ្សិបៗថា :

- អោយបងសូមទោសផងណា៎ ផលា!...

CHANBOKEO.COM

ភ្លាមនោះ បុរសយើងសង្កេតឃើញថា ផលាកំពុងមានទឹកភ្នែក រលីងរលោង ។ គេក៏លូកទៅចាប់ដៃនាង ទះបន្ថើរៗ ព្រមទាំង ស្រដីល្ហងលោមថា :

- តែយើងនៅអាចរាប់គ្នាជាមិត្ត ឬជាសាច់ញាតិបានទេតើហ៎...

ផលាលេបទឹកមាត់ក្អឹក បំបាត់ភាពសៅហ្មងក្នុងចិត្តហើយក៏ ញញឹមសាថ្មី :

- តើផលាអាចសុំស្គាល់នារី ដែលបងជ្រើសរើសជាគូជីវិតផងបាន ដែរឬទេ ?

- បើសិនជាបងរកគេឃើញ... នោះបងនឹងណែនាំអោយផលាបាន ជួបមិនខាន ។

បរិយាកាសក៏ប្រែជាធូរស្រាលបន្តិច ចំពោះបុរីដែលគេមាន ឱកាសទម្លាយនូវឫសក្នុងដួងចិត្តប្រាប់ផលាមក ។ តែចំពោះមាណវី វិញ ថ្វីបើនាងប្រឹងញញឹមដាក់បុរីបានយ៉ាងស្រស់បំព្រង ប៉ុន្តែនៅ ក្នុងចិត្ត... ធិតាឈឺសែនឈឺ... សឹងតែស្រែកឲ្យបែកអាកាស ព្រោះ តែការខកចិត្តចំពោះស្នេហា ។ នេះឬចិត្តបុរស ? ពិតជាសាវា ណាស់... នេះហើយស្នាមស្នេហ៍យុវវ័យ...ពិតជាប្រែប្រួលមិនទៀង ទាត់ដូចដែលចាស់ៗធ្លាប់បានផ្ដែផ្ដាំប្រដៅកូនចៅ... ប៉ុន្តែ ហេតុអ្វី.. ហេតុអ្វីក្មេងៗមិនព្រមជឿចាស់សោះ ? ពេលនេះផលាយល់ហើយ ថាអ្វីដែលឪពុកម្ដាយនាងបានប្រៀនមកនោះមិនខុសពីការពិតទេ ។ នាងធ្លាប់ប្រឆាំងរឹងរូសចំពោះការស្ដីប្រដៅរបស់គាត់នាគ្រាមួយក្នុង អតីតកាល ។ កាលណោះ មាណវីកំពុងវង្វេងនឹងស្នេហាឈាមរាវ លង់នឹងភាពសង្ហារបស់បុរី លង់នឹងសំដីដ៏សែនពិរោះ ហើយគេក៏ ប៉ិនយកចិត្តស្រីៗណាស់ តើនារីណាមួយមិនលង់នឹងមន្តស្នេហ៍របស់ គេនោះ ? សំណាងល្អ បុរីនៅរក្សាព្រំដែលសីលធម៌អោយផលា នៅឡើយ បើមិនដូច្នោះទេ ពេលនេះ ប្រហែលជាផលាត្រូវយំស្ទា ផងក៏មិនដឹង ។

ពេលបរិភោគអាហារក៏ឈានចូលមកដល់...

អ្នកស្រីបូរាក៏បានមកជួបជុំទទួលទានអាហារ ជាមួយអ្នកទាំង អស់គ្នាដូចដែលលោកបុរាណមានប្រសាសន៍ ។ ថ្វីបើចាស់ៗមាន អារម្មណ៍ថា បរិយាកាសពេលនោះ មានភាពមនោរម្យយ៉ាងណាក៏ ដោយ ក៏បុរីនិងផលាស្វែងរកសេចក្ដីសុខក្នុងចិត្តមិនឃើញឡើយ ។ ផលានឹកតូចចិត្តឥតឧបមាដែលនាងធ្លាប់ចាំបុរីអស់ច្រើនឆ្នាំ តែការ រង់ចាំបែរជាត្រូវខកបំណងយ៉ាងអាសារ ។ ចំណែកនរៈយើងវិញ បានវង្វេងជ្រុះបាត់បេះដូងនៅទីណាមិនដឹង ។ ពេលនេះគេមាន សល់នៅតែរូបកាយប៉ុណ្ណោះ ។

CHANBOKEO.COM

ឯដួងវិញ្ញាណរបស់គេ បានហោះ ហើរអណ្តែតចាកចោលខ្លួនគេ ទៅលង់ក្នុងទឹកស្ទឹងសង្កែ ឯក្រុងបាត់ដំបងនោះបាត់តាំងពីកាលណាទៅហើយ ។

*ooooooooooooooooo*

*ooooo*

*o*

CHANBOKEO . COM

# វគ្គទី១១
# ឪពុក

ប៊ុរីភ្ញាក់ពីព្រលឹម រៀបចំខោអាវ...

- គិតទៅណាហ្នឹងប៊ុរី ?

លោកបុរាណឃើញកូនរៀបឥវ៉ាន់ក៏សួរ ។

- គឺ... ចង់វិលទៅបាត់ដំបងវិញថ្ងៃនេះលោកប៉ា ។
- អូហ៍... ឥលូវនេះ កូនស្រលាញ់បាត់ដំបងវិញហើយហ្ន៎ស ?

ប៊ុរីឈ្ងោកមុខមិនហ៊ានតបនឹងឪពុកវិញទេ ។ លោកបុរាណក៏ មានប្រសាសន៍បន្តថា :

- ប៉ាមានការនៅភ្នំពេញនេះ មិនទាន់អាចត្រលប់ទៅផ្ទះវិញបានទេ ចាំពីរបីថ្ងៃទៀត ។ ដូច្នេះ ចូរកូនមើលថែទាំខ្លួនផងណ៎ា !
- បាទ លោកប៉ា !

រំពេចនោះ រ៉ាវុធបររថយន្តមកដល់ ។ ប៊ុរីក៏ប្រញិបប្រញាប់ ឡើងរថយន្តភ្លាម ស្រាប់តែ :

- ផលាសុំទៅតាមម្នាក់ផង បងប៊ុរី ! (ផលារត់មកដល់ដែរ)
- អូហ៍ បងមិនមែនទៅដើរលេងវិលល្ងាចទេ ផលា ! បើអូនចង់ ទៅលេង ចាំទៅជុំគ្នាជាមួយលោកប៉ារបស់បងវិញណ៎ា (ប៊ុរីឆ្លើយ)

ផលាធ្វើមុខស្មើក ថយចេញទៅវិញ ។ ការពិត នាងមិនទាន់ អស់ចិត្តទេ ដែលសុខៗ ប៊ុរីដើរចេញពីជីវិតស្នេហារបស់នាងទៅ ដោយសោះកក្រោះ ។
នាងចង់ដឹងណាស់ថាតើគូប្រជែងរបស់នាង ជានរណា ?
ហើយហេតុអ្វីនារីនោះមានឥទ្ធិពលដណ្តប់ចិត្តរបស់ប៊ុរី បានយ៉ាងងាយដូច្នេះ ?
តើប៊ុរីពិតជាបោះយុថ្កាចតទូកជីវិត ក្នុងទឹក

CHANBOKEO.COM

ស្មឹងសង្កៃនោះមែនឬក៏គ្រាន់តែជាភាពភ្លើតភ្លើនមួយរបស់គេដែល
មិនទាន់លះបង់បាននៅឡើយ ?

កំពុងតែគិត ស្រាប់តែ...ទីន! ទីន!

នារីសោភាមួយរូបបររថយន្តមកដល់ ។ ឃើញវត្ថុមានរបស់ នាងភ្លាម ប៊ុរីភ្ញាក់ក្រញាង
លាន់មាត់ថា :

- អូនសម្ផស្ស ?

ផលាបែរមើលទៅសម្ផស្ស ដែលដើរចុះពីរថយន្តក្នុងសម្លៀក យ៉ាងស៊ីវិល័យថ្លៃអស្ចារ្យ
ហើយបើកភ្នែកធំៗ ទំនងភ្ញាក់ផ្អើល ។ ឆវីល្អួចគិតក្នុងចិត្តតែម្នាក់ឯងថា :

- នេះឬ នារីម្ចាស់ចិត្តរបស់បងប៊ុរី ? ពិតជាសិចស៊ីណាស់តើហ៎!

សម្ផស្សឈ្លោកនិយាយជាមួយប៊ុរីនិងរ៉ាវុធ ដោយមិនរវីរវល់
នឹងវត្ថុមានរបស់ផលាដែលកំពុងឈរក្បែរនោះឡើយ :

- បងទាំងពីរទៅណាហ្នឹង ? កុំប្រាប់ណា ថាបងរ៉ាវុធកំពុងចង់នាំ
បងប៊ុរីទៅវាលចំណតយន្តហោះ!

- អូនទាយត្រូវហើយ សម្ផស្ស! (រ៉ាវុធឆ្លើយ) នាយប៊ុរីគេមានការ
ត្រូវត្រលប់ទៅបាត់ដំបងឥឡូវនេះ ។

- អញ្ចឹង សម្ផស្សសុំតាមទៅផង ។ កាលមុន សម្ផស្សខំតាមទៅ លេងដល់បាត់ដំបង
បងប៊ុរីចេញដើរក្រៅក្រុងចោលអូនបាត់ ។ លុះអូនត្រលប់មកភ្នំពេញវិញហើយ
ក៏នៅមិនឃើញមកតាមរកអូន ទៀត ។ ព្រឹកមិញអូនឮគិមណាងប្រាប់ថាបងស្នាក់នៅទីនេះ ទើប
អូនតាមមករកតែម្ដង ។ ស្អប់មែន បងប៊ុរីឯងនេះ! ឥឡូវចេះ
វាយឫកដាក់សម្ផស្សដល់ស្ទូរហើយ ។

សម្ផស្សនិយាយហាក់ដូចជាមិនបានដឹងរឿងប៊ុរីត្រូវរបួសដោយ
ផ្សែងគ្រាប់ផ្លោងនៅភ្នំជញ្ជាំងរហូតដល់ត្រូវការការព្យាបាលពិសេស នោះឡើយ ។
ថាផុតពីមាត់មិនទាន់ ស្រីស្រស់ក៏ហាក់ឡើងរថយន្ត របស់រ៉ាវុធនៅបាំងក្រោយភ្លាម ។

- ហើយចុះឡានរបស់អូនវិញនោះ សម្ផស្ស ? (រ៉ាវុធសួរ)

- បងរ៉ាវុធជួយយកទុកអោយផងទៅណ៎! នែះកូនសោរ!

CHANBOKEO.COM

សម្ផស្សបោះកូនសោរអោយរ៉ាវុធវិញហើយអង្គុយធ្វើមិនដឹង ។ រ៉ាវុធនិងបុរីមើលមុខគ្នា តែគ្មាននរណាហ៊ានវាចាថាម៉េចទេ ។ ភ្លាម នោះស្រាប់តែផលាបើកទ្វារម្ខាងទៀតចូលអង្គុយដែរ ព្រមទាំងវាចា ទៅបុរីថា :

- ផលានឹងជូនបងបុរីទៅបាត់ដំបងថ្ងៃនេះដែរ ។ មិនដែលបាន ជួបនិយាយគ្នាជាមួយបងបុរីយូរឆ្នាំ ផលាដូចជានឹកបងអ្វីម្ល៉េះទេ ។

បុរីភ្ញាក់ព្រើតនឹកក្នុងចិត្តថា :

- ក្រែងម្សិលមិញយើងនិយាយគ្នាជាក់ច្បាស់ហើយតើ ផលា ? ចុះ ហេតុអ្វី ថ្ងៃនេះ អូនដូរចិត្តទៅវិញអញ្ចឹង ?

ពេលនោះ បុរីរមួលក្នុងពោះ ហាក់ដូចជាចង់ឈឺ...

- យ៉ាងម៉េចហ្នឹងបុរី ? មិនស្រួលខ្លួនហ្អែស ? (រ៉ាវុធសួរ)
- គឺ គ្នាកំពុងពុលបរិយាកាស... ប្រហែលជាក្រុងភ្នំពេញនេះមាន ឧស្ម័នពុលច្រើនពេកទេដឹង ?

រ៉ាវុធយល់ហេតុការណ៍លួចញញឹម រួចហើយស្រដីខ្សិបៗដាក់ ត្រចៀករបស់មិត្តខ្លួនថា :

- មើលទៅ គ្មាននរណាអាចជួយឯងបានទេ បុរី... ចេះចង ត្រូវតែ ចេះស្រាយដោយខ្លួនឯងហើយ ។

ថាហើយ គេក៏បររថយន្តចេញទៅ ។ បុរីធ្វើមុខស្ពឹក និយាយ លែងចេញ ។ នៅបាំងខាងក្រោយ នារីរូបស្រស់ពីររូបលួចចោល កន្ទុយភ្នែកប្រយុទ្ធគ្នាយ៉ាងខែងរ៉ែង... មិនដឹងថាតើខ្លាមួយណាខ្លាំង ជាងទេ ទាល់តែយើងតាមដានតទៅទៀតហើយ ។

យន្តហោះរោទិ៍ង្ហូងយ៉ាងលាន់ខ្ទ័រដី...

បុរីភ័យអរៗតែក្នុងចិត្ត ។ គេបែរមើលភ្នំពេញជាចុងក្រោយ :

- ឱភ្នំពេញដ៏ស្រស់ស្អាតអើយ... ពេលនេះ ខ្ញុំសូមលាទៅស្វែងរក សោភ័ណពិតរបស់ទីក្រុងកំណើតរបស់ខ្ញុំ ឯបាត់ដំបងវិញហើយ មិនដឹងថ្ងៃណាយើងវិលជួបអ្នកទៀតទេ...

មែនហើយ... កាលគេចេញដំណើរពីភ្នំពេញទៅបាត់ដំបងកាល ពីជាងមួយខែមុននេះ គេគិតថា គេនឹងទៅបាត់ដំបងតែពីរបីថ្ងៃទេ ថៃដន្យ ស្ថានការណ៍បានផ្លាស់ប្តូរ ។ គេក៏បានធ្លាក់ជាប់ផុងក្នុងដីឥដ្ឋ នាមាត់ស្ទឹងសង្កែដកជើងមិនរួច... ថែមទាំងជ្រុះបាត់បេះដូងរបស់ គេទៅក្នុងទឹកស្ទឹងរកមិនទាន់ឃើញទៀតផង ។ ពេលនេះ អ្វីដែល គេប៉ងប្រាថ្នាធំបំផុតនោះ

គឺ...ស្វែងរកបេះដូងរបស់គេអោយឃើញ មកវិញ ។ មិនដូច្នេះទេ...
គេមិនចាកចោលដីបាត់ដំបងជាដាច់ ខាត ។ នរៈបានស្បថសច្ចាក្នុងចិត្តយ៉ាងដូច្នេះតែម្នាក់ឯង...

នៅកៅអីសងខាងឆ្វេងស្តាំរបស់ប៊ុរី... នារីពីររូបកំពុងដណ្តើម គ្នាយកចិត្តយកថ្លើមនរៈដល់ស្ទូរហើយ ជួនពេលខ្លះធ្វើអោយបុរស យើងគិតថា គេជាកូនតុក្កតាមួយអោយនារីធ្វើនុយសំរាប់ប្រជែងគ្នា ដណ្តើមជ័យលាភី ។ យូរៗម្តង នាយយើងលួចដើបទៅឈរនៅ មុខបន្ទប់ទឹកតែម្នាក់ឯង ដើម្បីគេចចេញពីសមរភូមិប្រយុទ្ធដោយ កម្លាំងកន្ទុយភ្នែកបាញ់ផ្តក់សម្លក់គ្នាអោយស្លាប់ចិត្តគូភាគីម្ខាងៗ ។

មកដល់ក្រុងបាត់ដំបងភ្លាម ប៊ុរីក៏ហៅរ៉ឺម៉កជិះ ។

- ស្លាប់ហើយ សម្ផស្ស ស្លៀកមីនីខ្លីយ៉ាងនេះ អោយឡើងជិះរ៉ឺម៉ក យ៉ាងម៉េចកើត ? ហៅឡានតាក់ស៊ីបានទេ បងប៊ុរី ?

ប៊ុរីលើកវ៉ែនតាខ្មៅពាក់ រួចឆ្លើយថា :

- ថៃដន្យ នៅបាត់ដំបង គេជិះតាក់ស៊ីតែសំរាប់ធ្វើដំណើរផ្លូវឆ្ងាយ ទេ ហើយចំណតឡានមានចម្ងាយដល់ទៅជាងបីគីឡូឯណោះ អូន សម្ផស្សចង់ដើរទៅហៅជិះ ជាមួយបងទេ ?
- ពុទ្ធោ ? ដល់ទៅបីគីឡូផង ? អញ្ចឹងអោយសម្ផស្សធ្វើម៉េច ?
- មានធ្វើម៉េច ? បើមិនជិះរ៉ឺម៉ក មានតែដើរប៉ុនហ្នឹងឯង !

សម្ផស្សបំរុងនឹងហក់ជិះខាងក្រោយ សំយុងជើងទៅហើយ ស្រាប់តែផលាលោតផ្លោតទៅអង្គុយកាត់មុខបានមុនភ្លែត ។ នារីរូបស្រស់ទាំងពីរធ្វើឌឺយដាក់គ្នាយ៉ាងឆ្មើងឆ្មៃ គ្មាននរណាមួយចាញ់ នរណាសោះ ។ ស្រាប់តែសម្ផស្សធ្វើជាមាយា :

- បងប៊ុរី ជួយលើកអូនដាក់រ៉ឺម៉កបន្តិច ។

ប៊ុរីបែរមើលជុំវិញខ្លួន ឃើញអ្នកដំណើរឈរមើលនរៈព្រោង ព្រាត ។ គេក៏នឹកភ្នករឿងមួយ :

- បងរ៉ឺម៉ក...! ជួយលើកអ្នកនាងរូបស្អាតដាក់រ៉ឺម៉កបន្តិច ចាំខ្ញុំថែម សោហ៊ុយអោយឌុបពីរដង ។

បុរសនោះឮដូច្នោះអរព្រើត ត្បិតគាត់នឹងបានលុយផងបានប៉ះ សាច់នារីរូបស្អាតផង ។ គាត់ក៏សើចស្ញាញចេញធ្មេញគ្រហុបសល់ តែអញ្ញាញធ្មេញពណ៌ផ្កាឈូកគួរឲ្យស្នេហ៍តែម្តង ។ គ្រាន់តែសម្ផស្ស ក្រលេកឃើញគាត់ភ្លាម ក៏ស្រែកវ៉ាសឡើង :

CHIANBOKEO.COM

- នែ៎ពូ មិនបាច់មកជិតទេ! ខ្ញុំឡើងមកជិះខ្លួនឯងក៏បានដែរ ។

សម្ផស្សតតោះតតះឡើងជិះដោយខ្លួនឯងយ៉ាងលំបាក ។ នាង ឧទានថា :

- យី! បើនឹងគ្មានអ្នកបរឡានមកទទួលបែបនេះ ប្រហែលជា សម្ផស្សមិនចេញពីភ្នំពេញឡើយ ។ យ៉ាប់មែនបងបុរី...! ម៉េចមិន ប្រាប់មុនថាយើងនឹងត្រូវជិះរ៉ឺម៉កទៅផ្ទះ ?

ភ្លាមនោះ ផលារមាស់មាត់ណាស់ក៏និយាយឡើងថា :

- អ៊ីយ៉ូយ! បងបុរី! ហេតុអីខ្ញុំវានេះវាភ្លេចច្រើនដូចមនុស្សចាស់ ទៅកើតហ្ន៎ ថាក្រុងបាត់ដំបងវាមិនស៊ីវិល័យដូចភ្នំពេញ... មកលេង ប៉ុន្មានដងហើយ ចេះតែភ្លេចបើកភ្នែកមើលគេមើលឯង... ទៅណា មកណា ដូចយាយចាស់ពពីមពពើមដកខ្ញី... យ៉ាប់ណាស់ខ្ញុំនេះ!

សម្ផស្សឮដូច្នោះក៏សម្លក់ផលាភ្លាម រួចក៏ស្រដីឡើងដែរ :

- បងបុរី! សម្ផស្សចង់ដើរលេងតែពីរនាក់បងទេ សូមប្រាប់អ្នក ទីបីផង ថាកុំមកជ្រៀតជ្រែកពេលយើងចេញទៅណាមកណា ។

បុរីតឹងចិត្តពេកក៏ដកដង្ហើមយូ នឹកក្នុងចិត្តតែម្នាក់ឯង...

- យើងនេះកំពុងនាំភ្លើងចូលផ្ទះហើយ ។ បើសិនយើងនាំអ្នកទាំង ទៅស្នាក់នៅផ្ទះរបស់យើង នោះប្រៀបដូចជាយើងភ្លើងដុតជីវិត ខ្លួនឯងដូច្នោះ ។ តើយើងគួរនាំនាងទាំងពីរទៅណា ដើម្បីកុំអោយ ម៉ៅយល់ច្រឡំនឹងយើង ?...

បន្តិចមក បុរីក៏បញ្ជាអ្នករ៉ឺម៉កអោយដឹកគេទៅដូនទាវ ។

- យី! បងបុរី! ផ្ទះបងមិនមែននៅដូនទាវឯណា ?

សម្ផស្សលាន់មាត់ ។ តែបុរីអង្គុយធ្វើព្រងើយហាក់មិនដឹង មិន ឮអ្វីទាំងអស់ ។ មួយសន្ទុះក្រោយមក គេក៏បានមកដល់មុខផ្ទះ របស់សាមេត ។ គេក៏ហក់ចុះពីរ៉ឺម៉ក ហើយដើរឡើងទៅលើផ្ទះរឹង ស្រាប់តែប្រទះសាមេត និងប្អូនប្រុសរបស់គេ ទាំងពីរនាក់ព្រមគ្នា នៅទីនោះតែម្តង :

- សួស្តីសាមេត!
- យី! បុរី ? សុខសប្បាយទេ ? ថ្ងៃនេះមាននាំមិត្តស្រីមកលេង យើងផងហ្អែស ?

(សាមេតលាន់មាត់)

CHANBOKEO.COM

សាមឿនលួចសម្លឹងនារីទាំងពីរយ៉ាងភ្លឹកពីចម្ងាយ តែគេមិន មានធ្វើមាត់ធ្វើកអ្វីទេ ព្រោះទុកអោយបងប្រុសចេញមុខទទួល ។

- គ្នាសុំផ្ញើមិត្តពីរនាក់អោយនៅស្នាក់លេងពីរបីថ្ងៃបានទេ ?

- អូហ៍ ? ហើយចុះឯងទៅណា ?

- គ្នាមានការផ្ទាល់ខ្លួនពិសេស មិនចង់អោយនារីរូបស្អាតត្រូវអំពល់ ជាមួយ ទើបគិតយកមកផ្ញើអោយនៅលេងនឹងឯងសិនទៅ...

- ប៉ុន្តែ... គ្នាមានសង្សារហើយណា៎... បើនាងឃើញនារីស្រស់ស្អាត លើផ្ទះរបស់ខ្ញុំ តើអោយខ្ញុំទៅដោះស្រាយជាមួយនាងបែបណា ?

- អឺ...គ្រាន់តែពីរបីថ្ងៃតើហ៍ វាមិនជាស្អីទេ ។ បើសិនសង្សារឯង មករករឿង ចាំគ្នាទៅជួយដោះស្រាយអោយ ។

សាមេតធ្វើអេះអុញ ស្រាប់តែប៉ុរីបក់ដៃ :

- សម្លស្ស ! ផលា ! នេះបងសាមេត ជាម្ចាស់ផ្ទះនេះហើយជាមិត្ត របស់បងផង ។ ចំណែកខាងនេះ គឺជាប្អូនប្រុសរបស់គេឈ្មោះ សាមឿន ។

ផលាលួចសម្លឹងសាមឿនមិនដាក់ភ្នែក ថែមទាំងគិតក្នុងចិត្ត ម្នាក់ឯងថា :

- យី ! នៅជនបទតូចតាចបែបនេះ មានបុរសសង្ហាដែរហ្ន៎ ?

សាមឿនហាក់ដូចជារអៀសខ្លួនបន្តិចដែរដែលធិតាទីក្រុងហ៊ឺហា រូបសោភាលួចគន់រូបគេមិនដាក់ភ្នែក ។ បន្តិចមក សាមេតក៏នាំនារី ទាំងពីរទៅបង្ហាញកន្លែងស្នាក់ ។ ភ្លាមនោះ ប៉ុរីក៏លួចខ្សិបប្រាប់ ទៅសាមឿនថា :

- បងលាទៅវិញសិនហើយ... ហើយប្រាប់សាមេតផងថាមិនបាច់ តាមរកបងទេ ព្រោះបងមិននៅផ្ទះ ។ ចាំពីរបីថ្ងៃទៀត បងមក ទទួលពួកនាងត្រឡប់ទៅវិញ ។

- បាទ !

សាមឿនឆ្លើយទាំងទឹកមុខឆ្ងើងឆ្ងល់ ។ ប៉ុរីក៏ហក់រឹងឡើងវ៉ុម៉ក ត្រលប់ក្រោយភ្លាមយ៉ាងរហ័សដោយមិនរង់ចាំមើលថាតើសាមេតគេ នឹងទទួលនារីទាំងពីររូបនោះយ៉ាងណាទេ ។ មួយសន្ទុះមក គេក៏ បានមកដល់ផ្ទះលោកគ្រូពេទ្យវិចិត្រ ក៏ជួបនឹងអ្នកគ្រួចរណៃ :

- ជំរាបសួរបាទ !

CHIANBOKEO.COM

- អូហ៍... បុរី! ជាសះស្បើយហើយហ្អែសកូន ?
- បាទ! បានស្រួលបួលវិញហើយ... ហើយចុះស្រីម៉ៅនៅដែរឬទេ អ្នកមីង ?
ស្រាប់តែអ្នកគ្រូជូតទឹកមុខតែម្តង រួចឆ្លើយថា :
- មែនហើយ... មីងក៏ចង់សួរកូនរឿងហ្នឹងដែរ... ថាតើកូនបាន ប្រព្រឹត្តអ្វីលើគេខ្លះ ទើបកូនស្រីរបស់មីងលែងជាមនុស្សធម្មតា នឹងគេរស់រលីងយ៉ាងអញ្ចឹង ?
បុរីស្លេះទឹកមុខភ្លាម រួចស្រាប់តែដាក់ខ្លួនលុតជង្គង់ចុះចំពោះ មុខអ្នកគ្រូ លើកដៃទាំងគូប្រណម្យឡើង :
- កូនពិតជាបានប្រព្រឹត្តខុសឆ្គងពិតមែន សូមអ្នកម្តាយលើកទោស ឲ្យកូនផង! ពេលនេះកូនចូលខ្លួនមកទទួលការដាក់ទោសពីអ្នក ម្តាយហើយ!
បុរីពោលទាំងអួលៗ ហាក់ដូចជាកំពុងមានក្តីអាឡោះអាល័យ នៅក្នុងចិត្តចំពោះស្រីម៉ៅជាអតិបរិមា ។ អ្នកគ្រូឃើញបុរីធ្វើដូច្នោះ ក៏ភ្ញាក់ស្រឡាំងកាំង ត្បិតមិននឹកស្មានថានរៈមកទទួលសារភាពខ្លួន យ៉ាងងាយៗដូច្នោះឡើយ ។ អ្នកគ្រូក៏មានប្រសាសន៍បន្តថា :
- ហើយបុរីមានគិតទេ ថាមីងនិងពូ គួរដាក់ទោសកូនយ៉ាងណា ?
- គឺ...យ៉ាងណាក៏បានដែរ សុំតែអនុញ្ញាតអោយខ្ញុំបានជួបម៉ៅវិញ
- ចុះបើម៉ៅគេមិនចង់ជួប តើគិតយ៉ាងម៉េចវិញ ?
- មិនមែនទេ... ខ្ញុំដឹងថាម៉ៅពិតជាចង់ជួបខ្ញុំ... តែបើនាងគេច ប្រហែលជាមកពីនាងខ្លាចចាស់ទុំស្តីបន្ទោស ឬក៏ខ្លាចខ្ញុំមានអតិត កាលមិនជ្រះស្រឡះ ដែលអាចធ្វើឲ្យប្រឡាក់ប្រឡូសដល់កត្តិយស របស់នាង ។
- ចេះគិតដូច្នោះ ល្អហើយ! ប៉ុន្តែ ចាស់ទុំរបស់នាង មិនបានស្តី បន្ទោសអ្វីដល់នាងទេ ព្រោះនាងជាជនរងគ្រោះ មិនមែនជាជន ដែលបំពានគេនោះទេ ។ ដូច្នេះ ចាស់ទុំចង់ដាក់ទោសអ្នកដែល បំពានគេមិនគប្បីឯណោះទៅវិញទេតើហ៍ កូនយល់ហើយឬនៅ ?
បុរីឮប្រយោគនេះ ក៏ឈ្ងោកមុខវាចាទៅអ្នកគ្រូថា :
- ឥឡូវនេះ កូនចូលខ្លួនមកអោយលោកឪពុកអ្នកម្តាយដាក់ទោស ហើយ សូមលោកជួយប្រដៃប្រដៅណែនាំផ្លូវកូនផង ។
នេះជាលើកដំបូងហើយដែលបុរីហៅអ្នកដទៃស្មើម្តាយរបស់ខ្លួន ដែលខ្លួនមិនដែលនឹកនាថានឹងធ្វើដូច្នេះឡើយ កាលពីដើមរៀងមក

CHANBOKEO.COM

សូម្បីតែអ្នកស្រីផៃយ៉ាដែលរៀបការនឹងលោកបុរាណពេញច្បាប់ ក៏
គេនៅមិនទាន់ទទួលអ្នកស្រីជាម្ដាយផង ។ បន្តិចមក អ្នកគ្រូមាន ប្រសាសន៍សួរមាណពទៀតថា :
- ហើយចុះ អតីតកាលរបស់ខ្លួនវិញ បុរីមានរៀបចំជ្រះស្រឡះ ហើយឬនៅកូន ?
បើមិនទាន់ជ្រះស្អាតទេ កុំអាលចង់ជួបកូនម៉ៅអី ក្រែងនាំអោយនាងល្អក់ចិត្តទទេៗ ។
ចូរបែរទៅជំរះរឿងចាស់ៗឲ្យ ស្អាត មានរបៀបសិនទៅ នោះម៉ៅគេនឹងរំភើបចិត្តចំពោះកូន
រិតតែខ្លាំងជាងនេះ ។ ម្យ៉ាងទៀត ពេលនេះ ម៉ៅក៏មិនបាននៅផ្ទះ ដែរទេ
ទោះបុរីចង់ជួបក៏មិនបានជួបគេឡើយ...

មាណពភ្ញាក់ព្រើត ងើបមុខឡើងសួរអ្នកគ្រូថា :
- តើម៉ៅគេទៅណា ? កូនសូមដឹងផងបានទេ អ្នកម្ដាយ ?
- កន្លែងដែលម៉ៅអាចទៅនោះ មិនមានច្រើនទេ ។ បើកូនពិតជា ស្រឡាញ់នាងប្រាកដមែន
យកបេះដូងរបស់ខ្លួនទៅគិតទៅថា តើ ម៉ៅគេចូលចិត្តទៅកន្លែងណាខ្លះ ?

ភ្លាមនោះ បុរីនឹកអរភើតតែម្ដង រួចថ្វាយបង្គំអ្នកគ្រូក្បាលដល់ កម្រាល :
- អរគុណអ្នកម្ដាយដែលបានជួយបំភ្លឺផ្លូវជីវិតរបស់កូន ។

មាណពក៏បាក់ចេញពីផ្ទះរឹង សំដៅមាត់ស្ទឹងសង្កែ ទៅកន្លែង
មួយដែលគេនឹងម៉ៅធ្លាប់មានអនុស្សាវរីយ៍នឹងគ្នា...

នៅលើដង្កត់ឈើមួយក្រោមម្លប់ដើមដូង ដែលដុះទេរចូលទៅ ក្នុងស្ទឹង នារីមួយរូប
សក់វែងអន្លាយខ្មៅរលើប នៅអង្គុយច្រងុក
សំកុកតែម្នាក់ឯងសម្លឹងខ្សែទឹកហូរដោយទឹកមុខក្រៀមក្រំ ។ គ្រាន់
តែក្រលេកឃើញវត្តមានរបស់ឆវីភ្លាម បេះដូងបុរីក៏កញ្ជ្រោលញាប់ ញ័រខុសចង្វាក់ភ្លាមតែម្ដង ។
គេឈរគយគន់នាងពីក្រោយយ៉ាងយូរ ស្ទើរមិនហ៊ានដកដង្ហើម ។
ក្រោមពន្លឺដ៏ស្រទន់នៃសែងឱភាសព្រះ សូរ្យពណ៌មាស
ឆ្លុះពណ៌ដ៏ស្រស់ស្អាតរបស់ផ្ទៃមេឃស្រកានាគទៅ ក្នុងទឹកស្ទឹងសង្កែ
ស្រស់កល្យាណីមានសោភ័ណមិនខុសពីរតននារី
នៅក្នុងគំនូរវិចិត្រកម្មរបស់សិល្បករញីកឌីមឡើយ ។ សូរសៀង
ស្រទន់នៃបទចម្រៀងរបស់លោកស៊ិនស៊ីសាមុត និពន្ធដោយលោក គង្គប៊ុនឈឿន
បានលាន់ឮល្វើយៗតាមរយៈឃោសនសព្ទក្នុងពិធី មង្គលមួយ

CHANBOKEO.COM

រសាត់តាមវាតាមកអង្អែលអារម្មណ៍បុរសយើងអោយរីង រិតតែព្រឺព្រួចអារម្មណ៍ឡើង រំភើបឡើងនឹងសោភ័ណនារីខេមរាដង ស្ទឹងសង្កែ...

- វិចិត្រករអើយកុំបាច់គូរអី... នៅក្នុងលោកិយ៍ស្រីល្អគ្មានទេ...
  មានតែរំដួលដងស្ទឹងសង្កែ ដែលខ្ញុំលួចស្នេហ៍...
  ទោះរយខួបខែក៏ នៅចាំចង...

ថៃដន្យ មាណវីមួយរូបនេះ មិនមែនជាផ្ការំដួលរបស់លោក គង្គប៊ុនឈឿនទេ តែជាផ្កាកុលាបមួយទងដែលកំពុងរីកចោលក្លិន យ៉ាងក្រអូបក្នុងបេះដូងរបស់បុរី កម្លោះក្រុងបាត់ដំបងយើង... នាង ពិតជាមានសោភ័ណសម្ផស្សស្រស់ត្រកាលប្រណីតគួរអោយចាប់ចិត្ត ចេតនាប្រតិពទ្ធ័យ៉ាងក្រៃលែង នឹងរកពាក្យអ្វីមកបរិយាយអោយ សមស្មើមិនបានឡើយ ។

បន្តិចមក គេក៏ដើរទៅជិតហើយដាក់ខ្លួនអង្គុយពីក្រោយស្រស់ កល្យាណ ។ គេលូកដៃស្រវាអោបចង្កេះធិតាពីក្រោយយ៉ាងថ្នមៗ ព្រមទាំងអោនខ្សិបហៅនាងដោយទឹកចិត្តប្រតិពទ្ធ័បេតីរំភើប :

- ម៉ៅ !

មាណវីបែរក្រោយរឹង យើងរង្វង់ភក្ត្ររបស់បុរីភ្លាម ក៏ភ្ញាក់ក្រញាងសម្តែងកិរិយាហាក់ដូចជារន្ធត់ញាប់ញ័រ :

- ម៉េចអូនធ្វើមុខភ្ញាក់ផ្អើលយ៉ាងហ្នឹង ? មិនសប្បាយចិត្តទេ ដែល ឃើញបងត្រលប់មកវិញ ?

ស្រស់ស្រីឈ្ងោកមុខនៅស្ងៀម តែបុរីទទួលអារម្មណ៍ថាធិតាមិន រើបម្រះគេចពីរង្វង់ដៃរបស់គេគ្រាមុនៗទៀតឡើយ ទំនងប្រហែល ជានាងក៏នឹករលឹកបុរសយើងខ្លាំងណាស់ គ្រាន់តែនាងខ្មាស់មិនហ៊ាន បើកទ្វារបង្ហាញដួងចិត្ត ឲ្យមាណពបានយល់បានដឹងអារម្មណ៍ពិត របស់នាងតែប៉ុណ្ណោះ ។ ឃើញធិតាធ្វើទឹកភ្នែករលីងរលោង នរៈក៏ យកដៃអង្អែលកេសារបស់នាងថ្នមៗ...

- ម៉ៅ ! បងនឹកអូនណាស់... អូនដឹងទេ ? បងនឹកអូនស្ទើរតែគាំង បេះដូងស្លាប់ម្តងៗទៅហើយ ហេតុដូចម្តេចក៏អូនគេចពីបងទៅ បាត់ឥតចឹង ព្រលឹងមាសបង ?

ស្រីម៉ៅនៅតែមិនឆ្លើយដដែល ប៉ុន្តែបុរីចាប់អារម្មណ៍ថាធិតា កំពុងតែរំជើបរំជួលក្នុងចិត្ត មិនតិចជាងរូបនាយឡើយ ព្រោះអី ពេលគេស្រវាចាប់ដៃនាងកាន់ឡើង

CHANBOKEO.COM

ស្រាប់តែឃើញត្រជាក់ស្រេប ហើយញ័រទទ្រើក ទំនងភ័យអរផង ជ្រួលច្របល់ក្នុងចិត្តផង ។ គេបបោសដៃនាងបន្តើរៗ :

- ឈប់ខឹង ឈប់ព្រួយចិត្ត ឈប់ខកចិត្តអ្វីទាំងអស់ណាំអូន! ពេលនេះបងវិលមកវិញហើយ... បងសន្យាថានឹងធ្វើអ្វីៗសព្វយ៉ាង ដើម្បីរក្សាកិត្តិយសជូនអូន...

ប៉ុរីឈ្ងោកសម្លឹងក្រសៃភ្នែករបស់មាណវីដែលកំពុងបែរសម្លឹង មកនាយហាក់កំពុងចង់ដឹងពីជំរៅចិត្តរបស់នាងចំពោះខ្លួនយ៉ាង ណា... កាន់តែសម្លឹង គេកាន់តែរំជួលចិត្តទប់មិនបានសោះ ។ មែនហើយ... ពិតមែនតែស្រីម៉ៅជានារីសាមញ្ញមួយរូប តែធិតាមានសន្តានចិត្តប្រពៃណាស់ ។ នរៈដឹងថា នាងគ្រាន់តែយកសំដី អាក្រក់របស់នាងមកបាំងចំណុចខ្សោយរបស់ខ្លួន តែប៉ុណ្ណោះ ។ ពេលនេះ គេក៏បានដឹងដែរថានាងកំពុងមានទឹកភ្នែករលីងរលោង ព្រោះតែត្រេកអរចំពោះវត្តមានរបស់នាយថ្វីបើនាងមិននិយាយស្តី ចេញមកអោយនាយដឹងក៏ដោយ ។ នាងមិនបានហក់រត់គេចពីរូបគេដូចរាល់ដងដែលនាងធ្លាប់ធ្វើចំពោះនាយនោះឡើយ ។ ផ្ទុយទៅ វិញនៅពេលគេលូកកាន់ដៃធិតាយើង គេមានអារម្មណ៍ថា នាង ក៏ស្រវាក្តាប់ដៃនរៈវិញយ៉ាងណែនហាក់ចង់បង្ហាញថា នាងកំពុង មានសេចក្តីនឹករលឹកចំពោះបុរសយើងខ្លាំងឥតឧបមា ។

ជំរៅដួងចិត្ត

- សម្លឹងកែវភ្នែកញ្ញែកដួងចិត្ត មន្តស្នេហ៍អម្រិតប្រោសចិន្តា
  អង្អែលបេះដូងថ្នមឱរា ចំណងទ័យាគូមង្គល ។
- ដៃទ្វេប្រទាក់ផ្ទាក់ក្លិនផ្កា កុលាបសោភាល្អនិមល
  អប់ដោយក្លិនស្នេហ៍ថៃវិបុល ដងស្ទឹងមណ្ឌលខ្ពស់សាក្សី ។
- ទឹកអើយជួយដឹងស្ទឹងអើយចាំ ដីជួយកត់ដាំចាំសំដី
  ដួងចិត្តបងមួយជូនចរណៃ បង្ហាញភក្តីន័យសង្ឃឹម ។
- ជឿបងណាំអូនស្ងួនពាលពៅ ថ្ងៃនេះតទៅសូមញញឹម
  ផ្កាស្លាមង្គលយើងក្រាបផ្ទឹម ស្នេហ៍លាស់ប៉ប្រឹមត្រកាលអើយ..

រំពេចនោះ នរៈឃើញធិតារលីងរលោងទឹកភ្នែក ។ គេក៏យក ដៃទៅអង្អែលកេសានារីថ្នមៗហាក់ប្រាថ្នាលួងលោមចិត្តនាងអោយ ធូរស្បើយ ។ មួយស្របក់ក្រោយមក មាណវីក៏ស្រដីថា :

- តើម៉ៅគួរគិតយ៉ាងណាទៅទើបល្អ ?

CHANBOKEO.COM

- អូនមិនបាច់គិតអ្វីទេម៉ៅ គិតត្រឹមតែថា បងស្រឡាញ់អូនហើយ ស្រឡាញ់រហូតរៀងទៅ...
- ហើយចុះ នារីឯទៀតនោះ ?
- គ្មានទេ... គ្មាននារីណាទៀតទេ...
- ចុះនាងគវិញ ?
- នាងគ ? ក្រែងនាងគក៏ជាអូន មិនមែនទេ ?
- ម៉ៅមិនមែនជានាងគទេ ។ ការពិត នាងគ គឺជាបងស្រីរបស់ នាងភីទេតើហ៎...
- តែបងជឿជាក់ថា នារីម្នាក់ដែលនៅបំរើថ្នាក់ថ្នមបងនោះ គឺជា អូន ថ្វីបើអូនងឺក់មិននិយាយរកបងក៏ដោយ ។
- តើមានអ្វីទៅដែលធ្វើអោយបងជឿជាក់ដល់ម្លឹងនោះ ?
- គឺ... និស្ស័យរបស់អូននោះអី... គឺទោះបីជាអូនខំធ្វើតោះតើយ ឬមាត់អាក្រក់នឹងបងយ៉ាងណាក៏ដោយ ក៏អូននៅតែបង្ហាញសន្តាន ចិត្តដ៏ល្អរបស់អូន ចំពោះបងជានិច្ចដែរ មិនថាពេលណាទេ ។ បង ធ្លាប់អោបបីត្រកងខ្លួនប្រាណរបស់អូន តាំងពីលើកដំបូងដែលយើង បានជួបគ្នា ធ្លាប់លួចថើបស្រង់ក្លិនខ្លួនរបស់អូន សូម្បីតែពេលអូន បាត់ស្មារតីមិនដឹងខ្លួន ធ្លាប់កាន់ដៃអូញអង្អែលជាញឹកញាប់ រឿងអ្វី ដែលថា បងចំណាំអូនមិនបាន ថ្វីបើកាលមួយនោះបងងងឹតភ្នែក មើលអ្វី មិនឃើញក៏ដោយ ?
- បងពិតជាមិនជឿមែនទេ ថានាងគនោះមានពិតមែន ?
- គឺ... មានមែន... ដល់ទៅពីរនាក់ ម្នាក់ប្រហែលជានាង គ ពិត ប្រាកដ រីឯម្នាក់ទៀតជានាងគដែលងឹក់ងរមិននិយាយជាមួយបង ។
- បងចង់ឃើញគេទេ ? នោះបងនឹងអាលបានជ្រើសរើសថា តើ នារីណាមួយពិតប្រាកដ ដែលបងកំពុងចាប់ចិត្តប្រតិពទ្ធ័...

ពេលនោះ ប៉ុរីរន្ធត់ចិត្តផង កន្ទះរាផង សង្ស័យផង មិនអស់ ចិត្តផង ។ ប៉ុរីយកដៃបបោសកេសានាងបន្តើរៗ ហើយស្រដីថា :
- ថ្វីបើបងមិនដឹងថា នាងគជានរណា តែបងដឹងថានរណាជាម៉ៅ ពិតប្រាកដ គឺបងអាចញែកអ្នកទាំងពីរដាច់ពីគ្នា បានយ៉ាងជាក់ ច្បាស់... តើអូនចង់ពិសោធន៍បងទេ ?

ថាមិនទាន់ចប់ពីមាត់ផង ស្រាប់តែមានមនុស្សក្អកហៅតែម្តង:
- បងប្រុស ? ជាសះស្បើយហើយហ្អឹង ?

ប៉ុរីចាំសម្លេងនោះច្បាស់ណាស់ ។ គេបែរមើលភ្លាមហើយលាន់ មាត់ហៅឡើងថា :

CHANBOKEO.COM

- ប្អូនភី ?
- ចាស គឺខ្ញុំមែន! បងពូកែណាស់ដែលចាំខ្ញុំបាន ។
- ហើយចុះ... បងស្រីនិងពុកម៉ែរបស់ប្អូនវិញនោះ ?
- គាត់នៅលេងជាមួយអ៊ីស្រីអ៊ីប្រុសឯណោះ ។ បងចង់ទៅជួប គាត់ទេ ?
- ចឹមិនចង់ តែបងចង់និយាយជាមួយម៉ៅសិន ។ ហើយចុះឯណា បងស្រីរបស់ប្អូន ?
- នរណាគេ ? បងគហ្វ៉ូស ?
- បាទ!
- នោះ! គាត់កំពុងឈរកាន់កង់ឯខាងលើមាត់ច្រាំងឯណោះ មិន ព្រមចុះមកទេ ខ្លាចរំខានបងទាំងពីរ ។

ប៊ុរីភ្ញាក់ព្រើត បែរមើលតាមដៃនាងតូចភី ឃើញមាណវីមួយ រូបសម្ផុរស្រអែម អាយុប្រហែល ១៧ឆ្នាំ មុខមាត់ស្រដៀងៗនឹង ស្រីម៉ៅដែរ កំពុងឈរកាន់កង់ ចាំនាងតូចភីពិតមែន ។ គេភ្ញាក់ ព្រើត នឹកក្នុងចិត្តថា :

- ម៉ៅនិយាយការពិតមែនតើហ៍...ពុទ្ធោអើយ...វីវរហើយ តិចយើង ធ្វើអ្វីជ្រុលជ្រួសទៅលើនាងគមែនទៅ ?

ពេលនោះ បុរសយើងក៏ពោលទៅកាន់នាងតូចថា :

- អញ្ជើងនាងតូចទៅផ្ទះមុនចុះ ចាំបងឡើងទៅតាមក្រោយ ។ គ្រា នេះ បងចង់និយាយជាមួយស្រីម៉ៅបន្តិច ។
- ចាស!

នាងតូចភីក៏រត់រឹងនាំនាងគចូលទៅក្នុងបរិវេណគេហដ្ឋានរបស់ លោកគ្រូពេទ្យវិចិត្រទៅ ។

- ឃើញហើយនៅ ? ម៉ៅមិនបានភូតភរទេ ។

ស្រីម៉ៅស្រដីឡើង ។

- បងដឹងតើហ៍ ហើយក៏ដឹងដែរថា នារីដែលនៅបំរើបងឯផ្ទះពូ មេឃុំម្នាក់នោះគឺអូនតែម្តង... ថ្វីបើពេលខ្លះ អូនផ្លាស់វេនជាមួយ នឹងប្អូនគក៏ដោយ ។
- ម៉េចក៏បងដឹងកើតថាជាម៉ៅ ?
- គឺ... បងប្រាប់ហើយតើ... ក្លិនខ្លួននិងនិស្ស័យរបស់អូននោះអី ។ ការពិត អូនបំរើបងទន់ភ្លន់ណាស់ មិនដូចប្អូនគទេ ដែលធ្វើអ្វីឲ្យ ផុតតែពីដៃ មិនហ៊ានមកជិតស្និទ្ធនឹងបងឡើយ ។

CHANBOKEO.COM

- មែនហ្ន៎ស ? ហើយនៅចំណុចត្រង់ណា ពេលវេលាត្រង់ណា ដែលបងនឹងថា ម្នាក់ជាម៉ៅ ឬម្នាក់ជាប្អូនគ ?

- គឺ... អ្នកដែលអង្គុយយាមបងគឺប្អូនគ តែអ្នកដែលធ្លាប់បញ្ចុក បាយបងគឺអូន... អ្នកដែលលាងរបួសអោយបងក៏ជាអូន ។ នារី ដែលនៅអង្គុយមាត់ជណ្ដើរយាមបងនោះក៏ជាអូន ។ ហើយនៅរាត្រី ដែលយើងរត់គេចពីភូមិទៅពួននៅក្នុងព្រៃ គឺអូនជាអ្នកនាំផ្លូវបង រហូត ហើយក៏នៅ...នែបនិត្យជាមួយបងមួយយប់ទល់ភ្លឺដែរ ។

- និយាយតែផ្ដាស...!

- បងនិយាយពិត មិនបានភូតភរទេ... ឬក៏អូនមិនចង់ទទួលគេជា ឪពុករបស់កូនដែលនៅក្នុងផ្ទៃរបស់អូននោះ ?

- នែ៎... បងកាន់តែនិយាយផ្ដេសផ្ដាសទៀតហើយ...

- ម៉ៅ... ? ម្ដេចក៏អូនមិនទទួលស្គាល់ការពិតយ៉ាងនេះ ? យើង បានឆ្លងកាត់ជីវិតរាក់ជ្រៅមកជាមួយគ្នាណ៎ាអូន... ហេតុដូចម្ដេចអូន បែរបដិសេធដូច្នេះទៅកើត ?

ម៉ៅជ្រួញចិញ្ចើម លែងស្ដីតែម្ដង ។ បុរីឃើញកិរិយារបស់នាង ក៏ដើបឈរឡើង ហើយស្រដីថា :

- មែនហើយ... ទោះជាបងខំនិយាយយ៉ាងណាក៏អូននៅតែមិនទុក ចិត្តបងដដែលហ្នឹង... ប៉ុន្តែ បំណាច់បងដាក់ចិត្តស្រឡាញ់រូបអូន ស្មោះនឹងអូនប៉ុណ្ណឹងហើយ អូននៅតែមិនព្រមទទួលរូបបងទៀត... បងក៏សុខចិត្តកាត់បេះដូងរបស់បងធ្វើស្ទឹងសង្កែនេះវិញចុះ ។

ថាហើយ មាណពក៏ដើររឹងទៅកាន់ឆ្នេរស្ទឹងសម្លឹងទឹកស្ទឹងមួយ ស្របក់ ក៏លោតប្រូងចុះទៅ ។

- នែ៎... ម៉េចបងធ្វើអ្វីផ្ដេសផ្ដាសយ៉ាងហ្នឹង ?

ម៉ៅស្រែកឡើងភ្លាត់សម្លេង កាលបើឃើញបុរីហក់ដាំក្បាលចុះ ទៅ ។ នាងភ័យណាស់ក៏ស្ទុះរឹង លោតហក់ចុះទៅក្នុងទឹក តាម ក្រោយមាណព ប្រឹងហែលតាមរកបុរសយើងភ្លាម ។ ថែដន្យ ខ្សែទឹករនូវវស្សាមានកំសួលខ្លាំងក្លាបន្តិចហើយ ។ ធិតាហែលផង កូកហៅបុរីផង តែមិនបានការអ្វី ។ បន្តិចមក មាណវីក៏មាន អារម្មណ៍ថានាងលែងមានកម្លាំងតស៊ូជាមួយខ្សែទឹកគួចនៅក្នុងស្ទឹង សង្កែបានទៀតហើយ ។ ធិតាក៏ឆ្មេចភ្នែក ហៅឈ្មោះបុរសយើងជា ចុងក្រោយថា :

- បងរែ...!!

CHANBOKEO.COM

រួចហើយនាងក៏សិចកាយស្រីមៗ ចុះទៅក្នុងបាតស្ទឹង រករលត់
ស្មារតីទៅហើយ ស្រាប់តែនាងមានអារម្មណ៍នឹងតិចៗថា មានដៃ មួយមកកៀកអោបខ្លួននាង
ហែលចេញទៅខាងលើផ្ទៃទឹកវិញយ៉ាង រហ័ស... នាងខំបើកភ្នែកមើលដែរ តែបើកមិនរួច
មើលអ្វីក៏មិន
ឃើញ ។ នារីក៏បិទភ្នែកទៅវិញលែងដឹងអ្វីទាំងអស់តែម្តង ។

មិនដឹងជាអស់ពេលយូរប៉ុនណាទេ... និតាយើងក៏បើកភ្នែកមក វិញម្តងទៀត :

- បងរ៉ៃ... (នាងខទានហៅខ្សឹបៗក្នុងមាត់)

ស្រាប់តែមានសម្លេងខ្សឹបៗក្បែរត្រចៀកនាងតបវិញថា :

- បងនៅទីនេះហើយអូន... បើកភ្នែកមក...មើលមុខបងមើល ថា
តើជាបងរ៉ៃរបស់អូនមែនឬមិនមែន ?

កាលបើឮសម្លេងដ៏ស្រទន់ក្បែរត្រចៀក មាណវីយើងក៏ខំបើក នេត្រាឡើង
ប្រទះឃើញរង្វង់មុខបុរសម្នាក់នៅពីមុខ កំពុងអង្គុយ បីនាងក្នុងរង្វង់ដៃរបស់គេ ។
ម៉ៅរំភើបក្នុងចិត្តយ៉ាងណាមិនដឹង ក៏ស្ទុះដើបឡើងស្រវាអោបនរៈ ហើយក៏ទ្រហោរយំហ៊ូឡើង :

- បងរ៉ៃ...

- ម៉ៅ ! បងត្រេកអរណាស់ដែលអូនដឹងខ្លួនមកវិញ (ប៊ុរីពោល)

- បង.... មិនមានគ្រោះថ្នាក់អីទេ មែនទេ ?

មាណវីសួរទាំងសសឹកខ្សឹកខ្សួល ។

- បងមានអីឯណា ? ហេតុអ្វីក៏ម៉ៅធ្វើបាបខ្លួនយ៉ាងនេះ ?

- គឺមកពី...ម៉ៅគិតថា...បងបានលោតទឹកសម្លាប់ខ្លួន....

- ពុទ្ធោ ! ម៉ៅ... បងសូមទោសណា៎... គឺបងលលេងនឹងអូនតើហ៍...
បងនេះពិតជាយ៉ាប់ណាស់...មិនស្គាល់ចិត្តម៉ៅសោះ... ! !

ប៊ុរីពោលទាំងចិត្តរំជើបរំជួលអាណិតនិតា ដែលសម្តែងនូវពលី ចំពោះរូបគេយ៉ាងស្មោះស្មគ្រ័ ។
ពេលនេះ គេយល់ជំរៅចិត្តរបស់
នារីហើយថានាងចាប់អារម្មណ៍ហើយស្រឡាញ់រូបគេប៉ុនណា...គឺនាង ស្រឡាញ់រូបគេ
រហូតដល់ហ៊ានប្រថុយប្តូរជីវិតដើម្បីរូបគេម្នាក់ ។ មាណពខិនថើបថ្ពាសនាង
បង្ហាញនូវទឹកចិត្តស្នេហានិងក្តីអាណិត អាសូររបស់គេចំពោះនិតាយ៉ាងធំធេង ។ ប៉ុន្តែ

CHANBOKEO.COM

ស្រីម៉ៅបែរជាមាន ទឹកមុខកាន់តែស្លេកឡើងហើយ ទំនងដូចជាហេវហត់ក្រៃលែង ។  ពេលនោះ នាងក៏រណ្តំចង្អោឡើង ។ ប៊ុរីភិតភ័យក្នុងចិត្តយ៉ាងតក្កមា ក៏ពោលឡើងថា :

- ម៉ៅ អូនរងាហើយ! ចាំបងម៉ាភ្លែតណា៎ ។

ប៊ុរីក៏ចុះទៅសំដៅទៅរកទូកមួយ :

- ប្អូនប្រុស ជួយចម្លងបងបន្តិចបានទេ?

- បាទ ។

- អញ្ចឹងអោយបងសុំខ្ចីក្រមាស្ពួតរបស់ប្អូនអោយបងស្រីងណ្តប់សិន បានទេ... ចាំដល់ផ្ទះបង បងនឹងសងប្អូនវិញ ។

- បាទៗ!

នរ:ក៏បីស្រីម៉ៅដាក់លើទូកហើយទទួលក្រមាពីក្មេងប្រុសម្ចាស់ ទូកយកមកដណ្តប់អោយនាង រួចហើយគេអង្គុយអោបធិតាពីក្រោយ អោយនាងបានទទួលភាពកក់ក្តៅមកវិញ ។ តាមផ្លូវ គេនឹកអាណិត ធិតាខ្លោចចិត្ត មិនដឹងជានិស្ស័យអ្វីទេ ដែលរូបគេតែងតែនាំគ្រោះ ថ្នាក់ដល់ស្រីម៉ៅជានិច្ច ច្រើនដងហើយ ។ ប៉ុន្តែ ពេលគេប្រទះ ឧប្បត្តិហេតុម្តង គេស្រឡាញ់អាណិតធិតាបន្តិច លុះជួបហេតុការណ៍ កាន់តែច្រើន បុរសយើងក៏កាន់តែដក់ចិត្តលើនារីថែមទ្វេឡើង ជា លំដាប់មិនមានស្រោកស្រោន្តថមថយពេលណាទេ ។ ពេលនេះ នៅ ក្នុងបេះដូងរបស់គេ ប៊ុរីបានឆ្លាក់ស្រីម៉ៅទុកទាំងរូប ទាំងចិត្ត ទាំង អនុស្សាវរីយ៍ទាំងឡាយដែលម៉ៅធ្លាប់ប្រគល់អោយរូបគេ... គ្មានថ្ងៃ ដែលគេនឹកចង់បែកព្រាត់ពីនាងឡើយ ។

មួយស្របក់ក្រោយមក ទូកក៏បាននាំអ្នកទាំងពីរមកដល់ច្រាំង មុខផ្ទះអ្នកគ្រូចរណៃ ។ ប៊ុរីដកប្រាក់អោយក្មេងរត់ទូក រួចហើយក៏ ប្រញាប់បីមាណវីឡើងត្រលប់ទៅផ្ទះភ្លាម ។ នៅក្នុងផ្ទះ គ្រប់ៗគ្នា ភ្ញាក់ផ្អើលណាស់ពេលឃើញប៊ុរីបីស្រីម៉ៅមកដល់ ។ ពេលនោះធិតា ក៏ទទួលការថែរក្សាភ្លាមៗពីលោកគ្រូពេទ្យនិងក្រុមគ្រួសារដែរ ។

នៅខាងក្រៅបន្ទប់ ប៊ុរីអង្គុយត្រដុសដៃ ស្តាយក្រោយថា ខ្លួន ចេះតែខុសហើយខុសទៀតមិនចប់... មិនដឹងជារាសីរបស់នាយត្រូវ បណ្តាសាពីអារក្សទេវតាឬក៏អ្វី បានជានាំគ្រោះអោយស្រីម៉ៅមិន ឈប់ឈរសោះ ។ បន្តិចមក លោកពេទ្យវិចិត្រនិងអ្នកគ្រូចរណៃ ចេញពីបន្ទប់របស់ម៉ៅមកវិញ ។ គ្រាន់តែឃើញក្រសែភ្នែករបស់ លោកទាំងពីរ

ប៊ុរីមានអារម្មណ៍ថាបេះដូងរបស់គេរន្ធត់រកគាំងម្តងៗ ទៅហើយ ។
លុះឃើញលោកទាំងពីរដាក់ខ្លួនចុះក្នុងសាឡុង ប៊ុរីក៏ ស្ទុះចុះពីកៅអី
ទៅអង្គុយបត់ជើងនៅលើកំរាលឥដ្ឋ លើកដៃសំពះ លោកទាំងពីរភ្លាមឡើង :
- កូនសូមទោស លោកឪពុក អ្នកម្តាយ! សូមមេត្តាកុំបន្ទោសម៉ៅ អី!
អ្វីៗដែលកើតឡើងទាំងឡាយ ជាកំហុសរបស់ប៊ុរីតែម្នាក់ឯង ទេ ។
សូមលោកដាក់ទោសកូនមកចុះ!!

ឮវាចាប៊ុរីភ្លាម អ្នកគ្រូនិងស្វាមីក៏បែរមើលមុខគ្នា ។ បន្តិចមក លោកគ្រូពេទ្យវិចិត្រក៏ស្រដីថា
:
- កូនប្រុសចេះទទួលស្គាល់អំពើរបស់ខ្លួននោះជាការប្រពៃហើយ ។ ដូច្នេះ ចាប់ពីពេលនេះតទៅ
ត្រូវកែប្រែស្ថានការណ៍អោយល្អ ធូរ ស្រាលមកវិញ ។
នារីជាភេទទន់ភ្លន់គួរឲ្យថ្នាក់ថ្នមថែរក្សាណាស់ ។ បើកូនស្គាល់តម្លៃរបស់គេហើយ
ចូររក្សាថ្នាក់ថ្នមហើយគ្រប់គ្រងឲ្យ
គេមានសេចក្តីសុខផងនោះទើបមានន័យថាកូនពិតជាបុរសដ៏ប្រពៃ
សម្រាប់គ្រួសារអនាគតរបស់កូនពិតមែន ។

កាលបើស្តាប់នូវវាចាដ៏មានហេតុផល ហើយទន់ភ្លន់បែបនោះ
ប៊ុរីត្រេកអរហូតដល់រលីងរលោងទឹកភ្នែក :
- បើកូនមិនបានទទួលការអភ័យទោសពីលោកឪពុកអ្នកម្តាយពេល នេះទេ
ជីវិតកូនប្រហែលជាគ្មានឱកាសកែប្រែអ្វីអោយល្អវិញបាន ឡើយ ។
កូនសូមថ្លែងអំណរគុណចំពោះលោកទាំងពីរដែលមាន អធ្យាស្រ័យចំពោះកូន ។
លោកពិតជាម្លប់ដ៏ត្រជាក់របស់កូនយ៉ាង ឧត្តុង្គឧត្តមបំផុត ។ ចាប់ពីថ្ងៃនេះតទៅ
កូនសន្យាថានឹងរៀបជីវិត របស់ខ្លួនអោយបានប្រពៃសមរម្យបំផុត មិនអោយអ្នកម្តាយនិង
លោកឪពុកត្រូវខកចិត្តដោយសារកូនឡើយ ។

ប៊ុរីលូនទៅក្រាបសំពះលោកទាំងពីរដោយក្តីគោរព ។ មែន ហើយ
សេចក្តីស្នេហាដែលដុះពន្លកនៅក្នុងបេះដូងរបស់គេពេល នេះ បានធ្វើអោយនរៈនឹងថា
បេះដូងរបស់មាតាបីតានិងមេត្តាធម៌ របស់លោក ផ្តល់សេចក្តីកក់ក្តៅប៉ុនណាសំរាប់ជីវិត
ហើយការដែល គេរក្សាសេចក្តីស្មោះត្រង់នឹងគូជីវិតរបស់ខ្លួននោះ វាមានន័យធំធេង
យ៉ាងណាចំពោះដួងចិត្តរបស់ខ្លួន និងចំពោះអនាគតជីវិតគូស្នេហ៍ របស់គេ ។

CHANBOKEO . COM

មួយយប់នោះ បុរសបានសុំលោកឧកញ៉ាទ័រនិងអ្នកគ្រូនៅកំដរម៉ៅ មួយយប់ទល់ភ្លឺ ។ ឃើញកិរិយារបស់នាយហាក់ដូចជាមានក្តីបារម្ភ ចំពោះសុខទុក្ខរបស់ម៉ៅពន់ពេក លោកទាំងពីរក៏សម្រេចចិត្តអោយ ប៊ុរីនៅកំដរ ។

ម្យ៉ាងដោយសារឃើញកូនៗកាន់តែដើរជ្រុលជ្រួស ធ្លាក់ផ្លូវកាន់តែឆ្ងាយទៅៗណាស់ទៅហើយ បើសិននៅជិតភ្នែកជិត ច្រមុះ មានចាស់ទុំគ្រប់គ្រងខ្លះនោះ ប្រហែលជាក្មេងមិនសូវហ៊ាន ជ្រុលជ្រួសប៉ុន្មានទេ ព្រោះថាបើសិនជាមានការអ្វី ចាស់ទុំនៅអាច នៅជួយណែនាំធ្វើអន្តរាគមន៍បានខ្លះៗ មិនឃ្លាតសីលធម៌ពេកទេ ។

ព្រឹកស្អែកឡើង...

លោកគ្រូពេទ្យហៅប៊ុរីមកខ្សិបប្រាប់ស្ងាត់ៗ :

- ប៊ុរី ប៉ាសុំនិយាយគ្នាតាមរបៀបកូនប្រុសបន្តិចបានទេ ?
- បាទ ! សូមលោកប៉ាមានប្រសាសន៍មកចុះ !
- កូនពិតជាស្រឡាញ់ស្រីម៉ៅណាស់ មែនទេ ?
- បាទ ! គឺស្រឡាញ់ស្មើនឹងជីវិតរបស់កូនផ្ទាល់ ។
- ហើយ តើកូននឹងមានគម្រោងការយ៉ាងណាទេ ចំពោះជីវិតរបស់ កូនទាំងពីរ ?
- លោកប៉ាចង់មានប្រសាសន៍ថាម៉េច បាទ ?
- គឺមានន័យថា បើសិនកូនបានរៀបការនឹងគ្នា តើកូនមានមុខរបរ អ្វីចិញ្ចឹមគ្រួសារបានដែរទេ ?
- គឺ... ខ្ញុំអាល័យតែវិលវល់ចិត្ត មិនទាន់ចេញរកការធ្វើនៅឡើយ ទេ លោកប៉ា !
- អឺ... បើគ្មានការធ្វើ តើឯងនឹងចិញ្ចឹមកូនយ៉ាងណា ? ពេលនេះ កូនឃើញទេ ស្រីម៉ៅឈឺញឹកញាប់ណាស់ ខានធ្វើការមកជាយូរ ហើយ ។ នោះដោយសារព្រោះហេតុអ្វី ? ហើយ... នៅពេលនេះ...

ស្រាប់តែលោកឧកញ៉ាទ័រទុចជើង បែរសម្លឹងមើលប៊ុរីដោយក្រសែ ភ្នែកយ៉ាងមុត ។ ប៊ុរីខ្លាចពន្លឺភ្នែកនោះណាស់ ក៏ដាក់មុខចុះភ្លាម ។ លោកវិចិត្រក៏មានប្រសាសន៍បន្តថា :

- កូនដឹងទេ ? ពេលនេះ ស្រីម៉ៅកំពុងតែពពោះហើយ !
- បាទ លោកប៉ា ?

ប៊ុរីបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល ។ កាលពីម្សិលគេនិយាយ លលេងស្រីម៉ៅទេ មិននឹកស្មានថាពេលនេះ ពាក្យចំអន់លេងរបស់

CHANBOKEO.COM

នាយក្លាយជាការពិតឥចឹងសោះ ។ ពេលនោះ គេនឹកខ្មាសអៀនខ្លួន ឯង
ខ្មាសលោកគ្រូពេទ្យឡើងក្តៅមុខភាយៗតែម្តង ។ ប៉ុន្តែលោក
វិចិត្របែរជាមានប្រសាសន៍តាមសម្រួល ទៅបុរីថា :

- ទាន់កូននៅមានពេលច្រើននៅឡើយ... ចូរកូនទៅគេងគិតទៅ
ថាកូនត្រូវធ្វើអ្វីខ្លះអោយបានឆាប់ៗ ដើម្បីកុំអោយកេរឈ្មោះរបស់ ម៉ៅត្រូវប្រឡាក់ប្រឡូស ម្យ៉ាង
កូនគួររក្សាកត្តិយសអោយកូនចៅ ខ្លួនផង កុំអោយកូនតូចរបស់ឯងកើតមកឥតខន្តស្លា នាំតែក្មេង
ទទួលវិបត្តិផ្លូវចិត្ត នៅពេលគេធំឡើង ។ ប៉ាម៉ាក់នៅចាំជួយជ្រោម ជ្រែងកូនហើយ
តែកូនកុំភ្លេច... រៀនប្រឹងប្រែង ជួយខ្លួនឯងផង ណាំកូនណាំ ។
- បាទ! លោកប៉ា!

បុរីលើកដៃសំពះលោកគ្រូពេទ្យ ដែលបានផ្តល់កម្លាំងចិត្តយ៉ាង កក់ក្តៅមុតមាំដល់នាយ ។
តាំងពីយូរមកហើយ ដែលគេបានឃ្លាត ចាកឪពុករបស់គេទៅ
មិនដែលបាននៅនិត្យជិតដិតនឹងពិគ្រោះកិច្ច ការអ្វីរបៀបជាឪពុកនិងកូន
ដូចនាយនិងលោកគ្រូពេទ្យវិចិត្រពេល នេះទេ ។ ពាក្យពេចន៍របស់លោកគ្រូពេទ្យ
ពិតជាមានឥទ្ធិពល ណាស់ ចំពោះជីវិតរបស់គេ ។ បើគេមិនប្រញាប់រត់រកការធ្វើ
មិនប្រញាប់រៀបខន្តស្លាទេ ម៉ៅនិងរូបគេព្រមទាំងកូន ច្បាស់ជា ត្រូវរងភាពអាមាស
ខ្វះក្តីកក់ក្តៅក្នុងជីវិតមិនខានឡើយ ។

ពេលនេះ ស្រាប់តែបុរីនឹកដល់ឪពុកខ្លួនតែម្តង រួចក៏នឹកសោក ស្តាយបំផុតដែលកាលពីក្មេង
គេជាមនុស្សមានចិត្តមានះ រុញច្រាន ឪពុកអោយឆ្ងាយពីខ្លួន
រហូតដល់ខ្លួនឯងត្រូវលង់ភាពឯកណ្តោច កណ្តែងត្រមង់ត្រមោច ។ កាលនោះ គេនឹកថា
ការមានសង្សារ មានមិត្តភក្តិច្រើននឹងធ្វើអោយជីវិតរបស់គេមានការកក់ក្តៅ ។ ផ្ទុយ ទៅវិញ
រូបគេគ្រាន់តែទទួលភាពកក់ក្តៅបណ្តោះអាសន្នម្តងម្កាល ប៉ុណ្ណោះ ។
ជួនកាលគេចង់ពិគ្រោះកិច្ចការខ្លះៗជាមួយមនុស្សចាស់
តែក៏គេគ្មាននរណានឹងនិយាយជាមួយក្រៅពីមីងបូរាដែលជាមនុស្ស
ស្រីដែលនៅចាស់ព្រៅមិនដែលមានប្តីមានកូន ។ គាត់មិនសូវជា ជិតដិតនឹងរូបនាយប៉ុន្មានដែរ
ថ្វីបើគាត់បានចិញ្ចឹមរូបនាយអស់ជា ច្រើនឆ្នាំក៏ដោយព្រោះគាត់មានចរិតរឹងត្អឹង
មិនសូវទន់ភ្លន់ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ នាយក៏នៅតែច្រានចោលឪពុករបស់នាយ
ដដែលហើយគិតថាមួយជីវិតនេះ នាយមិនបាច់ពឹងឪពុកក៏អាចរស់ នៅបានដែរ ។ ផ្ទុយទៅវិញ

CHANBOKEO.COM

ពេលនេះ គេយល់ហើយថា ការមាន ឪពុកនៅក្បែរ
នោះជីវិតច្បាស់ជាកក់ក្តៅជាងផ្លូវជីវិតដែលនាយ បានជ្រើសរើសមកនោះ ឆ្ងាយណាស់ ។
ពេលនេះ ប៉ុរីស្តាយក្រោយ ណាស់ដែលគេនៅក្មេងឆេវឆាវមិនបានគិតដិតដល់... មែនហើយ...
បើគេមានលោកបុរាណនៅក្បែរ ដើម្បីអោយគេចូលពិគ្រោះសូម យោបល់ សុំកម្លាំងចិត្ត
ម៉្លេះសមរូបគេមានការកក់ក្តៅក្នុងចិត្តមិន លែងឡើយ
ជាពិសេសក្នុងស្ថានការណ៍របស់នាយនិងស្រីម៉ៅពេល នេះ
ប៉ុរីពិតជាត្រូវការភាពកក់ក្តៅពីឪពុករបស់ខ្លួនក្រៃលែង ។

ប៉ុរីត្រលប់ទៅផ្ទះវិញ អង្គុយគិតយ៉ាងយូរថាគេត្រូវរៀបចំជីវិត របស់គេយ៉ាងណា ។ បន្តិចមក
គេក៏រត់ទៅប៉ុស្តិ៍ វាយតេលេក្រាម ទៅឪពុកភ្លាម រួចក៏រត់ទៅរើក្រដាសស្នាមសិក្សាទាំងឡាយ
ដើម្បី ចេញរកការធ្វើ ។

*oooooooooooooooooooo*

CHANBOKEO . COM

# វគ្គទី១២
# តម្លៃគ្រួសារ

ថ្ងៃបន្ទាប់មក...

ពូប្រេងបររថយន្តនាំលោកបុរាណព្រមទាំងភរិយា មកដល់បរិវេណលំនៅរបស់លោកវិញដោយសុវត្ថិភាព ។ បុរីស្ទុះទៅចេញទៅទទួលយ៉ាងលឿនព្រមទាំងលើកដៃសំពះផង :

- ជំរាបសួរលោកប៉ា! ជំរាបសួរម៉ាក់!

លោកបុរាណនិងអ្នកស្រីផៃយ៉ាភ្ញាក់ក្រញាង ធ្វើភាំង សម្លឹងមុខ គ្នាទៅវិញទៅមក ពេលឃើញកូនប្រុសជំរាបសួរអ្នកស្រីផៃយ៉ាហៅ លោកថា ម៉ាក់ យ៉ាងពេញមាត់ដូច្នោះ ។ អ្នកស្រីផៃយ៉ាក៏ញញឹម ទទួលភ្លាម :

- ថ្ងៃនេះ កូនមានទឹកមុខស្រស់បស់ណាស់... មានដំណឹងល្អអ្វីមក ជំរាបប៉ាម៉ាក់មែនទេ?

នៅក្នុងផ្ទះ បុរីញញឹម រួចលុតជង្គង់ចុះ ចំពោះលោកទាំងពីរ ព្រមទាំងលើកដៃប្រណម្យឡើងវាចាទៅលោកថា :

- លោកប៉ា! ម៉ាក់! អោយកូនសូមទោសដែលពីដើមមកកូនមានចិត្តអាស្មិមានះមិនស្គាល់ខុសត្រូវ មិនបានផ្តល់សេចក្តីគោរពចំពោះអ្នកមានគុណនិងចាស់ទុំក្នុងគ្រួសារ ក្នុងឋានៈជាកូនប្រុសម្នាក់ក្នុង ផ្ទះនេះ ។ ថៃដន្យកូនបានឆ្លងកាត់ជីវិតជាមនុស្សពេញវ័យ បាន ទទួលមេរៀនជីវិតខ្លះៗ ហើយបានដឹងថាខ្លួនបានប្រព្រឹត្តកំហុសជា ច្រើន... ពេលនេះកូនសូមចូលខ្លួនមកសុំការអភ័យទោសពីលោក ប៉ានិងម៉ាក់ ចំពោះអំពើឆ្គាំឆ្គងរបស់ខ្លួនកាលពីអតិតកាល ។ សូម លោកមេត្តាលើកលែងទោសអោយកូនផង ។

CHANBOKEO.COM

គេក្រាបសំពះឪពុករបស់គេ សិរសាដល់បាទាដែលលោកឪពុក
តែងតែផ្តល់នូវសេចក្តីស្រឡាញ់និងការយកចិត្តទុកដាក់ចំពោះជីវិត របស់នាយសព្វយ៉ាង
សូម្បីតែពេលកូនបម្រុះមានះនងៀលប្រឆាំង នឹងការគ្រប់គ្រងអប់រំរបស់លោក
យ៉ាងណាក៏ដោយ ។ បន្ទាប់មក គេក៏លូនទៅជិតអ្នកស្រីផៃយ៉ា ដែលកំពុងឈោងដៃទទួលយកនូវ
ការសំពះសូមទោសពីប៊ុរី ទាំងដួងចិត្តរំភើប :
- ម៉ាក់បានរង់ចាំកូនឲ្យត្រលប់មករស់នៅផ្ទះយើងវិញយូរហើយ ។ ផ្ទះយើងធំល្វឹងល្វើយណាស់
បើសិនមានរូបកូនទីនេះថែមម្នាក់ទៀត ប្រហែលជាកក់ក្តៅជាងមុនមិនលែងឡើយ ។
ប៊ុរីងើបមុខឡើងសម្លឹងមុខឪពុក រួចសម្លឹងមុខអ្នកស្រីផៃយ៉ា បន្ទាប់មកក៏ស្រដីថា :
- ចុះបើសិនជាកូនប្រសារនិងចៅៗ សូមខ្លួនចូលមកជ្រកទីនេះ
ក្រោមម្លប់គ្រប់គ្រងរបស់លោកប៉ានិងម៉ាក់ថែមទៀត តើលោកទាំង ពីរគិតយ៉ាងណាដែរ បាទ ?
លោកបុរាណសម្លឹងមុខកូន ហាក់ដូចជាយល់អត្ថន័យ រួចក៏មាន ប្រសាសន៍តបទៅកូនថា :
- បើគេជាសាច់ឈាមក្រុមគ្រួសាររបស់កូន ប៉ាទទួលដោយក្តីពេញ ចិត្តបំផុត ។
- ចំណែកម៉ាក់ក៏ដូច្នេះដែរ (អ្នកស្រីផៃយ៉ាតប) បើសិនមានចៅៗ មករត់លេងកំដរទីនេះ
ប្រហែលជាផ្ទះដ៏ទូលំទូលាយរបស់យើងនឹង
មានភាពអ៊ូអររស់រវើកលែងស្ងាត់ជ្រងំដូចមុនទៀតហើយ ។ ដូច្នេះ ម៉ាក់ប៉ាមិនសូវអផ្សុកផង ។
កាលបើឃើញលោកទាំងពីរទទួលរូបគេវិញយ៉ាងកក់ក្តៅ ប៊ុរី
រំភើបក្នុងចិត្តឡើងរលីងរលោងទឹកភ្នែក ។ បន្តិចមក គេក៏នាំលោក
បុរាណនិងអ្នកស្រីផៃយ៉ាទៅជួបលោកវិចិត្រភ្លាម ។
ថៃងនា្យ លោកវិចិត្រនិងអ្នកគ្រូចរណៃបានយល់ស្ថានការណ៍មុន ប៊ុរីគិតទៅទៀត ។
នៅពេលគេទៅដល់គេហដ្ឋានរបស់លោកភ្លាម អ្នកគ្រូនិងស្វាមីចេញមកទទួលលោកបុរាណ
ព្រមទាំងអ្នកស្រីផៃយ៉ា យ៉ាងរាក់ទាក់ ។ ក្នុងឱកាសដែលចាស់ៗកំពុងសន្ទនាគ្នា ប៊ុរីក៏សុំ
ខ្លួនទៅជួបស្រីម៉ៅនិងប្អូនៗភ្លាមដែរ ។
នៅមាត់ទ្វារបន្ទប់ស្រីម៉ៅ ប៊ុរីលួចមើលឃើញប្អូនៗទាំងបីរបស់ នាងអង្គុយតម្កង់ជុំវិញបងស្រី
សំណេះសំណាលចំអន់គ្នាទៅមក ពី នេះពីនោះយ៉ាងស្និទ្ធស្នាលរីករាយហើយកក់ក្តៅក្រៃលែង ។
ពេល នេះ នរ:នឹកអាណិតខ្លួនណាស់ដែលបានបាត់បង់នូវភាពកក់ក្តៅក្នុង
គ្រួសារជាយូរមកហើយ ។ នាគ្រាមួយក្នុងអតីតកាល គេធ្លាប់មាន ប្អូនស្រីម្នាក់ដែរ
តែប៊ុរីបែរជាមិនទទួលស្គាល់ ព្រោះគិតថានាងជា កូនរបស់ម៉ែចុង ។

CHANBOKEO.COM

គេមិនដែលបានថ្នាក់ថ្នមស្រឡាញ់នាងតូច ជា ប្អូន ឬក៏បង្ហាញសូម្បីតែភាពជាបងប្អូននឹងគ្នាចំពោះនាងបន្តិចបន្តួច ណាឡើយ ។ មិនថានាងនៅតូចជាទារកឬពេលនាងធំជាកុមារី ចេះ ស្តីនិយាយ ចេះយល់ដឹងនូវសេចក្តីស្រឡាញ់ហើយក៏ដោយ ក៏បុរី មិនដែលនឹកចង់បង្ហាញភាពស្និទ្ធស្នាលជាមួយប្អូនបន្តិចសោះ ។ គេ តែងតែចាត់ទុកនាងជាសាច់ដទៃជានិច្ច ។ ពេលនេះ បុរីបានឃើញ សភាពកក់ក្តៅក្នុងគ្រួសាររបស់ស្រីម៉ៅ ដែលបងប្អូនទាំងបួននាក់ ស្រឡាញ់គ្នាជិតដិតប្រឡៀងគ្នារអឹកដោយមិនគិតថាគេជាសាច់ឈាម បង្កើតឬគ្រាន់តែជាកូនចញ្ចឹម ។ មាណពក៏នឹកស្តាយដែលខ្លួនធ្លាប់ ចចេសមានះ រត់ចោលភាពកក់ក្តៅក្នុងគ្រួសារ ហើយឈោងចាប់ យកភាពត្រមង់ត្រមោចយ៉ាងឥតន័យនោះទៅវិញ ។ នៅក្នុងខណ: នេះ បុរីមានវិប្បដិសារីក្នុងចិត្តក្រៃលែង ដែលគេគ្មានឱកាសដើរ ថយក្រោយ ទៅសាងភាពកក់ក្តៅអោយដល់ប្អូនស្រីរបស់គេម្នាក់ ដែលគួរណាស់តែបានទទួលនូវក្តីស្រឡាញ់ ពីបងប្រុសរបស់នាង មុនពេលលាចាកលោកទៅ... តែពេលនេះ អ្វីៗក៏ហួសពេលទៅ ហើយ ។ ទឹកភ្នែកពីរតំណក់បានហូរស្រក់ពីកែវនេត្រាទាំងគូ របស់គេ ដោយមិនដឹងខ្លួន...

ស្តាយ...

- ស្តាយណាស់ដែលបងអស់វេលា  វិលថយក្រោយជាជួបរូបប្អូន
  ស្តាយបងយល់ខុសវង្វេងខ្លួន  មិនបាននិត្យស្ងួនពេញហត្ថា ។
- ស្តាយបងឆេវឆាវយុវវ័យ  មិនចេះគិតពៃរ៍ត្រិះពិចារណ៍
  គិតតែមានះដែងបិតា  គេចលោកស្រវាភពវង្វេង ។
- ស្តាយបងគ្មានពេលកែកំហុស  អ្វីៗហួសអស់គួរសង្វេង
  គិតវិញកាលណាចិត្តចំបែង  នេះឯងកម្លោបងប្រុសម្នាក់ ។
- បើអាចបង្វិលកង់ផែនដី  បងសុំវិលវៃថៃវរលក្ខណ៍
  ប្អូនស្រីបងមួយស្ងួនថ្នមថ្នាក់  អោយស្គាល់សុភមង្គលអើយ...

បន្តិចមក ប៊ុរីលើកម្រាមដៃផ្តិតទឹកភ្នែកចេញពីរង្វង់មុខហើយ កាត់ចិត្តប្រឹងញញឹមសាជាថ្មី ត្បិតពេលនេះ មាណពបំរុងទទួលនូវ ភាពមនោរម្យក្នុងគ្រួសារថ្មីវិញហើយ ។
នរៈយកដៃគោះទ្វារ ។
- បងប៊ុរី !
ប្អូនៗទាំងបីនាក់ហៅប៊ុរីព្រមគ្នាដោយទឹកមុខញញឹមត្រេកអរ ។ រំពេចនោះ បារមីស្រដីថា :
- មានគេកំពុងនឹកបងនែក ! ព្រឹកនេះ ម៉េចមិនឃើញបងមក ពិសារបបរព្រឹកជុំគ្នាអញ្ចឹង ? ម្ចាស់គេខំក្រោកដាំអាហារ រួចអង្គុយ រង់ចាំបងមកពិសា ឡើងរីងទឹកស្អកស្រូវស្រែអស់រលីង បងមាន ដឹងទេ ? មើលទៅ បងប្រហែលជាត្រូវសងជំងឺចិត្តគេហើយ ។
ស្រីម៉ៅលួចលូកដៃក្តិចប្អូនមិនអោយស្រដី ។ ប៊ុរីឃើញហើយ ញញឹមឡើងដោយដួងចិត្តសោមនស្សកាលបើដឹងថាមានគេម្នាក់បាន រង់ចាំផ្លូវរបស់នាយតាំងពីព្រឹក :
- គឺ...បងកំពុងរៀបខន្ធស្លា យកមកផ្ញើគេនោះអី ប្អូនបារមី ! សូម ប្អូនជួយប្រាប់គេផងណា៎... ! កុំអោយគេខឹងនឹងបងអី ។
ប៊ុរីពោលហើយចោលកន្ទុយភ្នែកទៅស្រីម៉ៅ ឃើញនាងលួច សម្លក់នាយវិញក្នុងកែវភ្នែកឃ្លាន់ខ្ញាញ់តែមានមន្តស្នេហ៍យ៉ាងណា មិនដឹង ធ្វើអោយបេះដូងរបស់គេញាប់ញ័ររកថាមិនត្រូវ ។ បន្ទាប់ មក គេក៏ស្រដីទៅប្អូនៗទាំងបីនាក់ថា :
- អោយបងសុំអនុញ្ញាតចុះឈ្មោះ ចូលរួមជាសមាជិកគ្រួសាររបស់ ប្អូនៗថែមម្នាក់ទៀតបានទេ ?
- ចាំបាច់ចុះធ្វើអីទៀត ? (បារមីឆ្លើយរឹងឡើង) ព្រោះពួកយើង បានចុះឈ្មោះបងដាក់ក្រាំងបញ្ជីគ្រួសារយើងតាំងពីយូរមកហើយ ។
ប៊ុរីភ្ញាក់ព្រើត បើកភ្នែកធំៗ បែរមើលចិត្រានិងវិសាល ឃើញ គេងក់ក្បាលញញឹមគ្រប់គ្នា ។ មាណពក៏លាន់មាត់ឡើងថា :
- ពិតមែនហ្អែស ? ហើយនរណាគេប្រាប់ប្អូនថា គួរចុះឈ្មោះបង ក្នុងក្រាំងបញ្ជីគ្រួសាររបស់ប្អូននោះ ?
ទាំងបីនាក់មើលមុខគ្នាហើយចោលកន្ទុយភ្នែកទៅមើលស្រីម៉ៅ ភ្លៀកៗ ។ បន្តិចមក ចិត្រាក៏ឆ្លើយថា :

CHANBOKEO.COM

- គឺបងប៊ុរីហ្នឹងណា៎ មិនដឹងទេ ? បងបានសុំចុះឈ្មោះក្នុងគ្រួសារ
យើងជាមួយនឹងម៉ាក់ប៉ាតាំងពីយូរមកហើយ ថែមទាំងធ្លាប់បរិភោគ
បាយជាមួយពួកយើងជាគ្រួសារផង ។

- អូហ៍ គ្រាន់តែបរិភោគបាយជុំគ្នាជាមួយប្អូនៗក៏ចាត់ទុកថាបងចុះ ឈ្មោះរួចហើយមែនទេ ?
(ប៊ុរីសួរ)

- មិនមែនទេ បាទ! ប៉ុន្តែការដែលបងផ្តល់ការចាប់អារម្មណ៍យ៉ាង ពិសេសចំពោះបងម៉ៅ
និងការចូលខ្លួនមកគោរពម៉ាក់ប៉ារបស់យើង នោះទេតើហ៍ ដែលចាត់ទុកថា
ជាការចុះឈ្មោះជាសមាជិកគ្រួសារ ពេញលក្ខណៈបាន ។

ប៊ុរីញញឹម កាលបើឮចិត្រាវែកញែកយ៉ាងពិរោះ ។ គេយកដៃ ទៅទះស្មាចិត្រាបន្តើរៗ :

- អរគុណប្អូនណាស់ដែលបើកចិត្តទូលាយទទួលបងជាញាតិ!

រួចហើយគេបែរទៅរកបារមីនិងវិសាល :

- បងក៏អរគុណប្អូនទាំងពីរដូចគ្នាដែរ ។ ចាប់ពីថ្ងៃនេះទៅ យើង ជាសាច់ញាតិនឹងគ្នាហើយណា៎!

- បាទ! ចា៎ស!

ប្អូនទាំងបីក៏ឆ្លើយឡើងព្រមគ្នា ស្រាប់តែវិសាលឆ្លើយបន្ថែម ទៀតថា :

- ប៉ុន្តែវិសាលវិញអាចទទួលបាន ត្រឹមតែបងប៊ុរីធ្វើល្អចំពោះបង
ម៉ៅរបស់ខ្ញុំប៉ុណ្ណោះ ។ បើបងធ្វើអោយបងម៉ៅស្រក់ទឹកភ្នែកពេល ណា
វិសាលពិតជាមិនទុកមុខមាត់អោយបងឡើយ ។

គេស្រដីខែងរ៉ែងណាស់ ហាក់ដូចជាស្រឡាញ់ការពារស្រីម៉ៅ ក្រៃលែង ។
ប៊ុរីឮហើយក៏សើចគ្រហាញតែម្តង :

- មែនហើយ! បើបងធ្វើអោយបងម៉ៅរបស់ប្អូនស្រក់ទឹកភ្នែកពិត មែន
បងនឹងចូលខ្លួនមកទទួលទោសពីប្អូនពៅមុនគេមិនខាន បង ហ៊ានសន្យា ។

ទាំងអស់គ្នាក៏សើចឡើងយ៉ាងក្អាកក្អាយ ។ បន្តិចមក ប្អូនទាំង បីក៏នាំគ្នាចេញទៅអស់
ទុកអោយប៊ុរីនៅតែពីរនាក់នឹងស្រីម៉ៅ ។

- អូនស្រួលបួលខ្លួនវិញហើយឬម៉ៅ ?

- ចា៎ស ស្រួលគ្រាន់ហើយ... គ្រាន់តែនៅធីងធោងបន្តិចបន្តួច...

ប៊ុរីក៏ដើបទៅអង្គុយជិត យកដៃទៅអង្អែលកេសានាងបន្តើរៗ:

-អញ្ចឹង អូនគេងវិញទៅ ចាំបងនៅកំដរ ។

CHANBOKEO.COM

និតាក៏ផ្ដេកខ្លួនទៅលើខ្នើយវិញ ។ បុរីទាញផាហ៊ុំដណ្ដប់អោយនារីរួចស្រដីថា :

- ម៉ៅ..! យើងស្គាល់គ្នាយូរហើយ តែយើងមិនដែលបានអង្គុយនិយាយគ្នាតាមសម្រួលម្ដងណាទេ... តើពេលនេះជាពេលល្អឬទេដែលយើងត្រូវនិយាយអ្វីល្អៗចំពោះគ្នាម្ដង ?

ស្រីម៉ៅសម្លឹងមុខនរៈដោយក្រសែភ្នែកស្រទន់ :

- បង...ចង់សួរម៉ៅរឿងអ្វីមែនទេ ?
- បាទ! មានរឿងច្រើនណាស់ដែលបងចង់ដឹងពីម៉ៅ ហើយបងក៏មានរឿងច្រើនទៀតសំរាប់ប្រាប់អូនវិញដូចគ្នាដែរ ។ នៅក្នុងខណៈដែលយើងចំរុងនឹងរួមដំណើរជីវិតជាមួយគ្នាទៅហើយ យើងគួរតែ ស្គាល់គ្នាជិតដិតជាងនេះមែនទេអូន ?

បុរីទាញដៃស្រីម៉ៅមកក្ដាប់យ៉ាងណែន ហាក់ដូចជាចង់បង្ហាញ ថាគេស្រឡាញ់ម៉ៅក្រៃលែង ។ និតាសម្លឹងក្រសែភ្នែកនរៈដែល សម្លឹងមកនាងវិញដោយទន់ត្រជាក់ ធ្វើអោយនាងមានជំនឿចិត្តចំពោះនាយជាងមុន ច្រើនដូចគ្នា ។

- បងចង់ដឹងអ្វីពីម៉ៅខ្លះទៅ ?
- ដឹងអ្វីៗទាំងឡាយនៅក្នុងជីវិតរបស់អូនទាំងសប្បាយទាំងទុក្ខ...
- ហើយចុះរឿងបងវិញ ? បងចង់ប្រាប់ម៉ៅរឿងអ្វីខ្លះដែរ ?
- ម៉ៅចង់ដឹងអ្វី បងប្រាប់ទាំងអស់!
- តែម៉ៅមិនដឹងថាត្រូវសួរបងពីអ្វីទេ... បងចង់ប្រាប់ម៉ៅអំពីអ្វីស្រដីតាមដែលចិត្តបងចង់ឲ្យអូនដឹង ម៉ៅទទួលស្ដាប់ទាំងអស់ ។
- ហើយយើងឈប់ប្រកែកយកឈ្នះចាញ់នឹងគ្នាទៀតណា៎អូន...

ភ្លាមនោះ ម៉ៅញញឹមឡើង :

- នរណាគេចង់យកឈ្នះចាញ់ជាមួយបងនោះ ? គឺបងតើហ៎ជាអ្នកចង់ឈ្នះ តែម៉ៅវិញ គ្រាន់តែជាអ្នករងការបំពានរបស់មនុស្សម្នាក់ នោះតើហ៎...

បុរីញញឹមធ្វើមាត់ក្របួចដាក់និតា :

- បាទៗ! បងទទួលកំហុសតែម្នាក់ឯងក៏បានដែរណា៎ព្រលឹងមាស បង! ការពិតបងឈប់រករឿងអូនយូរហើយតើហ៎... មានតែអូន វិញទេ ដែលងីក់ដាក់បងអត់ឈប់...

CHANBOKEO.COM

- នរណាគេងងឹក់ដាក់បងនោះ ? គេស្អប់បងតើហ៎ ព្រោះបងមានសង្សារច្រើន...ចិត្តមិនស្មោះត្រង់មួយនឹងមួយ...

- នរណាប្រាប់អូន ?

- គឺប៉ាម៉ាក់បងហ្នឹងនិយាយប្រាប់ប៉ាម៉ាក់អូន...

- អូនលួចស្តាប់ឮមែនទេ ?

- ដឹរីងាប់កុំចង់យកចង្អេរមកបាំងអី...!

- ប៉ុន្តែ នោះជាអតិតកាលទេតើ... ប៉ុន្តែបងបានទំលាក់ចរិតមិនល្អ នោះចោលអស់ហើយគ្មានសល់ទេ...

- ចោលតាំងពីអង្កាល់ ?

- តាំងពីបេះដូងរបស់បងមុតបន្លាកុលាបមួយទងនៅឆ្នេរស្ទឹងខៀវនោះអី...អូនមានស្គាល់ម្ចាស់ផ្កានោះទេ ?

- តែផ្តាស ! ចេះតែថា... ភូតម៉ៅទេនឹង ?

- នរណាគេហ៊ានភូតទៅ.. ? គេលែងហ៊ានភូតហើយ ខ្លាចម្ចាស់ផ្កាកុលាបនោះគេងងឹក់រត់គេចទៅព្រះនេត្រព្រះដូចមុនទៀត ។

- ហើយចុះនារីអតិតសង្សារនោះ...បងមានគិតដល់ចិត្តគេទេហ៎ ?

- បងនិយាយប្រាប់គេតាមត្រង់ហើយ... គិតថាគេយល់ចិត្តបង ច្បាស់ថាបងកំពុងរៀបចំដំណើរជីវិតថ្មីនឹគត់មត់មួយហើយ ។

- នាងមិនខឹងនឹងបងទេ ?

ប៊ុរីនៅស្ងៀមមួយស្របក់ក៏ស្រដីថា :

- ក្នុងលោកនេះ សង្សារអ្វីមិនសំខាន់ជាងភរិយានិងកូនរបស់បង ទេ ។ បងបានជូនពាក្យទៅម្ចាស់ដើមរបស់គេវិញអស់ហើយ អូន ឈប់គិតទៀតទៅណា៎ ។ នារីណាក៏លែងមានសិទ្ធមករញ៉ីរញ៉ៃនឹង ជីវិតគ្រួសាររបស់បងបានទៀតហើយ ។

- ម៉ៅសង្ឃឹមថាបងនិយាយពាក្យពិត !

- ជឿបងចុះណា៎អូន...

- មានអ្វីជាសាក្សីទេ ?

CHANBOKEO.COM

- កត្តិយសបងនិងគ្រួសារបងទាំងក្រុម មានទាំងប៉ាម៉ាក់បងដែល
នៅខាងលើឡៅកំពុងនិយាយគ្នាជាមួយប៉ាម៉ាក់អូននោះផង ព្រម ទាំងថៃមផ្កាស្លាមួយទៀតផង...
សមរម្យហើយឬនៅ ?

ស្រីម៉ៅញញឹមឡើងយ៉ាងបំព្រងតែម្តងកាលបើឮបុរីស្រដីប្រាប់ ដូច្នោះ ។
នេះជាលើកទីមួយហើយដែលបុរីបានឃើញនាងញញឹម យ៉ាងស្រស់
មិនមានលាក់លៀមអារម្មណ៍ដូចពេលមុនៗទេ ។ ការ ពិត មាណវីស្រស់ស្អាត
មានសោភ័ណមិនចាញ់នារីទីក្រុងប៉ុន្មានទេ
ថ្វីបើនាងមិនបានតាក់តែងកាយបន្ថែមក្រែមម្សៅដូចគេ ។ ទ្រាំនឹង
ការរំភើបចិត្តនឹងសោភ័ណកុលាបងងស្ទឹងមិនបាន បុរីឈ្ងោកមុខ ថើបថ្ពាល់នាងលាន់ខ្សឹតតែម្តង
ស្រាប់តែត្រូវមាណវីយកដៃទះទ្រូង បន្តើរៗតបវិញ :

- នែ៎ កុំលេងខូចផ្លូវកាត់ពេក ប្រយ័ត្នកូនកាត់រក៏!

បុរីសើចខឹកៗហើយឆ្លើយថា :

- អោយតែអូនប្រឹងស្ទូប់បងអោយច្រើនចុះ កូនៗច្បាស់ជាកាត់រក
បងទាំងអស់គ្រប់គ្នាមិនខានទេ ព្រោះអីចាស់ៗច្រើនថា ស្ទូប់ជំពប់ លើ នោះអីណា៎អូន!

ស្រីម៉ៅខ្នាញ់ណាស់យកដៃក្តិចបុរី លាន់មាត់ :

- អីយ៉ូយ!... (បុរីស្រែក តែបែរជាសើចគ្រហាញដាក់ម៉ៅវិញ) អូនដឹងទេ
ថាហេតុអ្វីបងចំណាំអូនបានពេលបងងងឹតភ្នែកនោះ ?

ម៉ៅភ្ញាក់ព្រើតសម្លឹងមុខនរៈ ស្រាប់តែនាយឆ្លើយទៀតថា :

- គឺអូនមានចិញ្ចឹមសំបុកខ្យាដំរី អោយតែបងនិយាយអ្វីមិនត្រូវចិត្ត
ខ្យាដំរីចេញខាំបងភ្លាម...ហើយចេះខាំម៉ូដតែមួយដូចគ្នាតែម្តង ។

ថាហើយនរៈសើចខឹកៗយ៉ាងរីករាយដែលគេបានលលេងនឹងគូ ស្នេហរបស់គេ ។ ចៃដន្យ
ស្រីម៉ៅបានបន្ទូរតរិយាបថដាក់បុរីយូរ ហើយ មិនសូវជាងងឹក់ដូចពេលមុនឡើយ ។
កាលបើឃើញនរៈ បញ្ចេញភាពរីករាយមករកនាង ធិតាមានអារម្មណ៍ថាពិភពលោក
មានពន្លឺភ្លឺថ្លាគួរអោយចង់រស់នៅក្រៃលែង ។

- នៅមានរឿងមួយទៀត... (បុរីពោលបន្ត) ម៉ៅមិនទាន់និយាយ
រឿងអូនប្រាប់បងនៅឡើយទេ...
- រឿងអ្វីទៅ...

CHANBOKEO.COM

- គឺរឿងដែលម៉ៅដើរតួជាប្អូនគនោះអី...
- នរណាថា ខ្ញុំធ្វើដូច្នោះ ? បងគិតតែម្នាក់ឯងទេ ។
- អញ្ជឹងប្រាប់បងមក ថារឿងរ៉ាវនោះយ៉ាងណាខ្លះ នៅឯព្រះនេត្រ
ព្រះ...ហេតុអ្វីបានជាបងទៅដល់ផ្ទះលោកពូមេឃុំនោះកើត ?

រំពេចនោះ ស្រាប់តែឮសូរសន្ធឹកឡានមួយបរចូលមកដល់មុខ
គេហដ្ឋានដ៏ស្កុកស្កម្ភរបស់លោកគ្រូពេទ្យវិចិត្រ ។ បុរីអើតទៅក្រៅ ឃើញនាងតូចភី នាងគ
និងចាស់ទុំពីរនាក់ទៀតកំពុងចុះពីរថយន្ត ដើរចូលមកក្នុងផ្ទះ ស្រាប់តែម៉ៅលាន់មាត់ឡើងថា :
- តោះ ! យើងចេញទៅក្រៅ ! ម៉ៅសុំណែនាំបងបន្តិច !

បុរីចេញមកតាម ។ ស្រាប់តែបុរសស្ត្រីទាំងពីរនាក់នោះឧទាន ព្រមគ្នាតែម្តងថា :
- សួស្តីក្មួយបុរី ! ជានាស្រួលបួលហើយហ្នែស ?

បុរីចំណាំសម្លេងគាត់ទាំងពីរច្បាស់ណាស់ ។ គេក៏លាន់មាត់ ឡើងថា :
- លោកពូមេឃុំ ? អ្នកមីង ?

គាត់ទាំងពីរងក់ក្បាល ។ ស្រីម៉ៅក៏ណែនាំថា :
- នេះជាពូភុំ និងមីងចំណាន ជាពូមីងរបស់ម៉ៅ ។ ការពិត មីង
ចំណានមិនមែនជានរណាក្រៅពីប្អូនស្រីរបស់ម៉ាក់ចរណៃឡើយ ។

បុរីភ្ញាក់ផ្អើលជាខ្លាំង តែក៏ត្រេកអរណាស់ដែរ ដែលរូបគេមាន ឱកាសបានស្គាល់មនុស្សចិត្តធម៌
ជួយសង្គ្រោះនាយផុតពីការយាយី របស់ពួកអាវខ្មៅចោរព្រៃទាំងនោះ ។
បុរីអោយសំពះលោកភ្លាម ។
ភ្លាមនោះ អ្នកគ្រូចរណៃ លោកគ្រូពេទ្យ លោកបុរាណ និងអ្នកស្រី
ផៃយ៉ាក៏បានចុះមកទទួលលោកពូមេឃុំនិងក្រុមគ្រួសារផងដែរ ។

នៅរាត្រីនោះ បរិយាកាសរវាងក្រុមគ្រួសារទាំងបីមានសភាព រមនាក្រៃលែង
ដែលគេបានមកភ្ជាប់សាច់ឈាមជាមួយគ្នាយ៉ាងជិត ជិតបំផុត ។ ទោះជាយ៉ាងណា
មានតែមនុស្សពីរនាក់ទេដែលរំភើប ជាងគេ នោះគឺបុរីនិងស្រីម៉ៅរបស់យើងនោះឯង ។
នៅមាត់ស្ទឹង សង្កែ អ្នកទាំងពីរបានអង្គុយជជែកគ្នា ក្នុងសភាវៈជាគូស្នេហ៍
ដែលយល់ចិត្តគ្នាយ៉ាងជាក់ច្បាស់ជាលើកដំបូង ។ ស្រីម៉ៅក៏រ៉ាយ រ៉ាប់រឿងទាំងឡាយ
ឲ្យបុរីស្តាប់ដើម្បីជម្រះនូវក្តីងឿងឆ្ងល់ដែលមាន នៅសល់ក្នុងចិត្តទាំងប៉ុន្មាន ។

CHANBOKEO.COM

# វគ្គទី១៣
# ខ្លួចជីវិត

ការពិត ស្រីម៉ៅជាកូនច្បងក្នុងចំណោមកូនប្រាំនាក់របស់ពួកគាត់ ដែលជាជនប្រមឹក ។ នាងបានត្រូវឪពុកលក់អោយទៅបំរើគេនៅ ហាងបាយសំរូបមួយនៅសេរីសោភ័ណ ។ កាលនោះ នាងមានវ័យ ប្រហែល៧ឆ្នាំប៉ុណ្ណោះ ។ ចៃដន្យ ម្ចាស់ហាងបាយនិងសាច់ញាតិ ក្រុមគ្រួសារមានចិត្តប្រេតនរកណាស់ ។ គេប្រើនាងអោយលាងចាន បោសច្រាសធ្វើការងារអ្វីៗដូចមនុស្សចាស់ មិនសូវបានបរិភោគឬ គេងគ្រប់គ្រាន់ទេ ជួនកាលត្រូវគេខោកគេវ៉ាយ គ្មានមេត្តាអ្វីបន្តិច ត្បិតគេយល់ថានាងជាកញ្ជះដាច់ថ្លៃ ។ នេះហើយ សង្គមខ្មែរអវិជ្ជា រាប់មនុស្សនឹងលុយ រាប់មនុស្សនឹងវណ្ណៈ ។ ជាតិជាកូនអ្នកក្រីក្រ ជាកូនអ្នកស្រែ តែងតែត្រូវគេជិះជាន់ប្រមាថមាក់ងាយដូច្នេះឯង មិនថាយុគណា សម័យណាទេ ។ មនុស្សខ្លះមានលុយ ប៉ុន្តែគ្មាន សីលធម៌ក្នុងខ្លួនបន្តិចឡើយ ព្រោះគេគិតថាលុយអាចបិទមុខគេ អោយថ្លៃបាន ដោយមិនបាច់ធ្វើអំពើល្អលើញាតិណាឡើយ ។

ទ្រាំនឹងទារុណកម្មដ៏ធ្ងន់ធ្ងរនោះមិនបាន ណានឹកម្តាយ នឹកបង ប្អូនផង នាងម៉ៅក៏លួចរត់ទៅផ្ទះជាច្រើនដង ដោយសុំឡានឈ្នួល ជិះត្រលប់មកភូមិជប់វិញហើយក៏ចុះដើររហូតដល់ផ្ទះ ។ គួរអនិច្ចា ណាស់! ពេលមកដល់ផ្ទះវិញ ឪពុករបស់នាងមិនមានមេត្តាដល់ កូនស្រីឡើយ ។ គាត់តែងតែចាប់នាងលក់បន្ត អោយទៅបំរើគេ ផ្សេងៗទៀត តែនាងម៉ៅនៅតែលួចរត់មកវិញបានរាល់ដង ។ នៅ វេវាងចៅកែចុងក្រោយ នាងបានតដៃតបនឹងកូនរបស់ចៅកែដែល វាយធ្វើបាបនាង រួចហើយម៉ៅក៏រត់គេចមកផ្ទះវិញដដែល ។ ភព្វ័ វាសនាមិនល្អ គ្រួសារនោះក៏តាមមករកនាងដល់ផ្ទះ ហើយបានស្តី បន្ទោសឪពុកនាងយ៉ាងច្រើនបំផុតរហូតដល់ធ្វើអោយពួកគាត់មួម៉ៅ

CHANBOKEO.COM

ចាប់ស្រីម៉ៅវាយដំច្រំធាក់លុះសន្លប់លែងដឹងខ្លួន ។ ម្ដាយនាងម៉ៅ ឃើញដូច្នោះ ក៏បីកូនរត់ទៅរកអ្នកគ្រូពេទ្យចំណាន អោយជួយ សង្គ្រោះ ។ ទទួលពេលនោះ អ្នកគ្រូចរណៃនៅទីនោះស្រាប់ ក៏ ចេញមុខការពារស្រីម៉ៅជំនួស ហើយបានហៅមេភូមិមេឃុំព្រម ទាំងប៉ូលីសឃុំអោយមកធ្វើជាសាក្សី ព្រោះអ្នកគ្រូបានសុំទិញយក ស្រីម៉ៅផ្ដាច់សិទ្ធិពីពូក្អាត់ពេញទី ។ ក្រោយមក អ្នកគ្រូចរណៃក៏ ចិញ្ចឹមថែរក្សានាងម៉ៅជាកូន ផ្ដល់ការរៀនសូត្រនិងជីវិតថ្មីដ៏មាន សេចក្ដីសុខរៀងរហូតតមក ។

ជួនកាល អ្នកដែលអោយកំណើតកូន មិនមែនសុទ្ធតែជាអ្នក មានគុណចំពោះកូនគ្រប់គ្នាទេ ។ អ្នកខ្លះមានកូនសំរាប់តែលក់កេង ប្រយោជន៍សំរាប់ខ្លួនឯងតែប៉ុណ្ណោះ ។ ពិតមែនហើយ បើសិនជា យើងឲ្យកំណើតកូនហើយ តែមិនបានអោយសេចក្ដីសុខនិងជីវិត ដ៏មានពន្លឺរុងរឿងដល់គេ នោះមិនហៅថាជាអ្នកមានគុណគ្រប់ លក្ខណៈនៅឡើយទេ ព្រោះមនុស្សដែលអោយកំណើតនោះ មិន ទាន់បានចាកផុតភាពជាសត្វតិរច្ឆាន ដែលបង្កើតកូនហើយព្រលែង ចោលដោយគ្មានសតិទទួលខុសត្រូវ ។ អ្វីដែលអាចញែកដាច់តម្លៃ មនុស្សអោយខុសពីសត្វនោះ គឺការដឹងខុសដឹងត្រូវ មានមនសិការ ខ្ពស់ ដឹងខុសហើយចេះកែមិនអោយខុសទៀតច្រំដែលៗ មាន សីលធម៌ចំពោះមនុស្សដូចគ្នា ហើយមានប្រាជ្ញាដោះស្រាយជីវិត ដោយមិនបាច់ធ្វើបាបកូន ជិះជាន់កម្លាំងកូន ឬលក់កូនលក់ចៅឲ្យ គេ ដើម្បីដោះស្រាយភាពទីទាល់ ពោលគឺមិនខាំអ្នកដទៃដូចសត្វ ដើម្បីប្រយោជន៍អញ...!

ស្រីម៉ៅក៏បានមករស់នៅឯបាត់ដំបង ហើយបានចូលរៀនរហូត ដល់ប្រលងឌីប្លូម ។ ថៃ្ងដន្យ កាលនោះ នាងបានដំណឹងអាក្រក់ពី ស្រុកកំណើតមកថា ឪពុករបស់នាងបានលក់កូនពីរនាក់ទៀតជាបន្ត បន្ទាប់ រួចហើយបានវាយម្ដាយនាងរហូតដល់ពិការ ព្រោះតែគាត់ បានឃាត់ពូក្អាត់មិនអោយលក់កូន ។ ស្រីម៉ៅកើតទុក្ខរហូតដល់ ប្រលងធ្លាក់ ។ នាងក៏សំរេចចិត្តថាឈប់រៀន ហើយរត់រកការធ្វើ វិញ ដើម្បីរកលុយផ្ញើទៅផ្ទះជួយម្ដាយនឹងប្អូន ។ ថ្វីបើអ្នកគ្រូចរណៃ និងលោកដុកទ័របានផ្ដល់ជីវិតគ្រួសារយ៉ាងកក់ក្ដៅដល់ធិតាត្បិតមិន ចង់អោយម៉ៅមានស្លាកស្នាមរបួសក្នុងចិត្តរិតតែខ្លាំងក៏ដោយ ក៏នាង ម៉ៅនៅតែកាត់ចិត្តមិនដាច់ពីគ្រួសារដើមរបស់នាងឡើយ...និយាយ អោយពិតទៅ ស្រីម៉ៅជាក្មេងស្រី ដែលគួរអោយអាណិតអាសូរ បំផុតហើយ ។ នាងគោរពប្រណិបតន៍បំរើអ្នកគ្រូ

និងក្រុមគ្រួសារ មិនអោយមានរឧិស្ថានឡើយ ព្រោះអីតាំងពីមករស់នៅជាមួយ លោកនាងមិនដែលត្រូវរំពាត់ ហើយលោកក៏អនុញ្ញាត្តអោយនាង រស់នៅ រៀនអ្វី ធ្វើការអ្វីសមនឹងវ័យរបស់នាងជានិច្ច ។ ក្នុងការ គ្រប់គ្រងរបស់គ្រួសារថ្មីនេះ នាងមានសេចក្តីសុខណាស់ ប៉ុន្តែ... ពេលណាខ្លួននាងបានទទួលសេចក្តីសុខរិតតែខ្លាំង នាងក៏មានចិត្តនឹកអាណិតម្តាយអាណិតប្អូនរិតតែខ្លាំងដែរ ដោយនាងមិនអាចមានលទ្ធភាពជួយស្រោចស្រង់ពួកគេអោយផុតពីទុគ៌តភាពបាន ។

ក្រោយមក ស្រីម៉ៅក៏បានទទួលដំណឹងមកថា ឪពុកនាងបាន អនិច្ចកម្មទៅដោយជំងឺថ្លើមព្រោះញៀនស្រា ។ ប្អូនពីរនាក់ក្នុង ចំណោមប្អូននាក់ដែលពូក្អាត់ឪពុករបស់នាងលក់អោយគេបានលួច រត់ត្រឡប់មកស្រុកវិញហើយនៅបំរើម្តាយរហូតមក ។ ចៃដន្យ នៅ រវាងឆ្នាំ១៩៧០ ស្រុកទេសក៏បានប្រែប្រួលមានសង្គ្រាម ធ្វើអោយកើតមានអសន្តិសុខនៅគ្រប់ទីកន្លែងទាំងអស់ក្នុងប្រទេស ។ ម៉ៅក៏ខកខានទៅលេងម្តាយអស់ជាយូរឆ្នាំ ។

ពោលពីរឿងបុរីនិងស្រីម៉ៅវិញម្តង...

ការពិតស្រីម៉ៅបានចងចាំបុរីរហូតមកតាំងពីរាត្រីបណ្តែតប្រទីប នោះម្ល៉េះ ។ នាងហាក់ដូចជាមាននិស្ស័យនឹងយុវជនម្នាក់នោះយ៉ាង ចម្លែកតែម្តងរហូតដល់ពាក់ខ្សែកដែលជាចំណងដៃរបស់នរៈ មិន ដែលដោះម្តងណាទេ ហើយនាងក៏តែងតែដើរមកសំកុករាល់ល្ងាច នៅមាត់ស្ទឹងកន្លែងដដែល ចាំមើលផ្លូវបុរីមួយថ្ងៃហើយមួយថ្ងៃ ទៀត តែបុរីមិនដែលត្រឡប់មករកនាងវិញដូចគេបានសន្យានោះ ឡើយ ។ យ៉ាងណាក៏មាណវីមិនលះបង់ការរង់ចាំនោះដែរ ។ នៅ រៀងរាល់ឆ្នាំនាងតែងតែធ្វើប្រទីបមកបណ្តែតនៅកន្លែងដដែល ក្នុងចិត្តប៉ុនប៉ងថានឹងបានជួបបុរីនៅថ្ងៃណាមួយ ។ ៨ឆ្នាំកន្លងទៅ នាងមិនដែលបានជួបគេម្តងណាឡើយ រហូតលុះថ្ងៃមួយដែលបុរីបរ រថយន្តកិនដើមអំពៅស្រីម៉ៅដែលបានដាច់ចំណងជ្រុះពីកង់ ។ ការពិតកាលណោះ នាងទើបចេញពីធ្វើការរោងចក្រ ចូលកាប់អំពៅ នៅផ្ទះរបស់សាមឿនជាមិត្តដើម្បីយកមកផ្ញើប្អូនៗឯផ្ទះ ។ លុះ ប្រមូលអំពៅចងជាប់កង់វិញវិញ ហើយនាងក៏ជិះត្រលប់មកផ្ទះ ក៏ប្រទះរថយន្តរបស់បុរីចតនៅលើថ្នល់មុខផ្ទះលោកបុរាណ ។ ម៉ៅចុះចតកង់ហើយយកដើមអំពៅទៅវាយឡើងសុសឡាន ដើម្បីសង សឹក ។ ពេលនោះបុរីចេញពីផ្ទះ មកស្រែកទាញកង់យាត់ស្រីម៉ៅ មិនអោយនាងជិះកង់គេចខ្លួនទៅ

CHANBOKEO.COM

ស្រាប់តែមាណវីដួលធ្លាក់ពីលើ កង់ ជំពប់ដួលទៅលើទ្រូងបុរីរួចផ្ងាករំលំទៅដីទាំងពីរនាក់ ។ កាល បើក្រោកឡើងឃើញភក្ត្រ័នរៈកាលណា ឱរានាងរំភើបខ្លាំងណាស់ ត្បិតម៉ៅនៅចំណាំមុខរបស់គេបាន ។ ពេលនោះ ថ្វីបើនរៈបាន ចំរើនវ័យទៅជាបុរសទីក្រុងយ៉ាងសង្ហាម្នាក់ក៏ដោយ គឺនាងបានចាំ ច្បាស់ក្នុងចិត្តថាបុរសនោះជាបុរីយ៉ាងពិតប្រាកដ ។ ថៃដន្យ គេមាន ឫកពាមិនគួរអោយរាប់ជាគ្នាសោះ ណាកំពុងតែខឹងនឹងរូប នាយ ដែលមិនព្រមទទួលខុសត្រូវអំពើឆ្គាំឆ្គងរបស់ខ្លួនផងនោះ នាងក៏ខ្ជក់ចិត្តចង់ចាញ់ចង់ឈ្នះបុរីតែម្តងទៅ ។

លុះមកដល់ផ្ទះវិញ ប្អូនទាំងបីរត់ទទួល ។

- បងម៉ៅ ហេតុអីបែកកែងដៃចេញឈាមឥចឹង ? (វិសាលសួរ)
- គឺបងត្រូវមនុស្សឆ្កួតដេញខាំ ដួលកង់បានជាត្រូវរបួសអញ្ចឹង!
- ហើយមនុស្សឆ្កួតហ្នឹងជាប្រុសកម្លោះឬអ្វី បានជាបងភ័យរហូត ដល់ទៅដួលកង់ ? (ចិត្រាចំអន់លេង)
- និយាយតែផ្តាស! នរណាទៅដឹង ថាគេកម្លោះ ?
- អូហូ! សារភាពហើយហ្អូសបងថាគេជាមនុស្សប្រុសមែនទេ ? សង្ហាទេបង ? (បារមីសួរ)
- សួរធ្វើអ្វី ? បងមិនចង់រំលឹកទេ ។
- ពុទ្ធោ! បើបងមិនប្រាប់ធ្វើម៉េចនឹងប្អូនតាមសងសឹកអោយបាន ទៅ បងម៉ៅ (ចិត្រាបន្ទរ)

ឃើញប្អូនលលេងពេក នាងក៏ឈប់និយាយ ។ ការពិត ប្អូនៗ របស់នាងស្រឡាញ់នាងណាស់ ។ គេទំលាប់លលេងនឹងបងស្រីតែ អញ្ចឹងតាំងពីយូរហើយ ។ បន្តិចមក ចិត្រាក៏យកថ្នាំមកបិទកែងដៃ អោយបងស្រីដែលនៅអង្គុយធ្វើមុខក្រញូវមិនបាត់ មិនដឹងថានាង កំពុងគិតអ្វីទេ ។

- បងម៉ៅ មានរឿងអ្វីមែនទេ ?

ស្រីធិតាមិនឆ្លើយទេ បែរជាញញឹមបន្លប់ប្អូនវិញថា :

- គឺមកពីបងឈឺកែងដៃទ្រាំមិនបាននោះអី ។

យប់នោះ ស្រីម៉ៅគេងរសាប់រសល់ទាល់ភ្លឺ នឹកខ្ញាញ់នឹងបុរស ដែលមិនចំណាំនាងមិនបាន ហើយក៏ខ្ញាញ់ចំពោះឫកពានិងសំដី អសុរសរបស់គេនោះក្រៃលែង ។

CHANBOKEO.COM

- គ្រាន់តែបែកគ្នា៨ឆ្នាំ គេប្រែប្រួលអោយស្រឡះតែម្តង...តើយើង គួរចងចាំពាក្យសន្យារបស់យើងគ្រានោះ ឬក៏យើងត្រូវបោះវាចោល អោយអាសារទៅវិញ ? មើលទៅគេ មិនសមជាមនុស្សដែលយើង ត្រូវរង់ចាំតទៅទៀតទេ...

នៅមុខកញ្ចក់ មាណវីអង្គុយសម្លឹងបន្តោងប្រាក់កាក់ដែលឆ្លាក់ ឈ្មោះវៃសង្កៃ ជាប់ក្រឡៅ... មិនដឹងថា តើនាងនិងវៃសង្កៃមាន និស្ស័យត្រឡប់មកជាមនុស្សពីរនាក់ ដែលយល់ចិត្តថ្លើមគ្នាដូចពី អតីតកាលវិញដែរឬទេ...

ព្រឹកឡើង នាងក៏ប្រទះបុរីសាជាថ្មីហើយក៏ទើសភ្នែកទើសចិត្ត នឹងគេដដែលទៀត ធ្វើអោយនាងរិតតែខ្ពាញ់នឹងរូបគេឡើង ។ ភព្វ ថៃដន្យ នាងក៏បានជួបគេទៀត នៅព្រលប់ថ្ងៃដដែល ពេលនាង ចេញពីធ្វើការមកវិញ ។ ទទួលថ្ងៃនោះ នាងមានវេនធ្វើការដល់ទៅ ១២ម៉ោងហើយមិនបានទទួលអាហារគ្រប់គ្រាន់ ។ ម្យ៉ាងទៀត ស្រីម៉ៅជាមនុស្សគេងមិនស្កប់ពេញភ្នែកផង ។ កាលបើបុរីរត់ឡើង ជិះកង់ពីក្រោយនាង ហើយស្រវាអោបចង្កេះរិតពោះរបស់ឆវីខ្លាំង ពេក នាងក៏ចប់ដកដង្ហើមមិនរួច ទន់ខ្លួន ដួលពីកង់ធ្លាក់ដីតែម្តង ទៅ ។ មាណពយើងក៏ជិះកង់បីយកនាងទៅដល់ផ្ទះរបស់គេ ហើយចេញទៅតាមពេទ្យ ទទួលលោកដុកទ័រវិចិត្រក៏បរឡានជ្រួសគ្នា ជា មួយបុរី ចូលមកដល់ផ្ទះបុរី ក៏ប្រទះនឹងស្រីម៉ៅនៅទីនោះតែម្តង ។ លោកក៏នាំខ្លួននាងចូលមន្ទីរពេទ្យជាបន្ទាន់ ។ ថៃដន្យ បុរីមិនព្រម លះបង់ចោលឬកពាឌឹងចំពោះម៉ៅសោះ ធ្វើអោយនារីរសាយអស់កម្លាំងចិត្តចំពោះនរ: ។

ប៉ុន្តែ... នៅក្នុងពេលដែលនាងកាន់តែស្អប់ កាន់តែគេច កាន់តែធ្មេចបំភ្លេចរូបគេពីក្នុងដួងចិត្ត បុរីបែរជាដើរចូលក្នុងជីវិតរបស់ នាងកាន់តែញឹកញាប់ឡើង ជិតដិតឡើងរៀងរាល់ថ្ងៃ ។ វត្តមាន របស់នរ: និងសំដីសំដៅនិងឥរិយាបថរបស់គេ បានផ្លាស់ប្តូរបន្តិច ម្តងៗ ចំពោះស្រីម៉ៅ មិនដឹងថាគេចំណាំនាងបានឬយ៉ាងណាទេ ។ ស្រាប់តែថ្ងៃមួយ បុរីបានទៅដល់ផ្ទះនាង.. ថែមទាំងណែនាំខ្លួនគេ អោយអ្នកគ្រូចរណៃបានស្គាល់ ធ្វើអោយម៉ៅនឹកខ្លាចចិត្តឪពុកម្តាយ ហើយនឹកអៀនខ្មាសក្នុងខ្លួនកាន់តែខ្លាំង ដែលមានបុរសចូលមក បង្ហាញដួងចិត្តប្រតិពទ្ធ័របស់គេចំពោះរូបនាង ចំពោះមុខម៉ាក់ប៉ា និងប្អូនៗដោយមិនមានលាក់លៀមអ្វីសោះ ។ ពេលនោះ នាងកាន់តែមានចិត្តរំភើបចំពោះបុរីរកថាមិនត្រូវសោះ ។ ទោះបីចិត្តមួយ នៅរារែក មិនដឹងថាបុរីមានគំនិតយ៉ាងណាចំពោះនាង... ក៏ចិត្តមួយ

CHANBOKEO.COM

ទៀតបែរជាជំរុញឲ្យនាងកាន់តែខិតទៅជិតរូបគេ ចង់នៅក្បែរគេ គ្រប់ពេលវេលាទាំងអស់ កាន់តែខ្លាំងឡើងដែរ ។ ពេលនោះ នាងទើបតែជួបគេមិនបានប៉ុន្មានថ្ងៃ តែមាណវីមានអារម្មណ៍ថា នាងបានជំពាក់ចិត្តយ៉ាងជ្រាលជ្រៅចំពោះបុរសម្នាក់នេះ ដោយមិនអាចប្រកែកបាន ។

ទោះជាយ៉ាងណាក៏ដោយ ធិតាមិនបានត្រៀមខ្លួនរៀបរយទទួល ការបើកបង្ហាញដួងចិត្តរបស់បុរី យ៉ាងឆាប់រហ័សបែបនោះដែរ ។ នៅពេលដែលនាងត្រូវបុរីចាប់ថើបបបូរមាត់ឯមាត់ស្ទើង នាព្រលប់ មួយនោះ មាណវីភ្ញាក់ផ្អើលហើយរន្ធត់តក់ស្លុតណាស់ ញាប់ញ័រ ណាស់ ខឹងណាស់ ភ័យណាស់ ហើយក៏ខ្មាស់ណាស់ផងដែរ មិនដឹង ថាត្រូវធ្វើកិរិយាយ៉ាងណាអោយសមទេ ។ នេះឬដួងចិត្តនារី ពេល បានបុរសប៉ះពាល់បន្តិចបន្តួចក៏ញាប់ញ័រវង្វេងគិតអ្វីមិនត្រូវ ?

ការពិត អ្វីដែលម៉ៅរន្ធត់បំផុតនោះគឺព្រោះនាងមិនដឹងថាតើបុរី លួងលោមនាង ព្រោះគេស្រឡាញ់ធិតាពិតប្រាកដ ឬក៏គេប្រព្រឹត្ត ព្រោះតែអារម្មណ៍ភ្លើតភ្លើនរបស់បុរស ដែលត្រូវកាមរាគឆាបឆេះ មួយពេលតែប៉ុណ្ណោះ ។

ព្រឹកស្អែកឡើង ពេលបុរីនាំឪពុកម្ដាយមកជួបនឹងប៉ាម៉ាក់របស់ នាង ធិតាក៏បានឮវាចាលោកបុរាណនិយាយពីសម្ពន្ធសង្សាររបស់ បុរី ។ ស្រីម៉ៅក្នុងនឹកខ្ពក់ខ្ពាញ់ក្នុងចិត្តសាជាថ្មី... ទទួលមានសំបុត្រ មកពីស្រុកប្រាប់ពីស្ថានភាពគ្រួសាររបស់នាង ធិតាប្រែជាវិលវល់ ក្នុងចិត្តលែងគិតអ្វីចេញតែម្ដង ក្រៅតែពីចង់គេចខ្លួនពីពិភពលោក នេះអោយឆ្ងាយពីបុរីតែប៉ុណ្ណោះ ។ ចៃដន្យអី បុរីមិនបានបណ្ដោយ ឲ្យនាងចាកចេញពីជីវិតរបស់គេដោយងាយៗទេ ។ គេក៏រត់តាម ពីក្រោយធិតា ឡើងរថយន្តម៉ុងហ្គួតធ្វើដំណើរទៅជាមួយនាងដែរ ។

នៅកណ្ដាលព្រៃ ក្រោមស្នៀគ្រប់កាំភ្លើងតូចធំរបស់ទ័ពអាវខ្មៅ ដែលចេញមកប្លន់កៀរអ្នកស្រុកតាមផ្លូវលើចំណោទភ្នំជញ្ជាំង បុរី បានអោបធិតាលោតចុះពីរថយន្ត រមៀលធ្លាក់តាមជំរាលភ្នំ រួច ហើយក៏ត្រូវរងគ្រោះដោយសារចំហាយផ្សែងផ្ទុះរបស់គ្រាប់ផ្លោងធំ មួយគ្រាប់ដួលសន្លប់បាត់ស្មារតីទៅ ។ សំណាងល្អ កាលនោះ ធវី បានធ្លាក់ទៅក្នុងគន្លុករណ្ដៅមួយតែម្នាក់ឯង មិនបានទទួលឥទ្ធិពល ចំហាយគ្រាប់នោះទេ ។ លុះនាងងើបឡើង វារទៅរកបុរី មាណព បានរលត់ស្មារតីទៅហើយ ។ នៅឯខាងលើផ្លូវថ្នល់ជាតិវិញ កង ទព័ខ្មែរក្រហមនិងកងទ័ពសាធារណរដ្ឋខ្មែរ

CHANBOKEO.COM

កំពុងប្រយុទ្ធគ្នាយ៉ាង ខ្លាំងក្លា ។ អ្នកដំណើរប្រមាណជាងមួយរយនាក់ត្រូវស្លាប់ និងរង
របួសយ៉ាងធ្ងន់ធ្ងរ ។ លុះស្ងប់គ្រាប់បន្តិចមក ស្រីម៉ៅក៏វារចេញមក រកជំនួយពីក្រុមទាហាន
ជួនអីមានអ្នកស្រុកជាច្រើនឡើងមកដល់ ដែរ ដើម្បីជួយសង្គ្រោះអ្នករងគ្រោះ ។ ពេលនោះ
ម៉ៅក៏បានជួប មេឃុំភុំដែលឡើងមកនឹងគេ ហើយក៏បានជួយសង្គ្រោះបុរីទាន់ ពេលវេលា ។

នៅថ្ងៃដដែលនោះ ម៉ៅក៏បានទៅទាន់ដង្ហើមម្តាយរបស់នាង
រួចក៏បានទុកដាក់សពរបស់គាត់ដោយផ្ទាល់ដៃផង ។ ចំណែកសព
របស់ប្អូនទាំងពីរវិញបានត្រូវអ្នកស្រុកបូជារួចស្រេចបាច់ តាំងពី នាងមិនទាន់មកដល់ភូមិម្លេះ ។
រីឯប្អូនពីររូបទៀតដែលនៅសល់ ម្នាក់រស់នៅឯវត្តពួក បំរើលោកគ្រូចៅអធិការវត្ត ហើយម្នាក់ទៀត
ជានាងគ ដែលមេឃុំភុំនិងភរិយារើសយកចិញ្ចឹមនោះឯង ។

ចំពោះពូមេឃុំនិងមីងចំណានជាភរិយា គាត់ហាក់យល់ចំណង ចិត្តរវាងម៉ៅនិងបុរីណាស់
ជាពិសេសពេលឮបុរីគេទទួលស្រីម៉ៅ ជាប្រពន្ធពេញៗមាត់ ដោយមិនមានខ្មាសអៀននរណា
គាត់ក៏ចេះ តែបណ្តោយៗអ្នកទាំងពីរទៅតាមដំណើរ ដែលដួងចិត្តរបស់គេ ដង្ហោយរកគ្នាទៅ
ឡិតច្រឡំស្មានថាអ្នកទាំងពីរជាប្តីប្រពន្ធនឹងគ្នា ពិតមែន គ្រាន់តែគេងដេកដាក់គ្នាប៉ុណ្ណោះ ។

ការរស់នៅជិតដិតនឹងគ្នារាល់ថ្ងៃរវាងបុរីនិងស្រីម៉ៅ យូរៗទៅ
បានធ្វើឲ្យមនោសញ្ចេតនារវាងអ្នកទាំងពីរ កាន់តែរីកធំឡើងជា លំដាប់ ។
ចំណែកពូមេឃុំក៏បានខិតខំរកវិធីទាក់ទងទៅបាត់ដំបង ដើម្បីនាំយកបុរីទៅព្យាបាល
កុំឲ្យយឺតពេល ខ្លាចមើលមិនជា ។ ថែងន្យ ភ្នំជញ្ជាំងដែលធ្លាប់មានប្រវត្តិតាំងពីបុរាណមកថា
ជាជំរក សំបុកក្រុមចោរព្រៃ ពេលនេះបានក្លាយ ជាសំបុកទ័ពខ្មែរក្រហម ទៅហើយ ។
ការធ្វើដំណើរចេញពីភូមិព្រះនេត្រព្រះ ទៅបាត់ដំបង
កាត់តាមភ្នំជញ្ជាំងតែងតែស្ថិតនៅក្នុងគ្រោះថ្នាក់ជានិច្ច ។

នារាត្រីមួយនោះ ដែលខ្មែរក្រហមចូលកៀរអ្នកស្រុកនៅព្រះ នេត្រព្រះ តាំងពីភូមិជប់
ប៉ោយក្លឿង ប៉ុស្តិ៍ចាស់ ប៉ោយសំរោង ប៉ោយត្រើងរហូតដល់ជើងភ្នំស្រេះ
ស្រីម៉ៅនិងបុរីបានរត់វង្វេងបាត់ ហ្វូងគ្រួសារពូមេឃុំទៅ ។ ដោយសារនាងមិនសូវស្គាល់ស្ថានភាព
ទឹកដីទីនោះ ព្រោះខានរស់នៅតាំងពីតូច នាងមិនដឹងថាត្រូវនាំ បុរីរត់គេចទៅណាទេ ។
ដូច្នោះហើយ នាងក៏សំរេចចិត្តនាំបុរីទៅ លាក់ខ្លួននៅគោកខ្មោច
ដោយគិតឃើញថាគ្មានមនុស្សម្នាណាគេ មកពួននៅកន្លែងដីផ្នូរកប់ខ្មោចទេ ។
នាងគិតថាទីនោះជាតំបន់ ដែលមានសន្តិសុខបំផុត ។ ពេលនោះ អ្នកទាំងពីរក៏មានឱកាស

CHIANBOKEO.COM

នៅនៃបនិត្យជិតដិតស្និទ្ធស្នាលផ្លូវកាយនឹងគ្នាជាលើកដំបូង....ភាសា ពាក្យពេចន៍ទន់ភ្លន់របស់បុរី
សមនឹងការថ្នាក់ថ្នមលួងលោមដ៏ផ្អែម ល្ហែម
ព្រមជាមួយនឹកទឹកចិត្តប្រតិពទ្ធ័ដែលអ្នកទាំងពីរចំពោះទៅ វិញទៅមកយ៉ាងជ្រាលជ្រៅធំធេង
បានធ្វើអោយគូស្នេហ៍ទាំងទ្វេហា ភ្លេចអស់នូវព្រំដែនសីមាជាកម្លោះក្រមុំ ។
ភ្លើងស្នេហ៍ដែលគេប្រឹង លាក់នៅក្នុងដួងចិត្តជាយូរមកហើយនោះ ក៏ឆាបឆេះរោលរាលឡើង
រហូតធ្វើអោយអ្នកទាំងពីរវង្វេងទៅក្នុងភាពភ្លើតភ្លើននៃកាមារម្មណ៍ ទប់ចិត្តទប់ប្រាណ
លែងបានតទៅទៀត...

ស្អែកឡើង មុនពេលធ្វើដំណើរ ពូមេឃុំបានតេរអូជួបលោក
វិចិត្រនិងលោកបុរាណនៅបាត់ដំបង ហើយក៏បានដឹងរឿងរ៉ាវពិត ប្រាកដរវាងអ្នកទាំងពីរ ។
គាត់ក៏នាំក្រុមគ្រួសារព្រមទាំងបុរីនិង ស្រីម៉ៅធ្វើដំណើរតាមឡានទ្រុងរបស់កងទ័ពសាធារណរដ្ឋ
រហូតមក ដល់ទីប្រជុំជន ក្រុងបាត់ដំបងដោយសុវត្ថិភាព ។ ពេលនោះ ចាស់
ទុំនៅបាត់ដំបងបានរៀបចំគំរោងការអោយបុរីទៅព្យាបាលភ្នែកនៅ ឯភ្នំពេញវិញ ត្បិតនៅទីនោះ
មានពេទ្យពិសេសអាចជួយអោយបុរី ឆាប់ជាសះស្បើយ ។
អ្នកគ្រូចរណៃបានមកទទួលកូនដល់ចំណត ព្រោះមិនចង់អោយស្រីម៉ៅ
ធ្វើដំណើរជូនបុរីទៅភ្នំពេញជាមួយបុរី ខ្លាចមិនសមភ្នែកអ្នកផង
ដែលអ្នកទាំងពីរមិនទាន់រៀបការនឹងគ្នា
ណាមួយបុរីវិញក៏មានទាន់បានលាពាក្យលាសំដីដាច់ស្រេចពីសង្សារ ចាស់របស់ខ្លួនដែរ
ទើបចាស់ៗសំរេចបំបែកអ្នកទាំងពីរមួយពេល ដើម្បីអោយបុរីមានវេលាគេងគិត
ថាតើគេស្រឡាញ់ពិតប្រាកដ ឬក៏គ្រាន់តែជាការសប្បាយភ្លើតភ្លើនមួយគ្រា ។ បើសិនបុរីពិតជា
មានចិត្តប្តូរផ្តាច់ជាមួយនឹងស្រីម៉ៅពិតមែននោះ គេនឹងវិលត្រលប់ មកបាត់ដំបងវិញជាមិនខាន
នៅពេលគេបានជាសះស្បើយ.... ចំណែកម៉ៅវិញក៏ត្រូវគេងរង់ចាំផ្លូវបុរី
យ៉ាងត្រមង់ត្រមោចបំផុត ។ កាលនោះ ចាស់ទុំទាំងសងខាងមិនបានដឹងទេថា ចំណងសម្ពន្ធ័ដួង
ចិត្តរវាងអ្នកទាំងពីរមានកិរិតរាក់ជ្រៅប៉ុនណាឡើយ គ្រាន់តែដឹងថា គេបែកគ្នាមិនបាន...

*oooooooooooooooooo*

*ooooo*

*o*

CHANBOKEO.COM

# វគ្គទី១៨
# កុលាបស្ទឹងខៀវ

ស្គរសម្លេងភ្លេងចៅព្រាហ្មណ៍ហែកូនកម្លោះ បានលាន់ឡើងរងំ តាមបណ្តោយខាងកើតដងស្ទឹងសង្កែ ។ បុរីដើរបាំងឆត្រ័ទាំងទឹក មុខញញឹមបំព្រងក្នុងសម្លៀកកូនកម្លោះយ៉ាងសង្ហា ដោយមានកាន់ ផ្កាស្លាយ៉ាងស្រស់ អមដោយក្បួនហែជំនូនចំនួន១២៦ថាស ចេញពីលំនៅលោកបុរាណសំដៅទៅគេហដ្ឋានលោកដុកទ័រវិចិត្រ ។ ក្បួនហែមិនទាន់មកដល់មុខផ្ទះកូនក្រមុំស្រួលបួលផង ស្រាប់តែសាមេតបរវេស្ប៉ាឌុបសង្សារដ៏ស្រស់សោភាររបស់គេមកដល់ ព្រមជាមួយ សាមឿនជាប្អូនដែលបរម៉ូប៊ីឡែតឌុបស្រីស្រស់ផលាមកដល់ដែរ ។ បុរីបើកភ្នែកធំៗ ទំនងហាក់ភ័យខ្លួននឹកខ្លាចសម្ផស្សមកឆាឆៅពិធី មង្គលរបស់គេថ្ងៃនេះ ។ សាមេតចតវេស្ប៉ាហើយក៏ស្ទុះមកខ្សិបប្រាប់បុរីយ៉ាងរហ័សថា :

- នែ៎ បុរីឯងកុំភ័យអី! ខ្ញុំបានដាក់នារីរូបស្រស់នៅវាលយន្តហោះ ព្រឹកមិញបាត់ទៅហើយ ។
- ថាម៉េចសាមេត ? ហេតុអ្វីនាងសុខចិត្តចាកចេញទៅងាយម្លេះ ?
- ថីមិនងាយ បើខ្ញុំភូតថា ឯងនៅចាំទទួលឯភ្នំពេញឯណោះ ។
- ពុទ្ធោ!
- អឺ... ភូតម៉ាពេលសិនទៅ ចាំយ៉ាងម៉េចយ៉ាងម៉ា ចាំដោះស្រាយ តាមក្រោយទៀត តែថ្ងៃនេះយើងត្រូវបន្តពីធីមង្គលការរបស់ឯង អោយបានអធឹកអធម្មបំផុត ឮទេ ?

បុរីញញឹមឡើង ទំនងហាក់ដូចជាធូរទ្រូង :

- អរគុណណាស់សម្លាញ់! ឯងជាមិត្តដែលដឹងចិត្តខ្ញុំបំផុតហើយ ។

CHANBOKEO . COM

ក្បួនហែបានមកដល់មាត់ជណ្តើរផ្ទះរបស់លោកគ្រូពេទ្យវិចិត្រ... ស្រីម៉ៅបានលេចខ្លួនឆ្លោឡើង ក្នុងសម្លៀកមង្គលការយ៉ាងប្រណិត ក្រៃលែង ធ្វើអោយបុរីឈរសម្លឹងគន់សោភ័ណរបស់នាងយ៉ាងភ្លឹក ភាំងស្មារតី ស្ទើរតែភ្លេចដកដង្ហើម ។

- ម៉ៅ!... (នរៈឧទានហៅឈ្មោះនាងខ្សិបៗ)

និតាញញឹមយ៉ាងស្រស់តបវិញ ។ បន្ទាប់មក បុរីក៏លើកផ្កាស្លា ហុចទៅនារីបណ្តូលចិត្តរបស់គេ រួចស្រដីថា :

- បងសូមធ្វើជីវិតនិងបេះដូងរបស់បង ជាមួយអូនផងណា៎ម៉ៅ!

មាណវីញញឹមពព្រាយដោយក្តីរំភើបសោមនស្ស រួចក៏ឆ្លើយតប ទៅបុរសជាទីស្រឡាញ់វិញថា :

- ម៉ៅសូមទទួលដោយដួងចិត្តរីករាយបំផុត ចា៎ស!

រួចហើយនាងក៏លូកដៃទៅទទួលយកផ្កាស្លាពីដៃបុរស ហើយក៏ ឱនកេសាទទួលយកកម្រងផ្កាម្លិះដ៏ក្រអូបពីបុរី ទាំងឱរារំដើបរំជួល ញាប់ញ័រ ។ ស្រាប់តែ...

- បងបុរី ?

សម្លេងស្រីម្នាក់ស្រែកឡើងយ៉ាងស្រួយស្រែសពីខាងក្រៅរបង ទៅ កាត់ចង្វាក់កម្មវិធីមង្គល ។ ទាំងអស់គ្នាភ្ញាក់ក្រញាង ងាកបែរ ក្រលេកទៅក្រោយ ឃើញនារីសិចស៊ីមួយរូបយ៉ាងស្រស់ឆើតឆាយ បោះជំហានចូលមកយ៉ាងក្លាហានទំនងដូចជាកំពុងខឹងសម្បារផង ។ បុរីភ្ញាក់ក្រញាងកាលបើឃើញមុខនាងភ្លាម ។ ឯស្រីម៉ៅក៏ភ្ញាក់ផ្អើល មិនខុសគ្នាពីបុរីប៉ុន្មានដែរ ។ នារីរូបស្រស់ ដើរមកដល់ជិតបុរី ក៏វាចាឡើងថា :

- ហេតុអ្វីក៏បំបាក់មុខសម្ផស្សបែបនេះ បុរសក្បត់ចិត្ត ?

បុរីគាំងឈឹងរកអ្វីនិយាយមិនឃើញ ក្រៅពីឈរព្រិចភ្នែកយ៉ាង ញាប់ ហាក់ដូចជាកំពុងអាមាសខ្លួន ។ រំពេចនោះ សម្ផស្សក៏បែរ មើលទៅស្រីម៉ៅហើយសម្លក់ចង់ឆ្លាយប្រស្រី ប៉ុន្តែនាងមិននិយាយ រកម៉ៅទេ បែរជាទៅនិយាយជាមួយបុរីវិញថា :

- ហេតុអ្វីបានអ្នក.... ? ហ៊ឹះ! ល្អណាស់... ដែលខ្ញុំមកឃើញទាន់ នឹងភ្នែកដោយខ្លួនឯង... មិត្តភក្តិរបស់អ្នក ក៏គ្មាននរណាមួយមាន ចិត្តស្មោះទេ សុទ្ធតែជាមនុស្សកុហកបោកប្រាសទាំងអស់ ។

CHANBOKEO.COM

សម្ពស្សខឹងខ្លាំងណាស់ សម្លក់ប៊ុរីនិងសាមេត សឹងជ្រុះប្រស្រី ភ្នែកតែម្តង ។ តែសាមេតនៅស្ងៀម មិនតបតសំដីមាណវីរូបឆោម ស្រស់នោះឡើយ ។ ឯប៊ុរីវិញក៏នៅស្ងៀម មិនមានតបតអ្វីដែរ បែរជាងាកមុខទៅមើលម៉ៅ រួចមើលទៅឪពុកម្តាយរបស់គេ ទំនង ហាក់ដូចជាសុំយោបល់ថា តើនាយគួរធ្វើយ៉ាងណាអោយសក្តិសម ? ស្រីម៉ៅក៏បែរសម្លឹងប៊ុរីវិញ ដោយក្រសែភ្នែកភ្លឺថ្លាផ្លេកៗ ទំនងចង់ បញ្ជាក់ថា
ដល់ពេលហើយដែលប៊ុរីត្រូវសម្តែងភាពក្លាហាន ជាកូន ប្រុសចេញមុខការពារកត្តិយសអោយនារី ដែលគេបេតីប្រតិពទ្ធ័ ហើយពេញចិត្តនឹងលើកផ្កាស្លាមង្គលជូនដល់នាង ។ កាលបើគេ ក្រលេកឃើញក្រសែភ្នែករបស់គូស្នេហ៍ភ្លាម ប៊ុរីទទួលអារម្មណ៍ថា
នាងកំពុងតែរង់ចាំការសំរេចចិត្តពីនាយយ៉ាងជាក់លាក់ពិតប្រាកដ ។
គេក៏លេបទឹកមាត់ផ្សើមបំពង់ក រួចហើយស្រដីយ៉ាងម៉ឺងម៉ាត់ថា :
- អរគុណសម្ពស្សដែលឆ្លៀតពេលមកចូលរួមពីធីមង្គលរបស់ខ្ញុំ ។ យើងជាមិត្តល្អនឹងគ្នាជាយូរហើយ សង្ឃឹមថាសម្ពស្សនឹងប្រសិទ្ធិពរ ដល់គូស្វាមីភរិយារបស់ខ្ញុំនូវពរជ័យយ៉ាងល្អប្រសើរបំផុត ហើយ សង្ឃឹមថាសម្ពស្សរាប់អានភរិយារបស់ខ្ញុំ ជាមិត្តរបស់នាងម្នាក់ដែរ ត្បិតអីស្រីម៉ៅនេះជានារីដែលប៊ុរី ស្រឡាញ់ប្រតិពទ្ធ័បំផុតក្នុងលោក នេះ គ្មានអ្វីប្រៀបស្មើបានឡើយ ។
សម្ពស្សឮហើយនៅស្ងៀម សម្លឹងស្រីម៉ៅមួយស្របក់ក៏សួរទៅ ប៊ុរីវិញថា :
- បុរសសាវាបំផុតដូចប៊ុរីនេះ តើចេះស្រឡាញ់នរណា រក្សានរណា បានដែរទៅ ? តើគួរអោយនាងទុកចិត្តបានទេថា អ្នកមិនប្រែប្រួល ចិត្តនៅថ្ងៃស្អែកហើយមិនទុកឲ្យនាងជូតទឹកភ្នែកនឹងក្បាលជង្គង់ ?
- ពិតជាទុកចិត្តបាន ដោយមានព្រះជាសាក្សី ព្រោះប៊ុរីស្វែងរក ឃើញម្ចាស់បេះដូងរបស់ខ្លួនពិតប្រាកដហើយ ! ហើយស្រីម៉ៅនេះ ហើយក៏ជានារីតែម្នាក់គត់ដែលមានសិទ្ធិធ្មឹមគូនឹងប៊ុរីទទួលផ្កាស្លា...
- ល្អ ! បើអាចធ្វើដូច្នេះបានមែន ទើបគេហៅថាកូនប្រុស !
សម្ពស្សគំហកអោយប៊ុរី ទាំងឃ្នាន់ខ្នាញ់ រួចស្រដីបន្តថា :
- ហើយបើថ្ងៃក្រោយ អ្នកដូរចិត្តយ៉ាងណានោះ... កុំសង្ឃឹមថាអាច វិលមករកសម្ពស្សវិញបានអោយសោះ ! !

CHANBOKEO.COM

ថាហើយ ធិតាក៏ដើរប៉ាត់ញ៉ាត់ចេញទៅទាំងកំហឹងពេញប្រាណ ដោយការខកចិត្តចំពោះបុរីយ៉ាងអនេកអនន្ត ។ ស្រីម៉ៅសម្លឹងធីរ មួយរូបនោះពីក្រោយ ដោយដួងចិត្តញាប់ញ័រយ៉ាងណាមិនដឹង ។ បុរីឃើញភរិយាមានផ្លាស់ប្ដូរទឹកមុខបាត់រីករាយ គេក៏លូកចាប់ដៃ នាងមកកាន់យ៉ាងណែន ហើយវាចាយ៉ាងទន់ភ្លន់ទៅរកនាងថា :

- ថ្វីបើបុរីមានប្រវត្តិអតីតកាលមិនសូវជាល្អប៉ុន្មាន ប៉ុន្តែចាប់ពីថ្ងៃនេះទៅ បងសូមសន្យា ដោយមានចាស់ទុំនិងភ្ញៀវទាំងឡាយជា សាក្សី ថាបងនឹងរក្សាចិត្តស្មោះស្ម័គ្រចំពោះតែម៉ៅម្នាក់ប៉ុណ្ណោះ... ជឿបងចុះណាអូន!

ពាក្យពេចន៍ទាំងនេះ បានក្លាយទៅជាឱសថទិព្វលាងភាពល្អក់កករនៅក្នុងចិត្តរបស់ម៉ៅអស់រលីងតែម្ដង ។ ភាពញញឹមក៏បានវិលវិញមកលើផ្ទៃមុខដ៏សោភារបស់នារីយ៉ាងពព្រាយ ។ ស្គរឃ្មោះ ការ និងសម្លេងភ្លេងបាយខុនចងដៃ បានលាន់ឮឡើងយ៉ាងរំពងក្រោមស្គរសម្លេងហ៊ោរកញ្ជ្រៀវខ្ញៀវខ្ញានៃញាតិមិត្តផងទាំងឡាយ ។ ទាំងលោកបុរាណ អ្នកស្រីផៃយ៉ា លោកវិចិត្រ អ្នកគ្រូចរណៃ លោកពូភុំមេឃុំព្រះនេត្រព្រះ អ្នកគ្រូពេទ្យចំណាន ពូប្រេង យាយលឿម ពូខេម ចិត្រា បារមី វិសាល នាងភី នាងគ សាមេត និងសង្សារ សាមឿន ផលា និងញាតិមិត្តជាភ្ញៀវទាំងអស់ ក៏ញញឹមឡើងយ៉ាងរីករាយជូនពរចងដៃកូនក្រមុំកូនកម្លោះទាំង ទ្វេហាដោយក្ដីស្រឡាញ់យ៉ាងពេញបេះដូង ។

បាយខុនមង្គល

\- សម្លេងឃ្មោះការលាន់រំពង — រណ្ដំឆ្លើយឆ្លងភ្លេងបាយខុន<br>
អមដោយពរជ័យលោកមានគុណ — ចងដៃតូចតន់និងរៀមរ៉ា ។

\- ផ្កាស្លាមង្គលហើរព្រោងព្រាត — ជូនពរវរនាថគូស្នេហា<br>
សៀងសើចក្អាកក្អាយលាយភ្លេងការ — នាំចិត្តស្នេហារំភើបក្រៃ ។

\- ញញឹមឡើងអូនដើម្បីស្នែក — ជីវិតល្អឯកមានរស្មី<br>
មង្គលគ្រួសារភ្លឺឥតបី — ត្បិតយើងភក្ដីស្មោះនឹងគ្នា ។

\- បងសូមសច្ចាព្រះប្រធាន — រក្សាស្នេហ៍ឋានក្សាន្តសុខា<br>
ពីរនាក់នឹងមុំគូស្នេហា — មង្គលថ្ងៃថ្លារៀងទៅអើយ ។

នៅក្នុងបន្ទប់ផ្សំដំណេក...

CHANBOKEO.COM

ប៉ុរីផ្ដេកខ្លួនកើយលើភ្លៅភរិយាដែលអង្គុយនៅលើពូកទន់ល្មើយ
- ម៉ៅ...!
- ចាំស!
- បងប្រាប់អូនច្រើនដងហើយណា៎ ថាបងស្រឡាញ់អូន... តែបង
មិនដែលឮអូននិយាយអ្វីមួយម៉ាត់ប្រាប់ពីចិត្តអូនចំពោះបងវិញទេ..
ម៉ៅញញឹម មិនព្រមស្ដី ។ ប៉ុរីឃើញហើយពោលបន្តថា :
- អូនប្រាប់បងបានទេ ថាអូនមានចិត្តយ៉ាងណាចំពោះបងដែរ ?
ស្រាប់តែនាងសើចខឹកៗ ហើយសួរវិញថា :
- បងដឹងរួចហើយតើ ម៉េចចាំបាច់អោយម៉ៅប្រាប់ផង ?
- ដឹងម៉េចកើត បើម៉ៅនិយាយអ្វីមួយម៉ាត់ដាក់បងអញ្ចឹង... ?
- គឺ បេះដូងអូនបាននិយាយប្រាប់បន្ដោងវៃសង្កែ តាំងពីយូរមក ហើយ
គ្រាន់តែម្ចាស់គេនោះមិនព្រមធ្វើដឹងធ្វើឮពីចិត្តអូនសោះ!
- អូនកុំចេះតែថា! ឯណា...ម៉េចមិនឮអញ្ចឹង ?
- អញ្ចឹង មកផ្ទៀងស្ដាប់ខ្លួនឯងម្ដងទៀតទៅណា៎!
ប៉ុរីខ្ទាញ់នឹងភរិយាពេក ក៏ស្រវាឱបភរិយាថើបញីញក់ ស្រាប់ តែនាងស្រែកឃាត់ :
- បង! ឈប់លេងអាក្រក់មើល៍... នេះអូនកំពុងតែ...
- កំពុងតែ... អ្វីទៅ...
ស្រស់ស្រីទុចដឹក់មិនព្រមប្រាប់ ទំនងហាក់នៅខ្មាសស្វាមី ។
- យើងជាប្ដីប្រពន្ធនឹងគ្នាទៅហើយ... អូននៅខ្មាស់ធ្វើអ្វីទៀត ?
នាងខាំមាត់ធ្វើអៀនប្រៀន ។ កិរិយារបស់នាងរិតតែធ្វើអោយ
ប៉ុរីខ្ទាញ់ឡើងចង់តែចាប់លេបទាំងរស់ទេ ។ ពេលនោះ និតាចាប់
ដៃនរៈអោយទៅដាក់លើផ្ទៃពោះរបស់នាង :
- គឺ... មានគេចង់និយាយរកបងនែ៎ក...!
ប៉ុរីភ្ញាក់ព្រើត ញញឹមឡើង ហើយអោនថើបដោយក្ដីស្រឡាញ់:
- កូនប៉ា! កូននិយាយថាម៉េចហ្នឹង ? ថាម៉ាក់របស់កូនស្រឡាញ់ប៉ា ដល់កិរិតហើយ
បាត់មុខមិនបានទេ មែនទេ ?

CHIANBOKEO.COM

ឮដូច្នោះ ស្រីម៉ៅលូកដៃក្ដិចប៊ុរីប៉ាត់ ដោយនឹកខ្មាសចំពោះ ពាក្យចំអន់របស់ប៊ុរី ។
ស្រាប់តែនរៈយើងសើចកក្អឹកឡើង :

- ម៉ៅសំបូរទ័ពខ្យាដីរម្ល៉េះ ? ពូកែទិចបងនល់សូរហើយ !

ស្រាប់តែស្រីម៉ៅសើចខឹកៗតបវិញថា :

- អញ្ចឹងហើយ... អោយសមមុខមនុស្សខូចហ្នឹងណា៎...!

ប៊ុរីយកដៃបូតច្រមុះភរិយា ដោយឃ្នាន់ខ្នាញ់ :

- តែណ្ហើយ បងក៏សុខចិត្តទ្រាំឲ្យខ្យាដីរខាំចុះ មិនតបតវិញទេ ។
- ព្រោះអ្វីទៅ ?... ហេតុអ្វី បងត្រូវទ្រាំផង... ?
- ព្រោះបងស្រឡាញ់គេ ហើយចង់អោយគេបោះត្រាសេចក្ដីស្នេហា របស់គេនៅលើខ្លួនបងហ្នឹងណា៎... ដើម្បីចំណាំថា បងនេះជាគូគាប់ បណ្ដូលចិត្តរបស់គេតែម្នាក់គត់ ។
- តែផ្ដាស...! នរណាគេចង់បោះត្រាលើខ្លួនបងនោះ ?
- នរណាគេមិនដឹងទេ អូនមានស្គាល់ទេ ? គេធ្លាប់បានខាំបងដាច់ សាច់ដៃ... នេះនែ៎ ស្នាមអោយក្រឡៅ ដំបៅយូរខែ ឡើងផ្លែសាច់ ទុកធ្វើចែកកូនចែកចៅមើលផង ។

ប៊ុរីលាត់ដៃអាវបហុចអោយប្រពន្ធមើល ហើយស្រដីបន្តថា :

- នេ៎ះ ស្នាមខាំមួយនេះ៎... អូនមានចំណាំខ្លះទេ ?

ស្រីម៉ៅយកដៃខ្ទប់មុខ ទំនងខ្មាសអៀន :

- ចុះបងមកធ្វើអោយគេខ្ញាញ់ធ្វើអ្វី... ? អញ្ចឹង ទាល់តែក្ដិចខ្ទាំ ខាំខ្លះ ទើបបានរាងចាល...
- នរណាថាបងរាងចាល... ពុទ្ធោ ?
- មិនទាន់រាងមែនហ្ស៎ ? អញ្ចឹងយកមួយទៀតទៅ...

ម៉ៅលូកដៃ រកក្ដិចសាជាថ្មី តែប៊ុរីចាប់ដៃនាងជាប់ហើយស្រដី ទៅនាងថា :

- កុំលេងក្ដិចអី... លេងខាំវិញយ៉ាងម៉េចដែរ... ? ម៉ោះ !
- អត់ទេ ម៉ៅឈប់លេងហើយ ! បងរៃលេងខូច...លែងមើស៍...!
- មិនលែងទេ... ព្រោះម៉ៅលេងខូចដាក់បងដែរ បងត្រូវតែដាក់ ទោសអូនវិញម្ដងហើយ ម្ដងនេះ ។

ប៊ុរីធ្លាប់ទម្លាក់ស្លាបចុះចាញ់ធិតាយូរហើយ ពេលនេះ ប្រហែល ជាគេចង់ឆ្លៀតឱកាសសងសឹកវិញហើយទេដឹងហ្ន៎ ? សូរសំណើច សុភមង្គលលាន់លាន់ឮរអឹក

រសាត់ចេញពីបន្ទប់គូស្វាមីភរិយាថ្មោង ថ្មីរបស់យើង កាត់ស្បែរាត្រីដ៏សែនស្ងាត់ជ្រងំ ដែលមានជនោរវាតា បកត្រសៀកៗ បបោសអង្អែលពិភពលោក អោយយល់តែភាពក្រេមក្សាន្តមនោរម្យក្រៃលែង ។

ពីធីបុណ្យបណ្ដែតប្រទីបជ្វាលាក៏ឈានចូលមកដល់ ។ នៅមាត់ ច្រាំងស្ទឹងសង្កែ ក្រុមគ្រួសារលោកគ្រូពេទ្យវិចិត្រនិងលោកបុរាណ បានចូលគ្នាតុបតែងប្រទីបយ៉ាងធំប្រណិតមួយ ។ នៅក្បែរនោះ បុរី និងស្រីម៉ៅក៏តុបតែងកូនប្រទីបដ៏ស្អាតបំផុតមួយដែរ គឺជាប្រទីបលើកទីមួយដែលគេទាំងពីរធ្វើរួមគ្នា ។ គូគាប់ទាំងទ្វេហាញញឹម ដាក់គ្នារួចលើកដៃប្រណម្យផ្សងទាំងពីរនាក់ ។  បន្ទាប់មកគេក៏អូស ប្រទីបចុះទៅក្នុងទឹកស្ទឹងបណ្ដែតចេញទៅ ។ អ្នកទាំងពីរសម្លឹង មើលតាមរហូតដល់ប្រទីបរសាត់ឆ្ងាយបាត់ពីកន្ទុយភ្នែក ។ បន្តិច មក បុរីបែរសម្លឹងមុខភរិយាហើយវាចាឡើងថា :

- ម៉ៅ ! យើងបានជួបគ្នាជាលើកដំបូងនៅទីនេះ ហើយក៏បាន សុំភ្ជាប់និស្ស័យនឹងគ្នាជាបងប្អូន...
- ប៉ុន្តែ...យើងក៏បែកគ្នាទៅជាច្រើនឆ្នាំ (ស្រីម៉ៅស្រដីបន្ត) ហើយ ម៉ៅតែងតែមកអង្គុយចាំការវិលត្រឡប់របស់បងវិញនៅទីនេះ....រីឯ បងក៏ភ្លេចពាក្យសន្យារបស់បងស្ងួនឈឹង ធ្វើអោយម៉ៅខកចិត្ត ឥតឧបមា ។
- ថៃដន្យបងបានវិលវិញពិតមែន... ហើយយើងក៏ជួបគ្នាសាជាថ្មី...
- រួចបងក៏ក្លាយជាមនុស្សថ្មីដែលមានចរិតគួរអោយស្អប់បំផុត ។

ស្រីម៉ៅសម្លក់បុរី ។ ស្រាប់តែនាយឆ្លើយវិញថា :

- ថៃដន្យ ពេលបងដឹងថា អូនជាស្រីម៉ៅរបស់បង បងក៏ដូរចរិត របស់បងមកវិញភ្លាម មិនអោយអូនខកចិត្ត ស្អប់បងទៀតទេ ។
- កាលនោះ បងនៅចំណាំម៉ៅ បានដែរហ៎ ?
- បើនិយាយពីចំណាំមុខមាត់រូបរាងនេះ គឺអត់ទេ ព្រោះម៉ៅបាន ចំរើនវ័យទៅជាស្រីក្រមុំដ៏ស្រស់ស្អាតប្លែកភ្នែកណាស់ ។ ហេតុ តែព្រេងនិស្ស័យទេវតាប្រទាន នារីម្នាក់នោះក៏បានលួចយកបេះដូង របស់បងទៅតាំងពីថ្ងៃដំបូង ដែលគេដួលធ្លាក់សង្កត់ខ្លួននាងមក លើទ្រូងបង នៅថ្ងៃទីមួយនោះម្ល៉េះ ។

បុរីបែរសម្លឹងមុខភរិយា រួចហើយញញឹមទើបសួរនាងថា :

CHANBOKEO.COM

- ម៉ៅនឹងទេ ថាថ្ងៃនោះ ហេតុអ្វីបានជាបងជិះកង់តាមពីអូន រហូត ធ្លាក់គន្លុក
ដួលកង់ចង់បាក់ក ?

ម៉ៅគ្រវីក្បាល ញញឹមតបវិញ ។ ប៉ុរីក៏ឆ្លើយថា :

- គឺមកពីបងស្លន់ស្លោ នឹងសោភ័ណក្រមុំស្ទឹងខៀវមួយទងនោះអី
ប្រឹងធាក់កង់ តាមមើលមុខ មើលរាងដ៏ស្រស់ស្អាតរបស់គេ ភ្លេច មើលផ្លូវ
ទើបធ្លាក់កន្លុកដួលកង់ដូច្នោះទៅ ។ កាលនោះ បងខ្មាស អូនអើយសែនខ្មាស!
សំណាងល្អដែរដែលអូនគេចខ្លួនបាត់មិននៅ សើចចំអកអោយបង
កុំអីប៉ុរីមិនដឹងជាយកមុខទៅទុកនៅឯណា ទេ ព្រះអើយ ។

- ហើយចុះ បងចំណាំដឹងថាជាម៉ៅនៅពេលណាដែរទៅ ?

- នៅថ្ងៃដែលម៉ៅដួលសន្លប់ បងបានបីម៉ៅយកទៅផ្ទះហើយក៏
បានឃើញអូនពាក់ខ្សែករបស់បងនៅលើខ្លួនអូន ទើបបងដឹងថាជា អូន ។ ពេលនោះ
បងក៏រំភើបសោមនស្សណាស់ ដែលបងបាន ជួបអូនវិញដូចបំណង ។ ម៉ៅ...! ការពិត
បងបានមកបាត់ដំបង ដើម្បីរកអូនជាច្រើនដង ថៃដន្យអភព្វ បងមិនស្គាល់ផ្ទះអូនទេ ។
ទើបបងចូលចិត្តមកឈរចាំអូននៅទីនេះវិញ ក្រែងលោបានប្រទះ រូបអូន តែបងខ្វះសំណាង
ទើបឃ្លាងរូបអូនរហូតដល់ទៅ៨ឆ្នាំ ។

- លុះដល់ជួបគ្នាហើយ ស្រាប់តែតាមរករឿងអូនតែម្តង...

- អ្នកណាថា ? ការពិត បងគ្រាន់តែរកលេសអោយបាននិយាយ ជាមួយអូនតើហ៎!
បើមិនធ្វើដូច្នេះ តើធ្វើម៉េចនឹងអូននិយាយស្តីរក បងទៅ ? ទៅសុំញ៉ៅអូនស្រួលៗ
ច្បាស់ជាឈ្លោករត់គេចមុខបាត់ មិនអោយបងឃើញមុខទេ ។ ទាល់តែធ្វើអោយអូនក្តៅចិត្តខ្លះ
ទើប អូនបែរមកតតាំងនឹងបង នឹងអាលឲ្យបងបានឃើញមុខអូនចំៗ
ដោយមិនបាច់គេចមុខគ្នាផង យល់ទេព្រលឹងថ្លើមថ្លៃ ?

- ពុទ្ធោអើយ! បងឯងខូចណាស់! ធ្វើអោយម៉ៅចាញ់កល...

- បើមិនខូចខ្លះ ធ្វើម៉េចនឹងមានគេចាប់អារម្មណ៍ពីបងទៅ ?

- តែសាវ៉ាដូចបងនេះ ធ្វើអោយស្រីៗគេឈឺចិត្តណាស់នឹងទេ ?

- នឹងតើហ៎... តែបងក៏ឈឺដូចគ្នាដែរ...!

- ឈឺ ? ឈឺរឿងអីទៅ ?

CHANBOKEO.COM

- គឺ... បើបងតម្រូវចិត្តគេ ហើយភ្លេចតម្រូវបេះដូងខ្លួនឯង បងក៏
នឹងឃ្លាតចាកម្ចាស់បេះដូងជាទីស្រឡាញ់របស់បង ដូចគ្នាដែរ ។ ពេលនោះ
បងនឹងត្រូវគេងឈឺអស់មួយជីវិតហើយ ។
- ហើយ នរណាទៅជាម្ចាស់បេះដូងរបស់បងនោះ ?
- គឺកុលាបមួយទងដែលដុះនៅឆ្នេរស្ទឹងខៀវក្រុងបាត់ដំបងនេះអី..
បន្លាកុលាបនោះមានពិសណាស់ ។ គ្រាន់តែបេះដូងបងមុតពិស បន្លាកុលាបនោះភ្លាម
ព្យាបាលលែងជាតែម្តង ។
- យី...! ពិសអ្វីទៅក៏សាហាវម្ល៉េះ ? (ធិតាសើចខឹកៗ)
- គឺពិសមន្តស្នេហ៍ណា៎អូន! ពេលនេះ ប៉ុរីត្រូវពិស រកថ្នាំបន្សាប ព្យាបាលមិនបានទេ...
មានតែក្លែបក្លិនគន្ធាកុលាបស្ទឹងខៀវប៉ុណ្ណោះ
ដែលអាចជួយព្យាបាលរបួសបេះដូងបងអោយបាត់ចុកចាប់បាន...
- តើបងនឹងត្រូវពិសនេះរហូតទៅមួយជីវិតទេហ្ន៎ ?
- អោយតែកុលាបនៅមានបន្លា បងត្រូវពិសតែរហូតហ្នឹង...
- ចុះបើកុលាបស្រពោនវិញនោះ ?
- កុលាបក្នុងបេះដូងរបស់បង មានជីវិតរីកត្រកាលជាអមតៈ មិន ចេះស្រពោនឡើយ
អូនដឹងទេ... ? ... ហើយបងក៏សូមថ្នមថៃផ្កា
កុលាបនោះក្នុងដួងហឫទ័យរបស់បងរៀងរហូតទៅ...

មន្តស្នេហ៍កុលាបស្ទឹងខៀវ

- កុលាបមួយទងដងស្ទឹងមាស ក្រោមសែងឱភាសពេញមង្គល
សាយគន្ធពិដោររំភោមនិមល ពេលរៀមបានយល់លង់ចិត្តស្នេហ៍
- កុលាបទងមាសម្ចាស់បេះដូង ផ្កាស្រស់មួយទងបងសូមថៃ
ដាំផ្កាលើឆ្នេរស្ទឹងសង្កែ រក្សាផ្កាស្នេហ៍ស្រស់ត្រកាល ។
- កុលាបបន្លាមុតទ័យា អប់ដោយគន្ធាសួគ៌វិសាល
សណ្តំកាមាវែងត្រអាល រំភើបស្រើបស្រាលកាយារម្មណ៍ ។
- កុលាបដងស្ទឹងព្រលឹងចិត្ត បងត្រកងនិត្យក្លែបក្លិនមុំ
រក្សាលំអងល្អភិរម្យ យល់តែសុខុមក្សាន្តចើ្ពកាល ។

CHANBOKEO.COM

គូស្នេហ៍ទាំងទ្វេហាញញឹមដាក់គ្នាយ៉ាងផ្អែមល្ហែម ក្រោមស្បៃសន្សើមត្រជាក់នៃផ្ទៃមេឃថ្លាយង់ ។ សៀងទឹកហូរលាយឡំនឹងសៀងវាតាបក់ត្រសៀកៗបបោសអង្អែលកាយ ហាក់បីដូចជាកំពុងតែប្រលោមដួងចិត្តគូគាប់របស់យើងអោយយល់តែភាពក្សេមក្សាន្ត ក្នុងអារម្មណ៍...

ចប់

CHANBOKEO . COM

# វាចាចុងក្រោយ

- សុភមង្គលកើតឡើងពីចិត្តស្រឡាញ់ ការយល់ចិត្ត និងភាពដែលមានអធ្យាស្រ័យចំពោះ គ្នា។ ពេលមានកំហុសខុសឆ្គងកើតឡើង ម្នាក់ត្រូវចេះយោគយល់លើកលែង ម្នាក់ត្រូវចេះកែ កំហុស ដើម្បីកុំអោយស្ថានការណ៍អពមង្គលវិលវិញម្តងទៀតសាជាថ្មី ច្រំដែល។
- សូវធ្វើជាដើមម្នាស់ដែលដុះលើដី មានរូបអាក្រក់ តែមានផ្លែផ្អែមឆ្ងាញ់ ប្រសើរជាជាង ធ្វើបញ្ចើក្អែក លើមែករុក្ខព្រឹក្សដ៏សែនខ្ពល់ តែគ្មានផលាល្អនឹងបេះភោក្តា។
- តម្លៃពិតរបស់មនុស្សមិនមែនស្ថិតនៅលើបបូរមាត់ដែលគេខំប្រឹងអួតអំពីគុណសម្បត្តិរបស់ គេនោះទេ តែស្ថិតនៅលើការប្រព្រឹត្តរបស់បុគ្គលនោះជាជាង ថាតើការប្រព្រឹត្តរបស់គេមាន សច្ចៈភាព និងមានសីលធមិគុណធមិកំពស់ប៉ុនណា។
- កាលនៅយុវវ័យ ជនខ្លះប្រព្រឹត្តអ្វីមិនបានគិតរាក់ជ្រៅទេ គិតតែពីធ្វើៗទៅដោយភាព ភ្លើនភ្លើន ព្រើលតាមចំណង់ដោយមិនគិតអំពីលទ្ធផលចុងក្រោយ។ ថៃដន្យ លុះឈានចូល ដល់វ័យមួយទៀតដែលចេះទទួលខុសត្រូវ... ទើបគេដឹងថា អ្វីដែលគេបានប្រព្រឹត្តពីក្មេងជា អំពើកម្លៅខ្វះការពិចារណា ហើយគេក៏មានវិប្បដិ្ឋសារីនឹកស្តាយក្រោយចំពោះការប្រព្រឹត្ត របស់គេ។ ពេលនោះ គេក៏កើតមានចិត្តសោកសៅ ព្រោះមិនដឹងថាត្រូវធ្វើយ៉ាងណា ដើម្បីកែកុនអតិតកាលឱ្យមកល្អជាវិញបាន...
- ជាតិជាអ្នកក្រីក្រ ជាកំណើតអ្នកស្រែ តែងតែត្រូវអ្នកមានជិះជាន់ប្រមាថមាក់ងាយបំផុត មិនថាយុគណា សម័យណាទេ។ មនុស្សខ្លះមានលុយ ប៉ុន្តែគ្មានសីលធមិក្នុងខ្លួនបន្តិចឡើយ ព្រោះគេគិតថាលុយអាចបិទមុខគេឱ្យថ្លៃបាន ដោយមិនបាច់ធ្វើអំពើល្អលើញាតិណា។
- អ្វីដែលអាចញែកតម្លៃមនុស្សអោយដាច់ខុសពីសត្វនោះ គឺការដឹងខុសដឹងត្រូវ មាន មនសិការនិងសម្បជញ្ញៈ (ដឹងខុសហើយចេះកែមិនអោយខុសទៀតច្រំដែល។) មានសីលធមិ និង គុណធមិចំពោះមនុស្សដូចគ្នា ពោលគឺមិនខាំអ្នកដទៃដូចសត្វ ដើម្បីប្រយោជន៍អាត្មា...!
- អ្នកដែលអោយកំណើតកូន មិនមែនសុទ្ធតែជាអ្នកមានគុណចំពោះកូនគ្រប់គ្នាទេ តួយ៉ាង ជនខ្លះ យកកូនលក់អោយទៅបំរើគេ ដើម្បីកេងប្រយោជន៍ជាលុយសំរាប់ខ្លួនជាម៉ែឪ។

អ្នកស្រី កែវ ចន្ទ័បូរណ៏

បញ្ជីរាយនាមកំណាព្យក្នុងរឿងកុលាបស្មឹងខៀវ

និពន្ធដោយអ្នកស្រីកែវចន្ទ័បូរណ៍


| លេខរៀង | ចំណងជើង | ទំព័រ |
|---|---|---|
| ១. | ស្មឹងខៀវនាវស្នេហ៍ | ២៦ |
| ២. | ផ្កាស្នេហ៍ | ៣៥ |
| ៣. | នឹក | ៦១ |
| ៤. | សោភណ័ទេវី | ៧៩ |
| ៥. | ភពស្នេហ៍វង្វេង | ៩២ |
| ៦. | កុលាបដួងចិត្ត | ៩៧ |
| ៧. | ខ្ពាញ់ | ១០៤ |
| ៨. | ស្នាមខាំដាំស្នេហ៍ | ១០៧ |
| ៩. | ញាប់ញ័រ | ១១៦ |
| ១០. | ថ្វីបើអូនខឹង | ១៤១ |
| ១១. | ចាំបងណាអូន | ១៥៦ |
| ១២. | ដំរៅដួងចិត្ត | ១៧៦ |
| ១៣. | ស្តាយ | ១៩១ |


CHANBOKEO.COM

១៨. បាយខុនមង្គល ២១៥

១៥. មន្តស្នេហ៍កុលាបស្ទឹងខៀវ ២២២


oooooooooសូមថ្លែងអំណរគុណooooooooo

oooooooooooooooo

oooooo

CHANBOKEO . COM